**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**

Université  Royale de Droit et des Sciences Economiques

Royal University of Law and Economics


## សារណាបញ្ចប់ការសិក្សា

# ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូងរាជធានី-ខេត្ត

**(ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម)**

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **រិន ថា**

**ផាត វណ្ណា**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ឈុន ណារ៉េត**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥

ឆ្នាំសរសេរសារណា ២០១៩

**សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច**
Université Royale de Droit et des Sciences Economiques
Royal University of Law and Economics

## សារណាបញ្ចប់ការសិក្សា

# ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌ នៅសាលាដំបូងរាជធានី-ខេត្ត

**(ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម)**

ស្រាវជ្រាវពីថ្ងៃទី ១៨ ខែ មីនា ដល់ថ្ងៃទី ១៦ ខែ ឧសភា ឆ្នាំ ២០១៩

តាក់តែងឡើងដោយ
និស្សិតឈ្មោះ **រិន ថា**
**ផាត ចណ្ឌា**

សាស្ត្រាចារ្យណែនាំ
បណ្ឌិត **ឈុន ណារ៉េត**

ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**
ជំនាន់ទី ១៩

ឆ្នាំចូលសិក្សា ២០១៥
ឆ្នាំសរសេរសារណា ២០១៩

# សេចក្តីថ្លែងអំណរគុណ

ការទទួលបាននូវភាពជោគជ័យមួយ មិនមែនជារឿងងាយស្រួលនោះទេ ហើយក៏មិនអាចធ្វើទៅរួចតែម្នាក់ឯងបាននោះដែរ គឺត្រូវមានអ្នកជួយលើកទឹកចិត្ត និងឧបត្ថម្ភគាំទ្រពីអ្នកនៅជុំវិញខ្លួន ទើបអាចទទួលបានជោគជ័យ។

យ៉ាងណាមិញ ក្នុងនាមខ្ញុំបាទជានិស្សិតឈ្មោះ **រិន ថា** និង **ផាត ខណ្ឌ** ដែលទើបតែទទួលបានជោគជ័យក្នុងការសរសេរសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះ ក៏អាស្រ័យដោយមានការជួយជ្រោមជ្រែងពីបុគ្គលសំខាន់ៗ ដែលក្នុងនោះ យើងខ្ញុំសូមថ្លែងអំណរគុណជូនចំពោះ៖

-លោកឪពុក **យុន រិន** អ្នកម្តាយ **ម៉ុខ រិន** និងលោកឪពុក **យុល សុផាត** អ្នកម្តាយ **ទិត្យ សុខា** ដែលមាននូវព្រហ្មវិហារធម៌ និងសង្គហធម៌ចំពោះកូនៗ មានយាយតា ពូមីង បងប្អូនជាដើម ដែលតែងតែជួយមើលការខុសត្រូវ និងអប់រំណែនាំ ផ្តល់ដំបូន្មានល្អៗ ដល់រូបយើងខ្ញុំ។

-លោកបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យណែនាំដ៏ល្អមួយរូប ក្នុងការជួយឲ្យសារណារបស់យើងខ្ញុំបានគ្រប់ជ្រុងជ្រោយ និងល្អប្រសើរ តាមរយៈការខិតខំប្រឹងប្រែងពន្យល់ណែនាំ ផ្តល់ជាមតិយោបល់ល្អៗ និងការកែតម្រូវនូវរាល់ខ្លឹមសារ ដែលលើសលស់ ឬខ្វះខាតជាដើម។

-ឯកឧត្តមសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ បុគ្គលិកបម្រើការនៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានខិតខំដឹកនាំគ្រប់គ្រង បំពេញការងារ បង្ហាត់បង្រៀន យ៉ាងយកចិត្តទុកដាក់ ដើម្បីធ្វើការបណ្តុះបណ្តាលនិស្សិត ឲ្យក្លាយទៅជាធនធានមនុស្សដ៏ពិតប្រាកដ ប្រកដោយគុណភាព គុណធម៌ និងភាតរភាពជាពិសេស ឲ្យទៅជាយុវជនគំរូ និងជាសសរទ្រូងយ៉ាងរឹងមាំ សម្រាប់ទ្រទ្រង់ប្រទេសជាតិ ប្រកបដោយសន្តិសុខ សន្តិភាព យុត្តិធម៌ និងការអភិវឌ្ឍ។

ដោយអំណាចនៃគុណានុភាព ដែលពួកលោកបានធ្វើនូវសេចក្តីល្អ ក៏ដូចជាការខិតខំប្រឹងប្រែងសព្វបែបយ៉ាងមកលើយើងខ្ញុំ គឺយើងខ្ញុំគ្មានអ្វីជាការតបស្នងសងគុណធំដុំចំពោះពួកលោកនោះទេ មានតែសូមបួងសួងដល់វត្ថុសក្តិសិទ្ធិក្នុងលោក តាមជួយទំនុកបម្រុងបីបាច់ថែរក្សាឃុំគ្រងពួកលោកទាំងអស់គ្នា សូមបានតែសិរីសួស្តី ជ័យមង្គល វិបុលសុខ សុភមង្គលគ្រប់ប្រការ ចូលកើតមានដល់អស់លោកគ្រប់គ្នាជានិច្ចនិរន្តតទៅ ។

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# អារម្ភកថា

ទ្រឹស្តីមួយបានពោលថា "**ជីវិតបើមិនទ្រាំលេបថ្ម លេបក្រួសទេ ធ្វើម្តេចនឹងអាចលេបមាស លេបពេជ្របាន**" គឺជាទ្រឹស្តី ដែលជាមាគ៌ា និងជាកម្លាំងចលករយ៉ាងខ្លាំងក្លា ក្នុងការជំរុញទឹកចិត្តឲ្យយើងខ្ញុំទទួលបានជោគជ័យក្នុងការសិក្សាស្រាវជ្រាវនៅថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ជាពិសេសគឺការ សរសេរសារណា បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនេះតែម្តង។

សៀវភៅសារណា មានចំណងជើងថា "**ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្ត (ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម)**" ដែលកំពុងតែមានវត្តមានក្នុងដៃរបស់លោកអ្នក គឺវាបានឧប្បត្តិឡើង តាមរយៈការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់ជាទីបំផុត ក្នុងការសម្រិតសម្រាំងចម្រាញ់យកខ្លឹមសារ ដែលមានគុណភាព និងសារៈប្រយោជន៍យ៉ាងចាំបាច់ ដើម្បីយកមកចងក្រងជាសៀវភៅនេះឡើង។ អ្នកសិក្សាផ្នែកនីតិសាស្ត្រ ក៏ដូចជាអ្នកដែលចង់ចេះ ចង់ដឹង និងចង់សិក្សាស្វែងយល់ពាក់ព័ន្ធនឹងរឿងក្តីព្រហ្មទណ្ឌ ជាពិសេស គឺដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌ ក្នុងការបន្តនីតិវិធី ដើម្បីឲ្យមានភាពស៊ីសង្វាក់ និងប្រទាក់ក្រឡាចាប់ពីពេលដំណើរការនៃរឿងក្តីរហូតដល់ចេញសាលក្រម នៅសាលាដំបូងរាជធានី-ខេត្ត។ ម្យ៉ាងវិញទៀត ក្នុងខ្លឹមសារនៃសៀវភៅនេះ ក៏បានរំលេចឡើងយ៉ាងក្បោះក្បាយអំពីដំណាក់កាលមន្ត្រីនគរបាលយុត្តិធម៌ តំណាងអយ្យការ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ ទៅតាមគោលការណ៍ដែលមានចែងក្នុងច្បាប់ ក៏ដូចជាការអនុវត្តជាក់ស្តែង ដោយយើងខ្ញុំ បានលើកយកចំណុចគោលសំខាន់ៗ មកបកស្រាយពន្យល់ ព្រមទាំងធ្វើការប្រៀបធៀប ដើម្បីឲ្យលោកអ្នកកាន់តែងាយយល់។

បើចង់ដឹងថា ខ្លឹមសារនៃសារណានេះ មានអត្ថន័យ អត្ថរស មានអត្ថប្រយោជន៍យ៉ាងណាចំពោះលោកអ្នក គឺលោកអ្នកគ្រាន់តែបង្អោនចិត្ត ដាក់កាយ ហើយចំណាយពេលវេលាខ្លះៗ ដើម្បីអាន និងតក់ត្រានៅចំណុចសំខាន់ៗទុក អ្នកនឹងដឹងថា សៀវភៅនេះមានអត្ថប្រយោជន៍អ្វីខ្លះ។

ជាចុងក្រោយ យើងខ្ញុំ ដែលជាអ្នកសិក្សាស្រាវជ្រាវ និងតាក់តែងសៀវភៅសារណានេះឡើង ក៏សូមលើកដៃប្រណមឡើង ខន្តីអភ័យទោសចំពោះលោកអ្នកសិក្សាទាំងឡាយ នូវរាល់កំហុសឆ្គងទាំងអត្ថន័យ អត្ថរស ខ្លឹមសារ ពាក្យពេជន៍ ឃ្លោងឃ្លា និងអក្ខរាវិរុទ្ធជាដើម ដែលកើតឡើងដោយអចេតនា។ ហើយយើងខ្ញុំ ដែលជាអ្នកតាក់តែងសង្ឃឹមជឿជាក់យ៉ាងមុតមាំថា សៀវភៅនេះ នឹងបានជាអត្ថប្រយោជន៍ ក៏ដូចជាឯកសារយោងដល់អ្នកសិក្សាស្រាវជ្រាវទៅថ្ងៃអនាគត។

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# សេចក្ដីធានាអះអាង

ខ្ញុំបាទឈ្មោះ **រិន ថា** ជាភាសាឡាតាំង **REN THA** ភេទប្រុស កើតថ្ងៃទី០២ ខែវិច្ឆិកា ឆ្នាំ១៩៩៥ មានទីកន្លែងកំណើតនៅភូមិមេលោង ឃុំព្រៃស្មៀត ស្រុកពារាំង ខេត្តព្រៃវែង ដោយមានលេខសម្គាល់ខ្លួន **BL15-0065** និងខ្ញុំបាទឈ្មោះ **ផាត វណ្ឌូ** ជាភាសាឡាតាំង **PHAT VANDO** ភេទប្រុស កើតថ្ងៃទី២៥ ខែតុលា ឆ្នាំ១៩៩២ មានទីកន្លែងកំណើតនៅភូមិកោះចេក ឃុំកោះចេក ស្រុកពាមជរ ខេត្តព្រៃវែង ដោយមានលេខសម្គាល់ខ្លួន **BL15-0043** ជំនាន់ទី១៩ បច្ចុប្បន្ន ជានិស្សិតថ្នាក់បង់ពេញថ្លៃនៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ហើយជាបេក្ខជនសរសេរសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំសិក្សា២០១៨-២០១៩។

យើងខ្ញុំ សូមធ្វើការធានាអះអាងចំពោះសាកលវិទ្យាធិការ សាកលវិទ្យាធិការរង ព្រឹទ្ធបុរស ព្រឹទ្ធបុរសរង សាស្ត្រាចារ្យ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ចថា៖

រាល់ខ្លឹមសារ នៃសារណាបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ ដែលមានប្រធានបទស្ដីអំពី "**ដំណាក់កាលទាំង ៤ នៃរឿងក្ដីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្ត** (**ករណីការអនុវត្តជាក់ស្ដែង និងបញ្ហាប្រឈម**" ចំពោះមុខនេះ គឺពិតជាបានឧប្បត្តិចេញពីការខិតខំប្រឹងប្រែងសិក្សាស្រាវជ្រាវដោយយកចិត្តទុកដាក់ និងដោយមានការជួយពន្យល់ណែនាំបន្ថែមពីលោកសាស្ត្រាចារ្យបណ្ឌិត **ឈុន ណារ៉េត** ជាសាស្ត្រាចារ្យដឹកនាំផងដែរ។ រាល់ផ្នែកនៃសារណានេះ គឺត្រូវបានដកស្រង់យកមកសរសេរ ដោយសុទ្ធតែមានប្រភពត្រឹមត្រូវ ច្បាស់លាស់ ទាំងឯកសារយោង ស្នាដៃអ្នកនិពន្ធ ឬរៀបរៀង ឆ្នាំបោះពុម្ព របាយការណ៍ កិច្ចសម្ភាស៍ផ្ទាល់ជាមួយស្ថាប័នពាក់ព័ន្ធ និងដោយមានគំនិតយោបល់ពីយើងខ្ញុំផ្ទាល់ផងដែរ។

ប្រសិនបើ មានផ្នែកណាមួយនៃសារណានេះ ផ្ទុយអំពីច្បាប់ និងនាំឲ្យមានការប៉ះពាល់ដល់ស្នាដៃ ក៏ដូចជាសិទ្ធិរបស់អ្នកនិពន្ធ ឬប្រហាក់ប្រហែលជាដើម យើងខ្ញុំសូមទទួលខុសត្រូវចំពោះមុខច្បាប់ និងទទួលយកទណ្ឌកម្មពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

ថ្ងៃចន្ទ ១៣កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩

# មាតិកា

វាក្យសព្ទដែលប្រើក្នុងសារណានេះ....................vii

## សេចក្តីផ្តើម

១.លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ....................០១
២.ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ....................០១
៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ....................០២
៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ....................០២
៥.សារៈសំខាន់នៃការសិក្សាស្រាវជ្រាវ....................០២
៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ....................០៣
៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ....................០៣

## ជំពូកទី១
## ការរំលឹកទ្រឹស្តី

**ផ្នែកទី១៖ ប្រព័ន្ធស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា**....................០៥
**កថាខណ្ឌទី១៖ ប្រវត្តិស្ថាប័នតុលាការកម្ពុជា**....................០៥
១.១.អំពីសាលាដំបូងរាជធានី-ខេត្ត....................០៦
១.២.អំពីតុលាការយោធា....................០៦
**កថាខណ្ឌទី២៖ ដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ**....................០៦
**កថាខណ្ឌទី៣៖ មូលហេតុនៃរឿងក្តីព្រហ្មទណ្ឌ**....................០៧
៣.១.ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ....................០៧
៣.២.តួអង្គសំខាន់ៗក្នុងរឿងក្តីព្រហ្មទណ្ឌ....................០៨

## ជំពូកទី២
## អំពីនគរបាលយុត្តិធម៌ និងអង្គភាពអយ្យការ

**ផ្នែកទី១៖ ដំណាក់កាលនគរបាលយុត្តិធម៌**....................១០
**កថាខណ្ឌទី១៖ ការផ្តល់និយមន័យអំពីនគរបាល**....................១០
១.១.នគរបាលរដ្ឋបាល....................១១
១.២.នគរបាលយុត្តិធម៌....................១២
**កថាខណ្ឌទី២៖ លក្ខខណ្ឌដើម្បីក្លាយខ្លួនជានគរបាលយុត្តិធម៌**....................១៣

២.១.តាមរយៈការប្រឡងប្រជែង..............................................................................................១៥
២.២.តាមរយៈឋានន្តរសក្តិ និងមុខងារ.....................................................................................១៦
២.៣.តាមរយៈការទទួលស្គាល់ដោយស្វ័យប្រវត្តិ..........................................................................១៦
**កថាខណ្ឌទី៣៖ សមាសភាពនគរបាលយុត្តិធម៌** .....................................................................១៧
៣.១.មន្ត្រីនគរបាលយុត្តិធម៌...........................................................................................................១៨
៣.២.ភ្នាក់ងារនគរបាលយុត្តិធម៌ ......................................................................................................១៨
៣.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត..........................................................................១៩
**កថាខណ្ឌទី៤៖ សមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌**..........................................................១៩
៤.១.សមត្ថកិច្ចដែនដី ..................................................................................................................១៩
៤.២.សមត្ថកិច្ចសម្ភារៈ .................................................................................................................២០
**កថាខណ្ឌទី៥៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌**...............................................................២០
៥.១.ការស៊ើបអង្កេតករណីជាក់ស្តែង..............................................................................................២០
៥.២.ការស៊ើបអង្កេតបឋម.............................................................................................................២៤
**កថាខណ្ឌទី៦៖ ភាពចំណុះនៃនគរបាលយុត្តិធម៌**......................................................................២៥
៦.១.ដំណាក់កាលស៊ើបអង្កេត .......................................................................................................២៥
៦.២.ដំណាក់កាលស៊ើបសួរ ...........................................................................................................២៦
៦.៣.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌ ..................................................................................២៦
**កថាខណ្ឌទី៧៖ ការបាត់បង់ជាសមាជិកភាពនៃនគរបាលយុត្តិធម៌**.........................................២៦
៧.១.តាមរយៈការពិន័យ................................................................................................................២៧
៧.២.តាមរយៈការចូលនិវត្តន៍...........................................................................................................២៧
**កថាខណ្ឌទី៨៖ ករណីការអនុវត្តជាក់ស្តែង**............................................................................២៨
៨.១.បញ្ហាដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌....................................................................២៨
៨.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម.........................................................................................៣០
**ផ្នែកទី២៖ ដំណាក់កាលអយ្យការ**.........................................................................................៣៣
**កថាខណ្ឌទី១៖ ការផ្តល់និយមន័យអង្គការអយ្យការ**................................................................៣៣
១.១.អត្ថន័យនៃអង្គការអយ្យការ ...................................................................................................៣៣
១.២.អត្ថន័យនៃព្រះរាជអាជ្ញា .......................................................................................................៣៣
**កថាខណ្ឌទី២៖ ការរៀបចំអង្គការអយ្យការ**..............................................................................៣៤

២.១.ការជ្រើសរើសព្រះរាជអាជ្ញា..........៣៧
២.២.សមាសភាពអង្គការអយ្យការ..........៣៩
២.៣.កាតព្វកិច្ចព្រះរាជអាជ្ញា..........៤០
២.៤.ចំណាត់ការសំណុំរឿងដោយអយ្យការ..........៤១
**កថាខណ្ឌទី៣៖ លក្ខខណ្ឌនៃការចោទប្រកាន់** ..........៤១
៣.១.ការពិនិត្យលើលក្ខខណ្ឌនៃការចោទប្រកាន់..........៤១
៣.២.សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា..........៤៤
**កថាខណ្ឌទី៤៖ សេចក្តីសម្រេចមិនចោទប្រកាន់ ឬចោទប្រកាន់របស់ព្រះរាជអាជ្ញា**...៤៤
៤.១.ដីកាតម្កល់រឿងទុកឥតចាត់ការ..........៤៤
៤.២.សេចក្តីសម្រេចក្នុងការចោទប្រកាន់..........៤៦
៤.៣.សិទ្ធិអំណាចផ្សេងៗទៀតរបស់អយ្យការ..........៤៩
**កថាខណ្ឌទី៥៖ ការបញ្ជប់មុខងារជាព្រះរាជអាជ្ញា** ..........៥០
៥.១.ការដាក់ទណ្ឌកម្ម..........៥០
៥.២.ការចូលនិវត្តន៍..........៥១
**កថាខណ្ឌទី៦៖ ករណីការអនុវត្តជាក់ស្តែង**..........៥២
៦.១.បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា..........៥២
៦.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម..........៥៣

## ជំពូកទី៣

## អំពីចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ

**ផ្នែកទី១៖ ដំណាក់កាលចៅក្រមស៊ើបសួរ**..........៥៤
**កថាខណ្ឌទី១៖ ការបើកការស៊ើបសួរ**..........៥៤
១.១.ការស៊ើបសួរដាក់បន្ទុក..........៥៥
១.២.ការស៊ើបសួរដោះបន្ទុក..........៥៥
១.៣.ការស៊ើបសួរជំនួស..........៥៦
**កថាខណ្ឌទី២៖ វិធានការណ៍និរន្តរាយ** ..........៥៦
២.១.ដីកាបង្គាប់ឲ្យចូលខ្លួន..........៥៧
២.២.ដីកាបង្គាប់ឲ្យនាំខ្លួន..........៥៧
២.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន..........៥៨

២.៤.ដីកាបង្គាប់ឲ្យឃុំខ្លួន........................................................................................៥៩
២.៥.ការឃុំខ្លួនបណ្តោះអាសន្ន.....................................................................................៦០
២.៥.១.ថិរវេលានៃការឃុំខ្លួនបណ្តោះអាសន្ន.........................................................៦១
២.៥.២.ការដោះលែងជនត្រូវចោទឲ្យនូវក្រៅឃុំ....................................................៦២
២.៦.ដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ..៦៤
២.៧.ការកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ .....................................៦៥
២.៧.១.តាមគំនិតផ្តួចផ្តើមរបស់ចៅក្រម...............................................................៦៥
២.៧.២.តាមបណ្តឹងសុំកែប្រែ ឬលើកលែងពីព្រះរាជអាជ្ញា......................................៦៥
២.៧.៣.បណ្តឹងសុំកែប្រែ ការត្រួតពិនិត្យតាមផ្លូវតុលាការដោយជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ ...............................................................................៦៦
២.៨.កិច្ចស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ..............................................................................៦៦
២.៨.១.ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា...............................................៦៧
២.៨.២.ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ.......................................................................................................៦៧
២.៨.៣.ការស្នើសុំឲ្យបំពេញកិច្ច ដោយដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី ..........................................................................៦៧
**កថាខណ្ឌទី៣៖ ការបិទការស៊ើបសួរ**...............................................................................៦៨
៣.១.ការសន្និដ្ឋានបញ្ជូនរបស់ចៅក្រមស៊ើបសួរ ..................................................៦៨
៣.២.ការសន្និដ្ឋានរបស់ព្រះរាជអាជ្ញា...............................................................៦៨
**កថាខណ្ឌទី៤៖ ដីកាដំណោះស្រាយ**...............................................................................៦៩
៤.១.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ..................................................៦៩
៤.២.ដីកាលើកលែងចោទប្រកាន់ ......................................................................៦៩
**កថាខណ្ឌទី៥៖ ការប្តឹងអំពីសេចក្តីសម្រេចរបស់ចៅក្រមស៊ើបសួរ** ........................៧០
៥.១.ការប្តឹងមោឃភាពកិច្ចនៃនីតិវិធី..............................................................៧០
៥.២.អ្នកមានសមត្ថកិច្ចប្តឹងទៅសភាស៊ើបសួរ......................................................៧១
៥.៣.សេចក្តីសម្រេចរបស់សភាស៊ើបសួរ ..........................................................៧១
៥.៣.១.សភាស៊ើបសួរសម្រេចមិនទទួលពាក្យប្តឹងសុំមោឃកម្ម............៧១
៥.៣.២.សភាស៊ើបសួរសម្រេចទទួលពាក្យប្តឹងសុំមោឃកម្ម .................៧២

៥.៤.បណ្តឹងឧទ្ធរណ៍ដីការបស់ចៅក្រមស៊ើបសួរ ..........................................................៧៣
៥.៥.ការប្តឹងផ្ទាល់ទៅសភាស៊ើបសួរ.........................................................................៧៤
**ផ្នែកទី២៖ ដំណាក់កាលចៅក្រមជំនុំជម្រះ**..........................................................................៧៥
**កថាខណ្ឌទី១៖ សមត្ថកិច្ចរបស់តុលាការ**...........................................................................៧៥
**កថាខណ្ឌទី២៖ ការប្តឹងទៅចៅក្រមជំនុំជម្រះ**.........................................................................៧៥
**កថាខណ្ឌទី៣៖ នីតិវិធីជំនុំជម្រះ**.........................................................................................៧៦
៣.១.នីតិវិធីមុនពេលសវនាការជំនុំជម្រះ .......................................................................៧៦
៣.២.នីតិវិធីសម្រេចមុនពេលអង្គសេចក្តី.......................................................................៧៧
៣.២.១.រយៈពេលបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងពិរុទ្ធជន.........៧៨
៣.២.២.ការដោះលែងជនជាប់ចោទដោយតុលាការ ..............................៧៨
៣.៣.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម..................................................................................៧៩
**កថាខណ្ឌទី៤៖ នីតិវិធីនាពេលសវនាការ** ............................................................................៨០
៤.១.សមាសភាពពេលសវនាការ........................................................................................៨០
៤.២.នីតិវិធី និងដំណាក់កាលនៃការជំនុំជម្រះ ...................................................................៨១
៤.៣.ការកំណត់ពេលបើកសវនាការ.................................................................................៨២
៤.៤.ការចូលរួមនីតិវិធីសវនាការ.......................................................................................៨២
៤.៤.១.ការចូលរួមរបស់ជនជាប់ចោទ ...................................................៨២
៤.៤.២.ការចូលខ្លួនរបស់ដើមបណ្តឹងរដ្ឋប្បវេណី ....................................៨៣
៤.៤.៣.ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវដើមបណ្តឹងរដ្ឋប្បវេណី........៨៣
៤.៤.៤.ការចូលខ្លួនរបស់សាក្សី.............................................................៨៣
**កថាខណ្ឌទី៥៖ ការពិភាក្សាដេញដោល**...................................................................................៨៤
៥.១.សិទ្ធិនិយាយជាបន្តបន្ទាប់...........................................................................................៨៥
៥.២.ការចុះដល់ទីកន្លែង ..................................................................................................៨៦
៥.២.១.ការស្វែងរកព័ត៌មានបន្ថែមរបស់តុលាការ.....................................៨៦
**កថាខណ្ឌទី៦៖ ការប្រកាសសាលក្រម**....................................................................................៨៦
៦.១.សាលក្រមចាត់របៀប ..................................................................................................៨៧
៦.២.សាលក្រមលើអង្គសេចក្តី.............................................................................................៨៧
៦.២.១.សាលក្រមចំពោះមុខ..................................................................៨៧

៦.២.២.សាលក្រមដែលត្រូវចាត់ទុកថាចំពោះមុខ ........ ៨៨
៦.២.៣.សាលក្រមកំបាំងមុខ ........ ៨៨
៦.៣.ខ្លឹមសារនៃសាលក្រម ........ ៨៨
៦.៣.១.ចំពោះជនជាប់ចោទ ........ ៨៩
៦.៣.២.ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី ........ ៨៩
៦.៣.៣.ចំពោះវត្ថុចាប់យក ........ ៩០
**កថាខណ្ឌទី៧៖ ឧប្បត្តិហេតុនាពេលសវនាការ** ........ ៩១
៧.១.វិវាទស្តីពីនិយតភាពនៃការកោះហៅ ........ ៩១
៧.២.ករណីមានបទល្មើសនាពេលសវនាការ ........ ៩១
៧.៣.អញ្ញត្រកម្ម ........ ៩២
៧.៣.១.មោឃភាពនៃនីតិវិធី ........ ៩២
៧.៣.២.សមត្ថកិច្ចរបស់តុលាការ ........ ៩២
៧.៣.៣.បញ្ហាបន្ទាន់បង្ហំ ........ ៩២

## សេចក្តីសន្និដ្ឋាន និងអនុសាសន៍

**១.សេចក្តីសន្និដ្ឋាន** ........ ៩៥
**២.អនុសាសន៍** ........ ៩៧
**គន្ថនិទ្ទេស**
**ឧបសម្ព័ន្ធ**

# វាក្យសព្ទដែលប្រើក្នុងសារណានេះ

**-កោសលវិច័យ** ជាប្រតិបត្តិការរបស់អ្នកជំនាញ ក្នុងការពិនិត្យពិច័យទៅលើបញ្ហានៃអង្គហេតុណាមួយ ដែលចៅក្រមត្រូវការឲ្យធ្វើការបំភ្លឺ។

**-ចៅក្រម** សំដៅដល់ចៅក្រមអាសនៈ រួមមានជាអាទិ៍ ចៅក្រមស៊ើបសួរ និងចៅក្រមជម្រះក្តី។

**-ជនល្មើស** រួមមាន ចារី សហចារី អ្នកផ្តើមគំនិត អ្នកសមគំនិត។

**-នគរបាល** ជាអ្នកថែរក្សាការពារ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និងបង្ក្រាបបទល្មើស ព្រមទាំងចាប់ជនល្មើស ក៏ជាជំនួយដល់តុលាការផងដែរ។

**-នគរបាលយុត្តិធម៌** ត្រូវបានចែកចេញជាមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យ។

**-និទ្ទោសភាព** ភាពនៃការគ្មានទោស។

**-និទ្ទេស** សេចក្តីចារឹក សេចក្តីដែលចុះដោយសង្ខេបនៅលើរឹមទំព័រ ឬនៅចុងទំព័រណាមួយ។

**-និយតភាព** ភាពត្រឹមត្រូវតាមច្បាប់ ភាពដែលមានរបៀប។

**-ទិដ្ឋាការ** ការចុះហត្ថលេខា និងបោះត្រាលើលិខិតណាមួយ ដើម្បីឲ្យលិខិតនោះបានបង់ពន្ធរួចហើយ។ និទ្ទេសដែលត្រូវចុះនៅលើលិខិតអ្វីមួយ ដោយអាជ្ញាធរមានសមត្ថកិច្ច ដើម្បីឲ្យគេទទួលស្គាល់ នូវអានុភាពនៃលិខិតនោះ។

**-បទល្មើស** គឺជាអំពើល្មើសរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ដែលច្បាប់បានហាមឃាត់។

**-បណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ** គឺជាបណ្តឹងមួយ ដែលបានធ្វើឡើងដោយជនរងគ្រោះ ឬដើមបណ្តឹងរដ្ឋប្បវេណីឬតតិយជន ហើយបណ្តឹងនេះមានពីរ បណ្តឹងទាមទារ និងបណ្តឹងបរិហារ។

**-ទោសព្រហ្មទណ្ឌ** គឺជាការបែងចែក ដែលមានចែងនៅក្នុងក្រមព្រហ្មទណ្ឌ គឺមូលទោស រួមមានទោសដាក់ពន្ធនាគារ និងទោសពិន័យជាប្រាក់។

**-ព្រះរាជអាជ្ញា** គឺជាស្ថាប័នធ្វើការស៊ើបអង្កេត និងចោទប្រកាន់។

**-មូលកភាព** សំដៅទៅលើភាពដែលមិនសមហេតុផល ឬភាពដែលមិនត្រឹមត្រូវ។

**-វិធានការណ៍និរន្តរាយ** គឺជាដំណាក់កាលមួយ ដែលជាការដកហូត សិទ្ធិ សេរីភាពរបស់បុគ្គលណាម្នាក់ ត្រូវបានអនុវត្ត ដោយអំណាចចាប់បង្ខំរបស់រដ្ឋ ពោលគឺ តាមរយៈស្ថាប័ននៃអំណាចតុលាការ។

**-សភាស៊ើបសួរ** ជាសភាមួយនៃសាលាឧទ្ធរណ៍ ដែលមានសមត្ថកិច្ចជំនុំជម្រះ លើបណ្តឹងឧទ្ធរណ៍ និងដីកាសម្រេចរបស់ចៅក្រមស៊ើបសួរ លើបណ្តឹងមោឃភាពនៃកិច្ចនីតិវិធី និងលើបណ្តឹងផ្ទាល់ពីចំណាត់ការរបស់ចៅក្រមស៊ើបសួរ។

**-អង្គចៅក្រម** សំដៅដល់ចៅក្រម និងព្រះរាជអាជ្ញា។

**-អធិបញ្ញា** សេចក្តីបង្គាប់ពីថ្នាក់លើទៅថ្នាក់ក្រោមតាមឋានានុក្រម ដែលច្បាប់បានកំណត់។

**-អាជ្ញាយុកាល** គឺជាការកំណត់ពេលវេលាយ៉ាងជាក់លាក់ ដែលមាននៅក្នុងច្បាប់ មានដូចជាអាជ្ញាយុកាលនៃបទល្មើស និងអាជ្ញាយុកាលនៃទោស។

**-អញ្ញត្រកម្ម** អំពើមិនដូចប្រក្រតី, ហេតុដែលកើតមានឡើងថ្មី ឬករណីលើកលែង។

# សេចក្ដីផ្ដើម

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការសិក្សាស្រាវជ្រាវ

បន្ទាប់ពីភ្លើងសង្គ្រាម ត្រូវបានបញ្ចប់សព្វគ្រប់នាឆ្នាំ ១៩៩៣ មក កម្ពុជាបានស្រុះស្រួលព្រម ព្រៀងឯកភាពគ្នា ធ្វើការបង្រួបបង្រួមជាតិឡើងវិញ ក្រោមកិច្ចខិតខំប្រឹងប្រែងដឹកនាំយ៉ាងយកចិត្ត ទុកដាក់ប្រកបដោយគតិបណ្ឌិត និងគោលនយោបាយឈ្នះៗ របស់**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ដែលបានធ្វើឲ្យប្រទេសកម្ពុជាទទួលបាននូវ សុខសន្តិភាព ស្ថេរភាព ភាតរភាព និងការអភិវឌ្ឍស្ទើគ្រប់វិស័យទាំងអស់។

ទន្ទឹមនឹងការកំពុងអភិវឌ្ឍនេះហើយ ដែលធ្វើឲ្យប្រទេសកម្ពុជា ជួបបញ្ហាជាច្រើន ដែលជា កត្តារាំងស្ទះដល់ការរីកចម្រើនរបស់ប្រទេសជាតិ។ ដើម្បីជាការរួមចំណែក ក្នុងការកាត់បន្ថយនូវ ភាពអវិជ្ជមានទាំងនោះ គឺត្រូវមានការចូលរួមយ៉ាងយកចិត្តទុកបំផុត ពីសំណាក់រាជរដ្ឋាភិបាល ថ្នាក់ ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ជាពិសេស គឺប្រជាពលរដ្ឋទាំងមូល ដែលជាស្នូលក្នុងការជួយជាតិ មាតុភូមិ។ ដើម្បីឲ្យប្រទេសជាតិមួយខ្លាំងក្លាទៅបាន គឺត្រូវមានច្បាប់សម្រាប់គ្រប់គ្រង ដើម្បីធ្វើឲ្យ មានប្រសិទ្ធិភាពតទៅបាន គឺត្រូវការមានអ្នកចូលរួមគោរពទាំងអស់គ្នា ហើយដើម្បីអាចឲ្យប្រជា ពលរដ្ឋគោរពច្បាប់បាន លុះត្រាណា តែប្រជាពលរដ្ឋមានចំណេះដឹងគ្រប់គ្រាន់ និងចេះច្បាប់ ព្រោះ ថា ប្រជាពលរដ្ឋមិនត្រូវនិយាយថា **ខ្លួនមិនចេះច្បាប់នោះទេ**។ ដើម្បីអាចឲ្យប្រជាពលរដ្ឋចេះដឹងបាន គឺត្រូវការ មានអ្នកផ្សព្វផ្សាយ និងបង្ហាត់បង្រៀនទៅដល់ពួកគាត់។

យ៉ាងណាមិញ សៀវភៅសារណាស្តីពី ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌនៅសាលា ដំបូងរាជធានី-ខេត្ត (ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម) ស្ថិតក្នុងទីនេះ ដែលយើងខ្ញុំជា និស្សិតច្បាប់ បានខិតខំស្រាវជ្រាវយកមកសរសេរយ៉ាងក្បោះក្បាយ ពាក់ព័ន្ធនៃនីតិវិធីព្រហ្មទណ្ឌ ជាពិសេស មុខងារ តួនាទី របស់បុគ្គលសំខាន់ៗ មួយចំនួន ក្នុងរឿងក្តីព្រហ្មទណ្ឌ មកលាតត្រដាង ធ្វើការបង្ហាញដល់សាធារណជន ដើម្បីឲ្យកាន់តែយល់ច្បាស់ ស៊ីជម្រៅ និងកាន់តែលម្អិតអំពីវិស័យ ច្បាប់ដែលពាក់ព័ន្ធទៅនឹងរឿងក្តីព្រហ្មទណ្ឌ។ ពិសេស យើងខ្ញុំមានសង្ឃឹមយ៉ាងគត់មុតថា សៀវភៅ នេះ នឹងបានចូលរួមជាចំណែកដល់ សិស្ស និស្សិត និងប្រជាពលរដ្ឋផងដែរ។

## ២.ចំណោទបញ្ហានៃការសិក្សាស្រាវជ្រាវ

សៀវភៅសារណា ដែលមានចំណងជើងថា "**ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌនៅ សាលាដំបូងរាជធានី-ខេត្ត (ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម)**" គឺយើងខ្ញុំ បានធ្វើការ កំណត់នូវសំណួរស្រាវជ្រាវយ៉ាងជាក់លាក់ដូចខាងក្រោម៖

១.តើមូលហេតុអ្វីខ្លះ ដែលនាំឲ្យកើតមានបទល្មើសព្រហ្មទណ្ឌ?

២.តើស្ថាប័ន និងតួអង្គណាខ្លះ ដែលជាអ្នកមានសមត្ថកិច្ចដោះស្រាយរឿងក្តីនេះ?

ចំពោះចម្លើយសំណួរស្រាវជ្រាវទាំងនេះ នឹងមានបង្ហាញនៅក្នុងជំពូកទី១ ទី២ និងទី៣ នៃសារណានេះ ដោយសំណួរទី១ គឺត្រូវបានដោះស្រាយក្នុងជំពូកទី១ និងសំណួរទី២ ត្រូវបានដោះស្រាយនៅក្នុងជំពូកទី២ និងទី៣។

## ៣.គោលបំណងនៃការសិក្សាស្រាវជ្រាវ

ដើម្បីឆ្លើយតបទៅនឹងចំណោទបញ្ហា នៃការស្រាវជ្រាវខាងលើនេះ យើងខ្ញុំបានស្រាវជ្រាវយកមកសរសេរចងក្រងឡើង ដោយមានគោលបំណងផ្តោតសំខាន់ទៅលើ៖

-ការស្វែងយល់អំពីមូលហេតុនៃរឿងរ៉ាវ និងទ្រឹស្តីច្បាប់ ស្តីពីកិច្ចនៃនីតិវិធីព្រហ្មទណ្ឌ។

-ការស្វែងយល់អំពីស្ថាប័ន ភាគី និងតួអង្គសំខាន់ៗ ក្នុងដំណើរការនៃរឿងក្តីព្រហ្មទណ្ឌ។

-លើកពីបញ្ហាប្រឈម ដែលកើតមានឡើង និងស្វែងរកដំណោះស្រាយដ៏សមរម្យបន្ថែម។

## ៤.ទំហំ និងដែនកំណត់នៃការសិក្សាស្រាវជ្រាវ

ចំពោះការសិក្សាស្រាវជ្រាវសារណានេះ យើងខ្ញុំ បានធ្វើការបែងចែកជាពីរផ្នែកសំខាន់ៗ ដើម្បីឲ្យកាន់តែច្បាស់លាស់ក្នុងខ្លឹមសារនៃសារណា ដែលផ្នែកទាំងនោះរួមមានដូច៖

**ក.ទំហំនៃការស្រាវជ្រាវ៖** គឺនៅក្នុងសាលាដំបូងរាជធានី-ខេត្ត នៃព្រះរាជាណាចក្រកម្ពុជា។

**ខ.ដែនកំណត់នៃការស្រាវជ្រាវ៖** គឺការសរសេររៀបរាប់ចាប់ពី ដំណាក់កាលនគរបាលយុត្តិធម៌ អយ្យការ ចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ។

## ៥.សារៈសំខាន់នៃសិក្សាការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវទៅលើប្រធានបទណាមួយ គឺពិតជាមានការលំបាកណាស់ ព្រោះយើងត្រូវការចំណាយពេលវេលាច្រើន ចំណាយកម្លាំងកាយចិត្ត ក៏ដូចជាថវិកាជាដើម ជាពិសេស គឺត្រូវមានចំណង់ចំណូលចិត្ត និងការព្យាយាមបន្ថែមទៀតផងដែរ ទើបការសិក្សាស្រាវជ្រាវរបស់យើងទទួលបានជោគជ័យ។

ទោះបីមានការលំបាកយ៉ាងណាក៏ដោយ ក៏យើងខ្ញុំ នៅតែខិតខំជម្នះឲ្យទាល់តែបាន ពីព្រោះថា ការសិក្សាស្រាវជ្រាវប្រធានបទនេះ គឺពិតជាមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ យើងខ្ញុំ ដែលក្នុងនោះរួមមានដូចជា៖

-ទទួលបានចំណេះដឹងថ្មីៗ ពាក់ព័ន្ធនឹងវិធីសាស្ត្រស្រាវជ្រាវ

-ទទួលបានប្រភពឯកសារជាច្រើនដែលទាក់ទងទៅនឹងប្រធានបទ

-យល់ដឹងកាន់តែលម្អិតទៅលើប្រធានបទ ដែលបានសិក្សាស្រាវជ្រាវ

-ចេះធ្វើការប្រៀបធៀបរវាងចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយ

-ធ្វើឲ្យកាន់តែច្បាស់បន្ថែមទៀត អំពីការរៀបប្រយោគ ឃ្លោងឃ្លា អក្ខរាវិរុទ្ធ

-ទទួលបានបទពិសោធន៍ល្អៗ ពីអ្នកមានចំណេះដឹង និងព្រមទាំងអ្នកមានបទពិសោធន៍

-ពិសេស គឺបានបន្សល់ស្នាដៃទុកសម្រាប់សិស្ស និស្សិត បានសិក្សាស្រាវជ្រាវបន្តទៀត។

## ៦.វិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ

ចំពោះវិធីសាស្ត្រនៃការសិក្សាស្រាវជ្រាវ យើងខ្ញុំ បានខិតខំប្រើប្រាស់នូវវិធីសាស្ត្រជាច្រើន ដើម្បីយកមកសរសេរសារណានេះឡើង ដែលក្នុងនោះរួមមានដូចះ

### ក.វិធីសាស្ត្រប្រមូលទិន្នន័យ

ចំពោះវិធីសាស្ត្រប្រមូលទិន្នន័យ គឺយើងខ្ញុំ បានសម្រេចចិត្តរៀបរៀងសរសេរសារណានេះឡើង ដោយបានធ្វើការប្រមូលទិន្នន័យ គឺតាមបែបគុណវិស័យ ដែលជាទិន្នន័យបានមកពីការប្រមូលឯកសារ ទ្រឹស្តី ព័ត៌មាន របាយការណ៍ ការជួបសម្ភាសន៍ ការសាកសួរដោយផ្ទាល់មាត់ ការស្នើសុំឯកសារ និងរបាយការណ៍ ដើម្បីឲ្យដំណើរការនៃការស្រាវជ្រាវនេះទទួលបានភាពជោគជ័យ។

ចំពោះប្រភព និងប្រភេទនៃវិធីប្រមូលទិន្នន័យ ឯកសារ និងព័ត៌មាន ដែលបានសរសេរតាមគុណវិស័យរួមមានះ

-រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-ក្រមព្រហ្មទណ្ឌ និងក្រមនីតិវិធីព្រហ្មទណ្ឌ

-លិខិតបទដ្ឋានគតិយុត្ត យុត្តិសាស្ត្រ សាលក្រម សាលដីកា និងបទបញ្ញប្បត្តិនានា

-របាយការណ៍ និងសៀវភៅមេរៀនសាស្ត្រាចារ្យផ្សេងៗ

-ការជួបសម្ភាសន៍ជាមួយសាស្ត្រចារ្យ គ្រូដឹកនាំ ក៏ដូចជាស្ថាប័នដែលពាក់ព័ន្ធផងដែរ

-និងការប្រមូលឯកសារទិន្នន័យជាច្រើនទៀតតាមប្រព័ន្ធផ្សព្វផ្សាយនានា។

### ខ.វិធីចងក្រង បញ្ចូលទិន្នន័យ និងព័ត៌មាន

បន្ទាប់ពីប្រមូលឯកសារ និងរបាយការណ៍បានគ្រប់គ្រាន់ហើយ យើងខ្ញុំ បានប្រើប្រាស់វិធីចងក្រងឯកសារ ទៅតាមផ្នែកនីមួយៗ ដើម្បីកុំឲ្យមានការភ័ន្តច្រឡំគ្នា ហើយក៏បានវាយឯកសារទាំងនោះបញ្ចូល បញ្ចូលទៅក្នុងប្រព័ន្ធកុំព្យូទ័រ ទៅតាមប្រភេទ និងផ្នែកដែលបានព្រៀងទុក។

## ៧.រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវ

ក្នុងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវប្រធានបទ: **ដំណាក់កាលទាំង ៤ នៃរឿងក្តីព្រហ្មទណ្ឌនៅសាលាដំបូងរាជធានី-ខេត្ត (ករណីការអនុវត្តជាក់ស្តែង និងបញ្ហាប្រឈម)** គឺបានបែងចែករចនាសម្ព័ន្ធនេះជា ៣ជំពូក ដូចខាងក្រោមគឺ

**ជំពូកទី១ ការរំលឹកទ្រឹស្តី៖** គឺជាការប្រមូលទ្រឹស្តីច្បាប់នានា ដែលពាក់ព័ន្ធយកមកសរសេរ និងរឿងរ៉ាវខ្លះៗ ដែលនាំឲ្យកើតមានបទល្មើសព្រហ្មទណ្ឌ។

**ជំពូកទី២ អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការ៖** គឺជាការសរសេររៀបរាប់យ៉ាងពិស្តារ អំពីតួនាទី ភារកិច្ច មុខងារ និងកិច្ចការសំខាន់ៗរបស់នគរបាលយុត្តិ និងអង្គការអយ្យការ ជាពិសេស ស្វែងរកអំពីបញ្ហាប្រឈម និងដំណោះស្រាយជាដើម។

**ជំពូកទី៣ អំពីចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ៖** នៅក្នុងជំពូកនេះ គឺបានសេរសេរ រៀបរាប់អំពីដំណើរនៃការស៊ើបសួរ ការចោទប្រកាន់ ការសម្រេចសេចក្តី និងកិច្ចការ ដែលចៅក្រម ស៊ើបសួរ និងចៅក្រមជំនុំជម្រះត្រូវបំពេញទៅតាមលក្ខខណ្ឌច្បាប់បានកំណត់។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍៖** ការស្វែងរកចំណុចវិជ្ជមាន និងអវិជ្ជមាន ដែលកើតមាន ឡើង និងការខិតខំព្យាយាមស្វែងរកដំណោះស្រាយដ៏សមរម្យដើម្បីចូលរួមកាត់បន្ថយនូវកង្វះខាត ទាំងឡាយនោះ ដែលបានកើតឡើង។

**គំនូសបំព្រួញនៃជំពូកនីមួយៗ**



# ជំពូកទី១
# ការរំលឹកទ្រឹស្ដី

# ជំពូកទី១
# ការរំលឹកទ្រឹស្តី

## ផ្នែកទី១៖ ប្រព័ន្ធស្ថាប័នតុលាការនៃព្រះរាជាណាចក្រកម្ពុជា

នៅក្នុងសង្គម ដែលប្រកាន់របបប្រជាធិបតេយ្យ អំណាចធំៗទាំងបី ត្រូវបែងចែកដាច់ពីគ្នា គឺ **អំណាចនីតិប្បញ្ញត្តិ អំណាចនីតិប្រតិបត្តិ និងអំណាចតុលាការ**។ ចំពោះរដ្ឋធម្មនុញ្ញរបស់ប្រទេសកម្ពុជាបច្ចុប្បន្ន ក៏មានការបែងចែកអំណាចទាំងបី ដាច់ដោយឡែកពីគ្នាផងដែរ គឺចាប់ពីជំពូកទី ៧ ដល់ជំពូកទី១២ថ្មី។

ពាក្យថា "**អង្គការនីតិប្រតិបត្តិ**" គឺសំដៅទៅលើរដ្ឋាភិបាល ដែលមានមានសមាសភាពចាប់ពីនាយករដ្ឋមន្ត្រី សមាជិកគណៈរដ្ឋមន្ត្រី ក្រសួងនានា និងរដ្ឋលេខាធិការដ្ឋានមួយចំនួនទៀតផង។

អង្គការនីតិប្រតិបត្តិមានតួនាទីគឺ "**ប្រតិបត្តិច្បាប់ ឬអនុវត្តច្បាប់ និងគោលនយោបាយទាំងឡាយណា ដែលរដ្ឋសភាបានអនុម័ត និងព្រឹទ្ធសភាបានផ្តល់ការយល់ព្រម**" ចប់សព្វគ្រប់។

ពាក្យថា "**អង្គការនីតិប្បញ្ញត្តិ**" គឺសំដៅលើស្ថាប័នសភា ដែលមាន **រដ្ឋសភា និងព្រឹទ្ធសភា**។ សភានេះ គឺមានតួនាទី "**តាក់តែងច្បាប់ និងអនុម័តច្បាប់**"។

សូមកត់សម្គាល់ថា បើគេប្រើពាក្យថា **សភា** គឺសំដៅលើស្ថាប័ននីតិប្បញ្ញត្តិ ឬពាក្យទូទៅដែលគេកត់សម្គាល់នូវសភាទាំងពីរថ្នាក់គឺ **រដ្ឋសភា និងព្រឹទ្ធសភា**។ តែបើគេចង់និយាយឲ្យចំឈ្មោះនីមួយៗ គឺគេប្រើពាក្យថា រដ្ឋសភា ឬព្រឹទ្ធសភា។

ពាក្យថា "**តុលាការ**" គឺសំដៅទៅលើសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់គឺ "**តុលាការកំពូល សាលាឧទ្ធរណ៍ និងសាលាដំបូង**" ដែលមានតុលាការរាជធានី-ខេត្ត និងតុលាការយោធា។ សាលាជម្រះក្តីមានតួនាទីកាត់ក្តីលើគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងរដ្ឋបាល និងពាណិជ្ជកម្មផងដែរ[១]។

### កថាខណ្ឌទី១៖ ប្រវត្តិស្ថាប័នតុលាការកម្ពុជា

ការមកដល់របស់អ៊ុកតាក់ (UNTAC) នៅក្នុងឆ្នាំ១៩៩២ បាននាំមកនូវការផ្លាស់ប្តូរដ៏សំខាន់នៅក្នុងប្រព័ន្ធតុលាការកម្ពុជា។ សាលាឧទ្ធរណ៍ ត្រូវបានបង្កើតឡើង ដែលជាលទ្ធផលកើតជាប្រព័ន្ធតុលាការ ដែលមានពីរជាន់ ( ជាន់ខ្ពស់ និងជាន់ទាប) ហើយចែកចេញជាបីថ្នាក់គឺ

ក.តុលាការរាជធានី ខេត្ត (តុលាការថ្នាក់ទី១)

ខ.សាលាឧទ្ធរណ៍ និង (តុលាការថ្នាក់ទី២)

គ.តុលាការកំពូល (តុលាការថ្នាក់ទី៣ និងជាថ្នាក់ចុងក្រោយ)។

---

[១] និពន្ធដោយ ឯកឧត្តម ឥន យឿន សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ បោះពុម្ពលើកទី៣ ទំព័រ១៥

ព័ត៌មានលម្អិតមានចែងនៅក្នុង **"ច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី"** ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៣[២]។

**១.១.អំពីសាលាដំបូងរាជធានី-ខេត្ត**

សាលាដំបូង គឺជាតុលាការជាន់ទាប ដែលក្នុងនោះរួមមាន តុលាការរាជធានី-ខេត្ត និង តុលាការយោធា។ យុត្តាធិការ របស់តុលាការនីមួយៗ គ្របដណ្តប់លើតំបន់ភូមិសាស្ត្រជាក់លាក់ណាមួយ ដែលតុលាការស្ថិតនៅ។ លើកលែងតែតុលាការយោធាមួយប៉ុណ្ណោះ ដែលមានយុត្តាធិការគ្របដណ្តប់លើទឹកដី នៃព្រះរាជាណាចក្រកម្ពុជាទាំងមូល។

តុលាការនេះ គឺជាតុលាការជម្រះក្តីថ្នាក់ទាបបំផុត។ ជាគោលការណ៍ តុលាការរាជធានី ឬ តុលាការខេត្ត មានពីរផ្នែកគឺ ផ្នែករដ្ឋប្បវេណី និងផ្នែកព្រហ្មទណ្ឌ។ ប៉ុន្តែនៅក្នុងការអនុវត្តន៍ ដោយសារចំនួនចៅក្រមនៅមានកម្រិតនៅឡើយ គេពុំទាន់ឃើញមានការបែងចែកច្បាស់លាស់រវាង ផ្នែកទាំងពីរនេះនៅឡើយទេ។ ចៅក្រម អាចដោះស្រាយទាំងរឿងក្តីរដ្ឋប្បវេណី និងរឿងក្តីព្រហ្មទណ្ឌ។ ចៅក្រម តែងតែសម្រេចលើករណីទាំងអស់ក្នុងនាមជាចៅក្រមតែមួយ[៣]។

**១.២.អំពីតុលាការយោធា**

តុលាការយោធា មានទីតាំងនៅក្នុងរាជធានីភ្នំពេញ។ តុលាការនេះ គឺជាតុលាការដំបូង ដែលមានយុត្តាធិការផ្តាច់មុខលើករណីទាំងឡាយ ដែលប្រព្រឹត្តឡើងដោយកងយោធា ដែលពាក់ព័ន្ធនឹង៖

-បទល្មើសយោធា (ការរំលោភករណីកិច្ចយោធា ការប្រព្រឹត្តិខុសវិន័យយោធា)។ និង

-បទល្មើសណាមួយ ដែលប៉ះពាល់ដល់ទ្រព្យសម្បត្តិកងទ័ព។

បទល្មើសធម្មតាផ្សេងៗ ទៀត (ដូចជា មនុស្សឃាត អំពើប្លន់) ដែលបង្កឡើងដោយ កងយោធិន គឺត្រូវនៅក្រោមយុត្តាធិការរបស់តុលាការរាជធានី ខេត្ត។ តុលាការយោធា ត្រូវស្ថិតនៅក្រោមការត្រួតពិនិត្យរបស់ក្រសួងការពារជាតិ ខាងផ្នែករដ្ឋបាល ហិរញ្ញវត្ថុ និងផ្នែកបរិក្ខារ[៤]។

---

[២] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៨

[៣] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៨

[៤] វិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ សៀវភៅសិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ទំព័រ៩

## ផ្នែកទី២៖ ដំណើរការនៃរឿងក្ដីព្រហ្មទណ្ឌ

ដើម្បីការពាររបបសង្គម សណ្ដាប់ធ្នាប់សាធារណៈ និងរបៀបរៀបរយសង្គម រដ្ឋបានប្រើប្រាស់នូវវិធានការផ្សេងៗ ដែលមានចរិកកែលម្អរផង និងមានលក្ខណៈបង្ខិតបង្ខំផង។ គ្រប់បទដ្ឋានគតិយុត្ត ដែលបានដាក់ចេញឲ្យប្រើប្រាស់ក្នុងគោលបំណងចាត់តាំង និងគ្រប់គ្រងសង្គម ដែលតែងតែមានលក្ខណៈបង្ខិតបង្ខំដើម្បីអនុវត្ត និងតទល់ជាមួយនឹងអំពើរំលោភបំពាន។ បើ អំពើរំលោភបំពានមានលក្ខណៈធ្ងន់ធ្ងរ បង្កឲ្យមានការអន្តរាយធំធេងនោះ រដ្ឋត្រូវប្រើប្រាស់នូវវិធានការខ្លាំងក្លា និងមានលក្ខណៈបង្ខិតបង្ខំតាមច្បាប់ព្រហ្មទណ្ឌ ឬលិខិតបទដ្ឋានព្រហ្មទណ្ឌ ដែលបានកំណត់ថាជាអំពើរំលោភបំពាននោះ ជាបទល្មើសដែលឬទេ និងកំណត់អំពីទោសទណ្ឌ ដើម្បីអនុវត្តទៅលើជនដែលបានប្រព្រឹត្តិបទល្មើស[៥]។

### កថាខណ្ឌទី១៖ មូលហេតុនៃរឿងក្ដីព្រហ្មទណ្ឌ

ដោយសារតែការរស់នៅមិនចុះសម្រុងនឹងគ្នា រវាងសត្វនិងសត្វ, សត្វនិងមនុស្ស, មនុស្សនិងមនុស្ស ដែលជាហេតុធ្វើឲ្យសង្គមមានការរីករវ ព្រោះតែមានការបៀតបៀន កាប់សម្លាប់ជិះជាន់គ្នាទៅវិញទៅមក។ ព្រោះតែហេតុដូច្នេះហើយ បានជាលោក ហ្ស៊ង់ហ្សាក់ រ៉ូស្សូ (Jean Jacques Rousseau) ជាទស្សនវិទូបារាំង ជាអ្នកទ្រឹស្ដីនយោបាយ និងអ្នកក្រមសីលធម៌ គឺបានវិភាគមិនប្លែកពីអ្នកនិពន្ធដទៃទៀតនៅជំនាន់នោះទេ គឺការវិភាគ ដែលចេញពីសភាពធម្មជាតិមូលដ្ឋាន។ នៅក្នុងសភាពធម្មជាតិ អ្នកខ្លាំងមានជ័យជំនះលើអ្នកខ្សោយ ហើយមានតែជម្លោះ សង្គ្រាម ការប្រឆាំង និងចលាចល។ ដូច្នេះហើយ មនុស្សមានផ្លូវតែមួយគត់ គឺការរត់ទៅជ្រកកោនក្រោមដំបូលរបស់រដ្ឋឱ្យជួយការពារខ្លួន។ លោកបានលើកឡើងថា **នៅក្នុងសង្គមមនុស្សប្រៀបបីដូចជាហ្វូងឆ្កែចចក ដែលចាំតែហែកហួរខាំគ្នាទៅវិញទៅមក ដើម្បីចិញ្ចឹមជីវិតរបស់ខ្លួន**។

នៅក្នុងទ្រឹស្ដីនយោបាយក្នុងស្នាដៃរបស់លោកដ៏សំខាន់មួយគឺ **កិច្ចព្រមព្រៀងសង្គម** ដែលបានសរសេរនៅឆ្នាំ១៧៦២។ មានន័យថា ដើម្បីឲ្យសង្គមមនុស្សរស់នៅសុខដុមរម្យនា និងឆន្ទៈរួមគ្នា គឺមនុស្សគ្រប់រូប ត្រូវការច្បាប់ដើម្បីរារាំងទប់ស្កាត់ កុំឲ្យមានការរំលោភបំពានកើតឡើង។

ដើម្បីឱ្យមានការកើតឡើងនូវឆន្ទៈរួម លោកបានគិតថា ជាការចាំបាច់ ត្រូវការនូវលក្ខខ័ណ្ឌមួយចំនួន ហើយជាបឋម គឺសមភាពនៅក្នុងសម្បត្តិឯកជន គឺជា**ច្បាប់សង្គម**។

ទោះបីជារដ្ឋ បានបង្កើតច្បាប់នានាក៏ដោយ ក៏នៅតែមានមនុស្សមួយចំនួន ដែលតែងតែប្រព្រឹត្តិខុសច្បាប់។

---

[៥] សាស្ត្រាចារ្យ ឆឹង ស៊ីនៀង សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ ទំព័រ៦ ឆ្នាំសិក្សា២០១៦-២០១៧

### ១.១.ដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌ

នីតិវិធីព្រហ្មទណ្ឌ គឺជាច្បាប់ ដែលសិក្សាពីរបៀបរបបនៃការរៀបចំអំណាចតុលាការជាជាន់ជាថ្នាក់ ពីការរៀបចំជាវិធីដើម្បីតម្រូវឲ្យសាលាជម្រះក្តី គោរពតាមគោលការណ៍ ដែលត្រូវគោរពសិទ្ធិ និងសេរីភាពបុគ្គល ក្នុងការឃាត់ខ្លួន ឃុំខ្លួន និងនីតិវិធីផ្សេងៗទៀត ដើម្បីត្រួតពិនិត្យការអនុវត្តច្បាប់ដោយអង្គការតុលាការគ្រប់ជាន់ថ្នាក់។

ច្បាប់នៃនីតិវិធីព្រហ្មទណ្ឌ ជាច្បាប់ដែលមានសារៈសំខាន់ខ្លាំងណាស់ សម្រាប់ដំណើរការរឿងក្តីព្រហ្មទណ្ឌ និងការការពារសង្គម ក៏ដូចជាសេរីភាពរបស់បុគ្គលផងដែរ ដោយអនុញ្ញាតឲ្យជនដែលគ្មានកំហុសអាចចៀសផុត ពីការភ័ន្តច្រឡំផ្នែកតុលាការ ពោលគឺឲ្យជនជាប់ចោទការពារខ្លួនផ្តល់នូវអំណះអំណាងបញ្ជាក់ពី ភាពបរិសុទ្ធរបស់ខ្លួន។

នីតិវិធីព្រហ្មទណ្ឌ នៃប្រទេសកម្ពុជា ត្រូវបានគ្រប់គ្រងដោយក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើនៅឆ្នាំ២០០៧ ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ប្រកាសឲ្យប្រើនៅឆ្នាំ២០១៤ និងមានច្បាប់ពិសេសជាច្រើនទៀតផងដែរ[៦]។

ចំពោះដំណាក់កាលនៃនីតិវិធីព្រហ្មទណ្ឌទាំងនោះ រួមមានដូចជា៖

ក.បណ្តឹងក្នុងរឿងក្តីព្រហ្មទណ្ឌ

ខ.ភាគីក្នុងរឿងក្តីព្រហ្មទណ្ឌ

គ.ភស្តុតាងក្នុងរឿងក្តីព្រហ្មទណ្ឌ

ឃ.អំពីនគរបាលយុត្តិធម៌

ង.អំពីអយ្យការ

ច.អំពីចៅក្រមស៊ើបសួរ

ឆ.អំពីការចៅក្រមជនុំជម្រះ និង

ជ.អំពីបណ្តឹងតវ៉ា

### ១.២.តួអង្គសំខាន់ៗ ក្នុងរឿងក្តីព្រហ្មទណ្ឌ

នៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ដែលបានអនុម័តនៅឆ្នាំ ២០០៧ កំណត់អំពីតួនាទី និងការទទួលខុសត្រូវរបស់ភាគីផ្សេងៗ នៃដំណើរការរឿងក្តីព្រហ្មទណ្ឌ។

យ៉ាងណាមិញ ចំពោះតួអង្គសំខាន់ៗ នៅក្នុងរឿងក្តីព្រហ្មទណ្ឌរួមមានដូចជា៖

១. នគរបាលយុត្តិធម៌

[៦] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ០១ ឆ្នាំ២០១៧-២០១៨

២. ព្រះរាជអាជ្ញា

៣. ជនល្មើស

៤. ជនរងគ្រោះ និងដើមបណ្តឹងរដ្ឋប្បវេណី

៥. អ្នកទទួលខុសត្រូវរដ្ឋប្បវេណី និង

៦. តតិយជន

# ជំពូកទី២
# អំពីនគរបាលយុត្តិធម៌ និងអង្គការអយ្យការ

# ជំពូកទី២
# អំពីនគរបាលយុត្តិធម៌ និងអង្គភាពអយ្យការ

នៅក្នុងដំណាក់កាលទាំងបួន នៃរឿងក្តីព្រហ្មទណ្ឌនៅតាមសាលាដំបូងរាជធានី-ខេត្ត ត្រូវបានចែកចេញជាពីរជំពូក ដោយជំពូកទី២ គឺចែកចេញជាពីរផ្នែកសំខាន់ៗ។ ដោយផ្នែកទី១ គឺត្រូវបានសរសេររៀបរាប់អំពីដំណាក់កាលនគរបាលយុត្តិធម៌ និងផ្នែកទី២ គឺដំណាក់កាលអង្គអយ្យការ។

## ផ្នែកទី១៖ ដំណាក់កាលនគរបាលយុត្តិធម៌

នៅក្នុងដំណាក់កាលទី១ នៃរឿងក្តីព្រហ្មទណ្ឌ បន្ទាប់ពីមានបទល្មើសកើតឡើងរួចហើយ ឬកំពុងកើតឡើង ឬនឹងកើតឡើងក្នុងពេលខាងមុខ ស្ថាប័នដែលពាក់ព័ន្ធក្នុងការជួយដោះស្រាយរឿងក្តីនេះមុខគេ គឺនគរបាលយុត្តិធម៌។ តើអ្នកណាខ្លះ ដែលជានគរបាលយុត្តិធម៌?

### កថាខណ្ឌទី១៖ ការផ្តល់និយមន័យអំពីនគរបាល

ដើម្បីដឹងថា អ្នកណាខ្លះ ដែលជានគរបាលយុត្តិធម៌ យើងគួរគប្បីសិក្សានិយមន័យជាមុនសិន ដើម្បីមានភាពងាយស្រួលក្នុងការកំណត់ចំណាំ។

ពាក្យថា **នគរបាល ឬប៉ូលិស** ត្រូវបានប្រើប្រាស់ក្នុងន័យទូលំទូលាយ ដែលមិនបានចង្អុលបង្ហាញពីស្ថាប័នទេ ប៉ុន្តែជាការកំណត់បង្ហាញអំពីមុខងារ ឬជាសកម្មភាព ដែលធ្វើការបម្រើផលប្រយោជន៍ទូទៅក្នុងការធានាឲ្យបាននូវសន្តិសុខ សណ្តាប់ធ្នាប់សង្គម ភាពសុខសាន្តជូនដល់ប្រជាពលរដ្ឋ ហើយបន្តិចម្តងៗ មានការចង្អុលបង្ហាញអំពីតួនាទី នៃរដ្ឋបែបទំនើប។

ដូច្នេះពាក្យថា **នគរបាល ឬប៉ូលិស** គឺសំដៅដល់ការយកចិត្តទុកដាក់ចំពោះសណ្តាប់សាធារណៈ ដែលពុំមានការរំខានដូចជា៖

-ភាពស្ងប់ស្ងាត់សាធារណៈ

-សន្តិសុខសាធារណៈ

-សុខុមាលភាពសាធារណៈ។

ជាគោលការណ៍ មុខងារនៃនគរបាលមានពីរយ៉ាងគឺ

**-គោលការណ៍ទី១៖** គឺដើម្បីធ្វើការថែរក្សាសណ្តាប់ធ្នាប់សាធារណៈឲ្យបានល្អ សកម្មភាពនគរបាលស្តែងឡើងតាមរយៈការបង្កើតបទដ្ឋានគតិយុត្តផ្សេងៗ ដើម្បីទប់ស្កាត់ និងធ្វើការការពារនូវការឃាយី ឬការរំខានណាមួយជាយថាហេតុ (ការបង្ការ)។

**-គោលការណ៍ទី២៖** ពេលដែលសណ្តាប់ធ្នាប់សាធារណៈត្រូវបានរំខាន ឬត្រូវបានគំរាមគំហែងតាមរយៈបទល្មើសផ្សេងៗ នោះសកម្មភាពនគរបាលត្រូវចាត់វិធានការភ្លាមៗ គឺការបង្ក្រាប

និងធ្វើការរុករកស្រាវជ្រាវ ព្រមទាំងបញ្ជូនជនល្មើស និងសំណុំរឿងតាមនីតិវិធីជាធរមាន (ស្តែងតាមរយៈនគរបាលយុត្តិធម៌)។

ផ្អែកតាមគោលការណ៍នេះ គេអាចទាញចេញនូវសកម្មភាពរបស់នគរបាលជាពីរប្រភេទគឺ

**១.នគរបាលរដ្ឋបាល** ( Police Administration = PA )

**២.នគរបាលយុត្តិធម៌** (Police Judicaire = PJ )[៧]។

### ១.១.នគរបាលរដ្ឋបាល

**ក.និយមន័យ**

**នគរបាលរដ្ឋបាល** គឺជាសកម្មភាព ដែលមានលក្ខណៈធានារក្សានូវសណ្តាប់ធ្នាប់សាធារណៈ ភាពស្ងប់ស្ងាត់ សុខុមាលភាពសាធារណៈ និងសប្បាយភាពជាសាធារណៈ។

**ខ.លក្ខណៈ**

**នរគបាលរដ្ឋបាល** មានបេសកកម្ម ដែលមានលក្ខណៈជាការតំណាងឲ្យសកម្មភាពសេវាសាធារណៈ ដោយជាគោលការណ៍ សកម្មភាពនេះ ត្រូវបានគេមើលឃើញថា ជាសកម្មភាពរបស់អាជ្ញាធររដ្ឋបាល ក្នុងនោះមានអាជ្ញាធររដ្ឋបាលថ្នាក់ជាតិ និងអាជ្ញាធររដ្ឋបាលថ្នាក់ក្រោមជាតិ។

ដូចនេះហើយ សកម្មភាពរបស់នគរបាលរដ្ឋបាល គឺសំដៅទៅដល់ការថៃរក្សាសណ្តាប់ធ្នាប់សាធារណៈ ចេញសេចក្តីសម្រេច ដែលជាវិធាន ដែល លក្ខណៈជាបទបញ្ជាទូទៅ។ បទបញ្ជាទូទៅរបស់នគរបាលរដ្ឋបាល មិនសំដៅទៅលើបុគ្គល ឬក្រុមណាមួយនោះទេ មានន័យថា គឺជាវិធានដែលចេញដោយអាជ្ញាធររដ្ឋបាលនេះ គឺត្រូវតែគោរពច្បាប់ ក៏ដូចជាសេចក្តីសម្រេចផ្សេងៗ ទៀត។ ព្រោះថា សេចក្តីសម្រេច ដែលមានលក្ខណៈជាវិធាន របស់នគរបាលរដ្ឋបាល ត្រូវមានមូលដ្ឋានគតិយុត្ត ជាពិសេស ត្រូវផ្អែកទៅលើមូលដ្ឋាន នៃសណ្តាប់ធ្នាប់សាធារណៈ។ ប៉ុន្តែ សណ្តាប់ធ្នាប់នៅទីនេះ មានន័យទូលំទូលាយ ដែលជាហេតុនាំឲ្យមានការបកស្រាយខុសៗ គ្នា និងអាចធ្វើឲ្យមានការប៉ះពាល់ដល់សេរីភាពសាធារណៈ ក៏ដូចជាសេរីភាពរបស់ប្រជាពលរដ្ឋ។

**គ.អំណាចរបស់នគរបាលរដ្ឋបាល**

អំណាចរបស់នគរបាលរដ្ឋបាល ត្រូវតែដោយបង្ខំនូវកម្លាំងប្រដាប់អាវុធតាមរយៈ អាជ្ញាធររដ្ឋបាលដែលមានសមត្ថកិច្ច។ ហើយអំណាចរបស់អាជ្ញាធរនគរបាលរដ្ឋបាលនេះ មានពីរប្រភេទទៀត ដែលក្នុងនោះរួមមាន៖

[៧] សាស្ត្រាចារ្យ មីន សំអុល សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៨៤-៨៥

**១.អាជ្ញាធរនគរបាលរដ្ឋបាលថ្នាក់ជាតិ៖** មាននាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ដែលជាប្រធានស្ថាប័ន។

**២.អាជ្ញាធរនគរបាលរដ្ឋបាលថ្នាក់ក្រោមជាតិ៖** មានអភិបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ និងសង្កាត់ជាដើម។

អំណាចរបស់អាជ្ញាធរនគរបាលរដ្ឋបាល ត្រូវប្រើប្រាស់ដោយបង្ខំនូវកម្លាំងប្រដាប់អាវុធនេះ មិនត្រូវប្រើប្រាស់ក្រៅច្បាប់ឡើយ ពោលគឺស្ថិតនៅក្នុងក្របខណ្ឌនៃច្បាប់ជានិច្ច[៨]។

### ១.២.នគរបាលយុត្តិធម៌

**ក.និយមន័យ**

**នគរបាលយុត្តិធម៌** គឺជាជំនួយនៃអំណាចតុលាការ និងធ្វើការទទួលបន្ទុកក្នុងការត្រួតពិនិត្យ បទល្មើស ឧក្រិដ្ឋ មជ្ឈិម និងបទលហុ ដោយកំណត់ពីអត្តសញ្ញាណ និងចាប់ជនល្មើស ព្រមទាំង ប្រមូលភស្តុតាងជាដើម។

**ខ.លក្ខណៈ**

យើងគួរស្វែងយល់នូវភាពខុសគ្នារវាង នគរបាលយុត្តិធម៌ និងយោធាថា៖

**យោធា** គឺជាអង្គភាពមួយ ដែលមានសមត្ថកិច្ចក្នុងការការពារជាតិ និងបូរណភាពទឹកដីនៃរដ្ឋ ឯករាជ្យមួយ។ រដ្ឋ ត្រូវការយោធាជាចាំបាច់ ដោយមិនអាចខ្វះបានឡើយ ព្រោះយោធាត្រូវប្រឈម ទៅនឹងសភាពការណ៍នានាចាំបាច់សម្រាប់សង្គម និងធានារក្សានូវសណ្តាប់ធ្នាប់ឡើងវិញ បន្ទាប់ពី មានការចលាចលបានកើតឡើង។ ប៉ុន្តែ ការដោះស្រាយបញ្ហានានាតាមរយៈការប្រើប្រាស់កម្លាំង យោធា គឺមិនសមស្របទៅនឹងកាលៈទេសៈទេ ចំពោះប្រទេស ដែលបានប្រកាន់យកនូវរបបលទ្ធិ ប្រជាធិបតេយ្យ វាមិនសមហេតុផលឡើយ។

**យោធា** គឺជាកម្លាំងស្នូលខាងផ្នែកនយោបាយរបស់ប្រទេសមួយ ហើយជាកម្លាំងដែលមាន អព្យាក្រឹត្យភាព ក្នុងការការពារឯករាជ្យ អធិបតេយ្យ និងបូរណភាពទឹកដី។

**យោធា** គឺជាកម្លាំងស្នូលខាងផ្នែកនយោបាយរបស់រដ្ឋ ហើយមានលក្ខណៈខុសពីកម្លាំង នគរបាល ដែលជាកម្លាំងសម្រាប់ប្រើប្រាស់ និងថែរក្សាសណ្តាប់ធ្នាប់សាធារណៈលក្ខណៈផ្ទៃក្នុង។

ដូចនេះ អាជ្ញាធររដ្ឋបាល បានបញ្ចៀបនូវការប្រើប្រាស់កម្លាំងយោធា គឺបំពេញសកម្មភាព របស់នគរបាលនេះ ដោយត្រូវបង្កើតកម្លាំងមួយជំនួសឲ្យយោធាវិញ នោះគឺ **កងរាជអាវុធហត្ថ**។

**កងរាជអាវុធហត្ថ** គឺជាផ្នែកមួយ នៃកងយោធពលខេមរភូមិន្ទ ស្ថិតក្រោមការផ្គត់ផ្គង់របស់

---

[៨] សាស្ត្រាចារ្យ មីន សំអុល សៀវភៅនីតិរដ្ឋបាលទូទៅ ឆ្នាំសិក្សា២០១៦-២០១៧ ទំព័រ៨៤-៨៥

អគ្គបញ្ជាការដ្ឋាន ហើយស្ថិតក្រោមការបញ្ជាផ្ទាល់របស់នាយករដ្ឋមន្ត្រី (បង្កើតឡើងដោយអនុក្រឹត្យលេខ៧៧ អនក្រ/បក ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ១៩៩៤) មានតួនាទីជានគរបាលរដ្ឋបាល ជានគរបាលយុត្តិធម៌ ជាតម្រួតយោធា និងមានលក្ខណៈពិសេសជាអន្តរក្រសួង (តាមរយៈការស្នើសុំអន្តរាគមន៍ពីអន្តរក្រសួងជាដើម)។

**កថាខណ្ឌទី២៖ លក្ខខណ្ឌដើម្បីក្លាយខ្លួនជានគរបាលយុត្តិធម៌**

អ្នកដែលអាចក្លាយខ្លួនទៅជាមន្ត្រីនគរបាលយុត្តិធម៌បាន ត្រូវបានកំណត់នៅក្នុងមាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចំពោះអ្នកដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌រួមមាន៖

**១.**មន្ត្រីនគរបាលយុត្តិធម៌ មានឋានន្តរសក្តិចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុត២ឆ្នាំ ក្នុងនគរបាលយុត្តិធម៌រួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

**២.**នាយទាហាននៃកងរាជអាវុធហត្ថ ដែលបានបម្រើការងារយ៉ាងតិច២ឆ្នាំនៅក្នុងកងរាជអាវុធហត្ថរួចហើយ ហើយបន្ទាប់ពីបានទទួលសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌។

**៣.** អ្នកមានឋានន្តរស័ក្តិ និងមុខងារដូចខាងក្រោម៖

**ក.** អភិបាល និងអភិបាលរងខេត្ត ក្រុង, អភិបាល អភិបាលរងស្រុក ខណ្ឌ និងមេឃុំ ចៅសង្កាត់។

**ខ.**ប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌, ប្រធាន និងអនុប្រធានកណ្តាលសន្តិសុខ និងប្រធាន និងអនុប្រធាននាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈនៃអគ្គស្នងការដ្ឋាននគរបាលជាតិ។

**គ.** ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ និងស្ថិតក្រោមឱវាទរបស់នាយកដ្ឋានកណ្តាលនគរបាលយុត្តិធម៌ នាយកដ្ឋានកណ្តាលសន្តិសុខ និងនាយកដ្ឋានកណ្តាលសណ្តាប់ធ្នាប់សាធារណៈ។

**ឃ.** ប្រធាន និងអនុប្រធាននាយកដ្ឋាន, ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែនាយកដ្ឋាននគរបាលព្រំដែន "ចំពោះបទល្មើសឆ្លងដែន", មន្ទីរប្រឆាំងគ្រឿងញៀន, នាយកដ្ឋាននគរបាលទេសចរណ៍, ស្នងការពិសេសការពារបេតិកភណ្ឌ។

**ង.**ស្នងការ និងស្នងការរងនគរបាលខេត្ត ក្រុង។

**ច.**ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក ដែលទទួលបន្ទុកការងារព្រហ្មទណ្ឌចំណុះស្នងការនគរបាលខេត្ត ក្រុង ដូចជា: ការិយាល័យនគរបាលព្រហ្មទណ្ឌ

កម្រិតធ្ងន់ និងការិយាល័យព្រហ្មទណ្ឌកម្រិតស្រាល, ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន, ការិយាល័យនគរបាលសេដ្ឋកិច្ច, ការិយាល័យបច្ចេកទេសវិទ្យាសាស្ត្រ ព្រហ្មទណ្ឌ, ការិយាល័យប្រឆាំងគ្រឿងញៀន, ការិយាល័យប្រឆាំងភេរវកម្ម និងការិយាល័យជនបរទេស។

**ឆ**.អធិការ និងអធិការរង, ប្រធាន និងអនុប្រធានផ្នែកព្រហ្មទណ្ឌ នៃអធិការដ្ឋាននគរបាលស្រុក ខណ្ឌ។

**ជ**.ប្រធាន និងអនុប្រធានការិយាល័យនគរបាលចរាចរ, ប្រធាន និងអនុប្រធានផ្នែកនគរបាលចរាចរ "ចំពោះបទល្មើសចរាចរណ៍"។ ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ, ប្រធាន និងអនុប្រធានអង្គភាព, ប្រធាន និងអនុប្រធានការិយាល័យគ្រប់គ្រងអាវុធជាតិផ្ទុះ "ចំពោះបទល្មើសអាវុធជាតិផ្ទុះ"។ ប្រធាន និងអនុប្រធានអង្គភាព, ប្រធាន និងអនុប្រធានការិយាល័យនគរបាលទេសចរណ៍

**ឈ**.ប្រធាន និងអនុប្រធានប៉ុស្តិ៍នគរបាលរដ្ឋបាលរដ្ឋបាលឃុំ សង្កាត់ "ចំពោះបទល្មើសព្រហ្មទណ្ឌ"។

**ញ**.មេបញ្ជាការ និងមេបញ្ជាការរងនៃកងរាជអាវុធហត្ថ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

**ដ**.មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថប្រចាំខេត្ត ក្រុង ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

**ឋ**.មេបញ្ជាការ និងមេបញ្ជាការរង នៃកងរាជអាវុធហត្ថប្រចាំ ស្រុក ខណ្ឌ ដែលទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

**ឌ**.ប្រធាន និងអនុប្រធានការិយាល័យ, ប្រធាន និងអនុប្រធានផ្នែក នៃកងរាជអាវុធហត្ថទទួលបន្ទុកកិច្ចការព្រហ្មទណ្ឌ។

**ឍ**.ប្រធាន និងអនុប្រធានអង្គភាពផ្សេងទៀត ដែលទទួលបន្ទុកកិច្ចការស៊ើបអង្កេតបទល្មើសព្រហ្មទណ្ឌ ដែលបង្កើតឡើងក្នុងករណីចាំបាច់[៥]។

បើយោងទៅតាមមាត្រា៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លក្ខខណ្ឌដើម្បីក្លាយខ្លួនទៅជាមន្ត្រីនគរបាលយុត្តិធម៌បានតាមរយៈ៣ របៀបដូចខាងក្រោម៖

[៥] មាត្រា៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**២.១.តាមរយៈការប្រឡងប្រជែង**

ដើម្បីអាចក្លាយខ្លួនទៅជាមន្ត្រីនគរបាលយុត្តិធម៌បាន ចាំបាច់ត្រូវឆ្លងកាត់ការប្រឡង ហើយអ្នកដែលអាចប្រឡងបាន ត្រូវតែជា **មន្ត្រីនគរបាលជាតិ** និង **នាយទាហាននៃកងរាជអាវុធហត្ថ** ចាប់ពីអនុសេនីយ៍ត្រីឡើងទៅ ដែលបានបម្រើការងារយ៉ាងតិចបំផុត២ ឆ្នាំ។

**មាត្រា ៦១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ៖** ចំពោះសញ្ញាបត្រនៃមន្ត្រីនគរបាលយុត្តិធម៌ ត្រូវផ្តល់ជូនបន្ទាប់ពីឆ្លងកាត់ការប្រឡងបែបវិជ្ជាជីវៈ ដែលរួមមានវិញ្ញាសាជាមូលដ្ឋានដូចខាងក្រោម៖

-វិញ្ញាសាស្តីពីនីតិព្រហ្មទណ្ឌ

-វិញ្ញាសាស្តីពីនីតិវិធីព្រហ្មទណ្ឌ

-វិញ្ញាសាស្តីពីករណីយកិច្ចសាស្ត្រ ដូចដែលមានចែងក្នុងក្រមសីលធម៌ ដែលតាក់តែងឡើងដោយអង្គការសហប្រជាតិ។

សញ្ញាបត្រនេះ ត្រូវចុះហត្ថលេខារួមដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ និងរដ្ឋមន្ត្រីពាក់ព័ន្ធ និងមានបោះត្រាផងដែរ[១០]។

**មាត្រា ៦២ .អំពីគណៈមេប្រយោគ៖** គណៈមេប្រយោគនៃការប្រឡង ស្ថិតក្រោមអធិបតីភាពរបស់អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬចៅក្រមអយ្យការអមតុលាការកំពូល ដែលទទួលនូវមុខងារនេះ។

**ក.ទាក់ទងនឹងមន្ត្រីនគរបាលជាតិ៖** គណៈមេប្រយោគ មានសមាសភាពដូចតទៅ៖

-ចៅក្រមស៊ើសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមអយ្យការម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង២រូប របស់ក្រសួងមហាផ្ទៃ។

**ខ.ទាក់ទងនឹងយោធិននៃកងរាជអាវុធហត្ថ៖** គណៈមេប្រយោគមានសមាសភាពដូចជា៖

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយប្រធានតុលាការកំពូល

-ចៅក្រមស៊ើបសួរម្នាក់ ដែលតែងតាំងដោយអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

-តំណាង២រូប មកពីក្រសួងការពារជាតិ។

**មាត្រា ៦៣.ចំពោះសម្បថនៃមន្ត្រីនគរបាលយុត្តិធម៌៖**

មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវសម្បថថា ខ្លួននឹងបំពេញដោយភក្តីភាព នូវមុខងាររបស់ខ្លួន។ សម្បថ ត្រូវធ្វើនៅមុខសាលាឧទ្ធរណ៍។ សម្បថ មិនចាំបាច់ធ្វើជាថ្មីម្តងទៀតនោះឡើយ នៅ

[១០] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១១ ឆ្នាំ២០១៦

ពេលដែលទទួលបាននីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌នាពេលក្រោយទៀត។ រូបមន្តនៃសម្បថត្រូវកំណត់ដោយប្រកាសរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

### ២.២.តាមរយៈឋានន្តរសក្តិ និងមុខងារ

ដោយយោងទៅតាមមាត្រា ៦០ នេះដដែល បានចែងអំពីអ្នកដែលមានគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនដូចជា អភិបាល អភិបាលរង ខេត្ត ក្រុង មេឃុំ ចៅសង្កាត់... ដែលពួកគាត់ទាំងអស់នេះ សុទ្ធតែជាអ្នកដែលមាននូវគុណសម្បត្តិជាមន្ត្រីនគរបាលយុត្តិធម៌។ ប៉ុន្តែ ពួកគាត់ក៏ត្រូវទទួលការតែងតាំងជាក់លាក់ និងស្បថនៅមុខសាលាឧទ្ធរណ៍ផងដែរ[១១]។

### ២.៣.តាមរយៈការទទួលស្គាល់ដោយស្វ័យប្រវត្តិ

មាត្រា ៦០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ លក្ខខណ្ឌនៃការផ្តល់គុណសម្បត្តិជាមន្ត្រីនគបាលយុត្តិធម៌ចំពោះនាយនគរបាលជាតិ និងនាយទាហាននៃកងរាជអាវុធហត្ថ។

នាយនគរបាលជាតិ ដែលមានវិញ្ញាបនបត្របញ្ជាក់ការសិក្សា ស្តីពីមន្ត្រីនគរបាលយុត្តិធម៌មុនពេលក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាបត្រជាន់ខ្ពស់ផ្នែកខាងនគរបាលយុត្តិធម៌ ហើយត្រូវបានតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ដោយប្រកាសរួមរបស់ក្រសួងមហាផ្ទៃ និងក្រសួងយុត្តិធម៌។

នាយទាហាន នៃកងរាជអាវុធហត្ថ ដែលមានវិញ្ញាបនបត្រនៃមន្ត្រីប៉ូលិសតុលាការ មុនក្រមនេះចូលជាធរមាន ត្រូវទទួលបានដោយស្វ័យប្រវត្តិ នូវសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌ ហើយត្រូវបានតែងតាំងជាមន្ត្រីនគរបាលយុត្តិធម៌ ដោយប្រកាសរួមរបស់ក្រសួងការពារជាតិ និងក្រសួងយុត្តិធម៌។

បន្ទាប់ពីក្រមនេះចូលជាធរមាន ដើម្បីទទួលបាននូវគុណសម្បត្តិ ជាមន្ត្រីនគរបាលយុត្តិធម៌មួយចំនួនដូចជា៖

**-មន្ត្រីព្រៃឈើ (ច្បាប់ព្រៃឈើ)៖** មន្ត្រីនៃរដ្ឋបាលព្រៃឈើមួយចំនួន ក៏អាចក្លាយទៅជាមន្ត្រីនគរបាលយុត្តិធម៌បានដែរ ដោយយោងទៅតាមច្បាប់ស្តីពីព្រៃឈើ ឆ្នាំ២០០២ បន្ទាប់ពីទទួលបាននូវការផ្តល់នីតិសម្បទាពីអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

**-មន្ត្រីនៃអង្គភាពប្រឆាំងអំពើពុករលួយ (ច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)៖** ដោយយោងតាមច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ ១៧ មេសា ២០១០ ប្រធាន និងអនុប្រធានអង្គភាពប្រឆាំងអំពើពុករលួយ ត្រូវទទួលបាននូវមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ដោយពេញច្បាប់។ ចំណែកឯមន្ត្រី

[១១] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១២ ឆ្នាំ២០១៦

ផ្សេងទៀតនៃអង្គភាពនេះ នឹងត្រូវទទួលបាននូវមុខងារជាមន្ត្រីនគរបាលយុត្តិធម៌។ អ្នកទាំងអស់ខាងលើនេះ ត្រូវបំពេញនីតិវិធីនៃការស្បថជាការស្រេច។

**-មធ្យោបាយផ្សេងៗ៖** មធ្យោបាយនេះ ប្រើសម្រាប់មន្ត្រីស្ថាប័នមួយចំនួនដូចជា៖ មន្ត្រីគយ បរិស្ថាន ជលផល... ក៏អាចក្លាយទៅមន្ត្រីនគរបាលយុត្តិធម៌បានដែរ[១២]។

**កថាខណ្ឌទី៣៖ សមាសភាពនគរបាលយុត្តិធម៌**

នគរបាលយុត្តិធម៌ ជាជំនួយរបស់អំណាចតុលាការ (មាត្រា ៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ព្រះរាជអាជ្ញា គឺជាអ្នកដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។ ប៉ុន្តែ នៅក្នុងការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ (មាត្រា ៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ជាងនេះទៅទៀត ក្រមនីតិវិធីព្រហ្មទណ្ឌ បានដាក់នគរបាលយុត្តិធម៌ ស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលជាអ្នក អនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌ (មាត្រា៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[១៣]។

ចំពោះសមាសភាពនគរបាលយុត្តិធម៌ ត្រូវបានបែងចែកចេញជា៣ ប្រភេទ នេះបើយោងតាមមាត្រា ៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**១.មន្ត្រីនគរបាលយុត្តិធម៌**

**២.ភ្នាក់ងារនគរបាលយុត្តិធម៌**

**៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត** ដែលច្បាប់ដោយឡែកប្រគល់អំណាចឲ្យធ្វើការពិនិត្យបទល្មើសខ្លះៗ ក្នុងរង្វង់នៃដែនសមត្ថកិច្ចរបស់ខ្លួន។

ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយមានអំណាចលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត កាលណាមន្ត្រីនេះ បំពេញមុខងាររបស់ខ្លួនជានគរបាលយុត្តិធម៌។

ក្រៅពីនេះ នគរបាលយុត្តិធម៌ ក៏ត្រូវស្ថិតក្រោមការឃ្លាំមើល និងការត្រួតពិនិត្យរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ផងដែរ ដោយអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ មានសិទ្ធិអនុវត្តអំណាចខាងវិន័យទៅលើនគរបាលយុត្តិធម៌បាន (មាត្រា ៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) បន្ទាប់ពី

---

[១២] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៣ ឆ្នាំ២០១៦

[១៣] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៨ ឆ្នាំ២០១៧-២០១៨

មានការរាយការណ៍ពីព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ ដោយអគ្គព្រះរាជអាជ្ញា ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ដើម្បីផ្តើមដំណើរការនីតិវិធីនៃការដាក់ពិន័យ (មាត្រា ៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្រៅពីនេះ អគ្គព្រះរាជអាជ្ញា ក៏អាចចេញវិធានការណ៍ដោយផ្ទាល់ទៅលើ មន្ត្រីនគរបាលយុត្តិធម៌បានដែរ ក្នុងករណីមានកំហុសធ្ងន់ធ្ងរ ក្រោយពីការកោះហៅមន្ត្រីនគរបាលយុត្តិធម៌នោះ មកផ្តល់សេចក្តីង្អេតរួចមក។

សេចក្តីសម្រេចដាក់វិន័យនោះអាចជា៖

-ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ ជាបណ្តោះអាសន្នសម្រាប់រយៈពេល៥ ឆ្នាំយ៉ាងច្រើនបំផុត។

-ហាមឃាត់មិនឲ្យបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌ជាស្ថាពរ។

សេចក្តីសម្រេចនេះ គឺត្រូវជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬក្រសួងការពារជាតិ។ សាមីខ្លួនមានសិទ្ធិប្តឹងតវ៉ាទៅរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ក្នុងអំឡុងពេល **១៥** ថ្ងៃ គិតពីថ្ងៃទទួលដំណឹង ហើយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ត្រូវសម្រេចក្នុងអំឡុងពេលយ៉ាងយូរបំផុត **១** ខែ គិតពីថ្ងៃទទួលពាក្យបណ្តឹង។ រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចបដិសេធការហាមឃាត់ ឬបន្ថយរយៈពេលនៃការហាមឃាត់បាន។ សេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ពុំអាចប្តឹងតវ៉ាបានទេ។

### ៣.១.មន្ត្រីនគរបាលយុត្តិធម៌

សមាសភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ គឺមានកំណត់នៅក្នុងមាត្រា ៦០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ តាមអត្ថន័យនៃមាត្រានេះ គុណសម្បត្តិដើម្បីក្លាយជាមន្ត្រីនគរបាលយុត្តិធម៌ គឺអាចទទួលបានតាមរបៀបពីរយ៉ាង៖

-តាមរយៈការប្រឡងយកសញ្ញាបត្រជាន់ខ្ពស់ខាងនគរបាលយុត្តិធម៌

-តាមមុខងារ និងឋានន្តរសក្តិរបស់មន្ត្រីនគរបាលយុត្តិធម៌

មាត្រា៦៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ម្នាក់ៗ ត្រូវស្បថនៅមុខសាលាឧទ្ធរណ៍។

### ៣.២.ភ្នាក់ងារនគរបាលយុត្តិធម៌

សមាសភាពរបស់ភ្នាក់ងារនគរបាលយុត្តិធម៌ មានកំណត់នៅក្នុងមាត្រា៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ភ្នាក់ងារនគរបាលយុត្តិធម៌ ត្រូវស្បថនៅចំពោះសាលាដំបូង (មាត្រា ៧៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ភ្នាក់ងារនគរបាលយុត្តិធម៌ អាចពិនិត្យបទលហុ និងជួយដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការបំពេញមុខងាររបស់ខ្លួន[១៤]។

[១៤] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៩ ឆ្នាំ២០១៧-២០១៨

### ៣.៣.មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត

មាត្រា៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ឲ្យមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈប្រភេទនេះ ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា ក្នុងពេលបំពេញមុខងាររបស់ខ្លួន ជានគរបាលយុត្តិធម៌។ បែបបទ និងនីតិវិធីនៃការផ្ដល់នីតិសម្បទា ត្រូវកំណត់ដោយប្រកាសរួមរវាងក្រសួងយុត្តិធម៌ និងក្រសួងពាក់ព័ន្ធ។

មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ត្រូវស្បថនៅសាលាដំបូង។ មន្ត្រីរាជការ និងភ្នាក់ងារទាំងនេះ ត្រូវធ្វើរបាយការណ៍ ដែលមានតម្លៃត្រឹមតែជាព័ត៌មានធម្មតាប៉ុណ្ណោះ។

រាល់កំហុសក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវធ្វើឲ្យដំណឹងដល់ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ បន្ទាប់មក ជូនព័ត៌មាននេះទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ដែលប្រកាសប្រាប់រដ្ឋមន្ត្រីពាក់ព័ន្ធ ដែលមន្ត្រី ឬភ្នាក់ងារនោះ នៅក្រោមឱវាទ ដើម្បីចាប់ផ្ដើមនីតិវិធីខាងវិន័យ[១៥]។

**កថាខណ្ឌទី៤៖ សមត្ថកិច្ចរបស់នគរបាលយុត្តិធម៌**

ចំពោះសមត្ថកិច្ចរបស់នគរបាលយុត្តិធម៌ ត្រូវបានចែកចេញជាពីរប្រភេទគឺ

### ៤.១.សមត្ថកិច្ចដែនដី

មន្ត្រីនគរបាលយុត្តិធម៌ មានសមត្ថកិច្ចនៅក្នុងព្រំប្រទល់ដែនដីអង្គភាព ដែលខ្លួនត្រូវបានចាត់តាំងឲ្យទៅបម្រើការងារ (មាត្រា ៦៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការកំណត់ពីមណ្ឌលរដ្ឋបាលដែលជាដែនដីសមត្ថកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ មានបញ្ជាក់នៅក្នុងសេចក្ដីសម្រេចតែងតាំងមន្ត្រីនគរបាលយុត្តិធម៌នោះ។ ហេតុនេះ មន្ត្រីនគរបាលយុត្តិធម៌ ដែលត្រូវបានចាត់តាំងឲ្យទៅបម្រើការងារនៅស្រុកណាមួយ នៃខេត្តណាមួយ មានសមត្ថកិច្ចដែនដីត្រឹមនោះប៉ុណ្ណោះ។

**ករណីលើកលែងគឺ**

-នៅរាជធានីភ្នំពេញ មន្ត្រីនគរបាលយុត្តិធម៌ គឺមានសមត្ថកិច្ចលើវិសាលភាព នៃរាជធានីទាំងមូល។

-ការអនុញ្ញាត ឲ្យបំពេញប្រតិបត្តិការ នៅលើវិសាលភាពនៃដែនដីជាតិទាំងមូល ដោយព្រះរាជអាជ្ញា ជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់ ក្នុងករណីបទល្មើសជាក់ស្ដែង។

-ការអនុញ្ញាត ឲ្យបំពេញប្រតិបត្តិការនៅលើវិសាលភាព នៃដែនដីនៃជាតិទាំងមូល ដោយចៅក្រមស៊ើបសួរនៅក្នុងដីកាចាត់ឲ្យស៊ើបសួរជំនួស។

ក្នុងករណី ដែលមានការពន្លាតដែនដីសមត្ថកិច្ច មន្ត្រីនគរបាលយុត្តិធម៌ ត្រូវសុំជំនួយពីមន្ត្រី

[១៥] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២០ ឆ្នាំ២០១៧-២០១៨

នគរបាលយុត្តិធម៌ ដែលមានសមត្ថកិច្ចដែនដី។ ចៅក្រម ត្រូវជូនព័ត៌មានតាមគ្រប់មធ្យោបាយដល់ព្រះរាជអាជ្ញា ដែលមានសមត្ថកិច្ចខាងដែនដីនោះ (មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)[១៦]។

**៤.២.សមត្ថកិច្ចសម្ភារៈ**

តាមក្រមនីតិវិធីព្រហ្មទណ្ឌ កងរាជអាវុធក៏ជានគរបាលយុត្តិធម៌ដែរ។ ព្រោះហេតុនេះហើយ កងរាជអាវុធហត្ថ អាចបំពេញមុខងារជានគរបាលយុត្តិធម៌នៅក្នុងបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ។ ប៉ុន្តែ ចំពោះបទល្មើសយោធា មានតែកងរាជអាវុធហត្ថទេ ដែលមានគុណសម្បត្តិជានគរបាលយុត្តិធម៌ (មាត្រា ៨១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រៅពីនេះ រដ្ឋបាលព្រៃឈើ មានសមត្ថកិច្ចជាមន្ត្រីនគរបាលយុត្តិធម៌ក្នុងការស៊ើបអង្កេតបទល្មើសព្រៃឈើ ហើយមិនអាចអាចស៊ើបអង្កេតបទល្មើសផ្សេងទៀតបានទេ។ ចំពោះសមត្ថកិច្ចសម្ភារៈនេះ យើងអាចហៅម្យ៉ាងទៀតបានថា **សមត្ថកិច្ចតាមសាច់រឿង** ក៏បានដែរ[១៧]។

**កថាខណ្ឌទី៥៖ អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌**

ក្រមនីតិវិធីព្រហ្មទណ្ឌ បានកំណត់អំណាចរបស់មន្ត្រីនគរបាលយុត្តិធម៌ ទៅតាមក្របខ័ណ្ឌនៃការស៊ើបអង្កេតថា តើជាការស៊ើបអង្កេតករណីជាក់ស្តែង ឬការស៊ើបអង្កេតបឋម។

**៥.១.ការស៊ើបអង្កេតករណីជាក់ស្តែង**

**ក.លក្ខខណ្ឌនៃការបើកការស៊ើបង្កេតករណីជាក់ស្តែង៖**

ការស៊ើបអង្កេតករណីជាក់ស្តែង ត្រូវបើកក្នុងករណីមានបទឧក្រិដ្ឋ ឬបទមជ្ឈិមជាក់ស្តែង (មាត្រា ៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

បទល្មើសជាក់ស្តែង ជាបទល្មើសដែលកំពុងប្រព្រឹត្ត បទល្មើសដែលទើបប្រព្រឹត្តរួចភ្លាម។ ចាត់ទុកជាបទល្មើសជាក់ស្តែងដែរ កាលណានៅក្រោយពេលមានបទល្មើសរួចបន្តិចមក ជនដែលគេសង្ស័យ ត្រូវបានសាធារណជន ស្រែកដេញប្រផាត់ចាប់ប្រភឹង ឬបុគ្គលដែលត្រូវគេរកឃើញមានវត្ថុ ឬមានស្លាកស្នាម ឬតម្រុយច្បាស់លាស់ ហើយស៊ីសង្វាក់ផ្សេងទៀត ដែលនាំឲ្យគេសន្និដ្ឋានបានថា បុគ្គលនោះបានប្រព្រឹត្ត ឬបានចូលរួមប្រព្រឹត្តបទល្មើស (មាត្រា ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

មាត្រា៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ចាត់ទុកដូចជាបទល្មើសជាក់ស្តែងដែរ បើទោះបីជាស្ថិតនៅក្រៅពីករណីដែលមានចែងនៅមាត្រា៨៦ ក៏ដោយ គ្រប់បទឧក្រិដ្ឋ ឬមជ្ឈិមទាំងឡាយណាដែលត្រូវបានប្រព្រឹត្តនៅក្នុងទីកន្លែង ដែលអ្នកកាន់កាប់នៅទីនោះ គឺសុំឲ្យព្រះរាជអាជ្ញា ឬមន្ត្រី

[១៦] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២០ ឆ្នាំ២០១៧-២០១៨

[១៧] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២១ ឆ្នាំ២០១៧-២០១៨

នគរបាលយត្តិធមិ ចូលមកពិនិត្យ ឬភ្នាក់ងារនគរបាលយុត្តិធមិ ក្នុងករណីដែលគ្មានមន្ត្រីនគរបាលយុត្តិធមិនៅទីកន្លែងនោះ។

**ខ.ដំណើរការនៃនីតិវិធី អំណាច និងកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធមិ**

**ខ.១.ការចុះទៅកាន់ទីកន្លែងកើតហេតុៈ** ដើម្បីធ្វើការពិនិត្យបទល្មើស ក្រោយពីរាយការណ៍ភ្លាមជូនព្រះរាជអាជ្ញា។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធមិអាចហាមឃាត់បុគ្គលគ្រប់រូបកុំឲ្យទៅទៅណាឆ្ងាយពីកន្លែងបទល្មើស រហូតដល់ពេលបញ្ចប់កិច្ចប្រតិបត្តិការរបស់ខ្លួន។ មន្ត្រីនគរបាលយុត្តិធមិ ត្រូវធ្វើកំណត់ហេតុស្តីពីការស្រាវជ្រាវ និងការពិនិត្យរបស់ខ្លួន។

**ខ.២.ការឃាត់ខ្លួនៈ** ក្នុងករណីបទឧក្រិដ្ឋ ឬមជ្ឈិមជាក់ស្តែង គ្រប់បុគ្គលទាំងអស់ អាចចាប់ខ្លួនជនល្មើស ហើយនាំខ្លួនជននោះ ទៅប្រគល់ជូនដល់មន្ត្រីនគរបាលយុត្តិធមិ ដែលនៅជិតបំផុត (មាត្រា ៨៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

មន្ត្រីនគរបាលយុត្តិធមិ អាចឃាត់ខ្លួនបុគ្គល ដែលសង្ស័យថា បានចូលរួមក្នុងបទល្មើស និងបុគ្គលដែលអាចផ្តល់ព័ត៌មានស្តីអំពីរឿងហេតុបាន។ ក្នុងករណីខាងក្រោយនេះ ការឃាត់ខ្លួនអាចធ្វើទៅបានលុះត្រាតែបុគ្គលនោះ ប្រកែកមិនព្រមផ្តល់ព័ត៌មាន និងមានការយល់ព្រមជាលាយលក្ខណ៍អក្សរឲ្យធ្វើការឃាត់ខ្លួនពីព្រះរាជអាជ្ញា (មាត្រា ៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅពេលមានការឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធមិត្រូវរាយការណ៍ជូនព្រះរាជអាជ្ញាភ្លាម។

រយៈពេលនៃការឃាត់ខ្លួនគឺ ៤៨ម៉ោង ដោយគិតចាប់ពីម៉ោងដែលសាមីខ្លួនមកដល់អង្គភាពនគរបាល ឬកងរាជអាវុធហត្ថ។ ការពន្យាពេលនៃការឃាត់ខ្លួនចំនួនមាន ២៤ ម៉ោងទៀត អាចធ្វើទៅបាន លុះត្រាតែមានលក្ខខណ្ឌដូចតទៅៈ

-មានតម្រុយបង្ហាញឲ្យឃើញថា មានពិរុទ្ធភាពលើបុគ្គល ដែលឃាត់ខ្លួន គឺជានីតិជន ក្នុងបទឧក្រិដ្ឋ។

-ការពន្យាពេលជាវិធានការណ៍ចាំបាច់ ដើម្បីឲ្យការស៊ើបអង្កេតប្រព្រឹត្តទៅបានល្អ។

-ការអនុញ្ញាតដោយព្រះរាជអាជ្ញា ជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។

-ចំពោះការឃាត់ខ្លួនអនីតិជន គឺអាចធ្វើបានចំពោះតែអនីតិជន អាយុចាប់ពី ១៤ ឆ្នាំឡើងទៅ (មាត្រា ៩៦ កថា. ចុងក្រោយនៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ រយៈពេលនៃការឃាត់ខ្លួន ប្រែប្រួលទៅតាមប្រភេទនៃបទល្មើសៈ

**-ចំពោះបទឧក្រិដ្ឋៈ**

-អនីតិជនដែលអាយុពី ១៤ ឆ្នាំ ដល់ក្រោម ឬស្មើ ១៦ ឆ្នាំៈ មិនហួសពី ៣៦ ម៉ោង។

-អនីតិជនដែលមានអាយុ ១៦ ឆ្នាំ ដល់ក្រោម ឬស្មើ ១៨ ឆ្នាំៈ មិនហួសពី ៤៨ ម៉ោង។

**-ចំពោះបទមជ្ឈិម៖**

-អនីតិជន ដែលមានអាយុពី ១៤ ឆ្នាំ ដល់ក្រោម ឬស្មើ ១៦ ឆ្នាំៈ មិនហួសពី ២៤ ម៉ោង។

-អនីតិជនដែលមានអាយុពី១៦ឆ្នាំ ដល់ក្រោម ឬស្មើ ១៨ ឆ្នាំៈ មិនហួសពី ៣៦ ម៉ោង។

ក្នុងរយៈពេលនៃការឃាត់ខ្លួន បុគ្គលដែលឃាត់ខ្លួនមានសិទ្ធិសុំសន្ទនាជាមួយមេធាវី ឬជាមួយជនណាម្នាក់ ដែលខ្លួនជ្រើសរើស កុំឲ្យតែជននេះមានការទាក់ទិននៅក្នុងរឿងជាមួយ។ ទំនាក់ទំនងនេះ អាចធ្វើបានក្នុងរយៈពេល ២៤ ម៉ោងបានកន្លងផុត តាំងពីពេលផ្តើមនៃការឃាត់ខ្លួនមក។ ការសន្ទនាមានរយៈពេល ៣០ នាទី (មាត្រា ៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រោយពីនេះ ការទទួលជំនួយពីគ្រូពេទ្យក្នុងពេលឃាត់ខ្លួន ក៏អាចធ្វើបានដែរ តាមការស្នើសុំរបស់ព្រះរាជអាជ្ញា ឬមន្ត្រីនគរបាលយុត្តិធម៌ (មាត្រា៩៩)។

សម្រាប់ការឃាត់ខ្លួនអនីតិជន មន្ត្រីនគរបាលយុត្តិធម៌ត្រូវជូនព័ត៌មានមានគ្រប់មធ្យោបាយដល់ឪពុកម្តាយ ដល់អ្នកតំណាងស្របច្បាប់ ឬដល់អ្នកដែលទទួលភារកិច្ចលើអនីតិជននេះ (មាត្រា ១០០នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ខ.៣.ការឆែកឆេរ៖**

មន្ត្រីនគរបាលយុត្តិធម៌ អាចធ្វើការឆែកឆេរបានតាមមាត្រា ៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយទទួលនូវការអនុញ្ញាតពីព្រះរាជអាជ្ញា (ជាលាយលក្ខណ៍អក្សរ ឬផ្ទាល់មាត់)។

ការឆែកឆេរត្រូវប្រព្រឹត្តទៅនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬគ្មានអ្នកកាន់កាប់ទេ ត្រូវធ្វើនៅចំពោះមុខសាក្សីពីរនាក់។

ក្នុងករណីដែលការឆែកឆេរ ត្រូវធ្វើនៅក្នុងការិយាល័យមេធាវី មន្ត្រីនគរបាល ពុំអាចធ្វើការឆែកឆេរបានឡើយ។ មានតែព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរប៉ុណ្ណោះ ដែលអាចឆែកឆេរបាននៅចំពោះមុខប្រធានគណៈមេធាវី ឬប្រតិភូរបស់ប្រធានគណៈមេធាវី ឬមេធាវីសាមី។ ចំពោះ អាគារសារព័ត៌មាន មន្ត្រីនគរបាលអាចធ្វើការឆែកឆេរបាន តែត្រូវធ្វើនៅចំពោះមុខព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរម្នាក់ ដែលជានាយ៉ាប់រងកុំឲ្យមានការឆែកឆេរនេះ ប៉ះពាល់ដល់ការប្រកបដោយសេរីនូវមុខរបរអ្នកសារព័ត៌មាន និងធ្វើឲ្យយឺតយ៉ាវដល់ការផ្សព្វផ្សាយព័ត៌មាននេះ ដោយមិនត្រឹមត្រូវ (មាត្រា ៩១ កថា.ទី៤នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ខ.៤.ការចាប់យកវត្ថុតាង៖**

មន្ត្រីនគរបាលយុត្តិធម៌ អាចចាប់យកវត្ថុតាងបាន តាមមាត្រា៩២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដោយត្រូវបិទស្លាកបោះត្រានៅលើវត្ថុតាងនោះ។ ក្រោយពីបានបង្ហាញវត្ថុ ដែលចាប់បានដល់អ្នកកាន់កាប់ទីកន្លែង ឬដល់សាក្សីពីរនាក់មើលរួច មន្ត្រីនគរបាលយុត្តិធម៌ ធ្វើកំណត់ហេតុស្តីពីការចាប់

យក ដែលមានរួមបញ្ជីសារពើភ័ណ្ឌនៃវត្ថុដែលចាប់យក។

ក្នុងករណីនេះ ព្រះរាជអាជ្ញា មានសមត្ថកិច្ចអាចបង្គាប់ឲ្យប្រគល់វត្ថុចាប់បាន ទៅម្ចាស់ដើមវិញ ប្រសិនវត្ថុនោះពុំមានប្រយោជន៍សម្រាប់ការសំដែងការពិតទេនោះ ហើយប្រសិនបើកម្មសិទ្ធិលើវត្ថុនោះ (គ្មានការជំទាស់អ្វីប្រាកដប្រជាទេ ហើយវត្ថុនោះពុំមែនជាវត្ថុដែលមានគ្រោះថ្នាក់ចំពោះមនុស្ស ឬទ្រព្យសម្បត្តិទេ (មាត្រា ១១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ប្រសិនបើព្រះរាជអាជ្ញាពុំព្រមប្រគល់ឲ្យវិញទេ អ្នកប្តឹងសុំ ឲ្យប្រគល់វត្ថុចាប់បាន អាចប្តឹងទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

**ខ.៥.ការស្តាប់ចម្លើយៈ**

មន្ត្រីនគរបាលយុត្តិធម៌អាចកោះហៅ និងស្តាប់ចម្លើយបុគ្គលគ្រប់រូប ដែលអាចផ្តល់ព័ត៌មានស្តីពីរឿងហេតុបាន (មាត្រា ៩៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ )។ ក្នុងន័យនេះ ជនសង្ស័យ ក៏អាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ស្តាប់ ចម្លើយបានដែរ។ ប្រសិនបើមានការរឹងទទឹង មន្ត្រីនគរបាលយុត្តិធម៌ត្រូវធ្វើការជូនដំណឹងទៅដល់ព្រះរាជអាជ្ញា ដែលអាចចេញបញ្ជាឲ្យចូលខ្លួនបាន។

ការបញ្ជាឲ្យចូលខ្លួន អនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌ប្រើប្រាស់កម្លាំងសាធារណៈ ដើម្បីបង្ខំបុគ្គលនោះឲ្យចូលបង្ហាញខ្លួនបាន។

**ខ.៦.ការត្រួតពិនិត្យខាងផ្នែកបច្ចេកទេស ឬវិទ្យាសាស្ត្រ (កោសលវិច័យ)**

ប្រសិនបើត្រូវធ្វើការពិនិត្យបច្ចេកទេស ឬវិទ្យាសាស្ត្រ ដែលមិនអាចបង្អង់បាន មន្ត្រីនគរបាលយុត្តិធម៌ អាចពឹងដល់បុគ្គលគ្រប់រូប ដែលមានមុខជំនាញ ប៉ុន្តែត្រូវឲ្យបុគ្គលនេះស្បថតាមសាសនា ឬជំនឿរបស់ខ្លួនថា នឹងជួយដោយភក្តីភាពដល់តុលាការជាមុនសិន ប្រសិនបើបុគ្គលនេះ ពុំមានឈ្មោះនៅក្នុងបញ្ជីអ្នកជំនាញថ្នាក់ជាតិទេ (មាត្រា ៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ខ.៧.ការបញ្ជូនកំណត់ហេតុ វត្ថុតាង និងបុគ្គលដែលត្រូវបញ្ជូនទៅព្រះរាជអាជ្ញា**

ក្រោយបញ្ចប់ការស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនកំណត់ហេតុ និងវត្ថុតាងទាំងអស់ទៅព្រះរាជអាជ្ញា (មាត្រា ១០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ប្រសិនបើ មានបុគ្គលឃាត់ខ្លួននៅពេលផុតកំណត់រយៈ ពេលឃាត់ខ្លួន មន្ត្រីនគរបាលយុត្តិធម៌ សុំសេចក្តីសម្រេចពីព្រះរាជអាជ្ញាថាតើត្រូវបញ្ជូនខ្លួនជននេះ ទៅព្រះរាជអាជ្ញា ឬដោះលែងឲ្យមានសេរីភាពឡើងវិញ (មាត្រា ១០៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ប្រសិនបើព្រះរាជអាជ្ញា សម្រេចថាឲ្យបញ្ជូនមន្ត្រីនគរបាលយុត្តិធម៌ ត្រូវបញ្ជូនខ្លួនបុគ្គលនោះទៅព្រះរាជអាជ្ញា ក្នុងរយៈពេលដ៏ឆាប់បំផុត តាមការដែលអាចធ្វើទៅបាន។ ប្រសិនបើមានការលំបាកក្នុងការដឹកជញ្ជូន ឬ ចម្ងាយនៃការដឹកជញ្ជូន រយៈពេលបន្ថែមអាចផ្តល់ឲ្យដោយព្រះរាជអាជ្ញា (មាត្រា ១០៤ កថា.ទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**ខ.៨.ការស្តាប់ការសន្ទនា**

មាត្រា១០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនអនុញ្ញាតឲ្យមន្ត្រីនគរបាលយុត្តិធម៌បង្គាប់ឲ្យស្តាប់ ឬថតសម្លេងការសន្ទនាតាមទូរសព្ទ ការចាប់ និងថតការឆ្លើយឆ្លងតាមគ្រប់មធ្យោបាយ ទូរគមនាគមន៍ តាមទូរសារ ឬសារតាមអ៊ីនធើណេតឡើយ។ ក្រមនីតិវិធីព្រហ្មទណ្ឌ ទទួលស្គាល់អំណាចនេះ តែសម្រាប់ចៅក្រមស៊ើបសួរប៉ុណ្ណោះ។

ផ្ទុយទៅវិញ មានករណីអញ្ញត្រកម្មមួយចំនួន ដែលគួរកត់ចំណាំរួមមាន៖

-មន្ត្រីនគរបាលយុត្តិធម៌នៃអង្គភាពប្រឆាំងអំពើពុករលួយ អាចលបស្តាប់ ឬថតសម្លេង ដាក់ខ្សែទូរសព្ទ ក្រោមការលបស្តាប់ និងថត (មាត្រា ២៧ នៃច្បាប់ស្តីពីការប្រឆាំងអំពើពុករលួយ)។

-មាត្រា ៨៨ នៃច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម៖ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ អាចអនុញ្ញាតឲ្យអ្នកស៊ើបអង្កេត តាមដាន និងដាក់ខ្សែទូរសព្ទក្រោមការលបស្តាប់។ បើវិធានការណ៍នេះអនុញ្ញាតឲ្យ ដោយព្រះរាជអាជ្ញា គឺអាចមានរយៈពេលត្រឹមតែ **២ ខែ**ប៉ុណ្ណោះ។ ការបន្ត ត្រូវអនុញ្ញាតដោយចៅក្រមស៊ើបសួរ។

-បទប្បញ្ញត្តិដូចគ្នានេះផងដែរ មានចែងនៅក្នុងមាត្រា ៨៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ពោលគឺ ព្រះរាជអាជ្ញា (ឬចៅក្រមស៊ើបសួរ) អាចអនុញ្ញាតឲ្យអាជ្ញាធរមានសមត្ថកិច្ចបង្គាប់ឲ្យចាប់ និងថតគ្រប់ការឆ្លើយឆ្លងគ្នា តាមមធ្យោបាយទូរគមនាគមន៍ ដូចជាសារតាមទូរសារ ឬសារតាមអ៊ីនធើណេតជាដើម។ ប៉ុន្តែ បើវិធានការណ៍នេះ អនុញ្ញាតឲ្យដោយព្រះរាជអាជ្ញា គឺអាចមានរយៈពេលត្រឹមតែ **២ ខែ**ប៉ុណ្ណោះ។ ការបន្ត ត្រូវអនុញ្ញាតដោយចៅក្រមស៊ើបសួរ។

**សម្គាល់៖** ការមិនអនុវត្តតាមបទប្បញ្ញត្តិខាងលើនេះ អាចប្រឈមនឹងការផ្តន្ទាទោសពីបទប៉ះពាល់ដល់ការសម្ងាត់នៃការសន្ទនាតាមទូរសព្ទ ដែលមានចែងនៅមាត្រា ៣១៨ នៃក្រមព្រហ្មទណ្ឌ ថា៖ អំពើប្រព្រឹត្តដោយគំនិតទុច្ចរិត ស្តាប់ ឬធ្វើឲ្យច្របូកច្របល់ ការសន្ទនាតាមទូរសព្ទត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី **១ ខែ ទៅ ១ ឆ្នាំ** និងពិន័យជាប្រាក់ពី **១ សែនរៀល ទៅ ២ លានរៀល**[១៨]។

### ៥.២.ការស៊ើបអង្កេតបឋម

ការស៊ើបអង្កេតបឋម អាចដំណើរការបានដោយការផ្តួចផ្តើមរបស់មន្ត្រីនគរបាលយុត្តិធម៌ ឬតាមការស៊ុំរបស់ព្រះរាជអាជ្ញា ក្នុងករណី ដែលមានបទល្មើសជាបទឧក្រិដ្ឋ បទមជ្ឈិម ឬបទលហុ។ ការស៊ើបអង្កេតបឋម ដំណើរការនៅក្នុងករណី ដែលបទឧក្រិដ្ឋ ឬបទមជ្ឈិម មិនជាក់ស្តែង ឬក៏ក្នុងករណី ដែលថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងបានកន្លងផុត។ មាត្រា១០៦ នៃក្រមនីតិវិធី

[១៨] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២២-២៥ ឆ្នាំ២០១៧-២០១៨

ព្រហ្មទណ្ឌ កំណត់ថិរវេលានៃការស៊ើបអង្កេតករណីជាក់ស្តែងតែ ៧ ថ្ងៃប៉ុណ្ណោះ គិតចាប់ពីថ្ងៃ ដែលប្រព្រឹត្តបទល្មើស។

អំណាច និងការតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងក្របខណ្ឌនៃការស៊ើបអង្កេតបឋមមានលក្ខណៈប្រហាក់ប្រហែល និងអំណាច និងការកាតព្វកិច្ចរបស់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងក្របខណ្ឌនៃការស៊ើបអង្កេតករណីជាក់ស្តែង ដោយគ្រាន់តែបទប្បញ្ញត្តិ យោងមានភាពខុសគ្នា។ វិធានទាក់ទិននឹងការស៊ើបអង្កេតបឋម មានចែងចាប់ពីមាត្រា ១១១ រហូតដល់មាត្រា ១១៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំណុចដែលខុសប្លែកគ្នាខ្លាំងគឺ ទាក់ទិននឹងអំណាចនៃការឆែកឆេរ ដែលមានចែងនៅក្នុងមាត្រា ១១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះ មន្ត្រីនគរបាលយុត្តិធម៌ គឺអាចធ្វើការឆែកឆេរបាន ប៉ុន្តែត្រូវមាន៖

១-ការយល់ព្រមច្បាស់លាស់ និងពិតប្រាកដពីអ្នកកាន់កាប់ទីកន្លែង ជាលាយលក្ខណ៍អក្សរ និងសរសេរដោយផ្ទាល់ដៃរបស់អ្នកកាប់កាប់ទីកន្លែង។ ប៉ុន្តែប្រសិនបើអ្នកកាន់កាប់ទីកន្លែងមិនចេះអក្សរ ត្រូវសរសេរពីការយល់ព្រមរបស់អ្នកកាន់កាប់ទីកន្លែង និងការដែលជននេះពុំចេះសរសេរអក្សរ។

២-ដីកាអនុញ្ញាតឲ្យឆែកឆេរពីប្រធានសាលាដំបូង តាមការសុំរបស់ព្រះរាជអាជ្ញា ប្រសិនបើអ្នកដែលកាន់កាប់ទីកន្លែងអវត្តមាន ឬបដិសេធការឆែកឆេរ។ ការឆែកឆេរ ត្រូវធ្វើនៅចំពោះមុខអ្នកកាន់កាប់ទីកន្លែង ឬសាក្សីពីរនាក់ ហើយមិនអាចផ្តើមមុនម៉ោង ៦ព្រឹក និងក្រោយម៉ោង ១៨ល្ងាចឡើយ។

ប្រសិនបើមន្ត្រីនគរបាលយុត្តិធម៌ ពុំបានអនុវត្តឲ្យបានត្រឹមត្រូវតាមនីតិវិធី ហើយមានការបំពានទៅលើសិទ្ធិបុគ្គល មន្ត្រីនគរបាលយុត្តិអាចត្រូវផ្តន្ទាទោសតាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌឆ្នាំ២០០៩។

## **កថាខណ្ឌទី៦៖ តាពចំណុះនៃមន្ត្រីនគរបាលយុត្តិធម៌**

គោលបំណង នៃការបង្កើតឲ្យមានមន្ត្រីនគរបាលយុត្តិធម៌ គឺដើម្បីធានានូវប្រសិទ្ធភាពនៃបណ្តឹងអាជ្ញា និងជួយសម្របសម្រួលដល់ដំណើរការរឿងក្តីព្រហ្មទណ្ឌ។ មន្ត្រីនគរបាលយុត្តិធម៌បានដើរតួនាទីយ៉ាងសំខាន់នៅក្នុងដំណាក់កាលស៊ើបអង្កេត និងស៊ើបសួរ។

### **៦.១.ដំណាក់កាលស៊ើបអង្កេត**

នៅក្នុងដំណាក់នេះ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមការដឹកនាំដោយព្រះរាជអាជ្ញា មានន័យថា បើសិនជាមន្ត្រីណាមួយប្រព្រឹត្តខុសក្នុងពេលបំពេញបេសកកម្មរបស់ខ្លួន ក្នុងករណីនេះជាតួនាទី និងសិទ្ធិអំណាចរបស់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ក្នុងការដាក់ទណ្ឌកម្មខាងវិន័យ។

នៅក្នុងដំណាក់កាលស៊ើបអង្កេត មន្ត្រីនគរបាលយុត្តិធម៌ បានដើរតួនាទីយ៉ាងសំខាន់ក្នុងការធានានូវប្រសិទ្ធភាពនៃបណ្តឹងអាជ្ញា និងការស្វែងរកភស្តុតាង ដើម្បីចាប់ជនល្មើស។

មាត្រា ៥៨៖ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពការងាររបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

ព្រះរាជអាជ្ញា មានអំណាចទៅលើមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត ដែលចែងនៅក្នុងមាត្រា ៨២ (ការផ្តល់នីតិសម្បទាចំពោះមន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត) នៃក្រមនេះ កាលណាមន្ត្រីនេះ បំពេញមុខងាររបស់ខ្លួនជាមន្ត្រីនគរបាលយុត្តិធម៌។

ការអនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស មន្ត្រីនគរបាលយុត្តិធម៌ ត្រូវស្ថិតនៅក្រោមអំណាចរបស់ចៅក្រមស៊ើបសួរ[១៩]។

### ៦.២.ដំណាក់កាលស៊ើបសួរ

ដំណាក់កាលមួយ ដែលសំណុំរឿងស្ថិតនៅក្រោមការសម្របសម្រួលរបស់ចៅក្រមស៊ើបសួរ ដែលគាត់ជាអ្នក ដែលមានសិទ្ធិអំណាចដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងករណី មានដីការចាត់ឲ្យស៊ើបសួរជំនួស។

យ៉ាងណាក៏ដោយ ព្រះរាជអាជ្ញា ឬចៅក្រមស៊ើបសួរ មិនមានសមត្ថកិច្ចដាក់ទណ្ឌកម្ម ចំពោះមន្ត្រីនគរបាលយុត្តិធម៌នោះទេ គឺគាត់ត្រូវតែធ្វើសេចក្តីរាយការណ៍ដល់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ ហើយទើបអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ប្រកាសជូនដំណឹងដល់រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិពី ចំណាត់ការនៃនីតិវិធីវិន័យ។ ការដាក់ទណ្ឌកម្មមានដូចជា៖

-ការហាមមិនឲ្យបំពេញការងាររយៈពេល **៥ឆ្នាំ** យ៉ាងច្រើនបំផុត

-ហាមមិនឲ្យបំពេញការងារជាស្ថាពរ ប៉ុន្តែមុខងារជាមន្ត្រី នៃស្ថាប័នដើមនៅរក្សាដដែល[២០]។

### ៦.៣.បេសកកម្មរបស់មន្ត្រីនគរបាលយុត្តិធម៌

មន្ត្រីនគរបាលយុត្តិធម៌ គឺមានបេសកកម្មចំនួន៣ ធំៗគឺ

១-ទទួលពាក្យបណ្តឹង អាចជាបណ្តឹងបរិហារ ឬបណ្តឹងទាមទារ។

២-ស្វែងរកបទល្មើសដោយខ្លួនឯង។

៣-ស៊ើបអង្កេត ទាំងករណីបទល្មើសជាក់ស្តែង និងមិនជាក់ស្តែង។

បើយោងទៅតាមមាត្រា៨៦ បានផ្តល់និយមន័យយ៉ាងច្បាស់ពីបទល្មើសជាក់ស្តែង[២១]។

---

[១៩] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៤-១៥ ឆ្នាំ២០១៦

[២០] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៥ ឆ្នាំ២០១៦

## កថាខណ្ឌទី៧៖ ការបាត់បង់ជាសមាជិកភាពនៃនគរបាលយុត្តិធម៌

ចំពោះការបាត់បង់ជាសមាជិកភាព នៃនគរបាលយុត្តិធម៌ គឺដោយសារតែនគរបាលយុត្តិធម៌នោះបានប្រព្រឹត្តខុសឆ្គងទៅលើវិន័យបញ្ញត្តិ ក៏ដូចជាការដល់អាយុដែលត្រូវចូលនិវត្តន៍ ហើយការបាត់បង់នេះទៀតសោត គឺអាស្រ័យទៅតាមមុខងាររបស់នគរបាលយុត្តិធម៌នោះផងដែរ។

### ៧.១.តាមរយៈការពិន័យ

រាល់ការប្រព្រឹត្តកំហុសទាំងឡាយ ដែលបានប្រព្រឹត្តដោយមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ មន្ត្រីរាជការ និងភ្នាក់ងារសាធារណៈដទៃទៀត នៅក្នុងពេលបំពេញមុខងាររបស់ខ្លួន ត្រូវតែឲ្យដំណឹងដោយព្រះរាជអាជ្ញា ឬដោយចៅក្រមស៊ើបសួរ ជូនចំពោះអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។ អគ្គព្រះរាជអាជ្ញា ប្រកាសប្រាប់ដំណឹងដល់រដ្ឋមន្ត្រី (រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ឬរដ្ឋមន្ត្រីក្រសួងការពារជាតិ ចំពោះមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌) ឬភ្នាក់ងារនោះ នៅក្រោមឱវាទ ដើម្បីចាប់ផ្តើមនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ ការបន្តនៃនីតិវិធីខាងវិន័យ។ អគ្គព្រះរាជអាជ្ញា ត្រូវបានផ្តល់ដំណឹងអំពីចំណាត់ការនៃនីតិវិធីវិន័យ។ ទណ្ឌកម្មខាងវិន័យ មិនមែនជាឧបសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសត្រូវបាន ប្រព្រឹត្តឡើង[២២]។

ការសម្រេចដាក់ទណ្ឌកម្មនេះ អាចធ្វើឡើងតាមរយៈការស្តីបន្ទោស ការផាកពិន័យ ការព្យួរការងារ ឬការបណ្តេញចេញពីក្របខណ្ឌនៃមុខងារជាដើម ដែលជាហេតុធ្វើឲ្យបាត់បង់ជាសមាជិកភាពនៃនគរបាលយុត្តិធម៌។

### ៧.២.តាមរយៈការចូលនិវត្តន៍

ដូចដែរបានលើកឡើងហើយថា នគរបាលយុត្តិធម៌ គឺត្រូវបានចែកចេញជាបី ដែលរួមមានមន្ត្រីនគរបាលយុត្តិធម៌ ភ្នាក់ងារនគរបាលយុត្តិធម៌ និងមន្ត្រីរាជការសាធារណៈដទៃទៀត ដែលច្បាប់បានផ្តល់ឲ្យ ដូច្នេះ ការចូលនិវត្តន៍របស់ពួកគាត់ គឺត្រូវបានកំណត់ទៅតាមច្បាប់ដោយឡែកពីគ្នា។ តួយ៉ាងដូចជា មន្ត្រីនគរបាលយុត្តិធម៌ ត្រូវបានចូលនិវត្តន៍ទៅតាមច្បាប់ដែលបានបញ្ញត្តិរបស់ខ្លួន ហើយនគរបាល និងភ្នាក់ងារសាធារណៈដទៃទៀត គឺតាមការផុតអាណត្តិ ឬដល់អាយុជាដើម។

[២១] ឯកឧត្តម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៥ ឆ្នាំ២០១៦

[២២] មាត្រា ៦៤, មាត្រា ៧៩ និងមាត្រា ៨២ ក្រមនីតិវិធីព្រហ្មទណ្ឌ នៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ២០០៧

**កថាខណ្ឌទី៨៖ ករណីការអនុវត្តជាក់ស្តែង**

នៅក្នុងប្រទេសប្រជាធិបតេយ្យ ការអនុវត្តគោលការណ៍ច្បាប់ ជាមូលដ្ឋានគ្រឹះនៃការគោរពសិទ្ធិមនុស្ស ដូច្នេះគ្រប់បទល្មើស ដែលបានកើតឡើង ត្រូវតែបើកការស៊ើបអង្កេតដោយហ្មត់ចត់ ដើម្បីស្វែងរកជន ដែលប្រព្រឹត្តបទល្មើសយកមកផ្តន្ទាទោសតាមច្បាប់ បើពុំនោះទេនឹងធ្វើ ឲ្យសង្គមច្របូកច្របល់ គ្មានយុត្តិធម៌ ក្លាយជាសង្គមអនាធិបតេយ្យ គ្មានច្បាប់ទម្លាប់។ គ្រប់ការស៊ើបអង្កេតបទឧក្រិដ្ឋ បទមជ្ឈិម និងបទល្មើសផ្សេងៗ ទៀត ច្បាប់បានប្រគល់អំណាចទៅឲ្យខាងនគរបាលយុត្តិធម៌ ដើម្បីធ្វើការត្រួតពិនិត្យ កំណត់អត្តសញ្ញាណ ចាប់ខ្លួនជនល្មើស ព្រមទាំងធ្វើការប្រមូលភស្តុតាង។

បន្ទាប់ពីបានធ្វើការសិក្សាអំពីតួនាទី ភារកិច្ច មុខងារ បេសកកម្ម ក៏ដូចជានីតិវិធីនានារបស់នគរបាលចប់សព្វគ្រប់ហើយ យើងសង្កេតឃើញថា នៅក្នុងដំណាក់កាលនៃមន្ត្រីនគរបាលយុត្តិធម៌ គឺពិតជាមានការមមាញឹកខ្លាំងណាស់ ចំពោះការបំពេញការងាររបស់ខ្លួន។ ហើយអ្វីដែលកាន់តែមានភាពស្មុគស្មាញថែមទៀតនោះ គឺនគរបាលយុត្តិធម៌ ត្រូវប្រឈមជាមួយបញ្ហានានាជាច្រើនដូចជា ការដោះស្រាយបញ្ហាជាមួយជនរងគ្រោះ ការប្រចុយប្រចានជាមួយនឹងជនល្មើស ឬការការស៊ើបអង្កេតមានភាពលំបាកជាដើម ជាហេតុនាំឲ្យមានកត្តារាំងស្ទះក្នុងការអនុវត្តការងាររបស់ខ្លួន។

**៨.១.បញ្ហាដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌**

ដោយយល់ឃើញថា មន្ត្រីនគរបាលយុត្តិធម៌មានតួនាទី និងភារកិច្ចយ៉ាងសំខាន់ ដែលមិនអាចខ្វះបានក្នុងការចូលរួមអន្តរាគមន៍គ្រប់បទល្មើសព្រហ្មទណ្ឌ ហេតុដូច្នេះហើយ ទើបមន្ត្រីនគរបាលជួបប្រទះនឹងបញ្ហាប្រឈមជាច្រើន។

ចំពោះបញ្ហាប្រឈមដែលកើតមានចំពោះមន្ត្រីនគរបាលយុត្តិធម៌រួមមានដូចជា៖

**ក.ការធ្វេសប្រហែសគួបផ្សំនឹងការខ្វះសម្ភារៈ មធ្យោបាយ**

-ការងារមួយចំនួនអសកម្ម ដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឲ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានបទល្មើសកើតឡើង។

ការចាត់តាំងអនុវត្តរបស់អង្គភាពពាក់ព័ន្ធនៅមានការយឺតយ៉ាវ ខ្វះការទទួលខុសត្រូវ គួបផ្សំនឹងការមិនបានត្រួតពិនិត្យសកម្មភាពការងាររបស់មន្ត្រីថ្នាក់ក្រោម ឲ្យបានត្រឹមត្រូវផងនោះ ធ្វើឲ្យប្រសិទ្ធភាពនៃការអនុវត្តផែនការ វិធានមិនទាន់ទទួលបានលទ្ធផលល្អនៅឡើយ។

-ការងារស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបទៅតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស គឺការគ្រប់គ្រងមុខសញ្ញានៅក្នុងមូលដ្ឋាន ដូចជាមុខសញ្ញាក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញា

សេសសល់ មុខសញ្ញាករណីតស៊ូ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។

-ខ្វះមធ្យោបាយ សម្ភារៈ ថវិកា ដើម្បីបម្រើឲ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឲ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា ពេលខ្លះមានមធ្យោបាយខ្វះប្រេង សាំង យានជំនិះ អាគុយ ភ្លើងជាដើម[២៣]។

**ខ.មន្ត្រីនគរបាលយុត្តិធម៌មានអាណាព្យាបាលពីរ**

នៅក្នុងកិច្ចប្រតិបត្តិការបង្ក្រាបបទល្មើសព្រហ្មទណ្ឌ មន្ត្រីនគរបាលយុត្តិធម៌ ស្ថិតក្រោមអំណាចរបស់ព្រះរាជអាជ្ញា និងចៅក្រមស៊ើបសួរតាមរយៈដីកាចាត់ឲ្យស៊ើបសួរជំនួស។ នៅក្នុងការបំពេញបេសកកម្ម មន្ត្រីនគរបាលយុត្តិធម៌ទទួលបញ្ជា ឬសុំបញ្ជាតែពីអាជ្ញាធរតុលាការរហូតដល់ចប់កិច្ចប្រតិបត្តិការខ្លួន។ ទន្ទឹមនឹងនោះ មន្ត្រីនគរបាលយុត្តិធម៌ ក៏ត្រូវរាយការណ៍តាមឋានានុក្រមដល់មេកើយខ្លួន អំពីរឿងហេតុកើតឡើង និងសុំយោបល់ដឹកនាំ។ ដូច្នេះ មន្ត្រីនគរបាលយុត្តិធម៌ត្រូវមានអាណាព្យាបាលពីរតាមឋានានុក្រមការងាររដ្ឋបាល ស្ថិតក្រោមការត្រួតពិនិត្យរបស់ស្នងការនគរបាលរាជធានីភ្នំពេញ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងការងារងារនីតិវិធីព្រហ្មទណ្ឌ ស្ថិតក្រោមការសម្របសម្រួលរបស់ព្រះរាជអាជ្ញា។

តាមគោលការណ៍ច្បាប់ មន្ត្រីនគរបាលយុត្តិធម៌ មិនអាចតម្កល់រឿងព្រហ្មទណ្ឌណាមួយទុកឥតចាត់ការបានទេ ទោះបីជាក្រោយពីមានការសម្រុះសម្រួលគ្នារវាងជនល្មើស និងជនរងគ្រោះ ឬក៏មានការដកពាក្យប្តឹងក៏ដោយ។ មន្ត្រីនគរបាលយុត្តិធម៌ ដែលរក្សាទុកកំណត់ហេតុ ឬវត្ថុតាងដោយចេតនា ឬលាក់បំបាំងដល់អាជ្ញាធរតុលាការ អំពីអត្ថិភាពនៃកំណត់ហេតុ ឬវត្ថុតាង ត្រូវចាត់ទុកថា មន្ត្រីនគរបាលយុត្តិធម៌នោះបានប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌ ដែលត្រូវផ្តន្ទាទោសតាមក្រម-ព្រហ្មទណ្ឌ ឆ្នាំ២០០៩ ។

នៅក្នុងការអនុវត្តជាក់ស្តែង ជាបទពិសោធន៍ មានរឿងមួយបានកើតឡើងចំពោះដល់មន្ត្រីនគរបាលយុត្តិធម៌ ក្រោយពីទទួលបញ្ជាពីថ្នាក់ដឹកនាំឲ្យធ្វើការសម្របសម្រួលបញ្ចប់រឿងទំនាស់នេះ ដោយមានការឯកភាពរវាងជនល្មើស និងជនរងគ្រោះ។ មន្ត្រីនគរបាលយុត្តិធម៌ ក៏បានសុំយោបល់ពីព្រះរាជអាជ្ញាដែរ ចំពោះករណីដែលគាត់បានទទួលបញ្ជាពីមេកើយឲ្យសម្របសម្រួល។ ពេលនោះ ព្រះរាជអាជ្ញា យល់ព្រមតាមការស្នើសុំ តែត្រូវបញ្ជូនសំណុំរឿងមកកាន់អយ្យការ ដើម្បីឲ្យគាត់ពិនិត្យមើលអង្គហេតុ។ មន្ត្រីនគរបាលយុត្តិធម៌ បានរៀបចំសំណុំរឿងបញ្ជូនទៅឲ្យព្រះរាជ-អាជ្ញា នៅពេលដែលព្រះរាជអាជ្ញា ទទួលបានសំណុំរឿងរួចហើយ គាត់ក៏បានពិនិត្យមើលអង្គហេតុ

[២៣] ដោយ សុខ ដី បេក្ខជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៧

និងអង្គច្បាប់ចប់ សព្វគ្រប់ហើយ គាត់យល់ឃើញថា មានភស្តុតាងគ្រប់គ្រាន់សម្រាប់ធ្វើការចោទប្រកាន់។ ព្រះរាជអាជ្ញាក៏សម្រេចធ្វើការចោទប្រកាន់ បញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរ។ ជាលទ្ធផលចុងក្រោយសំណុំរឿងនេះ ត្រូវបានបញ្ចប់ជាស្ថាពរនៅតុលាការ ប៉ុន្តែ មន្ត្រីនគរបាលយុត្តិធម៌រូបនោះ ត្រូវបានថ្នាក់ដឹកនាំសម្រួលភារកិច្ចរបស់គាត់វិញ។

**-សមត្ថកិច្ចជាន់គ្នារវាងនគរបាលជាតិ និងកងរាជអាវុធហត្ថ**

ជាគោលការណ៍ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧ មាត្រា ៦០ បានផ្តល់នីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ដល់មន្ត្រីនៃនគរបាលជាតិ និងមន្ត្រីនៃកងរាជអាវុធហត្ថ មានភារកិច្ចធ្វើការត្រួត ពិនិត្យបទឧក្រិដ្ឋ បទមជ្ឈិម បទលហុ កំណត់អត្តសញ្ញាណ ចាប់ជនល្មើស ព្រមទាំងការប្រមូលភស្តុតាង។ មន្ត្រីនគរបាល និងមន្ត្រីកងរាជអាវុធហត្ថ ចុះដល់កន្លែងកើតហេតុដូចគ្នា មានសិទ្ធិពិនិត្យទីកន្លែងកើតហេតុ សម្ភាសន៍សាក្សី ជនរងគ្រោះ ស្រង់ចម្លើយជនសង្ស័យ និងធ្វើការឆែកឆេររហូតដល់ចប់កិច្ចប្រតិបត្តិការរៀងៗខ្លួន។ គ្រប់បេសកកម្មរបស់អង្គភាពទាំងពីរ មានគោល-ដៅរួម មាន គោលបំណងតែមួយ ដើម្បីការពារផលប្រយោជន៍សាធារណៈ ព្រទ្យសម្បត្តិ អាយុជីវិត មិនចាំបាច់ ឲ្យគាត់បំពេញភារកិច្ចជាន់គ្នានាំឲ្យខាតបង់ពេលវេលា បាត់បង់ថវិការជាតិ។ ហេតុដូច្នេះ គួរបែងចែកភារកិច្ចរវាងមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធហត្ថ ឲ្យបានច្បាស់លាស់ក្នុងការដើរតួជាមន្ត្រីនគរបាលយុត្តិធម៌។

ក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ ២០០៧ មាត្រា ៨១ បានចង្អុលបង្ហាញពីការកំណត់សមត្ថកិច្ចរបស់នគរបាលជាតិ និងកងរាជអាវុធនៅក្នុងវិស័យនគរបាលយុត្តិធម៌។ ទោះបីជាក្រមនេះ បានចង្អុលបង្ហាញទៅលើអនុក្រឹត្យស្តីអំពីការបែងចែកភារកិច្ចមន្ត្រីនគរបាលជាតិ និងមន្ត្រីកងរាជអាវុធ-ហត្ថ ក៏ដោយ ប៉ុន្តែរហូតមកដល់ពេលនេះ នៅពុំទាន់ឃើញមានអនុក្រឹត្យ ស្តីពីការកំណត់សមត្ថកិច្ចក្នុងការបំពេញមុខងារជាមន្ត្រីនគរបាលយុត្តិធម៌នៅឡើយទេ[២៤]។

### ៨.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម

### ក.យន្តការបណ្តុះបណ្តាលជំនាញ និងច្បាប់

គោលនយោបាយកំណែទម្រង់កងកម្លាំងប្រដាប់អាវុធរបស់រាជរដ្ឋាភិបាល ដោយផ្តោតការយកចិត្តទុកដាក់ទៅលើការអភិវឌ្ឍធនធានមនុស្ស និងការបង្កើតសមត្ថភាពខាងវិជ្ជាជីវៈនៃកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ តាមរយៈនៃការបណ្តុះបណ្តាលប្រកបដោយគុណភាព និងប្រសិទ្ធភាព។

---

[២៤] ដោយ សុខ ងី បេក្ខជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៧-៩

ក្រសួងមហាផ្ទៃបានដាក់ចេញនូវយន្តការកំណែទម្រង់កងកម្លាំងនគរបាលជាតិឲ្យក្លាយទៅជាកងកម្លាំងមួយ ដែលមានវិជ្ជាជីវៈពិតប្រាកដ បំពាក់ដោយបច្ចេកទេសទំនើប មានអត្តចរិតសុភាពរាបសារ មានសមត្ថភាពបំពេញភារកិច្ច មានស្មារតីទទួលខុសត្រូវខ្ពស់ គោរពប្រតិបត្តិច្បាប់ គោរពសិទ្ធិមនុស្ស រក្សាសន្តិសុខ និងសណ្តាប់ធ្នាប់សង្គម ការពារអាយុជីវិត និងទ្រព្យសម្បត្តិនានារបស់ប្រជាពលរដ្ឋ។ ដើម្បីអនុវត្តយន្តការនេះ ក្រសួងមហាផ្ទៃ បានប្រគល់ភារកិច្ចទៅឲ្យបណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើជាសេនាធិការក្នុងការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទូទាំងប្រទេស។ ដើម្បីឲ្យបណ្ឌិត្យសភានគរបាលកម្ពុជា អនុវត្តបានតាមផែនការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិទទួលបានជោគជ័យ ត្រូវមានការគាំទ្រពីរាជរដ្ឋាភិបាល ពីក្រសួងមហាផ្ទៃ និងការចូលរួមសហការគ្រប់អង្គភាព គ្រប់ភាគីពាក់ព័ន្ធទាំងអស់ ជាពិសេស នាយកដ្ឋានបុគ្គលិក នៃអគ្គស្នងការដ្ឋាននគរបាលជាតិ មានការគាំទ្រ និងមានយន្តការតាមដានចំពោះនិស្សិត សិក្ខាកាម ដែលបណ្ឌិត្យសភានគរបាលកម្ពុជាបានដាក់វិន័យ ឬបណ្តេញចេញពីការសិក្សា។

**ខ.យន្តការពង្រឹងការអនុវត្តច្បាប់**

**-ការលុបបំបាត់អំពើពុករលួយៈ** ជាគោលការណ៍នគរបាលយុត្តិធម៌ មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តិអំពើអបាយមុខ អំពើពាលា ដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួន ទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តបទល្មើស ជនប្រព្រឹត្តសកម្មភាពចាប់ជំរិត លួច ឆក់ ប្លន់ កេងប្រវ័ញ្ចសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃដែលស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមគំហែងប្រជាពលរដ្ឋ ដើម្បីធ្វើសំណូកការពារជនល្មើស និងប្រើប្រាស់សម្ភារៈរបស់រដ្ឋ បម្រើផលប្រយោជន៍ខ្លួន ព្រមទាំងហ៊ានប្រព្រឹត្តិនូវបទល្មើសផ្សេងៗដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បំបាំងនូវសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាង ដើម្បីប្រយោជន៍បុគ្គល។

**-ការលុបបំបាត់វប្បធម៌អន្តរាគមន៍ៈ** បរិបទនៃសង្គមខ្មែរនាបច្ចុប្បន្ន តែងតែកើតមាននូវបញ្ហាអន្តរាគមន៍ជាញឹកញាប់ វាគឺជាទម្លាប់ពលរដ្ឋខ្មែរ ក្នុងការទំនាក់ទំនងគ្នានៅក្នុងសង្គម ប៉ុន្តែបញ្ហាទាំងនេះ បានក្លាយជាទម្លាប់មិនអាចកែប្រែបាន សូម្បីតែអ្នករត់ម៉ូតូឌុបម្នាក់ ក៏អាចស្គាល់នគរបាលម្នាក់ដែរ ក្នុងការជួយអន្តរាគមន៍ពេលដែលខ្លួនត្រូវការជាយថាហេតុ មិនថាមានរឿងរ៉ាវតូច ឬធំនោះទេ តែងតែចូលខ្លួនមកដោះស្រាយបញ្ចប់បញ្ហា ដោយមិនទុកឲ្យសមត្ថកិច្ចចាត់ការតាមនីតិវិធី និងច្បាប់ឡើយ។ អ្នកដែលមានអំណាច មានឋានៈតួនាទីនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលធ្វើឲ្យការបំពេញតួនាទីមិនទាន់បានល្អ មិនបានប្រកាន់ភ្ជាប់ក្នុងការអនុវត្តច្បាប់ និងមិនមានយុត្តិធម៌នៅក្នុងសង្គម។ ដើម្បីលុបបំបាត់នូវបញ្ហាទាំង

នេះ ចាំបាច់ត្រូវពង្រឹងតួនាទី ភារកិច្ចមន្ត្រីនគរបាលយុត្តិធម៌ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលមិនបានប្រតិបត្តិតាមច្បាប់ ត្រូវតែទទួលខាងវិន័យ និងទណ្ឌកម្មជាដាច់ខាត មិនត្រូវលើកលែងចំពោះមន្ត្រីនគរបាលយុត្តិធម៌ណាម្នាក់ ដែលធ្វើឲ្យមានកំហុសឆ្គងក្នុងការបំពេញតួនាទីនោះទេ។

**-ការលុបបំបាត់វប្បធម៌និទណ្ឌភាព៖** កាលណាគ្មានយុត្តិធម៌ វានឹងមាននូវនិទណ្ឌភាព បើមាននិទណ្ឌភាព គឺគ្មានភាពស្មើគ្នាចំពោះមុខច្បាប់ឡើយ។ **និទណ្ឌភាព** គឺគ្មានការចាប់ខ្លួន និងនាំខ្លួនជនប្រព្រឹត្តិបទល្មើសមកធ្វើការវិនិច្ឆ័យទោស ពីព្រោះតែមុខតំណែង ឥទ្ធិពល ឬទ្រព្យធនរបស់ពួកគេ។ ដើម្បីចៀសវាងនូវរាល់បញ្ហាអស់ទាំងនេះ នគរបាលជាតិត្រូវមានភក្ដីចំពោះ ជាតិ សាសនា ព្រះមហាក្សត្រជានិច្ច។ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការស៊ើបអង្កេតភ្លាមៗ នូវខណៈពេលដែលខ្លួនបានដឹងពីការប្រព្រឹត្តិបទល្មើស មិនត្រូវរង់ចាំឲ្យនរណាម្នាក់ ធ្វើពាក្យបណ្ដឹងជាមុននោះទេ មុនពេលដែលខ្លួនចាប់ផ្ដើមស៊ើបអង្កេត។

ជាគោលការណ៍ បើមានបទល្មើសព្រហ្មទណ្ឌ បទឧក្រិដ្ឋ ឬបទមជ្ឈិម កើតឡើង ទោះបីជាគ្មានបណ្ដឹងក៏ដោយ មន្ត្រីនគរបាលយុត្តិធម៌ត្រូវតែបើការស៊ើបអង្កេត ស្រាវជ្រាវស្វែងរកជនល្មើស ដើម្បីកសាងសំណុំរឿងបញ្ជូនទៅតុលាការ។ បើមិនដូច្នោះទេ បញ្ហានិទណ្ឌភាព និងសកម្មភាពល្មើសច្បាប់កាន់តែមានច្រើនឡើងៗ ធ្វើឲ្យសង្គមច្របូកច្របល់ គ្មានសណ្ដាប់ធ្នាប់ គ្មានសុវត្ថិភាព ក្លាយទៅជាសង្គមមួយអនាធិបតេយ្យ[២៥]។

[២៥] ដោយ សុខ ងី បេក្ខជនបណ្ឌិតជំនាន់ទី១ សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ទំព័រ៩-១០

## ផ្នែកទី២៖ ដំណាក់កាលអយ្យការ

ស្ថាប័នអយ្យការ និងមហាអយ្យការ គឺមាន ៣ ថ្នាក់ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលតំណាងដោយព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារង។ មហាអយ្យការអមសាលាឧទ្ធរណ៍ តំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញា។ មហាអយ្យការអមតុលាការកំពូល តំណាងដោយអគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមតុលាកំពូល[២៦]។

### កថាខណ្ឌទី១៖ ការផ្តល់និយមន័យនៃអង្គការអយ្យការ

នៅក្នុងច្បាប់ស្តីពីលក្ខន្តិកៈនៃចៅក្រម និងព្រះរាជអាជ្ញា ដែលត្រូវបានប្រកាសឲ្យប្រើនាថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤ ក៏បានផ្តល់និយមន័យ ក៏ដូចជាតួនាទី ភារកិច្ច និងសិទ្ធិអំណាចរបស់ស្ថាប័នអយ្យការ និងមាននៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌជាដើម។

#### ១.១.អត្ថន័យនៃអង្គការអយ្យការ

"អយ្យការ" គឺជាស្ថាប័នមួយរបស់រដ្ឋ សម្រាប់ដំណើរការនៃបណ្តឹងសាធារណៈ ឬបណ្តឹងព្រហ្មទណ្ឌ។ ពាក្យថា "អយ្យការ" គឺជាស្ថាប័នមួយ ដូចនេះ ពាក្យថា "អង្គការអយ្យការ" គឺជាស្ថាប័នអយ្យការទាំងឡាយណា ដែលត្រូវបានដាក់ពង្រាយអមនៅតាមសាលាជម្រះក្តីនីមួយៗ គ្រប់ជាន់ថ្នាក់។ អយ្យការ ជាស្ថាប័ន ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា និងការពារផលប្រយោជន៍សាធារណៈ។

"**តួនាទីអយ្យការ ត្រូវតែចែកឲ្យដាច់ពីមុខងារតុលាការ**"។ អង្គការអយ្យការ មិនមែនជាស្ថាប័នដែលទទួលបន្ទុកក្នុងការជម្រះក្តីដូចតុលាការឡើយ ប៉ុន្តែ អយ្យការ គឺជាភាគីនៃរឿងក្តីព្រហ្មទណ្ឌ ដែលជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅ ដោយមានសិទ្ធិក្នុងការធ្វើបណ្តឹងអាជ្ញា។ ដូចនេះ ដើម្បីអាចបំពេញនូវតួនាទីរបស់ខ្លួន ក្នុងនាមជាភាគីនៃរឿងក្តី ឬជាគូក្តីដើម ហើយអយ្យការ ត្រូវមានអ្នកតំណាងរបស់ខ្លួននៅគ្រប់សាលាជម្រះក្តី ដែលអ្នកតំណាងទាំងនោះ គឺជាមន្ត្រីក្នុងស្ថាប័ន ដែលគេតែងហៅថា "**តំណាងអយ្យការ គឺបានដល់ព្រះរាជអាជ្ញា**"។

#### ១.២.អត្ថន័យនៃព្រះរាជអាជ្ញា

ការចោទប្រកាន់ គឺជាតួនាទីរបស់អយ្យការ។ ការចោទប្រកាន់ ធ្វើតាមរយៈបណ្តឹងអាជ្ញា។ មាត្រា ១៣១ ថ្មីនៃរដ្ឋធម្មនុញ្ញាចែងថា មានតែអង្គការអយ្យការទេ ដែលមានសិទ្ធិធ្វើបណ្តឹងអាជ្ញា។ ព្រះរាជអាជ្ញាដឹកនាំ និងសម្របសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន (មាត្រា ៣៧ កថាខណ្ឌទី ១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ហេតុនេះ ព្រះរាជអាជ្ញា គឺអាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំ ដែល

---

[២៦] http://www.facebook.com/thachantha អត្ថបទស្រាវជ្រាវ តួនាទីសិទ្ធិអំណាច របស់អង្គការអក្យការ ទំព័រ១

មានប្រយោជន៍ដល់មន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ ហើយអាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី ឬភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំឲ្យមានអ្នកជំនួស។ ម្យ៉ាងវិញទៀត ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលានៅអង្គភាពនគរបាលយុត្តិធម៌ អាចចូលរួមស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការណ៍ឃាត់ខ្លួន។ ក្រៅពីនេះ ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនីតិវិធីព្រហ្មទណ្ឌនេះ បានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ ក្នុងការស៊ើបអង្កេត (មាត្រា ៣៧ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ព្រះរាជអាជ្ញារង ដែលស្ថិតនៅក្រោមអំណាចរបស់ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ ដែលព្រះរាជអាជ្ញាមានក្នុងការស្រាវជ្រាវ និងចោទប្រកាន់បទល្មើស (មាត្រា៣៨នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្រៅពីអំណាចដឹកនាំ សម្របសម្រួលសកម្មភាពនគរបាលយុត្តិធម៌ អំណាចបើកការស៊ើបអង្កេត ព្រះរាជអាជ្ញា មានតួនាទីយ៉ាងសំខាន់ក្នុងការធ្វើឲ្យបណ្តឹងអាជ្ញាមានចលនា មានន័យថា ចោទប្រកាន់អំពីបទល្មើសណាមួយ[២៧]។

**កថាខណ្ឌទី២៖ ការរៀបចំអង្គការអយ្យការ**

ពេលណា គេនិយាយដល់អង្គការអយ្យការ គេមិនអាចភ្លេចបានឡើយ នូវដួងព្រលឹងរបស់តួអង្គនេះ។ នៅក្នុងប្រព័ន្ធកាលានុវត្តភាពនេះ ព្រះរាជអាជ្ញា ត្រូវបានគេចាត់ទុកជាម្ចាស់នៃបណ្តឹងអាជ្ញា និងជាភាគីនៅក្នុងរឿងព្រហ្មទណ្ឌ និងជាអ្នកតំណាងឲ្យផលប្រយោជន៍ទូទៅ។

ពាក្យថា ព្រះរាជអាជ្ញានៅអមតុលាការកំពូល គេអាចហៅបាន ២ បែប៖

១.អគ្គព្រះរាជអាជ្ញា នៃមហាអយ្យការអមតុលាការកំពូល (ហៅពេញ)

២.អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល

មាត្រា ២៨ ថៅក្រមអយ្យការមានដូចជា៖

១.អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជរង និងព្រះរាជអាជ្ញាអមតុលាការកំពូល។

២.អគ្គព្រះរាជអាជ្ញា អគ្គព្រះរាជអាជ្ញារង និងព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

៣.ព្រះរាជអាជ្ញា និងព្រះរាជអាជ្ញារងអមសាលាដំបូង។

បើយោងទៅតាមមាត្រាខាងលើ អាចបញ្ជាក់បានថា ស្ថាប័នអយ្យការ គឺជាអ្នកអមតុលាការកំពូល មិនមែនមនុស្សទេ ដែលជាអ្នកនៅអមតុលាការកំពូល។ អគ្គព្រះរាជអាជ្ញា គឺជាមនុស្ស ហើយមហាអយ្យការ គឺជាស្ថាប័ន។ នៅក្នុងឋានៈជាអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល រដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម បានផ្តល់តួនាទីមួយដល់សំខាន់ ក្នុងឋានៈជាប្រធាននៃ

[២៧] សាស្ត្រាចារ្យ រុន ព ណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២៧ ឆ្នាំ២០១៧-២០១៨

ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។ គាត់ជាអ្នកត្រួតពិនិត្យ ទៅលើកំហុសខាងវិន័យរបស់ព្រះរាជអាជ្ញាទាំងអស់។ បើយោងតាមមាត្រា ៤ សមាជិកនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមមាន ១១ រូប។ ហើយមានមុនងារសំខាន់២គឺ

១.ការតែងតាំង និងផ្លាស់ប្តូរនៃចៅក្រមទាំងអស់ និង

២.ការដាក់វិន័យ

ដោយយោងតាមរដ្ឋធម្មនុញ្ញ និងច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ប្រធានតុលាការកំពូល ត្រូវបានផ្តល់មុនងារមួយដ៏សំខាន់ក្នុងឋានៈជាប្រធានឧត្តមក្រុមប្រឹក្សាវិន័យនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម មានសិទ្ធិក្នុងការពិនិត្យរាល់កំហុសឆ្គងខាងវិន័យរបស់ចៅក្រមទាំងអស់។ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក៏ជាប្រធាននៃឧត្តមក្រុមប្រឹក្សាវិន័យប៉ុន្តែ គាត់មើលតែកំហុសវិន័យរបស់ព្រះរាជអាជ្ញាទេ។ ដូច្នេះ ប្រធាននៃឧត្តមក្រុមប្រឹក្សានៃអង្គចៅ-ក្រមមានពីរដោយឡែកពីគ្នា អញ្ចឹងបើរឿងដែលជាកំហុសវិន័យរបស់ចៅក្រម គឺប្រធានតុលាការកំពូលជាអ្នកដើរតួជាប្រធាននៃឧត្តមក្រុមប្រឹក្សាវិន័យ ដឹកនាំសមាជិក ៩ រូបទៀត។ ប៉ុន្តែប្រសិនជាការដាក់វិន័យ ប្រធានតុលាការកំពូល ឬអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ក្រុមឧត្តមក្រុមប្រឹក្សាវិន័យត្រូវប្រជុំដោយមានវត្តមានព្រះមហាក្សត្រ ដោយមានការចូលរួមរបស់មន្ត្រីក្រសួងយុត្តិធម៌។

តើការរៀបចំអង្គការតុលាការ និងអង្គការអយ្យការនៃសាលាជំនុំជម្រះក្តីនេះ អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ឬប្រធានតុលាការ ត្រូវបានគេចាត់ទុកថាគាត់ជានាយឋានានុក្រមនៃសាលាជម្រះក្តីទូទាំងប្រទេសដែរឬទេ?

ជាទូទៅ បើយើងមើលទៅលើរចនាសម្ព័ន្ធរដ្ឋបាលៈ វាបានបែងចែកមុខងារតាមថ្នាក់ ដែលថ្នាក់លើមានអំណាចទៅលើថ្នាក់ក្រោម។

អគ្គនាយកដ្ឋាន > នាយកដ្ឋាន > ការិយាល័យ។ តាមឋានានុក្រមរដ្ឋបាល អ្នកតូច ត្រូវតែគោរពចំពោះអ្នកធំ។

ចំពោះរដ្ឋបាលតុលាការៈ

កំពូល > ឧទ្ធរណ៍ > ដំបូង (២៥រាជធានី-ខេត្ត)

នៅក្នុងការគ្រប់គ្រងផ្នែកតុលាការវិញ មិនដូចគ្នានិងរចនាសម្ព័ន្ធរដ្ឋបាលនោះទេ ព្រោះការគ្រប់គ្រងរដ្ឋបាល នៃតុលាការមានការបែងចែកដាច់ពីគ្នា រវាងតុលាកាកំពូល ឧទ្ធរណ៍ និងដំបូង។ ហើយប្រធានតុលាការកំពូល មិនមែនជាអ្នកមានអំណាចរដ្ឋបាលនៃអង្គការតុលាការទូទាំងប្រទេសនោះទេ ពីព្រោះថាៈ

-ដើម្បីឲ្យមានឯករាជ្យរបស់តុលាការ ក្នុងការសម្រេចក្តី មានន័យថា ប្រធានតុលាការនីមួយៗ គាត់គ្រប់គ្រងតែរដ្ឋបាលរបស់គាត់ ដោយអត់មានឆ្លងគោលការណ៍ណាមួយទេ។ តុលាការកំពូល មិនអាចបង្ខំឲ្យតុលាការជាន់ទាប ធ្វើតាមខ្លួននោះទេ ប៉ុន្តែ គេបង្កើតឲ្យមានយន្តការឧបាស្រ័យទៅវិញ គេនិយាយថា សាលាដំបូងសម្រេចមកបែបនេះ បើអ្នកឯងមិនសុខចិត្តប្តឹងទៅឧទ្ធរណ៍។

-ក៏ប៉ុន្តែ តុលាការកំពូលអាចចេញសេចក្តីសម្រេច ដោយធ្វើការបកស្រាយច្បាប់នានា ដែលយើងហៅថា យុត្តិសាស្ត្រ។ ហើយយុត្តិសាស្ត្រនេះ មានតម្លៃដូចច្បាប់ដែរ អាចចាប់ង្ខំឲ្យតុលាការជាន់ទាបគោរពទៅលើការបកស្រាយនោះ ប៉ុន្តែមិនមែនលិខិតរដ្ឋបាលទៅបញ្ជាឲ្យធ្វើតាមនោះទេ។

ដូច្នេះហើយ ទើបគេបង្កើតឲ្យមានរដ្ឋបាលគ្រប់គ្រងដោយឡែកពីគ្នា ទៅតាមសាលាជម្រះក្តីនីមួយៗ ដែលគេហៅថា អង្គភាពរដ្ឋបាលៈ

-នៅតុលាការកំពូល មានអគ្គលេខាធិការដ្ឋានមួយ។

-នៅសាលាឧទ្ធរណ៍ មានអគ្គលេខាធិការដ្ឋានមួយ។

-នៅសាលាដំបូងមាន លេខាធិការដ្ឋានមួយ។

ប្រធានសាលាជម្រះក្តីនីមួយៗ ធ្វើការគ្រប់គ្រងទៅលើផ្នែករដ្ឋបាលរបស់ខ្លួន ដោយឡែកពីគ្នា។ ប្រធានតុលាការកំពូល មិនអាចមកមើលការខុសត្រូវរដ្ឋបាលនៅសាលាឧទ្ធរណ៍ ហើយប្រធានសាលាឧទ្ធរណ៍ ក៏មិនអាចមកមើលការខុសត្រូវរដ្ឋបាលនៅសាលាដំបូងបាននោះដែរ។

ចំណែក **រដ្ឋបាលស្ថាប័នអយ្យការៈ** ដោយយោងទៅតាមមាត្រា ២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មាត្រា ៣០, ៣១ និង ៣២ នៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម និងមាត្រា ៧៥ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា។

ដោយយោងទៅតាមមាត្រាខាងលើបានបង្ហាញថា នៅក្នុងការគ្រប់គ្រងរដ្ឋបាល នៃស្ថាប័នអយ្យការ មិនដូចជាការគ្រប់គ្រងរដ្ឋបាល នៃស្ថាប័នតុលាការនោះទេ។ ការគ្រប់គ្រងរបស់ស្ថាប័នអយ្យការត្រូវស្ថិតនៅក្រោមឋានានុក្រម ហើយឋានានុក្រមនេះ ពិសេសដាច់ដោយឡែកទៅតាមសមត្ថកិច្ចដែនដីរបស់ខ្លួន ហើយឋានានុក្រមនោះ មានលក្ខណៈពិសេសខុសពីរដ្ឋបាលទូទៅ។ ដើម្បីដឹងថាឋានានុក្រមនោះ ខុសគ្នាយ៉ាងណានោះ ដោយយើងត្រូវមើលទៅលើផ្ទៃក្នុងអង្គភាពគាត់មួយសិន ថានៅសាលាដំបូងព្រះរាជអាជ្ញា ដែលជាមេគេ មានសិទ្ធិធ្វើអ្វីខ្លះ? រួចហើយបានមើលទៀតថា តើអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មានសិទ្ធិធ្វើអ្វីខ្លះ ទៅលើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញានៃសាលាដំបូង?

ឋានានុក្រមពិសេសនេះ ជាទូទៅប្រើទាំងផ្នែករដ្ឋបាល និងចំណាត់ការសំណុំរឿង ដែលគេឲ្យឈ្មោះថា **អធិបញ្ញា**។ ហើយអធិបញ្ញានេះ គឺវាមានចរិតលក្ខណៈរបស់វាទៅទៀត ថាតើពេលណា

ទើបធ្វើអធិបញ្ញាបាន ហើយធ្វើនៅក្នុងទម្រង់ដូចម្ដេច និងអ្នកទទួលអធិបញ្ញាមានសិទ្ធិអ្វីខ្លះ?

ចំពោះ អធិបញ្ញា គឺត្រូវធ្វើឡើងក្រោមទម្រង់៣យ៉ាងគឺ

១.ត្រូវធ្វើឡើងជាលាយលក្ខណ៍អក្សរ។

២.ក្នុងទិសដៅនៃការចោទប្រកាន់ ហើយមិនអាចក្នុងទិសដៅតម្កល់រឿងទុកឥតចាត់ការទេ។

៣.អ្នកទទួលអធិបញ្ញា ត្រូវតែអនុវត្តតាមជាដាច់ខាត។

ប៉ុន្តែយ៉ាងណាក៏ដោយ ច្បាប់បានរក្សាសិទ្ធិទុកឲ្យចៅក្រមអយ្យការ ក្រោមពាក្យស្លោកមួយគឺ **ការជាទាសី សម្ដីជាសេរីភាព**។ ឧទាហរណ៍៖ នៅក្នុងពេលបើកសវនាការ ព្រះរាជអាជ្ញាមានសិទ្ធិបញ្ចេញយោបល់របស់ខ្លួនដោយសេរី ទោះបីជាផ្ទុយពីអធិបញ្ញាក៏ដោយ។ មាត្រា ៣០ បានការពារដល់ចៅក្រមអយ្យការ ក្នុងការធ្វើការកត់សម្គាល់ផ្ទាល់មាត់ ដោយសេរី តាមសតិសម្បជញ្ញៈរបស់ខ្លួន ហើយវាមិនអាចជាកំហុសនៃការដាក់វិន័យណាមួយបានឡើយ។

អ្នកដែលអាចចេញអធិបញ្ញារួមមាន៖

-ព្រះរាជអាជ្ញានៃសាលាដំបូង អាចចេញអធិបញ្ញាទៅលើព្រះរាជអាជ្ញារងទាំងអស់។

-អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចចេញអធិបញ្ញាទៅព្រះរាជអាជ្ញា ដែលឋិតនៅក្នុងដែនដីរបស់ខ្លួន។

-រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មានសិទ្ធិចេញអធិបញ្ញា ទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងព្រះរាជអាជ្ញាអមសាលាដំបូងទាំងអស់ លើកលែងតែអគ្គព្រះរាជអាជ្ញាអមតុលាការកំពូលតែប៉ុណ្ណោះ។

**មូលហេតុ៖**

១.ដោយហេតុថា អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល មិនមានសិទ្ធិចេញអធិបញ្ញានេះទេ ដោយហេតុថា សាលាកំពូល គឺចៅក្រមកាត់ក្ដីតែទៅលើអង្គច្បាប់ទេ គាត់មិនបានកាត់ក្ដីទៅលើអង្គហេតុនោះឡើយ ហើយចំពោះរឿងធ្វើអធិបញ្ញា គឺមិនត្រូវផ្អែកទៅលើអង្គហេតុទាំងស្រុងទេ។

២.អគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ជាប្រធាននៃឧត្តមក្រុមប្រឹក្សាវិន័យទៅទៀត ដូច្នេះបើធ្វើអធិបញ្ញាឲ្យគេចោទខុស អញ្ចឹងបានអ្នកណាមកដាក់វិន័យគាត់។ ដូច្នេះហើយ ទើបគេទុកគាត់ដើម្បីឲ្យគាត់មើលទៅលើវិន័យរបស់ព្រះរាជអាជ្ញាដែលប្រព្រឹត្តខុស។

### ២.១.ការជ្រើសរើសព្រះរាជអាជ្ញា

ការជ្រើសរើស និងការបណ្ដុះបណ្ដាលព្រះរាជអាជ្ញា ត្រូវអនុវត្តរួមគ្នាជាមួយការជ្រើសរើស និងការបណ្ដុះបណ្ដាលចៅក្រម តាមបញ្ញត្តិនៃជំពូកទី២ (ចៅក្រម) ផ្នែកទី៥ (ការជ្រើសរើសចៅក្រម)

នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា[២៨]។

សិស្សព្រះរាជអាជ្ញា ដែលបានបញ្ចប់ការបណ្តុះបណ្តាលវិជ្ជាជីវៈដោយជោគជ័យ ត្រូវតែងតាំងដោយព្រះរាជក្រឹត្យ ជាព្រះអាជ្ញាកម្មសិក្សា ក្នុងឋានន្តរសក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវធ្វើកម្មសិក្សារយៈពេល១ឆ្នាំ គិតចាប់ពីកាលបរិច្ឆេទនៃការតែងតាំង។

ការធ្វើកម្មសិក្សារបស់ព្រះរាជអាជ្ញាកម្មសិក្សា ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ បន្ទាប់ពីបានពិគ្រោះយោបល់ជាមួយសមាជិកទាំងអស់នៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

ការតែងតាំងជាព្រះរាជអាជ្ញាកម្មសិក្សា មានអានុភាពដល់ការរៀបចំប្រាក់បៀវត្ស និងការគិតអំពីអតីតភាពការងារ[២៩]។

ព្រះរាជអាជ្ញាកម្មសិក្សា ដែលបានបំពេញកម្មសិក្សាចប់ដោយជោគជ័យ ត្រូវតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា និងមានឋានន្តរស័ក្តិជាអនុព្រះរាជអាជ្ញាថ្នាក់ដំបូងគេ។ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រមលើកសេចក្តីស្នើថ្វាយព្រះមហាក្សត្រ អំពីការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញានេះតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងយុត្តិធម៌។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ អាចសម្រេចឲ្យព្រះរាជអាជ្ញាកម្មសិក្សា បន្តធ្វើកម្មសិក្សា ១ឆ្នាំបន្ថែមទៀត កាលបើព្រះរាជអាជ្ញាកម្មសិក្សានោះ ពុំទទួលបានជោគជ័យក្នុងការធ្វើកម្មសិក្សា ឬមានការអាក់ខានមិនបានធ្វើកម្មសិក្សាសរុបទាំងអស់លើសពី ៣០ថ្ងៃ។

ក្នុងករណីដែលព្រះរាជអាជ្ញាកម្មសិក្សាឈប់រហូតលើសពី ៣០ថ្ងៃ ដោយគ្មានការអនុញ្ញាតច្បាប់ ឬព្រះរាជអាជ្ញាកម្មសិក្សា ដែលមិនបានទទួលជោគជ័យជាថ្មីម្តងទៀត ក្នុងការធ្វើកម្មសិក្សាបន្ថែម ត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា ដោយត្រូវអនុវត្តទៅតាមបញ្ញត្តិនៃមាត្រា៨៩ នៃច្បាប់នេះ[៣០]។

ព្រះរាជអាជ្ញាកម្មសិក្សា ដែលមិនមានសម្បទាគ្រប់គ្រាន់ ឬមានសុខភាពមិនគ្រប់គ្រាន់ដើម្បីបំពេញមុខងាររបស់ខ្លួនតាមលក្ខខណ្ឌ ដែលច្បាប់បានកំណត់ ឬមានការខុសឆ្គងនៅក្នុងការបម្រើការងារមិនបានពេញលេញ អាចត្រូវលុបឈ្មោះចេញពីក្របខណ្ឌព្រះរាជអាជ្ញា បានគ្រប់ពេលវេលាដោយអនុវត្តតាមបញ្ញត្តិនៃមាត្រា ៨៩ នៃច្បាប់នេះ។

[២៨] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៨២ ទំព័រ២៥ ឆ្នាំ២០១៤

[២៩] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៨៣ ទំព័រ២៦ ឆ្នាំ២០១៤

[៣០] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៨៤ ទំព័រ២៦ ឆ្នាំ២០១៤

ការលុបឈ្មោះចេញ ឬការតាំងស៊ប់ក្នុងក្របខណ្ឌព្រះរាជអាជ្ញា ត្រូវធ្វើក្នុងរយៈពេល ៣ខែ យ៉ាងតិច ក្រោយពីការបញ្ចប់កម្មសិក្សា[៣១]។

**២.២.សមាសភាពរបស់អង្គការអយ្យការ**

ចំពោះសមាសភាព នៃអង្គការអយ្យការ គឺត្រូវបានចែកចេញជា ៣ ផ្នែកផ្សេងៗ ពីគ្នា ដោយចំណុចទី១ និងទី២ គឺមិនបានលើកយកសរសេរពិស្តារនោះទេ រីឯចំណែកចំណុចទី៣ គឺជាចំណុចដែលសំខាន់ ដែលត្រូវយកមកសរសេរយ៉ាងពិស្តារ អំពីសមាសភាពនៃអយ្យការអមសាលាដំបូងរាជធានី-ខេត្ត ដែលរួមមានដូចតទៅ៖

**ចំណុចទី១៖ មហាអយ្យការអមតុលាការកំពូល**

ពាក្យថា **មហាអយ្យការ** គឺសម្តៅលើឈ្មោះស្ថាប័នមួយ ដែលនៅអមតុលាការកំពូល។ ដើម្បីយល់កាន់តែច្បាស់លាស់ យើងសូមលើកជាឧទាហរណ៍មកបញ្ជាក់៖ សាកលវិទ្យាល័យភូមិន្ទនីតិ-សាស្ត្រ និងវិទ្យាសាស្ត្រដសេដ្ឋកិច្ច នេះគឺជាឈ្មោះស្ថាប័ន។ ដោយឡែក មហាអយ្យការ ក៏ជាឈ្មោះស្ថាប័ន ឬទីកន្លែងមួយដែរ។ ចំពោះអ្នក ដែលធ្វើការនៅក្នុងមហាអយ្យការអមតុលាការ កំពូល គឺមានសមាសភាពដូចខាងក្រោម៖

មហាអយ្យការអមតុលាការកំពូលមានសមាសភាពដូចតទៅ៖

-អគ្គព្រះរាជអាជ្ញា

-អគ្គព្រះរាជអាជ្ញារង

-ព្រះរាជអាជ្ញា

-ក្រឡាបញ្ជី និង

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត។

**ចំណុចទី២៖ មហាអយ្យការអមសាលាឧទ្ធរណ៍**

ដូចដែលបានបញ្ជាក់ខាងលើរួមមកហើយថា នៅអមតុលាការកំពូល មានមហាអយ្យការអមតុលាការកំពូល។ ដោយឡែក នៅសាលាឧទ្ធរណ៍វិញ ក៏មានស្ថាប័នមួយនៅអមដែរ ដែលគេហៅថា មហាអយ្យការអមសាលាឧទ្ធរណ៍។

សមាសភាព ដែលបម្រើការងារនៅមហាអយ្យការអមសាលាឧទ្ធរណ៍មានដូចតទៅ៖

-អគ្គព្រះរាជអាជ្ញា

-អគ្គព្រះរាជអាជ្ញារង

[៣១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៨៥ ទំព័រ២៦ ឆ្នាំ២០១៤

-ព្រះរាជអាជ្ញា

-ក្រឡាបញ្ជី និង

-មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត។

**ចំណុចទី៣៖ អយ្យការអមសាលាដំបូងរាជធានី-ខេត្ត**

នៅតាមសាលាដំបូងរាជធានី-ខេត្ត គឺមានស្ថាប័នមួយនៅអមដូចនៅសាលាឧទ្ធរណ៍ និងនៅតុលាការកំពូលដែរ។ ស្ថាប័ននោះហៅថា **អយ្យការអមសាលាដំបូង**។

អយ្យការអមសាលាដំបូង មានសមាសភាពដូចតទៅ៖

- ព្រះរាជអាជ្ញា
- ព្រះរាជអាជ្ញារង
- ក្រឡាបញ្ជី និង
- មន្ត្រីរដ្ឋបាល និងអាចមានមន្ត្រីជំនាញផ្នែកច្បាប់ផ្សេងទៀត[៣២]។

### ២.៣.ភារកិច្ចព្រះរាជអាជ្ញា

ព្រះរាជអាជ្ញា ត្រូវមានភារកិច្ចទទួលខុសត្រូវចំពោះកិច្ចការ ដែលបានប្រគល់ឲ្យ និងគោរពបទបញ្ញាយ៉ាងម៉ឺងម៉ាត់នូវក្រមសីលធម៌របស់ខ្លួន។

ក្នុងជីវភាពរស់នៅផ្ទាល់ខ្លួន ព្រះរាជអាជ្ញា មិនត្រូវប្រព្រឹត្តិអំពើណាមួយ ដែលនាំឲ្យអាប់ឱនដល់កិត្តិយស និងសេចក្តីថ្លៃថ្នូររបស់ខ្លួន និងដល់កិត្យានុភាព នៃអង្គការអយ្យការឡើយ។

ព្រះរាជអាជ្ញា ដែលកំពុងបំពេញមុខងារនៅតាមអយ្យការអមសាលាជម្រះក្តី គ្រប់ជាន់ថ្នាក់ត្រូវសុំការអនុញ្ញាតជាមុនពីរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ មុននឹងផ្សាយ ឬសុំឲ្យផ្សាយតាមគ្រប់មធ្យោបាយទាំងអស់នូវអត្ថបទ ឬការសរសេរសំណៅព្រមទាំងមតិផ្សេងៗ ដែលអាចធ្វើឲ្យប៉ះពាល់ដល់កិត្យានុភាពនៃស្ថាប័នអយ្យការ ឬស្ថាប័នតុលាការ។ បញ្ញត្តិនេះ មិនត្រូវយកមកអនុវត្តឡើយ ចំពោះការធ្វើសេចក្តីថ្លែងការណ៍ជាសាធារណៈរបស់ព្រះរាជអាជ្ញា ដោយអនុលោមតាមក្រមនីតិវិធីព្រហ្មទណ្ឌ។

ក្នុងវិស័យនយោបាយ ព្រះរាជអាជ្ញា ត្រូវប្រកាន់ជាដាច់ខាតនូវឥរិយាបថអព្យាក្រឹត។

ការរំលោភលើបញ្ញត្តិនៃកថាខណ្ឌទី២ និងទី៣ នៃមាត្រានេះ ត្រូវទទួលទោសវិន័យ ដោយមិនគិតដល់ការចោទប្រកាន់ជាបទល្មើសព្រហ្មទណ្ឌទេ ប្រសិនបើមាន[៣៣]។

---

[៣២] ដោយ ស៊ាង សំភស់ សមាសភាពរបស់អង្គការអយ្យការ ឬស្ថាប័នអយ្យការ និងតួនាទីរបស់ចៅក្រមអយ្យការ ទំព័រ២-៣

[៣៣] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៩៦ ទំព័រ៣០ ឆ្នាំ២០១៤

ព្រះរាជអាជ្ញាទាំងអស់ មិនត្រូវបោះបង់ការងាររបស់ខ្លួន ឬអវត្តមានដោយគ្មានការអនុញ្ញាតពីថ្នាក់លើផ្ទាល់របស់ខ្លួនជាមុនឡើយ។

សំណើសុំអនុញ្ញាតអវត្តមានរបស់ព្រះរាជអាជ្ញាអមសាលាដំបូង អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងអគ្គព្រះរាជអាជ្ញាអមតុលាការកំពូល ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌[៣៤]។

ការបោះបង់ការងារ ឬអវត្តមានឥតច្បាប់ ដោយពុំមានមូលហេតុចាប់ពី១៥ថ្ងៃឡើងទៅ ត្រូវទទួលវិន័យផ្អាកមិនឲ្យបើកប្រាក់បៀវត្ស ឬដាក់ឲ្យទំនេរគ្មានបៀវត្ស ដោយពុំមានមូលហេតុលើសពី៣០ថ្ងៃ ហើយព្រះរាជអាជ្ញានោះ នៅតែមិនត្រឡប់មកបំពេញការងារវិញ ក្រោយការដាក់កំហិតចំនួនពីរដងនោះ ត្រូវលុបឈ្មោះពីក្របខណ្ឌ[៣៥]។

### ២.៤.ចំណាត់ការសំណុំរឿងដោយអយ្យការ

តើត្រូវធ្វើយ៉ាងណា ដើម្បីឲ្យការចោទប្រកាន់របស់ព្រះរាជអាជ្ញាមានប្រសិទ្ធិភាព?

អយ្យការ គឺជាស្ថាប័នមជ្ឈការ ឬស្ថាប័នកណ្ដាលមួយនៃគ្រប់ព័ត៌មានទាំងអស់ ដែលទាក់ទងទៅនឹងបទល្មើសព្រហ្មទណ្ឌ។

នៅក្នុងរឿងក្ដីព្រហ្មទណ្ឌភាគច្រើន មានបណ្ដឹងពីរគឺ **បណ្ដឹងព្រហ្មទណ្ឌ និងបណ្ដឹងរដ្ឋប្បវេណី**។ ជាទូទៅក្រោយទទួលនូវបណ្ដឹង ឬដឹងពីរឿងក្ដីព្រហ្មទណ្ឌមួយហើយនោះ គាត់ធ្វើការសម្រេចចោទប្រកាន់ ឬមិនចោទប្រកាន់។ ក្នុងនោះមានពាក្យបីដែលត្រូវបានប្រើមានន័យដូចគ្នាគឺ

-ការចោទប្រកាន់

-ការធ្វើបណ្ដឹងអាជ្ញា

-និងការដាក់ឲ្យបណ្ដឹងអាជ្ញាមានដំណើរការ។

ពាក្យទាំងបីនេះ មានន័យស្មើគ្នា គឺធ្វើដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ (RI)។ ដោយយោងតាមមាត្រា ៥៨ (នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដើម្បីឲ្យបណ្ដឹងអាជ្ញាមានប្រសិទ្ធិភាព៖

-គេបានដាក់ឲ្យមានការសម្របសម្រួល សកម្មភាពការងាររបស់នគរបាលយុត្តិធម៌ ដើម្បីឲ្យសំណុំរឿងមានតុល្យភាព និងការចោទប្រកាន់ទទួលបានជោគជ័យ។

-និងយោងតាមមាត្រា ៤០ (នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដោយមុននឹងសម្រេច ព្រះរាជអាជ្ញាអាចបើកឲ្យមានការស៊ើបអង្កេតបឋម ឬបង្គាប់ឲ្យមានការស្រាវជ្រាវបន្ថែម[៣៦]។

---

[៣៤] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៩៧ ទំព័រ៣០ ឆ្នាំ២០១៤

[៣៥] ច្បាប់ស្ដីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៩៨ ទំព័រ៣១ ឆ្នាំ២០១៤

[៣៦] ឯកឧត្ដម កើត រិទ្ធ សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ១៦-២០ ឆ្នាំ២០១៦

## កថាខណ្ឌទី៣៖ លក្ខខណ្ឌនៃការចោទប្រកាន់

ក្រោយពីការទទួលបណ្ដឹងទាមទារ ឬបណ្ដឹងបរិហារពីជនណាម្នាក់ ឬទទួលរបាយការណ៍ពីមន្ត្រីនគរបាលយុត្តិធម៌ក៏ដោយ អយ្យការអាចមិនទាន់ធ្វើការចោទប្រកាន់ ប្រសិនបើយល់ឃើញថាពុំទាន់មានភស្តុតាងគ្រប់គ្រាន់ ដើម្បីធ្វើការចោទប្រកាន់នៅឡើយ។ អយ្យការអាចឲ្យមន្ត្រីនគរបាលយុត្តិធម៌ ធ្វើការស្វែងរកភស្តុតាងបន្ថែម ឬបើកការស៊ើបអង្កេតបឋមបាន (មាត្រា ៤០ កថាខណ្ឌទី២ វាក្យសព្ទទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ដោយហេតុថា ព្រះរាជអាជ្ញាជាម្ចាស់នៃបណ្ដឹងអាជ្ញា គាត់អាចទទួលពាក្យបណ្ដឹងអំពីរឿងក្ដីព្រហ្មទណ្ឌណាមួយបាន។ ពាក្យបណ្ដឹងនោះ អាចធ្វើឡើងដោយជនរងគ្រោះ ឬសាច់ញាតិរបស់ជនរងគ្រោះ មន្ត្រីនគរបាលយុត្តិធម៌ មន្ត្រីផ្សេងទៀត ដែលមានសមត្ថកិច្ចចាត់ការរឿងព្រហ្មទណ្ឌដូចជា មន្ត្រីគយជាដើម ឬក៏តតិយជនដែលបានដឹងឮពីបទល្មើសឧក្រិដ្ឋ ឬមជ្ឈិមណាមួយ។

### ៣.១.ការពិនិត្យលើលក្ខខណ្ឌនៃការចោទប្រកាន់

មុននឹងធ្វើការសម្រេចសេចក្ដី ព្រះរាជអាជ្ញា ត្រូវពិនិត្យទៅលើកត្តាច្រើនយ៉ាងដូចជា៖

-តើអំពើនោះ មានធាតុផ្សំនៃបទល្មើសព្រហ្មទណ្ឌគ្រប់គ្រាន់ដែរឬទេ ជាពិសេស គឺធាតុផ្សំនីត្យានុកូល ធាតុផ្សំសត្យានុម័ត ធាតុផ្សំអត្តនោម័ត?

-ត្រូវធ្វើការវាយតម្លៃកំណត់បទល្មើសឲ្យសមស្របទៅនឹងអំពើប្រព្រឹត្ត។ ឧទាហរណ៍៖ ជនម្នាក់បានឆក់យកទូរសព្ទរបស់អ្នកដទៃ។ អំពើនេះ នឹងត្រូវវាយតម្លៃកំណត់ថា ជាបទលួច។

-ត្រូវពិនិត្យថា តើជនសង្ស័យមានអភ័យឯកសិទ្ធិដែរឬទេ? ឧទាហរណ៍៖ អភ័យឯកសិទ្ធិគ្រួសារ (មាត្រា ៣៥៥ នៃក្រមព្រហ្មទណ្ឌ) អភ័យឯសិទ្ធិការទូត (អនុសញ្ញាទីក្រុងវីយែន៖ មិនអាចធ្វើការចោទប្រកាន់លើជនសង្ស័យនោះបានទេ)។

-តើជនល្មើស ត្រូវចោទប្រកាន់ក្នុងនាមជាអ្វី ឲ្យសមស្របទៅនឹងអំពើប្រព្រឹត្តរបស់ជននោះ?

**ឧទាហរណ៍៖** ការចោទប្រកាន់ក្នុងនាមជាចារី សហចារី អ្នកសមគំនិត ឬជាអ្នកផ្ដើមគំនិត។

-ត្រូវពិនិត្យថា តើស្ថិតក្នុងសមត្ថកិច្ចដែរឬទេ? ដោយយោងតាមមាត្រា៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ដែលមានសមត្ថកិច្ចគឺ៖

+ព្រះរាជអាជ្ញានៃទីកន្លែង ដែលមានការប្រព្រឹត្តបទល្មើស។ ឧទាហរណ៍៖ បទល្មើសកើតនៅខេត្តព្រៃវែង ស្ថិតក្នុងសមត្ថកិច្ចរបស់អយ្យការអមសាលាដំបូងខេត្តព្រៃវែង។

+ព្រះរាជអាជ្ញានៃលំនៅរបស់ជន ដែលបានសង្ស័យថា គឺបានប្រព្រឹត្តបទល្មើស។

**ឧទាហរណ៍៖** ជនល្មើសបានប្រព្រឹត្តបទល្មើសនៅរាជធានីភ្នំពេញ ប៉ុន្តែ គេដឹងថា ជននេះមានទីលំនៅ នៅខេត្តស្វាយរៀង ហើយជនរងគ្រោះ ក៏ដាក់ពាក្យបណ្ដឹងទៅអយ្យការអមសាលា

ដំបូងខេត្ត ស្វាយរៀង។ ក្នុងករណីនេះ អយ្យការអមសាលាដំបូងខេត្តស្វាយរៀង មានសមត្ថកិច្ច។

+ព្រះរាជអាជ្ញាទីកន្លែង ចាប់ខ្លួនជនដែលត្រូវបានសង្ស័យថា បានប្រព្រឹត្តិបទល្មើស។

**ឧទាហរណ៍៖** ជនល្មើសបានបាញ់សម្លាប់ជនរងគ្រោះនៅខេត្តកំពង់ស្ពឺ ហើយបានរត់គេចខ្លួន និងលាក់ខ្លួននៅរាជធានីភ្នំពេញ បន្ទាប់មកក៏ត្រូវបានចាប់ខ្លួន។ នៅក្នុងករណីនេះ អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ក៏មានសមត្ថកិច្ចដែនដីដែរ។

នៅក្នុងឧទាហរណ៍ខាងលើនេះ អយ្យការអមសាលាដំបូងខេត្តកំពង់ស្ពឺ និងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ សុទ្ធតែមានមានសមត្ថកិច្ច។ នៅក្នុងការអនុវត្តជាក់ស្តែង នឹងមានការសម្របសម្រួលគ្នា ហើយជាទូទៅរមែងតែងប្រគល់សមត្ថកិច្ចឲ្យអយ្យការ ដែលមានសមត្ថកិច្ចតាមទីកន្លែងប្រព្រឹត្តិបទល្មើស។

-ត្រូវពិនិត្យថា តើនៅក្នុងករណីនេះ ចាំបាច់ត្រូវមានបណ្តឹងពីជនរងគ្រោះដែរឬទេ?

**ឧទាហរណ៍៖** ដើម្បីអាចចោទប្រកាន់ពីបទបរិហាកេរ្តិ៍ជាសាធារណៈ ចាំបាច់ត្រូវមានបណ្តឹងពីជនរងគ្រោះ (មាត្រា ៣០៩ នៃក្រមព្រហ្មទណ្ឌ)។

-ត្រូវពិនិត្យថា តើបណ្តឹងអាជ្ញាត្រូវរលត់ហើយឬនៅ?

+មរណភាពរបស់ជនល្មើស

+ការផុតអាជ្ញាយុកាល

+ការលើកលែងទោសជាទូទៅ

+និរាករណ៍ច្បាប់ព្រហ្មទណ្ឌ

+អាជ្ញាអស់ជំនុំ

យោងតាមមាត្រា ៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ មិនត្រឹមប៉ុណ្ណោះ មានមូលហេតុផ្សេងទៀត នៃការរលត់បណ្តឹងអាជ្ញា (មាត្រា ៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) មានដូចជា៖

+ដោយការសម្របសម្រួលជាមួយរដ្ឋ

+ដោយការដកពាក្យបណ្តឹងនៅក្នុងករណី ដែលពាក្យបណ្តឹងនេះ ជាលក្ខខណ្ឌចាំបាច់នៃការចោទប្រកាន់ ជាបទព្រហ្មទណ្ឌ

+ដោយការបង់ប្រាក់ពិន័យសរុប ឬប្រាក់ពិន័យសម្របសម្រួល។

ក្រមនីតិវិធីព្រហ្មទណ្ឌថ្មី បានជ្រើសរើសយកគោលការណ៍ នៃកាលានុវត្តភាពនៃការចោទប្រកាន់ពុំមែនគោលការណ៍នីត្យានុកូលភាពនៃការចោទប្រកាន់ ដូចក្នុងច្បាប់នីតិវិធីព្រហ្មទណ្ឌឆ្នាំ ១៩៩៣ឡើយ។

មាត្រា ៤០ កថាខណ្ឌទី ២ នៃក្រមនីតិវិធីព្រហ្មទណ្ឌចែងថា៖ ព្រះរាជអាជ្ញា អាចសម្រេចតម្កល់រឿងទុកឥតចាត់ការ ឬធ្វើការចោទប្រកាន់ពីបទល្មើសព្រហ្មទណ្ឌ។ បទប្បញ្ញត្តិនេះ ជាបទប្បញ្ញត្តិ គោល ដែលនាំឲ្យមានការបកស្រាយថា ក្រមនីតិវិធីព្រហ្មទណ្ឌប្រកាន់យកគោលការណ៍កាលានុវត្ត ភាពនៃការចោទប្រកាន់។

គោលការណ៍កាលានុវត្តភាពនៃការចោទប្រកាន់ គឺមានន័យថា ទោះបីជាមានបទល្មើសព្រហ្មទណ្ឌក៏ដោយ ប៉ុន្តែប្រសិនបើព្រះរាជអាជ្ញាយល់ឃើញថា ការចោទប្រកាន់នឹងមិនមានផលប្រយោជន៍អ្វីសោះឡើយ គឺព្រះរាជអាជ្ញាអាចតម្កល់រឿតទុកឥតចាត់ការបាន។ ផ្ទុយទៅវិញ ប្រសិនបើច្បាប់តម្រូវឲ្យប្រកាន់យកគោលការណ៍នីត្យានុភាពនៃការចោទប្រកាន់វិញ ព្រះរាជអាជ្ញា ដាច់ខាត ត្រូវតែធ្វើការចោទប្រកាន់ នៅពេលដែលមានបទល្មើសព្រហ្មទណ្ឌ ដោយមិនអាចតម្កល់រឿងទុកឥតចាត់ការឡើយ[៣៧]។

### ៣.២.សេរីភាពក្នុងការសម្រេចរបស់ព្រះរាជអាជ្ញា

ជាគោលការណ៍ ព្រះរាជអាជ្ញា មានសេរីភាពពេញលេញក្នុងការសម្រេចពីការចោទប្រកាន់ ឬមិនចោទប្រកាន់។ ប៉ុន្តែ ដោយហេតុថា ព្រះរាជអាជ្ញាស្ថិតក្នុងអង្គ ដែលមានឋានានុក្រម ដូច្នេះ ព្រះរាជអាជ្ញាត្រូវធ្វើតាមបង្គាប់របស់ថ្នាក់លើតាមឋានានុក្រមរបស់ខ្លួន ដែលបង្គាប់បញ្ជាឲ្យធ្វើការចោទប្រកាន់លើអំពើណាមួយ ទោះបីព្រះរាជអាជ្ញាខ្លួនឯងយល់ថា ពុំត្រូវចោទប្រកាន់ក៏ដោយ។ គួរបញ្ជាក់ផងថា មានតែការបញ្ជាឲ្យចោទប្រកាន់ប៉ុណ្ណោះ ដែលព្រះរាជអាជ្ញា ត្រូវអនុវត្តតាម ប៉ុន្តែប្រសិនបើមានបញ្ជាមិនឲ្យចោទប្រកាន់ តែព្រះរាជអាជ្ញាបានចោទប្រកាន់រួចទៅហើយ គឺព្រះរាជ-អាជ្ញា ពុំអាចដកហូតការចោទប្រកាន់របស់ខ្លួនបានឡើយ[៣៨]។

## កថាខណ្ឌទី៤៖ សេចក្តីសម្រេចមិនចោទប្រកាន់ ឬចោទប្រកាន់របស់ព្រះរាជអាជ្ញា

### ៤.១.ដីកាតម្កល់រឿងទុកឥតចាត់ការ

បើសិនជាព្រះរាជអាជ្ញាយល់ថា មិនមែនជារឿងព្រហ្មទណ្ឌ ឬគ្មានភស្តុតាងណាមួយឲ្យជឿថា ពិតជាមានបទល្មើសកើតឡើងមែននោះ ព្រះរាជអាជ្ញានឹងចេញ **ដីកាតម្កល់រឿងទុកឥតចាត់ការ** (មាត្រា៤១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលមានសំអាងច្បាប់ និងសំអាងហេតុ។ ដីកាតម្កល់រឿងទុកឥតចាត់ការ អាចប្តឹងតវ៉ាទៅអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ ក្នុងរយៈពេល២ ខែ គិតពីថ្ងៃទទួលដំណឹងពីដីកានេះ ដោយអ្នកប្តឹងត្រូវដាក់ពាក្យនៅការិយាល័យក្រឡាបញ្ជីកាន់សំណុំរឿង។ ប្រសិន

[៣៧] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២៨-២៩ ឆ្នាំ២០១៧-២០១៨

[៣៨] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ២៩ ឆ្នាំ២០១៧-២០១៨

បើអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ យល់ឃើញថា ការតវ៉ាមានមូលហេតុត្រឹមត្រូវ អគ្គព្រះរាជ-អាជ្ញាត្រូវចេញ អធិបញ្ញាឲ្យព្រះរាជអាជ្ញាអមសាលាដំបូង ធ្វើការចោទប្រកាន់ឡើងវិញ។

ទោះជាយ៉ាងណាក្តី សេចក្តីសម្រេចនេះ ពុំមានអាជ្ញាអស់ជំនុំទេ ដោយសារតែព្រះរាជអាជ្ញាអាចសើរើ កែប្រែសេចក្តីសម្រេចរបស់ខ្លួន នៅពេលដែលបណ្តឹងអាជ្ញាមិនទាន់រលត់។

មូលហេតុនៃការចេញដីកាតម្កល់រឿងទុកឥតចាត់ការអាចមានដូចជា៖

**១.អង្គហេតុដែលប្តឹង មិនមែនជាបទល្មើសព្រហ្មទណ្ឌ។**

ឧទាហរណ៍៖ លោកស្រី ណារី បានប្តឹងលោក សម្បត្តិ ដែលបានខ្ចីប្រាក់គាត់ ហើយពុំព្រមសងប្រាក់វិញ។ នៅក្នុងករណីនេះ អំពើរបស់លោក សម្បត្តិ មិនមែនជាបទល្មើសព្រហ្មទណ្ឌនោះទេ វាជាអំពើល្មើផ្នែករដ្ឋប្បវេណី ហេតុហើយ តំណាងអយ្យការនឹងតម្កល់រឿងទុកឥតចាត់ការ។

**២.ធាតុផ្សំនៃបទល្មើសមិនគ្រប់គ្រាន់។**

ឧទាហរណ៍៖ កញ្ញា បុប្ផា បានប្តឹងចោទប្រកាន់លើលោក ចាន់ធី ថាបានឆបោកប្រាក់រូបនាងចំនួន១០០០ដុល្លារ ក៏ប៉ុន្តែពុំមានភស្តុតាងណាមួយបញ្ជាក់អំពីការប្រើកលល្បិច ដែលជាធាតុផ្សំនៃបទល្មើសឡើយ។

**៣.មានមូលហេតុនៃការរំលត់បណ្តឹងអាជ្ញា។**

**៤.បុគ្គលដែលពាក់ព័ន្ធជាជនដែលមានអភ័យឯកសិទ្ធិ។**

ឧទាហរណ៍៖ លោក ដារីត បានវាយលោក សំខាន់ ចំនួន២ដៃ។ លោក ដារីត គឺជាមន្ត្រីទូតរបស់ប្រទេសបារាំង ដែលមានអភ័យឯកសិទ្ធិ។ ដូច្នេះ តំណាងអយ្យការ គឺមិនអាចធ្វើការចោទប្រកាន់បានទេ។

**៥.ការមិនទទួលខុសត្រូវរបស់ជនល្មើស។**

ឧទាហរណ៍៖ លោក រ៉ាមី បានចាក់លោក សុភាព ចំនួនមួយកាំបិត ក៏ប៉ុន្តែ គេដឹងជាទូទៅថា លោក រ៉ាមី គឺជាជនវិកលចរិត ហើយមានការបញ្ជាក់ពីគ្រូពេទ្យជំនាញផងដែរ។

**៦.អនិយ័តភាពនៃនីតិវិធី (គឺនីតិវិធីនៃភាពមិនប្រក្រតី)**

ឧទាហរណ៍៖ មន្ត្រីនគរបាលយុត្តិធម៌ បានធ្វើការឆែកឆេរដោយខុសនីតិវិធី ហើយរកបានភស្តុតាងដែលបញ្ជាក់ថា លោក សុភ័ក្ត្រ បានលួចយកខ្សែករបស់អ្នកដទៃ ប៉ុន្តែដោយសារតែការឆែកឆេរធ្វើឡើងដោយខុសទៅនឹងនីតិវិធីច្បាប់ ដូច្នេះ តំណាងអយ្យការ គឺអាចតម្កល់រឿងទុកឥតចាត់ការបាន។

**៧.ការមិនស្គាល់អត្តសញ្ញាណរបស់ជនល្មើស។**

ឧទាហរណ៍៖ លោក សុភាព បានប្តឹងពីជនមិនស្គាល់ដែលបានលួចយកកាបូបប្រាក់របស់គាត់។ ប៉ុន្តែ ទោះបីជាស្វែងរកយ៉ាងណាក៏ដោយ ក៏មិនអាចដឹងបានថា តើនរណាជា

អ្នកលួចដែរ។ នៅក្នុងករណីបែបនេះ តំណាងអយ្យការ គឺអាចធ្វើការចោទប្រកាន់បានទៅលើអញ្ញាតជន (ជនមិន ស្គាល់អត្តសញ្ញាណកម្ម) ប៉ុន្តែ ស្របជាមួយគ្នានេះ តំណាងអយ្យការក៏អាចតម្កល់រឿងទុកឥតចាត់ការបានដែរ។

**៨.ការចោទប្រកាន់នឹងមិនផ្តល់ផលប្រយោជន៍អ្វីឡើយ។**

ឧទាហរណ៍៖ លោក ភក្តី បានបើកម៉ូតូកៀរជនរងគ្រោះម្នាក់បណ្តាលឲ្យរងរបួស។ ប៉ុន្តែលោក ភក្តី បានខិតខំជួយយកជនរងគ្រោះទៅមន្ទីរពេទ្យ បានចេញថ្លៃព្យាបាលជំនួសជនរងគ្រោះ។ ម្យ៉ាងទៀត ជនរងគ្រោះក៏មិនប្តឹងលោក ភក្តី ដែរ។ ដូច្នេះ តំណាងអយ្យការអាចតម្កល់រឿងទុកឥតចាត់ការ ពីព្រោះថាលោក ភក្តី បានដឹងពីកំហុសឆ្គងរបស់គាត់ទៅហើយ ដូច្នេះ ពុំចាំបាច់ធ្វើការផ្តន្ទាទោសរូបគាត់បន្ថែមទៀតនោះទេ[៣៩]។

**៩.ការរងបង្កព្យសនកម្មតិចតួច។**

ឧទាហរណ៍៖ លោក ជី អាយុ ១៦ឆ្នាំ បានលួចយកចានមួយរបស់លោកស្រី ណារី។

**៤.២.សេចក្តីសម្រេចក្នុងការចោទប្រកាន់**

នៅពេលដែលមានភស្តុតាងធ្ងន់ល្មមអាចជឿបានថា ជនសង្ស័យអាចនឹងប្រព្រឹត្តអំពើដែលគេប្តឹងមកនោះមែន ព្រះរាជអាជ្ញានឹងចាប់ផ្តើមធ្វើការចោទប្រកាន់។

ក្នុងករណី ដែលមន្ត្រីរាជការណាម្នាក់ ត្រូវបានតុលាការធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញាត្រូវជូនដំណឹងអំពីការចោទប្រកាន់នេះទៅប្រធានស្ថាប័នសាមី ក្នុងរយៈពេល **៧២ម៉ោង** យ៉ាងយូរ (មាត្រា៥១ នៃច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិល)។ ការចាប់ផ្តើមចោទប្រកាន់ចំពោះ អនីតិ-ជន ត្រូវជូនដំណឹងទៅអនីតិជនជាប់សង្ស័យ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់អនីតិជននោះ។

ទាក់ទងនឹងអនីតិជន ដែលជាជនជាប់សង្ស័យ សេចក្តីណែនាំអំពីការអនុវត្តគោលការណ៍នានាក្នុងច្បាប់ជាតិ និងអន្តរជាតិ ដែលកំពុងនៅជាធរមានទាក់ទងនឹងយុត្តិធម៌អនីតិជន ចេញដោយរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៥ បានកំណត់ថា៖ ប្រសិនបើមានភាពមិនច្បាស់លាស់អំពីអាយុរបស់អនីតិជនដែលជាប់សង្ស័យនោះទេ ព្រះរាជអាជ្ញាគប្បីធ្វើការស៊ើបអង្កេតបន្ថែម ដើម្បីស្វែងរកការពិតនៃអាយុរបស់អនីតិជន ដែលជាប់សង្ស័យនោះ។

ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យតិចជាង១៣ឆ្នាំ ព្រះរាជអាជ្ញា គប្បីចេញដីកាតម្កល់រឿងទុកឥតចាត់ការ ហើយឲ្យដំណឹងទៅភាគីដើមបណ្តឹងរដ្ឋប្បវេណី។

[៣៩] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ៣០-៣១ ឆ្នាំ២០១៧-២០១៨

ប្រសិនបើលទ្ធផលនៃការស៊ើបអង្កេតបឋមឃើញថា អាយុរបស់អនីតិជនជាប់សង្ស័យនោះចាប់ពី១៣ឆ្នាំឡើងទៅ តែតិចជាង១៨ឆ្នាំ ព្រះរាជអាជ្ញាអាចផ្តើមចោទប្រកាន់បាន។

ការចាប់ផ្តើមធ្វើការចោទប្រកាន់នេះ គឺអាចធ្វើទៅតាមវិធីបីយ៉ាង (មាត្រា៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ដែលរួមមានដូចជា៖

**១.បើកការស៊ើបសួរ៖ ព្រះរាជអាជ្ញាចេញដីកាសន្និដ្ឋានរឿងឲ្យស៊ើបសួរ ( RI )**

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ គឺជាដីកា ដែលព្រះរាជអាជ្ញាប្តឹងទៅចៅក្រមស៊ើបសួរឲ្យធ្វើការស៊ើបសួរលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ។

ដីកាបញ្ជូនរឿងឲ្យស៊ើបសួរ ត្រូវមាននិទ្ទេស ដូចកំណត់ក្នុងមាត្រា ៤៤ នៃក្រមនីតិវិធី ព្រហ្ម-ទណ្ឌ ពោលគឺ

**ក.សេចក្តីសង្ខេបនៃអង្គហេតុ**

ឧទាហរណ៍៖ កាលពីថ្ងៃទី៣០ ខែមីនា ឆ្នាំ២០១៣ លោក សំណាង បានឆក់យកកាបូបរបស់កញ្ញា ម៉ានិត ដែលកំពុងតែជិះម៉ូតូតាមដងផ្លូវ ប៉ុន្តែភ្លាមៗ នោះ ក្រោយពីបានឮសម្រែករបស់កញ្ញា ម៉ានិត អ្នកធ្វើដំណើរតាមដងផ្លូវនៅក្បែរនោះ ក៏បានធ្វើអន្តរាគមន៍ ចាប់ខ្លួនលោក សំណាង និងយកបានកាបូបរបស់កញ្ញា ម៉ានិត ទៅប្រគល់ឲ្យនគរបាលប៉ុស្តិ៍។

**ខ.ការកំណត់ឈ្មោះបទល្មើស**

ឧទាហរណ៍៖ អំពើលួច ឃាតកម្ម អំពើរំលោភសេពសន្ថវៈ ជាដើម។

**គ.ការបង្ហាញអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើស**

ឧទាហរណ៍៖ មាត្រា ១៩៩ នៃក្រមព្រហ្មទណ្ឌ មាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន (បទជួញដូរដោយខុសច្បាប់នូវសារធាតុញៀន)។

**ឃ.ឈ្មោះបុគ្គលដែលត្រូវរងការស៊ើបសួរ ប្រសិនបើអាចកំណត់បាន**

នៅក្នុងករណីមិនអាចកំណត់បាន តំណាងអយ្យការអាចបើកការស៊ើបសួរ ប្រឆាំងទៅនឹងអញ្ញាតជន ពោលគឺ ជនមិនស្គាល់ (សាវតាជាតិ)។

**ង.ចុះកាលបរិច្ឆេទ និងហត្ថលេខា**

ព្រះរាជអាជ្ញា មានកាតព្វកិច្ចធ្វើដីកានេះ ស្នើឲ្យចៅក្រមស៊ើបសួរធ្វើការស៊ើបសួរ ក្នុងករណីដូចខាងក្រោម៖

-បទល្មើសឧក្រិដ្ឋជាក់ស្តែង ឬមិនជាក់ស្តែង ។

-បទល្មើសមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថា ត្រូវបើកការស៊ើបសួរ។

**ច.ការបញ្ជូនរឿងរឿងទៅជំនុំជម្រះផ្ទាល់ (CD)**

ក្នុងករណីនេះ ព្រះរាជអាជ្ញា ចេញដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ ហើយនឹងចេញដីកាកោះហៅបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់។ ដូច្នេះសំណុំរឿង នឹងត្រូវបញ្ជូនទៅចៅក្រមជំនុំជម្រះ។

ការបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ អាចធ្វើបានតែចំពោះបទមជ្ឈិម (មាត្រា៤៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) និងបទលហុ (មាត្រា៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ) ប៉ុណ្ណោះ។

ចំពោះបទមជ្ឈិម ដែលព្រះរាជអាជ្ញាយល់ឃើញថា មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់ ដើម្បីឲ្យតុលាការ ធ្វើការជំនុំជម្រះវិនិច្ឆ័យសេចក្តីលើរឿងនេះបាន ព្រះរាជអាជ្ញា នឹងប្រើវិធីនៃការចោទប្រកាន់នេះ។

**ឧទាហរណ៍ ៖** លោក សុភាព បានលួចគោរបស់អ្នកជិតខាងចំនួនពីរក្បាល។ ដប់ថ្ងៃក្រោយមក ម្ចាស់គោបានដាក់ពាក្យបណ្តឹងលើលោក សុភាព ដោយមានសាក្សីពីរនាក់បានឃើញយ៉ាងច្បាស់លាស់។ លើសពីនេះទៅទៀត នៅពេលដែលតំណាងអយ្យការ បានកោះហៅលោក សុភាព មកស្តាប់ចម្លើយ លោក សុភាព បានសារភាពថា គាត់ពិតជាបានលួចគោនោះមែន ដោយសារតែម្ចាស់គោបានចងទុកចោល ហើយគាត់ត្រូវការប្រាក់ជាបន្ទាន់ ដើម្បីយកទៅព្យាបាលជំងឺប្រពន្ធរបស់គាត់។ នៅក្នុងស្ថានភាពបែបនេះ ឃើញថា មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ពីបទល្មើសដែលព្រះរាជអាជ្ញា មិនចាំបាច់បើកការស៊ើបសួរ (RI) ទៀតនោះទេ គឺព្រះរាជអាជ្ញា នឹងបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់តែម្តង។

ចំពោះបទលហុវិញ ព្រះរាជអាជ្ញា ត្រូវតែជ្រើសរើសយកវិធីនៃការចោទប្រកាន់នេះ (មាត្រា ៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ហើយក៏មិនមានបទប្បញ្ញត្តិណាផ្សេង ដែលអនុញ្ញាតឲ្យតំណាងអយ្យការ បើកការស៊ើបសួរ ឬប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះបទលហុនោះទេ។

ឧទាហរណ៍ ៖ លោកស្រី បញ្ញា បានប្តឹងចោទប្រកាន់លើលោកស្រី រស្មី ថាបានដើរនិយាយបរិហារកេរ្តិ៍បគាត់។ នៅក្នុងករណីនេះ ព្រះរាជអាជ្ញា ត្រូវតែធ្វើការស៊ើបអង្កេតឲ្យបានច្បាស់លាស់ ដើម្បីស្វែងរកភស្តុតាងបញ្ជាក់ ហើយប្រសិនបើត្រូវធ្វើការចោទប្រកាន់ ព្រះរាជអាជ្ញា នឹងបញ្ជូនរឿងនោះទៅជំនុំជម្រះផ្ទាល់តែម្តង ដោយមិនអាចប្រើប្រាស់វិធីណាផ្សេងឡើយ។

**ឆ.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម**

ប្រសិនបើលក្ខខណ្ឌនៃមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ត្រូវបានបំពេញ ព្រះរាជអាជ្ញា អាចប្រើប្រាស់នីតិវិធីនេះបាន ដោយគ្រាន់តែធ្វើកំណត់ហេតុនីតិវិធីបង្ហាញខ្លួនភ្លាមប៉ុណ្ណោះ ពុំមានចេញជាដីកាសន្និដ្ឋានអ្វីនោះទេ ដែលលក្ខខណ្ឌរួមមាន៖

-បទល្មើសមជ្ឈិមជាក់ស្តែង។

-បទល្មើសត្រូវផ្តន្ទាទោសដាក់ពន្ធនាគារយ៉ាងតិច ១ឆ្នាំ និងយ៉ាងច្រើន ៥ឆ្នាំ។

ឧទាហរណ៍៖ បទលួច (យោងតាមមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ បទលួច ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៦ខែ ទៅ ៣ឆ្នាំ ដូច្នេះ បទលួច គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារចំនួន ៣ឆ្នាំ ពោលគឺចន្លោះពី ១ឆ្នាំ ទៅ ៥ឆ្នាំ)។ ដូច្នេះ ចំពោះបទលួច អាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបាន។

បទគំរាមកំហែង (យោងតាមមាត្រា ២៣៦ នៃក្រមព្រហ្មទណ្ឌ ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារ ពី ១ខែ ទៅ ៥ខែ ដូច្នេះ បទគំរាមកំហែង គឺជាបទល្មើស ដែលត្រូវផ្តន្ទាទោសដាក់ពន្ធនាគារតិចជាង ១ឆ្នាំ)។ ដូច្នេះ តំណាងអយ្យការ មិនអាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាមបានទេ។

-ជនជាប់ចោទជានីតិជន។

-រឿងក្តីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន។

ឧទាហរណ៍៖ លោក ដារ៉ា អាយុ ២០ឆ្នាំ បានខ្ចីម៉ូតូរបស់មិត្តភក្តិគាត់ ដើម្បីយកទៅប្រើប្រាស់មួយភ្លែត ប៉ុន្តែផ្ទុយទៅវិញ បែរជាយកម៉ូតូនោះទៅបញ្ចាំនៅកុងស៊ីបញ្ចាំ ហើយភ្លាមៗ នោះម្ចាស់ម៉ូតូក៏តាមទាន់ និងចាប់ខ្លួនលោក ដារ៉ា ប្រគល់ជូននគរបាលប៉ុស្តិ៍តែម្តង។ នៅចំពោះមុខមន្ត្រីនគរបាលយុត្តិធម៌ លោក ដារ៉ា បានសារភាពពីចេតនាទុច្ចរិតរបស់គាត់។

នៅក្នុងស្ថានភាពបែបនេះ តំណាងអយ្យការ អាចប្រើនីតិវិធីនៃការបង្ហាញខ្លួនភ្លាម បានពីព្រោះថា៖ លោក ដារ៉ា បានប្រព្រឹត្តិបទមជ្ឈិម ពោលគឺ បទរំលោភលើទំនុកចិត្ត តាមបញ្ញត្តិនៃមាត្រា ៣៩១ និងមាត្រា ៣៩២ នៃក្រមព្រហ្មទណ្ឌ។

-បទល្មើសនេះ គឺជាបទល្មើសជាក់ស្តែង ដោយហេតុថា លោក ដារ៉ា ត្រូវបានចាប់ខ្លួននៅពេលដែលកំពុងតែបញ្ចាំម៉ូតូជនរងគ្រោះ។

លោក ដារ៉ា មានអាយុ ២០ឆ្នាំ ពោលគឺជានីតិជន។

រឿងក្តីនេះ មានលក្ខណៈគ្រប់គ្រាន់អាចជំនុំជម្រះបាន ពីព្រោះថា លោក ដារ៉ា បានសារភាពពីចេតនាទុច្ចរិតរបស់គាត់ រួមជាមួយនឹងវត្ថុតាងជាម៉ូតូ ដែលលោក ដារ៉ា បានយកទៅបញ្ចាំ ហើយត្រូវបានចាប់ខ្លួនជាក់ស្តែងតែម្តង។[៤០]

### ៤.៣.សិទ្ធិអំណាចផ្សេងៗ ទៀតរបស់អយ្យការ

-ព្រះរាជអាជ្ញាដឹកនាំ និងសម្រួលសកម្មភាពរបស់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌ទាំងអស់ នៅក្នុងសមត្ថកិច្ចដែនដីរបស់ខ្លួន។

-ព្រះរាជអាជ្ញា អាចចុះទៅកាន់កន្លែងស៊ើបអង្កេត និងធ្វើគ្រប់ការណែនាំដែលមានប្រយោជន៍ដល់មន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌។

-ព្រះរាជអាជ្ញា អាចដកសិទ្ធិស៊ើបអង្កេតពីមន្ត្រី និងភ្នាក់ងារនគរបាលយុត្តិធម៌ និងរៀបចំជំនួសមន្ត្រីនគរបាលយុត្តិធម៌ និងភ្នាក់ងារនគរបាលយុត្តិធម៌នោះ។

-ព្រះរាជអាជ្ញា អាចធ្វើអធិការកិច្ចបានគ្រប់ពេលវេលា នៅអង្គភាពនគរបាលយុត្តិធម៌។

-ព្រះរាជអាជ្ញា អាចចូលរួមស្តាប់ចម្លើយ ត្រួតពិនិត្យការអនុវត្តវិធានការឃាត់ខ្លួន ជាពិសេស

[៤០] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ៣១-៣៤ ឆ្នាំ២០១៧-២០១៨

គឺការគោពរទម្រង់ច្បាប់ និងការកាន់កាប់ទីកន្លែងឃាត់ខ្លួន។

មាត្រា ៣៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ បានចែងថា៖ ព្រះរាជអាជ្ញា ប្រើប្រាស់អំណាចទាំងអស់ ដែលក្រមនេះបានទទួលស្គាល់ឲ្យដល់មន្ត្រីនគរបាលយុត្តិធម៌ នៅក្នុងការស៊ើបអង្កេត។ ក្នុងន័យនេះ ព្រះរាជអាជ្ញា អាចធ្វើការស៊ើបអង្កេតផ្សេងៗ (ការស៊ើបអង្កេតករណីជាក់ស្តែង ឬបឋម) និងអាចធ្វើការឃាត់ខ្លួនជនជាប់សង្ស័យ ។ល។

នៅក្នុងការអនុវត្តជាក់ស្តែង ព្រះរាជអាជ្ញា ច្រើនតែធ្វើការស៊ើបអង្កេតបឋម ដោយកោះហៅជនពាក់ព័ន្ធមកស្តាប់ចម្លើយ ហើយកម្រឃើញមានការឃាត់ខ្លួនជនជាប់សង្ស័យនោះទេ។

-ចៅក្រមអយ្យការ ត្រូវតែមានវត្តមាននៅក្នុងពេលសវនាការរឿងព្រហ្មទណ្ឌ (មាត្រា ២៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្នុងគោលដៅដើម្បីសម្រួលដល់ចំណាត់ការរឿងក្តីព្រហ្មទណ្ឌ នៅពេលខ្លះ នៅក្នុងការអនុវត្តជាក់ស្តែង តំណាងអយ្យការអាចសម្រេចបញ្ចូល ឬបំបែកសំណុំរឿងព្រហ្មទណ្ឌបាន។ នៅក្នុងករណីបែបនេះ តំណាងអយ្យការចេញដីកាសម្រេចបំបែកសំណុំរឿង ឬដីកាសម្រេចបញ្ចូលសំណុំរឿងទាំងនោះបាន។

## កថាខណ្ឌទី៥៖ ការបញ្ចប់មុខងារជាព្រះរាជអាជ្ញា

### ៥.១.ការដាក់ទណ្ឌកម្ម

នៅក្នុងបញ្ញត្តិនៃជំពូកទី២ (ចៅក្រម) ផ្នែកទី១០ (ទណ្ឌកម្មវិន័យ) នៃច្បាប់នេះ ដែលអនុវត្តចំពោះចៅក្រម ត្រូវយកមកអនុវត្តដូចគ្នាផងដែរ ចំពោះព្រះរាជអាជ្ញា។ ដោយក្នុងនោះដែរ មាត្រា ៥៤ នៃច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា បានចែងដូច្នេះថា៖

កំហុសរបស់ព្រះរាជអាជ្ញា ក្នុងការបំពេញកាតព្វកិច្ចវិជ្ជាជីវៈ និងការធ្វើឲ្យប៉ះពាល់ដល់កិត្តិយស សីលធម៌ស្អាតស្អំ និងសេចក្តីថ្លៃថ្នូរប្រាសចាកពីក្រមសីលធម៌របស់ចៅក្រម និងព្រះរាជអាជ្ញា នាំឲ្យមានទណ្ឌកម្មខាងវិន័យ តាមបទប្បញ្ញត្តិនៃច្បាប់នេះ។ ប៉ុន្តែ ការប្រើប្រាស់ឆន្ទានុសិទ្ធិរបស់ចៅក្រម និងព្រះរាជអាជ្ញាក្នុងការអនុវត្តច្បាប់ មិនត្រូវចាត់ទុកថាជាកំហុសខាងវិន័យឡើយ។

ទណ្ឌកម្មខាងវិន័យ មិនមែនជាឧសគ្គដល់ការធ្វើបណ្តឹងអាជ្ញាទេ ប្រសិនបើមានបទល្មើសណាមួយត្រូវបានប្រព្រឹត្តិ។

ទណ្ឌកម្មខាងវិន័យមាន២ ថ្នាក់គឺ

១.ទណ្ឌកម្មថ្នាក់ទី១

ក.ការស្តីបន្ទោសដោយផ្ទាល់មាត់

ខ.ការស្តីបន្ទោសដោយចុះក្នុងសំណុំលិខិតផ្ទាល់ខ្លួន

គ.ការផ្អាកមិនឲ្យចុះឈ្មោះក្នុងតារាងដំឡើងថ្នាក់ ឬឋានន្តរសក្តិមួយរយៈ តែមិនត្រូវ

ឲ្យពី២ឆ្នាំទេ ឬលុបឈ្មោះចេញពីតារាងដំឡើងថ្នាក់ ឬឋានន្តរសក្តិវិញ ក្នុងករណីដែលមានចុះឈ្មោះ រួចហើយ។

២.ទណ្ឌកម្មថ្នាក់ទី២

ក.ការផ្លាស់ដោយបង្ខំ អាចតម្រូវឲ្យទទួលការបណ្ដុះបណ្ដាលបន្ថែម

ខ.ការព្យួរពីការងារមិនឲ្យមានបៀវត្ស ក្នុងរយៈពេលមិនឲ្យលើសពី១ឆ្នាំ

គ.ការបន្ថយមួយថ្នាក់ ឬច្រើនថ្នាក់ ឬបន្ថយឋានន្តរសក្តិ

ឃ.ការដាក់ឲ្យចូលនិវត្តន៍ដោយបង្ខំ

ង.ការបញ្ឈប់ពីមុខងារដោយបង្ខំ

ច.ការបណ្ដេញចេញពីក្របខណ្ឌ

ទណ្ឌកម្មថ្នាក់ទី២ ត្រូវធ្វើឡើងដោយព្រះរាជក្រឹត្យ បន្ទាប់ពីមានការសម្រេចពីឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម[៤១]។

ក្នុងករណី មានការបញ្ឈប់ពីមុខងារដោយបង្ខំ ឬការបណ្ដេញចេញពីក្របខណ្ឌដោយអនុលោមតាមបញ្ញត្តិនៃច្បាប់នេះ សាមីខ្លួនមានសិទ្ធិទទួលយកប្រាក់ទាំងអស់ ដែលបេឡាសោធននិវត្តន៍បានកាត់លើប្រាក់បៀវត្សរបស់ខ្លួនរួចមកហើយ តាមច្បាប់ ឬបទបញ្ញានៃបេឡាសោធននិវត្តន៍[៤២]។

### ៥.២.ការចូលនិវត្តន៍

ព្រះរាជអាជ្ញាទាំងពីរភេទ ត្រូវចូលនិវត្តន៍ នៅពេលគ្រប់អាយុ ៦០ឆ្នាំ។ ដោយឡែក ព្រះរាជ-អាជ្ញាទាំងអស់ នៃមហាអយ្យការអមតុលាការកំពូល ដែលមានអាយុចាប់ពី ៦០ឆ្នាំឡើងទៅ ត្រូវចូលនិវត្តន៍តាមការស្នើសុំរបស់សាមីខ្លួន។ ប៉ុន្តែ នៅពេលដែលដល់អាយុ ៦៥ឆ្នាំ ឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ត្រូវសម្រេចអំពីការបន្តការងាររបស់ព្រះរាជអាជ្ញាទាំងអស់ នៃមហាអយ្យការអមតុលាការកំពូល តាមការសុំរបស់សាមីខ្លួន។

រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ លើកសេចក្ដីព្រាងព្រះរាជក្រឹត្យថ្វាយព្រះមហាក្សត្រអំពីកិច្ចការខាងលើនេះ[៤៣]។

## កថាខណ្ឌទី៦៖ ករណីការអនុវត្តជាក់ស្តែង

នៅក្នុងការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញា ចំពោះការចោទប្រកាន់ជនល្មើស ក៏ដូចជានៅក្នុងរឿងក្ដីនីមួយៗ គឺពិតជាមានភាពប្រែប្រួល និងបត់បែនទៅតាមកាលទេសៈ ដែលពេលខ្លះ

[៤១] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៥៥ ទំព័រ១៧ ឆ្នាំ២០១៤

[៤២] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា៥៦ ទំព័រ១៧ ឆ្នាំ២០១៤

[៤៣] ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា មាត្រា១០១ ទំព័រ៣១ ឆ្នាំ២០១៤

អាចនឹងប្រាសចាកអំពីបទប្បញ្ញត្តិ ក៏ដូចជាទៅតាមនីតិវិធីច្បាប់។ ចំពោះ ការអនុវត្តជាក់ស្តែងរបស់ព្រះរាជអាជ្ញា យើងសង្កេតឃើញថា តែងតែមានកត្តាពីរកើតឡើងចំពោះពួកគាត់គឺ៖

**៦.១.បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា**

ដូចដែលបានរៀបរាប់ពីខាងលើរួចមកស្តីអំពី តួនាទី ភារកិច្ច មុខងារ របស់ព្រះរាជអាជ្ញាក្នុងរឿងក្តីព្រហ្មទណ្ឌ ដែលព្រះរាជអាជ្ញា គឺដើរតួនាទីជាអ្នកធ្វើការចោទប្រកាន់ចំពោះជនណាម្នាក់ នៅក្នុងបទល្មើសប្រភេទណាមួយក្នុងបទល្មើសព្រហ្មទណ្ឌ។ ហើយបញ្ហាប្រឈម ដែលតែងតែកើតមានចំពោះព្រះរាជអាជ្ញា គឺរួមមានដូចជា៖

**-ការចុះទៅដល់ទីតាំងផ្ទាល់៖** នៅពេលមានបទល្មើសកើតឡើង ព្រះរាជអាជ្ញា តែងតែចុះទៅកាន់ទីតាំងកើតហេតុដោយផ្ទាល់ ដើម្បីធ្វើការឃាត់ខ្លួន និងចាប់ខ្លួនជនល្មើស ដើម្បីដំណើរការនីតិវិធីនៃការចោទប្រកាន់ ក្នុងអំឡុងពេលនោះហើយ ដែលព្រះរាជអាជ្ញា អាចនឹងជួបហានិភ័យដល់ខ្លួន ក៏ដូចជាត្រូវ ជួបប្រទះបញ្ហាជាមួយនឹងជនល្មើស ឬក៏អ្នកដែលពាក់ព័ន្ធ ជាហេតុធ្វើឲ្យព្រះរាជអាជ្ញាមានការ លំបាកជាខ្លាំងក្នុងចាប់ខ្លួនជនប្រព្រឹត្តបទល្មើសយកមកចោទប្រកាន់។

**-ការសហការជាមួយមន្ត្រីនគរបាលយុត្តិធម៌៖** ដូចដែលបានដឹងហើយថា បទល្មើសមួយតែងតែកើតឡើងក្នុងដែនដីណាមួយជាក់ជាពុំខាន ដូច្នេះ ព្រះរាជអាជ្ញា ត្រូវការអាជ្ញាធរដែនដីនោះសហការជាមួយ ដើម្បីបំពេញការងារ។ តែផ្ទុយទៅវិញ ប្រសិនបើអាជ្ញាធរនៃដែនដីនោះ ធ្វើព្រងើយកន្តើយ មិនព្រមសហការ ហើយមិនយកចិត្តទុកចំពោះការតាមចាប់ខ្លួនជនល្មើសនោះទេ គឺពិតជាច្បាស់ណាស់ថា ព្រះរាជអាជ្ញា ប្រាកដជាពិបាកក្នុងការបំពេញការងាររបស់ខ្លួន។

**-វប្បធម៌នៃការអន្តរាគមន៍៖** ចំពោះវប្បធម៌អន្តរាគមន៍ គឺតែងតែកើតមានជារាយៗ ចំពោះប្រជាពលរដ្ឋខ្មែរយើង ជាពិសេសចំពោះអ្នកដែលមានលុយ មានអំណាច មុខងារ តួនាទីធំៗ ដែលតែងតែប្រព្រឹត្តិបទល្មើសហើយ តែបែរជាមិនត្រូវបានទទួលបានការចោទប្រកាន់ ឬចោទប្រកាន់មិនស្មើភាពជាមួយនឹងជនល្មើសធម្មតា។ កត្តានេះហើយ ដែលធ្វើឲ្យព្រះរាជអាជ្ញា ជួបប្រទះការលំបាកអាស្រ័យដោយមានការជ្រៀតជ្រែក ឬការស្នើសុំពីជនអ្នកមានអំណាចជាដើម។

**-បញ្ហាសន្តិសុខផ្ទាល់ខ្លួន៖** បញ្ហាសន្តិសុខផ្ទាល់ខ្លួន ក៏ដូចជាសន្តិសុខគ្រួសារ ក៏ជារឿងសំខាន់ ព្រោះថា ព្រះរាជអាជ្ញា ជាអ្នកធ្វើការចោទប្រកាន់ជនណាម្នាក់ ដែលជាហេតុធ្វើ ឲ្យជននោះមានការខឹងសម្បា ចងគំនុំគុំគួន និងបក្សពួកសាច់ញាតិរបស់គេមានការស្អប់ខ្ពើម តាម សងសឹកជាដើម ដែលអាចធ្វើឲ្យព្រះរាជអាជ្ញា មានការភ័យខ្លាចចំពោះសុវត្ថិភាពផ្ទាល់ខ្លួនរបស់ពួកគាត់ ក៏ដូចជាគ្រួសារផងដែរ។

### ៦.២.ដំណោះស្រាយចំពោះបញ្ហាប្រឈម

ចំពោះបញ្ហា ដែលតែងតែកើតមានក្នុងសង្គមជាតិយើង ជាពិសេស ដែលកើតមានចំពោះដល់ព្រះរាជអាជ្ញា នៅតាមសាលាដំបូងរាជធានី-ខេត្ត ក្នុងប្រទេសកម្ពុជា គឺពិតជាមានការលំបាកណាស់ សម្រាប់ធ្វើការដោះស្រាយ។ ដើម្បីបានជាដំណោះស្រាយខ្លះ ក្នុងការជួយសម្រួលដល់បញ្ហាដែលកើតមានចំពោះព្រះរាជអាជ្ញា គឺយើងទាំងអស់គ្នា ត្រូវគោរពទៅតាមនីតិវិធីច្បាប់ដែលមានចែងជាធរមាន ក៏ដូចជាបន្តខិតខំប្រឹងប្រែងអនុវត្តច្បាប់ ឲ្យបានល្អទាំងអស់គ្នា។ ដែលកត្តាទាំងនេះ គឺត្រូវការ ការចូលយ៉ាងយកចិត្តទុកដាក់អំពីសំណាក់ស្ថាប័នពាក់ព័ន្ធ ដែលរួមមានដូចជា៖

**-ការយកចិត្តទុកពីសំណាក់ស្ថាប័នសាមី៖** ស្ថាប័នសាមី គឺជាអ្នកមើលការខុសត្រូវដោយផ្ទាល់ទៅលើការបំពេញការងាររបស់មន្ត្រីក្រោមឱវាទ ដូច្នេះ ប្រសិនបើមានបញ្ហាអ្វីកើតឡើង គឺត្រូវតែជួយរកដំណោះស្រាយ ក៏ជួយរកទប់វិធីទប់ស្កាត់ កុំឲ្យបញ្ហានោះកើតមានឡើងបន្តទៀត។

**-ការរួមសហការគ្នារវាងនគរបាលយុត្តិធម៌ជាមួយនឹងព្រះរាជអាជ្ញា៖** ដូចដែលបានដឹងហើយថា មន្ត្រីនគរបាលយុត្តិធម៌ គឺជាជំនួយដល់ព្រះរាជអាជ្ញា ក្នុងការបង្ក្រាបបទល្មើស ស៊ើបអង្កេតបទល្មើស ក៏ដូចជាតាមចាប់ជនល្មើស យកមកផ្តន្ទាទោសទៅតាមច្បាប់ដែលបានកំណត់។ ដូច្នេះហើយ មន្ត្រីនគរបាលយុត្តិធម៌ ត្រូវធ្វើការយ៉ាងស្អិតរមួយជាមួយព្រះរាជអាជ្ញា ហើយនៅក្នុងករណី ដែលមន្ត្រីនគរបាល ពុំបានយកចិត្តទុកដាក់នោះទេ នឹងធ្វើឲ្យមានការពិបាកដល់ព្រះរាជអាជ្ញា ជាពិសេស ប្រសិនបើ មានការឃុបឃិតជាមួយនឹងមន្ត្រីនគរបាលណាមួយទៀតនោះ ច្បាស់ជាកាន់តែពិបាកទៀតហើយ អាស្រ័យហេតុនេះ គឺត្រូវការការរួមសហការគ្នាយ៉ាងល្អប្រសើរ។

**-ការលុបបំបាត់នូវវប្បធម៌អន្តរាគមន៍៖** បញ្ហា ដែលកើតមានចម្បងចំពោះព្រះរាជអាជ្ញា គឺអាស្រ័យដោយមានវប្បធម៌អន្តរាគមន៍ពីសំណាក់អ្នកមានអំណាច មានបុណ្យសក្តិ មានខ្នងបង្អែក ក៏ដូចជា អ្នកមានលុយជាដើម ដែលជាហេតុ ធ្វើឲ្យមានការរាំងស្ទះដល់ការបំពេញការងាររបស់ព្រះរាជអាជ្ញា ជាដើម។

យ៉ាងណាមិញ ដើម្បីឲ្យមានយុត្តិធម៌ដល់ការអនុវត្តច្បាប់ និងមិនឲ្យកកស្ទះនូវសំណុំរឿងព្រះរាជអាជ្ញាខ្លួនឯង ក៏មិនត្រូវមើលឃើញតែអំពីផលប្រយោជន៍ដល់ខ្លួននោះទេ។

ជាចុងក្រោយ ដើម្បីធ្វើឲ្យស្ថាប័នអយ្យការ មានភាពងាយស្រួលក្នុងការបំពេញការងារ គឺគ្រប់ស្ថាប័នពាក់ព័ន្ធ ត្រូវចូលរួមសហការគ្នាឲ្យបានល្អ ដើម្បីលុបបំបាត់នូវអំពើអាក្រក់នានា ដែលតែងតែកើតមានក្នុងស្ថាប័នតុលាការ ក៏ដូចជាក្នុងសង្គមជាតិទាំងមូល។

# ជំពូកទី៣

## អំពីចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ

# ជំពូកទី៣
# អំពីចៅក្រមស៊ើបសួរ និងចៅក្រមជំនុំជម្រះ

## ផ្នែកទី១៖ ដំណាក់កាលចៅក្រមស៊ើបសួរ

ដោយយោងតាមជម្រើសប្រព័ន្ធវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា ចៅក្រមស៊ើបសួរ មាននាទីសំខាន់ណាស់ក្នុងការចូលរួមចំណែកស្វែងរកយុត្តិធម៌ដល់គូភាគី។ តួនាទីយ៉ាងមានសារៈសំខាន់របស់ចៅក្រមស៊ើបសួរ គឺការសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ដែលជាសេចក្ដីសម្រេចមានលក្ខណៈប៉ះពាល់យ៉ាងខ្លាំងទៅនឹងសិទ្ធិ សេរីភាពរបស់បុគ្គល បានន័យថា ចៅក្រមស៊ើបសួរ មិនត្រឹមតែធ្វើការស៊ើបសួរនោះទេ គឺត្រូវស្វែងរកផងដែរ នូវភស្តុតាងដាក់បន្ទុកតាមការបង្ហាញពីព្រះរាជអាជ្ញា និងត្រូវស្វែងរកផងដែរ នូវភស្តុតាងដោះបន្ទុកទាំងឡាយណាដើម្បីបកស្រាយពីភាពត្រឹមត្រូវនៃអំពើមួយ[៤៤]។

### កថាខណ្ឌទី១៖ ការបើកការស៊ើបសួរ

ចៅក្រមស៊ើបសួរ មិនអាចបើកកិច្ចនីតិវិធីស៊ើបសួរណាមួយ ដោយឯកឯងបានឡើយ បើពុំមាន សេចក្ដីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា[៤៥]។ កាលណាចៅក្រមស៊ើបសួរ បានទទួលពាក្យបណ្ដឹងដោយមានការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ចៅក្រមស៊ើបសួរត្រូវធ្វើតាមនីតិវិធីដូចមានកំណត់ក្នុងមាត្រា ១៣៩[៤៦] (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) និងមាត្រា ១៤០[៤៧] (ការបង់ប្រាក់តម្កល់ទុក)។ ការស៊ើបសួរ ត្រូវធ្វើឡើងចំពោះបទឧក្រិដ្ឋ តែបទបជ្ជិមអាចធ្វើក៏បាន ឬមិនធ្វើក៏បាន។ ចៅក្រមស៊ើប មិនអាចស៊ើបសួរលើអង្គហេតុនូវចំណុចណា ដែលមិនបានបង្ហាញដោយព្រះរាជអាជ្ញានោះឡើយ។

ប្រសិនបើមានលេចចេញអង្គហេតុថ្មី ដែលអាចជាបទល្មើសព្រហ្មទណ្ឌ នៅក្នុងពេលស៊ើបសួរនោះ ចៅក្រមស៊ើបសួរត្រូវជូនព័ត៌មានអំពីអង្គហេតុនោះទៅព្រះរាជអាជ្ញា។ ក្នុងករណីនេះ ព្រះរាជអាជ្ញា អាចប្ដឹងសុំឲ្យចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរអំពីអង្គហេតុថ្មីនេះ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។ បើគ្មានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ ចៅក្រមស៊ើបសួរគ្មានអំណាចស៊ើបសួរអំពីអង្គហេតុថ្មីនោះឡើយ។

---

[៤៤] មាត្រា ១២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៤៥] មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៤៦] មាត្រា ១៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៤៧] មាត្រា ១៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប៉ុន្តែ ចៅក្រមស៊ើបសួរ មិនចាំបាច់សុំដីកាសន្និដ្ឋានបញ្ជូនរឿងបន្ថែមទេ ប្រសិនបើអង្គហេតុថ្មីនោះ ជាស្ថានទម្ងន់ទោសទៅលើអង្គហេតុ ដែលមានចែងនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរដំបូង (មាត្រា១២៥[៨៤])។

ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចដែនដីចំពោះគ្រប់បទល្មើស ដែលបានប្រព្រឹត្តនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន។ ចៅក្រម ដែលមាសមត្ថកិច្ចគឺ

-ចៅក្រមនៃទីកន្លែង ដែលបទល្មើសបានកើតឡើង

-ចៅក្រមនៃលំនៅឋាន ទីសំណាក់របស់បុគ្គល ដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស

-ចៅក្រមនាទីកន្លែង ដែលចាប់ខ្លួនបុគ្គល ដែលសង្ស័យថា បានប្រព្រឹត្តបទល្មើស។

ចៅក្រមស៊ើបសួរ មានសមត្ថកិច្ចលើគ្រប់បុគ្គលទាំងអស់ លើកលែងតែជាសមត្ថកិច្ចរបស់តុលាការពិសេសនោះទេ។ នៅពេលជនជាប់ចោទ បានបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរជាដំបូងចៅក្រមស៊ើបសួរ ត្រូវពិនិត្យអំពី៖

-អត្តសញ្ញាណនៃជនដែលបានបញ្ជូនមក

-ប្រាប់អំពីរឿងហេតុដែលបានធ្វើការចោទប្រកាន់

-ប្រាប់អំពីឈ្មោះបទល្មើសដែលបានចោទប្រកាន់

-មានសិទ្ធិឆ្លើយ ឬមិនឆ្លើយ ចំពោះការសួររបស់ចៅក្រមស៊ើបសួរ និងសិទ្ធិមានមេធាវី

ក្នុងករណីដែលជនជាប់ចោទនៅក្រៅឃុំ បន្ទាប់ពីការបង្ហាញខ្លួនដំបូង ជននោះត្រូវប្រកាសប្រាប់ទៅចៅក្រមស៊ើបសួរ អំពីអាសយដ្ឋានរបស់ខ្លួន ឬនៅពេលដែលខ្លួនត្រូវបានផ្លាស់ប្តូរទីលំនៅ។ ម៉្យាងទៀត គ្រប់ការឲ្យដំណឹង ដែលបានធ្វើឡើយតាមរយៈអាសយដ្ឋានចុងក្រោយ ដែលប្រកាសឡើងដោយជនជាប់ចោទនោះ ត្រូវចាត់ទុកថា បានធ្វើឡើងដល់សាមីខ្លួនផ្ទាល់[៨៥]។

### ១.១.ការស៊ើបសួរដាក់បន្ទុក

យោងតាមសេចក្តីសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា ដែលបានកំណត់អំពីអង្គហេតុ និងចំណុច ដែលត្រូវឲ្យស៊ើបសួរ ហើយជាចំណុចនៃការស៊ើបសួរដាក់បន្ទុកពីព្រះរាជអាជ្ញានោះ ថាតើពិតជាមានករណីដូចជាការចង្អុលបង្ហាញក្នុងដីកានេះដែរឬទេ។

### ១.២.ការស៊ើបសួរដោះបន្ទុក

ថ្វីត្បិតចៅក្រមស៊ើបសួរ អាចធ្វើការស៊ើបសួរត្រឹមតែការចង្អុលបង្ហាញ តាមរយៈដីកាសន្និដ្ឋាន

[៨៤]មាត្រា ១២៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨៥]មាត្រា ១៤៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញាក៏ដោយ ក៏ចៅក្រមមានសេរីភាពក្នុងការស៊ើបសួរ បានន័យថា ចៅក្រមស៊ើបសួរ ធ្វើការងាររបស់ខ្លួនដោយស្វែងរកភស្តុតាងទាំងឡាយណា ដែលជាមូលហេតុនៃភស្តុតាងដោះបន្ទុកផងដែរ ក្នុងអត្ថន័យនេះ គឺដើម្បីការពារនូវសិទ្ធិជនជាប់ចោទ និងធានាផងដែរនូវភាពត្រឹមត្រូវ និងយុត្តិធម៌។ ចៅក្រមស៊ើបសួរដើរតួនាទីប្រៀបដូចជាអាជ្ញាកណ្តាល ក្នុងការស្វែងរកការពិត និងជាអ្នកបង្ហាញផងដែរ អំពីភាពត្រឹមត្រូវរវាងបដិវិវាទនៃអយ្យការ និងជនជាប់ចោទ ដើម្បីដាក់ឲ្យចៅក្រមធ្វើការពិចារណាដោយយោងតាមច្បាប់។

**១.៣.ការស៊ើបសួរជំនួស**

ទោះបីជាការស៊ើបសួរ ជាភារៈកិច្ចរបស់ចៅក្រមស៊ើបសួរក៏ពិតមែន តែបើយោងតាមមូលហេតុមួយចំនួន ដែលបណ្តាលឲ្យចៅក្រម មិនអាចបំពេញភារៈកិច្ចនេះបាន ឬដោយមានភាពស្មុគស្មាញនៃបទល្មើសត្រូវស៊ើបសួរបន្ថែមទៀត ខណៈពេលនោះចៅក្រមស៊ើបសួរ អាចចេញដីកាចាត់ឲ្យស៊ើបសួរជំនួសបាន។

យោងតាមរយៈដីកាមួយនេះ ចៅក្រមស៊ើបសួរ អាចប្រគល់សិទ្ធិដល់ចៅក្រម នៃតុលាការរបស់ខ្លួន ឬតុលាការ ឬនគរបាល ឬក៏អង្គការផ្សេងទៀត ចាត់ឲ្យស៊ើបសួរជំនួស ដើម្បីបំពេញនាទីស៊ើបសួរជំនួសខ្លួនបាន[៥០]។

ដីកាប្រភេទនេះ ត្រូវបានបញ្ជាក់អំពីប្រភេទនៃកិច្ចដែលត្រូវធ្វើ និងថិរវេលា ដែលត្រូវឲ្យស៊ើបសួរជំនួស។ ដោយកិច្ចនេះផងដែរ ត្រូវមានកិច្ចទំនាក់ទំនងដោយផ្ទាល់ទៅនឹងបទល្មើស ដែលបានចោទប្រកាន់។ ដីកានេះ មិនអាចមានលក្ខណៈទូទៅទេ និងតម្រូវឲ្យមានការណែនាំឲ្យបានច្បាស់លាស់មុននឹងអនុវត្ត។ ម្យ៉ាងវិញទៀត ដីកានេះ ត្រូវមានកាលបរិច្ឆេទ ការចុះហត្ថលេខានៃចៅក្រមស៊ើបសួរ ប្រគល់សិទ្ធិ និងមានការបោះត្រាបញ្ជាក់ផង[៥១]។

គ្រប់ពេលណាក៏ដោយ ឲ្យតែចៅក្រមស៊ើបសួរយល់ឃើញថាជាការគួរ នោះគាត់មានសិទ្ធិអំណាចពេញលេញក្នុងការដកហូតដីកានេះបានគ្រប់ពេលវេលា។

**កថាខណ្ឌទី២៖ វិធានការណ៍និរន្តរាយ**

នៅក្នុងវិធានការណ៍និរន្តរាយ គឺជាដំណាក់កាលមួយ ដែលជាការដកហូតសិទ្ធិសេរីភាពរបស់បុគ្គលណាម្នាក់ ត្រូវបានអនុវត្តដោយអំណាចចាប់បង្ខំរបស់រដ្ឋ គឺតាមរយៈស្ថាប័ននៃអំណាចតុលាការ។

[៥០] មាត្រា ១៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥១] មាត្រា ១៧៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ត្បិតតែវិធានការណ៍មួយនេះ បានរំលោភលើសិទ្ធិ និងសេរីភាពនៃជនជាប់ចោទក៏ពិតមែន តែក្នុងវត្ថុបំណងដើម្បីរក្សានូវតុល្យភាព និងសណ្តាប់ធ្នាប់ក្នុងសង្គម ក្នុងនោះសិទ្ធិសេរីភាពរបស់ជនជាប់ចោទ ក៏ត្រូវបានធានាតាមច្បាប់ផងដែរ។ ក្នុងការប្រើវិធានមួយនេះ ចៅក្រមស៊ើបសួរមានសិទ្ធិអំណាចក្នុងការចេញដីកាមួយចំនួន ដូចមានចែងនៅក្នុងបញ្ញត្តិជំពូកទី៣ គន្ថីទី៤ នៃក្រមនេះ[៥២]។ ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចូលខ្លួន នាំខ្លួន ចាប់ខ្លួន និងឃុំខ្លួន។

### ២.១.ដីកាបង្គាប់ឲ្យចូលខ្លួន

ដីកាបង្គាប់ឲ្យចូលខ្លួន គឺជាការបញ្ជាក់ទៅលើបុគ្គលណាម្នាក់ ឬច្រើនឲ្យចូលទៅបង្ហាញខ្លួននៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាមួយនេះ ត្រូវចេញចំពោះជនត្រូវចោទ ឬទៅលើជនណាមួយដែលមានតម្រុយអំពីពិរុទ្ធភាព[៥៣]។ ដីកាបង្គាប់ឲ្យចូលខ្លួន គឺត្រូវកំណត់នូវនិទ្ទេសដូចតទៅ៖

-អត្តសញ្ញាណនៃជនដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ ដែលបង្ក្រាបអំពើល្មើស

-ថ្ងៃ ខែ ឆ្នាំ និងម៉ោងពេល ដែលត្រូវចូលខ្លួន

-ឈ្មោះ និងឋានៈនៃចៅក្រម ដែលចេញដីកា។

ត្រូវចាត់ទុកថា ជាដីកាដែលបានការនោះ គឺត្រូវកំណត់កាលបរិច្ឆេទ ហត្ថលេខាចៅក្រមស៊ើបសួរ និងបោះត្រាផង។ មួយវិញទៀត ដីកានេះត្រូវបញ្ជូនទៅដល់ជន ដែលពាក់ព័ន្ធដោយមន្ត្រីនគរបាលយុត្តិធម៌ ឬភ្នាក់ងារនគរបាលយុត្តិធម៌ ឬដោយអាជ្ញាសាលា។ អ្នកដែលមានកម្មវត្ថុក្នុងដីកានេះ ត្រូវចុះហត្ថលេខាជាចំណាំ ថាពិតជាបានទទួលដីកានេះនៅដើមដីកា។

### ២.២.ដីកាបង្គាប់ឲ្យនាំខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យនាំខ្លួន។ ដីកាបង្គាប់ឲ្យនាំខ្លួន គឺជាដីកាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យចាប់ និងនាំបុគ្គលណាម្នាក់ទៅចំពោះមុខចៅក្រមស៊ើបសួរ។ ដីកាបង្គាប់ឲ្យនាំខ្លួន អាចត្រូវចេញទៅលើជនត្រូវចោទ ឬទៅលើបុគ្គលណាម្នាក់ ដែលមានតម្រុយពិរុទ្ធភាព[៥៤]។ ដែលដីកានេះ ត្រូវចុះនិទ្ទេសដូចខាងក្រោម៖

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

[៥២] មាត្រា ១៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥៣] មាត្រា ១៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥៤] មាត្រា ១៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដីកា។

ដីកាបង្គាប់ឲ្យនាំខ្លួន ត្រូវចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[៩៥]។ បើពុំមានកំណត់ណាមួយដូចខាងលើទេ ត្រូវចាត់ទុកជាមោឃៈ។ ដីកានេះមានទិសដៅក្នុងការស្វែងរកជន ដែលជាកម្មវត្ថុនៃដីកានេះ ដែលត្រូវអនុវត្តដោយមន្ត្រីនគរបាលយុត្តិធម៌ មិនត្រឹមតែប៉ុណ្ណោះ ដោយយោងតាមស្ថានភាពពិសេស ដីកានេះបានបង្គាប់ដល់នគរបាល និងកងរាជអាវុធហត្ថផងដែរ។ ចំពោះការអនុវត្តដីកានេះ ក្នុងករណីនៃការចូលលំនៅឋាន បទបញ្ញត្តិនៃការឆែកឆេរ ក៏ត្រូវយកមកអនុវត្តផងដែរ។ បុគ្គលដែលនឹងត្រូវបង្ហាញខ្លួនបន្ទាប់ពីការអនុវត្តដីកានេះរួចហើយ តែមិនអាចធ្វើការបង្ហាញខ្លួនបាននៅថ្ងៃនោះចំពោះមុខចៅក្រមស៊ើបសួរ ឬអ្នកជំនួសដោយស្ថានភាពពិសេសណាមួយ ជននោះត្រូវបញ្ជូនខ្លួនទៅអង្គភាពនគរបាល ឬមណ្ឌលឃុំខ្លួន ឬក៏ពន្ធនាគារ ដើម្បីធានាការបង្ហាញខ្លួន តែការបង្ហាញខ្លួនគឺនៅថ្ងៃបន្ទាប់ បើពុំនោះទេជនដែលពាក់ព័ន្ធនឹងត្រូវដោះលែងឲ្យមានសេរីភាព។

**គួរបញ្ជាក់ផងដែរថា៖** ថិរវេលានៃការឃុំខ្លួនជាបណ្ដោះអាសន្ន ដោយផ្អែកតាមអានុភាពនៃដីកានេះ វាមិនមែនជាការឃុំខ្លួនបណ្ដោះអាសន្ន ដែលត្រូវបានកំណត់ក្នុងជំពូកទី៤ ផ្នែកទី៥ (ការឃុំខ្លួនបណ្ដោះអាសន្ន) នោះទេ តែបើមានការឃុំខ្លួនបណ្ដោះអាសន្ន ត្រូវបានអនុវត្តដោយយោងតាមផ្នែកនេះ នោះថិរវេលាត្រូវរាប់បញ្ចូលក្នុងរយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន។

### ២.៣.ដីកាបង្គាប់ឲ្យចាប់ខ្លួន

ចៅក្រមស៊ើបសួរ អាចចេញដីកាបង្គាប់ឲ្យចាប់ខ្លួន[៩៦]។ ដីកាបង្គាប់ឲ្យចាប់ខ្លួន គឺជាបញ្ជាដល់កងកម្លាំងសាធារណៈឲ្យស្រាវជ្រាវ និងនាំខ្លួនជននោះ ទៅក្នុងពន្ធនាគារ ឬមណ្ឌលឃុំខ្លួន និងប្រាប់ដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួនឲ្យទទួល នឹងឃុំខ្លួនជននោះ[៩៧]។ ដីកានេះ ត្រូវប្រគល់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ជាអ្នកអនុវត្ត[៩៨]។ ទោះបីជាចៅក្រមស៊ើបសួរ មានសិទ្ធិអំណាចក្នុងការចេញដីកាបង្គាប់ឲ្យចាប់ខ្លួនក៏ដោយ តែចាំបាច់ណាស់ ចៅក្រមស៊ើបសួរ ត្រូវតែសុំយោបល់ពីព្រះរាជអាជ្ញាមុននឹងចេញដីកានេះ[៩៩]។ ចៅក្រមស៊ើបសួរ អាចចេញដីកានេះបានលុះត្រាតែ៖

-ជាបទល្មើសឧក្រិដ្ឋ ឬមជ្ឈិម ដែលត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារ

[៩៥] មាត្រា ១៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៦] មាត្រា ១៩៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៧] មាត្រា ១៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៨] មាត្រា ១៩៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧
[៩៩] មាត្រា ១៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-បុគ្គលដែលពាក់ព័ន្ធ បានគេចខ្លួនមិនដឹងជាស្ថិតនៅទីកន្លែងណា ឬស្ថិតនៅក្រៅដែនដីនៃព្រះរាជាណាចក្រកម្ពុជា។

-និទ្ទេសដែលត្រូវចុះលើដីកាបង្គាប់ឲ្យចាប់ខ្លួន។ ហើយដីកាបង្គាប់ឲ្យចាប់ខ្លួន គឺមាននិទ្ទេសដូចខាងក្រោមៈ

-អត្តសញ្ញាណនៃបុគ្គលដែលពាក់ព័ន្ធ

-បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់បង្ក្រាបបទល្មើសនេះ

-ឈ្មោះ និងឋានៈនៃចៅក្រមដែលចេញដីកា

-ដីកាបង្គាប់ឲ្យចាប់ខ្លួន ត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងត្រូវមានបោះត្រាផង[៦០]។ ព្រះរាជអាជ្ញាជាអ្នកធានាដល់ការផ្សព្វផ្សាយដីកានេះ។ ដោយឡែកក្នុងករណីចាំបាច់ ដីកាបង្គាប់ឲ្យចាប់ខ្លួន អាចផ្សព្វផ្សាយជាអន្តរជាតិតាមរយៈក្រសួងយុត្តិធម៌ ដោយប្រើយន្តការនានា ដែលមានប្រសិទ្ធភាព[៦១]។

### ២.៤.ដីកាបង្គាប់ឲ្យឃុំខ្លួន

ក្រោយពីចៅក្រមស៊ើបសួរ បានចេញដីកាបង្គាប់ឲ្យចាប់ខ្លួនរួចហើយនោះ កិច្ចបន្ទាប់របស់ចៅក្រមស៊ើបសួរអាចចេញដីកាបង្គាប់ឲ្យឃុំខ្លួន[៦២]។ ដីកាបង្គាប់ឲ្យឃុំខ្លួន គឺជាបញ្ជាដល់ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ឲ្យទទួល និងឲ្យឃុំខ្លួនជនត្រូវចោទ។ ចៅក្រមស៊ើបសួរ អាចនឹងចេញដីកាបង្គាប់ឲ្យឃុំខ្លួនបាន លុះត្រាតែជនត្រូវចោទជាកម្មវត្ថុនៃដីកាសម្រេចឲ្យឃុំខ្លួនបណ្ដោះអាសន្ន[៦៣]។

ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវតែទទួល និងឃុំខ្លួនបុគ្គល ដែលមានដីកាបង្គាប់ឲ្យឃុំខ្លួន រហូតទាល់តែបានទទួលការឲ្យដំណឹងអំពីការដោះលែងឲ្យមានសេរីភាពវិញ។ មិនត្រឹមតែប៉ុណ្ណោះ ប្រធានពន្ធនាគារ ឬមណ្ឌលឃុំខ្លួន ត្រូវរក្សាទុកដើមដីកាបង្គាប់ឲ្យឃុំខ្លួន ឬចុងដីកានេះដែលបញ្ជាក់ថា ត្រឹមត្រូវតាមច្បាប់ដើម[៦៤]។

ម៉្យាងវិញទៀត ដីកាបង្គាប់ឲ្យឃុំខ្លួនមានចុះនិទ្ទេសដូចតទៅៈ

-អត្តសញ្ញាណរបស់ជនត្រូវចោទ

-ប្រភេទនៃបទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់ និងបង្ក្រាបបទល្មើសនេះ

---

[៦០] មាត្រា ១៩៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦១] មាត្រា ២០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦២] មាត្រា ២១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៣] មាត្រា ២២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៤] មាត្រា ២២២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-ឈ្មោះ និងឋានៈរបស់ចៅក្រមដែលចេញដី។

ដីកាបង្គាប់ឲ្យឃុំខ្លួន ត្រូវមានចុះកាលបរិច្ឆេទ ចុះហត្ថលេខាដោយចៅក្រមស៊ើបសួរ និងមានបោះត្រាផង[៦៥]។

### ២.៥.ការឃុំខ្លួនបណ្តោះអាសន្ន

ដោយយោងតាមគោលការណ៍សេរីភាព ជនត្រូវចោទ ត្រូវតែមានសេរីភាព។ តែប្រសិនបើមានលក្ខខណ្ឌ ពិសេសជនត្រូវចោទនោះ ត្រូវបានឃុំខ្លួនបណ្តោះអាសន្ន។ ការឃុំខ្លួននេះត្រូវអនុវត្តចំពោះតែបទឧក្រិដ្ឋ ឬបទមជ្ឈិមដែលច្បាប់កំណត់ទោសដាក់ពន្ធនាគារស្មើ ឬលើសពី ១ឆ្នាំ។ ការឃុំខ្លួនបណ្តោះអាសន្ននេះជាការចាំបាច់គឺ

-ដើម្បីបញ្ចប់បទល្មើស ឬបង្ការបទល្មើសកុំឲ្យកើតជាថ្មី។

-ដើម្បីរាំងកុំឲ្យមានការគាបសង្កត់លើសាក្សី ឬជនរងគ្រោះ ឬដើម្បីរាំងកុំឲ្យមានការត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងអ្នកសមគំនិត។

-ដើម្បីរក្សាភស្តុតាង ឬតម្រុយជាសម្ភារៈ។

-ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការចាត់ការតាមនីតិវិធីដើម្បីការពារសន្តិសុខជនត្រូវចោទ។

-ដើម្បីធានារក្សាសណ្តាប់ធ្នាប់សាធារណៈ កុំឲ្យមានការច្របូកច្របល់ ដែលបណ្តាលមកពីបទល្មើស[៦៦]។

ការសម្រេចឃុំខ្លួនបណ្តោះអាសន្ននេះ ត្រូវតែមានសំអាងហេតុ និងអាចត្រូវធ្វើឡើងដោយគំនិតផ្តួចផ្តើមពីចៅក្រមស៊ើបសួរ ឬតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា និងត្រូវមានលិខិតជូនដំណឹងដល់ជនត្រូវចោទ និងព្រះរាជអាជ្ញាភ្លាម។ នៅក្នុងករណី ការឃុំខ្លួនបណ្តោះអាសន្ន មាត្រា ២២០ (និយមន័យដីកាបង្គាប់ឲ្យឃុំខ្លួន) មាត្រា ២២១ (និទ្ទេសដែលត្រូវបានចុះលើដីកាបង្គាប់ឲ្យឃុំខ្លួន) មាត្រា ២២២ (ការអនុវត្តដីកាបង្គាប់ឲ្យឃុំខ្លួន) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

មួយវិញទៀត ចៅក្រមស៊ើបសួរ កាលបើបានទទួលសេចក្តីសន្និដ្ឋានពីព្រះរាជអាជ្ញាសុំឲ្យឃុំខ្លួនជនត្រូវចោទ ចៅក្រមរូបនេះ មានរយៈពេល ៥ថ្ងៃ ដើម្បីធ្វើការឆ្លើយតបទៅនឹងព្រះរាជអាជ្ញា បើចៅក្រមស៊ើបសួរ យល់ឃើញថាមិនឃុំខ្លួន តែបើថិរវេលានេះ ចៅក្រមស៊ើបសួរមិនបានគោរពទេ នោះការប្តឹងទៅសភាស៊ើបសួរ គឺត្រូវធ្វើឡើងដោយព្រះរាជអាជ្ញា ដែលជាស្ថាប័ននៃការសម្រេចលើ

[៦៥] មាត្រា ២២១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៦] មាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ករណីនេះជំនួសផងដែរ[៦៧]។

ការបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នអាចធ្វើបានដែរ បើព្រះរាជអាជ្ញាធ្វើការស្នើសុំទៅចៅក្រមស៊ើបសួរ ឬចៅក្រមស៊ើបសួរខ្លួនឯងនោះក៏អាចបញ្ចប់ការឃុំខ្លួនបណ្ដោះអាសន្នបានដែរ ក្នុងករណីបើយល់ឃើញថា មូលហេតុនៃការឃុំខ្លួនលែងមានទៀតហើយ។

**២.៥.១.ថិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្ន**

ប្រសិនបើចៅក្រមស៊ើបសួរសម្រេចឃុំខ្លួនជនត្រូវចោទជាបណ្ដោះអាសន្ន ការឃុំខ្លួនជាបណ្ដោះអាសន្ននេះ ត្រូវស្ថិតក្នុងថិរវេលា ដែលកំណត់ដោយច្បាប់។ ចំពោះថិរវេលានេះ មានការប្រែប្រួលទៅតាមប្រភេទនៃបទល្មើស ដែលបានចោទប្រកាន់ និងអាយុរបស់ជនត្រូវចោទដែលឃុំខ្លួន។

**ក.ប្រសិនបើជនជាប់ចោទពីបទឧក្រិដ្ឋប្រឆាំងមនុស្សជាតិ ឧក្រិដ្ឋប្រល័យពូជសាសន៍ ឬបទឧក្រិដ្ឋសង្គ្រាម:** ការឃុំខ្លួនមិនអាចលើសពី ១ឆ្នាំ បានទេ ចំពោះបទល្មើសនីមួយៗ។ ប៉ុន្តែនៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យាពេលឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ១ឆ្នាំ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ហើយការពន្យាពេលនេះ អាចធ្វើបានតែពីរដងគត់[៦៨] ។

**ខ.ប្រសិនបើជនជាប់ចោទពីបទឧក្រិដ្ឋផ្សេងទៀត:**

**-ចំពោះជនត្រូវចោទជានីតិជន៖** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៦ខែបានទេ។ ប៉ុន្តែ នៅពេលផុតថិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យាពេលការឃុំខ្លួនបណ្ដោះអាសន្នម្ដងបាន ៦ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ចៅក្រមស៊ើបសួរអាចសម្រេចពន្យាការឃុំខ្លួនបណ្ដោះអាសន្នបានតែ ២ដង គត់[៦៩] ។

ចំពោះអនីតិជនអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នឹងត្រូវចោទប្រកាន់ពីបទឧក្រិដ្ឋដោយថិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ៖

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ខែ បានទេ កាលណាអនីតិជននេះ មានអាយុតិចជាង ១៦ឆ្នាំ។

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៦ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ[៧០]។

---

[៦៧] មាត្រា ២០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៨] មាត្រា ២១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៦៩] មាត្រា ២០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧០] មាត្រា ២១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**គ-ប្រសិនបើជនជាប់ចោទពីបទមជ្ឈិមៈ**

**-ចំពោះជនត្រូវចោទជានីតិជនៈ** រយៈពេលនៃការឃុំខ្លួនបណ្ដោះអាសន្ន មិនអាចលើសពី ៤ ខែបានទេ។ ប៉ុន្តែ នៅពេលផុតចិរវេលានេះ ចៅក្រមស៊ើបសួរ អាចពន្យារការឃុំខ្លួនបណ្ដោះអាសន្ន បានតែម្ដងគត់មិនឲ្យលើសពី ២ខែ ដោយដីកាមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់។ ម្យ៉ាងវិញទៀត ចិរវេលានៃការឃុំខ្លួនបណ្ដោះអាសន្នខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់ឡើយ[៧១]។ **ឧទាហរណ៍:** ជនត្រូវចោទ ជាប់ចោទពីបទ **អំពើលួច** ដែលតាមច្បាប់ត្រូវផ្ដន្ទាទោសដាក់ពន្ធនាគារចាប់ពី ៦ខែ ដល់ ៣ឆ្នាំ (មាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌ)។ ដូច្នេះ អប្បបរមានៃទោស គឺរយៈពេល ៦ខែ។ ពាក់កណ្ដាលនៃអប្បបរមាគឺ ៣ខែ។ ហេតុនេះ មានន័យថា ការឃុំខ្លួនបណ្ដោះអាសន្នមិនត្រូវឲ្យលើសពី ៣ខែ ឡើយ។ ចំណែកឯបទល្មើស **ទទួលផលចោរកម្ម** វិញ ត្រូវបានច្បាប់កំណត់ទោស ដាក់ពន្ធនាគារចាប់ពី ២ឆ្នាំ ទៅ ៥ឆ្នាំ (មាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ) ហេតុនេះពាក់កណ្ដាលអប្បបរមានៃទោសគឺ ១ឆ្នាំ។ ដូច្នេះមានន័យថា ការឃុំខ្លួនបណ្ដោះអាសន្ន គឺ ៤ខែ ហើយចៅក្រមស៊ើបសួរអាចពន្យារពេលបន្ថែមបាន ២ខែទៀត តែម្ដងគត់ ជាការសរុបមិនឲ្យលើសពី ៦ខែ ឡើយ (ក្នុងករណីនេះ ៦ខែ គឺតិចជាង ១ឆ្នាំ ដែលជាចំនួនពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលបានកំណត់ដោយច្បាប់សម្រាប់បទ **ទទួលផលចោរកម្ម**)។

ចំពោះអនីតិជនមានអាយុចាប់ពី ១៤ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ នឹងត្រូវចោទប្រកាន់ពីបទមជ្ឈិម ដោយចិរវេលាឃុំខ្លួនបណ្ដោះអាសន្ន មានដូចតទៅ៖

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ២ខែ បានទេ កាលណាអនីតិជននេះមានអាយុតិចជាង ១៦ឆ្នាំ។

-ការឃុំខ្លួនបណ្ដោះអាសន្នមិនអាចលើសពី ៤ខែ បានទេ កាលណាអនីតិជននេះ មានអាយុចាប់ពី ១៦ឆ្នាំ ដល់ក្រោម ១៨ឆ្នាំ ចិរវេលានៃការឃុំខ្លួននៅចំណុចទី១ និងចំណុចទី២ ខាងលើនេះ មិនត្រូវលើសពីពាក់កណ្ដាលនៃអប្បបរមានៃទោស ដែលច្បាប់បានកំណត់សម្រាប់អនីតិជននោះឡើយ[៧២]។

## ២.៥.២.ការដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ

ក្នុងករណី ដែលជនត្រូវចោទ ជាប់ឃុំខ្លួនបណ្ដោះអាសន្ន ក្រោយពីមានដីកាសម្រេចរបស់

[៧១] មាត្រា ២០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧២] មាត្រា ២១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ចៅក្រមស៊ើបសួររួចហើយ ដោយដីកានោះ មាននូវសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ ក៏ប៉ុន្តែក្រមនីតិវិធីព្រហ្មទណ្ឌបានចែងពីការដោះលែងជននៅជាប់ឃុំនោះ ឲ្យនៅក្រៅឃុំវិញបានតាមវិធីបីយ៉ាងគឺ

**ក-តាមគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ៖** នៅក្នុងករណីនេះ ចៅក្រមស៊ើបសួរចេញ **ដីកាបញ្ជូនឲ្យឆ្លើយ** ដើម្បីសុំយោបល់ពីព្រះរាជអាជ្ញា ដែលទាក់ទិននឹងបំណងរបស់ចៅក្រមស៊ើបសួរក្នុងការដោះលែងជនត្រូវចោទនៅជាប់ឃុំខ្លួននោះឲ្យមានសេរីភាពឡើងវិញ។ ក្នុងករណីនេះព្រះរាជអាជ្ញា ត្រូវផ្តល់យោបល់របស់ខ្លួនក្នុងរយៈពេលយ៉ាងខ្លីបំផុត។ តាមក្រមនីតិវិធីព្រហ្មទណ្ឌ ជាធម្មតា ចៅក្រមស៊ើបសួរ ត្រូវរងចាំយោបល់ពីព្រះរាជអាជ្ញាសិន មុននឹងសម្រេចដោះលែងជនត្រូវចោទ ប៉ុន្តែក្នុងករណីបន្ទាន់ ចៅក្រមស៊ើបសួរ បង្គាប់ឲ្យដោះលែងភ្លាម ហើយចៅក្រមត្រូវចង្អុលបង្ហាញប្រាប់ពីមូលហេតុនៃការបន្ទាន់នេះនៅក្នុងដីកាសម្រេចរបស់ខ្លួន[៧៣]។ បន្ទាប់មកចៅក្រមស៊ើបសួរចេញ **ដីកាសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ**។

ចំពោះមូលហេតុនៃការបន្ទាន់ មានជាឧទាហរណ៍ដូចជា ជនត្រូវចោទដែលនៅជាប់ឃុំខ្លួននោះ ត្រូវបញ្ជូនទៅព្យាបាលនៅបរទេសភ្លាមៗ ដោយមិនអាចរងចាំបានឡើយ យោងទៅលើស្ថានភាពជម្ងឺមានសភាពធ្ងន់ធ្ងររបស់ជនត្រូវចោទ មិនអាចព្យាបាលនៅក្នុងប្រទេសបាន ជាដើម។

**ខ-តាមគំនិតផ្តួចផ្តើមរបស់ព្រះរាជអាជ្ញា ៖** នៅក្នុងករណីនេះ គឺព្រះរាជអាជ្ញាត្រូវតែធ្វើសេចក្តីសន្និដ្ឋានសុំឲ្យដោះលែងជនត្រូវចោទ។ ដោយឡែក ចៅក្រមស៊ើបសួរ ត្រូវសម្រេចក្នុងរយៈពេល ៥ថ្ងៃ ថាយល់ព្រមដោះលែងឲ្យនៅក្រៅឃុំ ឬមិនព្រមដោះលែងឲ្យនៅក្រៅឃុំ បន្ទាប់ពីបានទទួលសេចក្តីស្នើសុំពីព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរ ពុំបានសម្រេចក្នុងរយៈពេលកំណត់នេះទេ នោះព្រះរាជអាជ្ញាអាចប្តឹងទៅសភាស៊ើបសួរ ដើម្បីសម្រេចជំនួស។ ចៅក្រមស៊ើបសួរ អាចចេញ **ដីកាសម្រេចឲ្យដោះលែងនៅក្រៅឃុំ** ឬ**ដីកាសម្រេចមិនព្រមដោះលែងនៅក្រៅឃុំ**។ ដោយឡែកចំពោះដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុត្រឹមត្រូវ និងច្បាស់លាស់ (មាត្រា ២១៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**គ-តាមពាក្យសុំឲ្យដោះលែងនៅក្រៅឃុំរបស់ជនត្រូវចោទ ឬមេធាវីជនត្រូវចោទ៖** ក្នុងរកណីដែលទទួលបានពាក្យសុំនេះ ចៅក្រមស៊ើសួរ ត្រូវបញ្ជូនពាក្យសុំនេះទៅព្រះរាជអាជ្ញាភ្លាម ដើម្បីសុំយោបល់ និងបញ្ជូនសំណុំរឿងឲ្យព្រះរាជអាជ្ញាពិនិត្យ។ ព្រះរាជអាជ្ញា ត្រូវផ្តល់យោបល់ក្នុងរយៈពេលខ្លីបំផុត។ ចៅក្រមស៊ើបសួរ ត្រូវសម្រេចថា ដោះលែង ឬមិនដោះលែង ក្នុងរយៈពេល ៥ថ្ងៃនេះ

[៧៣] មាត្រា ២១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

បន្ទាប់ពីពេលបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេច ក្នុងរយៈពេល ៥ថ្ងៃនេះ ជនត្រូវចោទ អាចប្តឹងទៅសភាស៊ើបសួរ ឲ្យសម្រេចជំនួសបាន។ ចៅក្រមស៊ើបសួរអាចចេញ **ដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ** ឬ**ដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ**។ ចំពោះដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំ ត្រូវតែមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ ចេញដីកាសម្រេចមិនព្រមដោះលែងឲ្យនៅក្រៅឃុំម្តងហើយនោះ ជនត្រូវចោទអាចដាក់ពាក្យសុំឲ្យដោះលែងសាជាថ្មីម្តងទៀត ក្នុងរយៈពេល ១ខែ បន្ទាប់ពីមានសេចក្តីសម្រេចលើកមុន[៧៤]។

### ២.៦.ដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្នុងករណី ដែលចៅក្រមស៊ើបសួរ សម្រេចមិនឃុំខ្លួនបណ្តោះអាសន្ន ឬសម្រេចដោះលែងជនត្រូវចោទឲ្យនៅក្រៅឃុំ នោះចៅក្រមស៊ើបសួរ អាចដាក់ជននេះឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយតម្រូវឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចមួយ ឬច្រើន ដែលមានចែងក្នុងមាត្រា ២២៣ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

កាតព្វកិច្ចនៃការត្រួតពិនិត្យតាមផ្លូវតុលាការ ដែលមានចែងនៅក្នុងមាត្រា ២២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មានចំនួន ១២ គឺ

១-មិនត្រូវចេញក្រៅព្រំប្រទល់ដែនដីកំណត់ដោយចៅក្រមស៊ើបសួរ។

២-មិនត្រូវផ្លាស់ប្តូរលំនៅឋានដោយគ្មានការអនុញ្ញាតពីចៅក្រមស៊ើបសួរ។

៣-មិនត្រូវទៅកាន់ទីកន្លែងខ្លះ ដែលកំណត់ដោយចៅក្រមស៊ើបសួរ។

៤-ត្រូវបង្ហាញខ្លួនតាមការកំណត់នៅអង្គភាពនគរបាល ឬកងរាជអាវុធហត្ថ ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៥-ត្រូវឆ្លើយតបនឹងការកោះហៅពីគ្រប់បុគ្គល ដែលចាត់តាំងដោយចៅក្រមស៊ើបសួរ។

៦-ប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីគ្រប់ឯកសារបញ្ជាក់អំពីអត្តសញ្ញាណ។

៧-មិនត្រូវបើកបររថយន្ត។

៨-មិនត្រូវទទួល ឬជួបបុគ្គលមួយចំនួន ដែលចង្អុលបង្ហាញដោយចៅក្រមស៊ើបសួរ។

៩-ដាក់ប្រាក់ធានា ដែលចំនួនប្រាក់ធានា និងចិរវេលាបង់ប្រាក់នេះ ត្រូវបានកំណត់ដោយចៅក្រមស៊ើបសួរ ដោយផ្អែកទៅលើធនធានរបស់ជនត្រូវចោទ។

១០-មិនត្រូវកាន់កាប់ ឬយកតាមខ្លួននូវអាវុធ។ ត្រូវប្រគល់ជូនដល់ការិយាល័យក្រឡាបញ្ជីនូវអាវុធ ដែលជនត្រូវចោទកាន់កាប់។

[៧៤] មាត្រា ២១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

១១-ត្រូវប្រគល់ខ្លួនឲ្យពេទ្យពិនិត្យព្យាបាល និងជាយថាហេតុ ដាក់ឲ្យស្ថិតនៅក្រោមរបបព្យាបាលរោគក្នុងមន្ទីរពេទ្យ។

១២-មិនត្រូវធ្វើសកម្មភាពខាងវិជ្ជាជីវៈខ្លះ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ មិនអាចហាមឃាត់ការអនុវត្តនូវអាណត្តិបោះឆ្នោត ឬសកម្មភាពខាងអាជីពបានឡើយ។

ក្រៅពីកាតព្វកិច្ចនៅក្នុងមាត្រានេះ ចៅក្រមស៊ើបសួរពុំអាចបង្គាប់ឲ្យជនត្រូវចោទគោរពនូវកាតព្វកិច្ចណាផ្សេងទៀតបានទេ។ ដោយឡែក ចំពោះដីកាសម្រេចនេះ (ដីកាសម្រេចដាក់ជន ត្រូវចោទឲ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ) មិនអាចធ្វើចំពោះអនីតិជនអាយុក្រោម ១៤ ឆ្នាំ បានឡើយ[៧៥]។

ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរចេញដីកានេះបាន។ នៅក្នុងករណីនេះចៅក្រមស៊ើបសួរត្រូវចេញក្នុងរយៈពេល ៥ថ្ងៃ។ ចៅក្រមស៊ើបសួរ ចេញ **ដីកាសម្រេចដាក់ជនត្រូវចោទឲ្យនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ** ឬ**ដីកាសម្រេចបដិសេធ ការសុំឲ្យដាក់ជនត្រូវចោទនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ**។ ប្រសិនបើចៅក្រមស៊ើបសួរ ពុំបានសម្រេចក្នុងរយៈពេល ៥ថ្ងៃ នេះទេ ព្រះរាជអាជ្ញា អាចប្តឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសបាន[៧៦]។

### ២.៧.ការកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ

ក្រោយពីចេញដីកាសម្រេចនេះរួចហើយ គឺអាចមានការកែប្រែ ឬបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការដោយមានរបៀបបីយ៉ាងដូចតទៅ៖

#### ២.៧.១.តាមគំនិតផ្តួចផ្តើមរបស់ចៅក្រមស៊ើបសួរ

ចៅក្រមស៊ើបសួរ អាចកែប្រែខ្លឹមសារនៃកាតព្វកិច្ច អាចលុបចោល ឬបញ្ចូលកាតព្វកិច្ចថ្មីបានគ្រប់ពេលវេលា។ មិនតែប៉ុណ្ណោះ ចៅក្រមស៊ើបសួរ ក៏អាចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការបានដែរ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ សម្រេចតាមដីកា ដែលត្រូវជូនដំណឹងក្នុងរយៈពេលដ៏ខ្លីបំផុតដល់ព្រះរាជអាជ្ញា និងជនត្រូវចោទ[៧៧]។

#### ២.៧.២.តាមបណ្តឹងសុំកែប្រែ ឬលើកលែងពីព្រះរាជអាជ្ញា

ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ត្រូវសម្រេចពីបណ្តឹងនេះក្នុងរយៈពេល ៥ថ្ងៃ។ ប្រសិនបើចៅក្រមស៊ើបសួរមិនបានសម្រេចក្នុងរយៈពេលនេះទេ ព្រះរាជអាជ្ញា អាចប្តឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ដោយឡែក ចំពោះដីកា សម្រេចមិនព្រមធ្វើតាមបណ្តឹងសុំ

[៧៥] មាត្រា ២២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧៦] មាត្រា ២២៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៧៧] មាត្រា ២២៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

របស់ព្រះរាជអាជ្ញានោះទេ ត្រូវតែមានសំអាងហេតុ[78]។

**២.៧.៣.បណ្ដឹងសុំកែប្រែ ការត្រួតពិនិត្យតាមផ្លូវតុលាការ ដោយជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ**

ជនត្រូវចោទ អាចធ្វើពាក្យសុំឲ្យលើកលែង ឬកែប្រែការត្រួតពិនិត្យតាមផ្លូវតុលាការបាន គ្រប់ពេលវេលា។ ចៅក្រមស៊ើបសួរ បញ្ជូនពាក្យនេះភ្លាមទៅព្រះរាជអាជ្ញា ដើម្បីសុំយោបល់ និងជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីពិនិត្យ។ ក្នុងករណីនេះ ចៅក្រមស៊ើបសួរ ត្រូវសម្រេចយ៉ាងយូរបំផុតក្នុងរយៈពេល ៥ថ្ងៃ គិតពីថ្ងៃបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា។ ប្រសិនបើចៅក្រមស៊ើបសួរពុំបានសម្រេចក្នុងរយៈពេលនេះទេ ជនត្រូវចោទអាចប្ដឹងទៅសភាស៊ើបសួរឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរបាន។ ប្រសិនបើមានពាក្យសុំសាជាថ្មី មុនពេលដែលចៅក្រមស៊ើបសួរ ឬសភាស៊ើបសួរសម្រេចលើពាក្យសុំមុននោះ រយៈពេល ៥ថ្ងៃ ត្រូវចាប់ផ្ដើមគិតពីពេលចេញដីកាសម្រេចលើពាក្យសុំពីមុន។ មួយវិញទៀត ដីកាសម្រេច ដែលមិនព្រមធ្វើតាមពាក្យសុំ ត្រូវតែមានសំអាងហេតុ។

ក្នុងករណីនេះផងដែរ ចៅក្រមស៊ើបសួរចេញ **ដីកាសម្រេចកែប្រែ ការត្រួតពិនិត្យតាមផ្លូវតុលាការ** ឬ**ដីកាសម្រេចបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ** ឬ**ដីកាសម្រេចមិនព្រមកែប្រែ** ឬ**បញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ** មាត្រា ២២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

ប្រសិនបើជនត្រូវចោទ ដែលត្រូវបានដាក់ស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការនោះជនត្រូវចោទជាប់កាតព្វកិច្ចដោយចៅក្រមស៊ើបសួរ។ ហេតុនេះ បើសិនមានការគេចវេសពីកាតព្វកិច្ចដោយចេតនា អាចនឹងត្រូវដាក់ទណ្ឌកម្ម។ ក្នុងករណីនេះ មាត្រា ២៣០[79] អនុញ្ញាតឲ្យចៅ-ក្រមស៊ើបសួរឃុំខ្លួនជនត្រូវចោទបណ្ដោះអាសន្នបាន ទោះបីជា ទោសជាប់ពន្ធនាគារដែលត្រូវរងនោះមានថិរវេលាប៉ុន្មានក៏ដោយ ហើយទោះបីជាជនត្រូវចោទបានជាប់ឃុំបណ្ដោះអាសន្នអស់រយៈពេលអតិប្បបរមា ដែលមានចែងនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌនេះក៏ដោយ។ ប៉ុន្តែ រយៈពេលឃុំខ្លួនបណ្ដោះអាសន្ន ក្នុងករណីនេះគឺ ៤ខែ យ៉ាងយូរសម្រាប់នីតិជន និង ២ខែ យ៉ាងយូរសម្រាប់អនីតិជន ដោយពុំមានការបែងចែកប្រភេទបទល្មើសចោទប្រកាន់ទេ (មាត្រា ២៣០ កថាខណ្ឌចុងក្រោយនៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**២.៨.ការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ**

ក្រមនីតិវិធីព្រហ្មទណ្ឌ បានផ្ដល់សិទ្ធិឲ្យព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី ឬមេធាវី ក្នុងការស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបាន។

[78]មាត្រា ២២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[79]មាត្រា ២៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ២.៨.១.ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា

គ្រប់ពេលវេលានៃការស៊ើបសួរ ព្រះរាជអាជ្ញាអាចស្នើសុំឲ្យចៅក្រមស៊ើបសួរធ្វើកិច្ចស៊ើបសួរណាមួយ ដែលខ្លួនយល់ឃើញថាមានប្រយោជន៍។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមសេចក្តីសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេនោះ ចៅក្រមរូបនេះ ត្រូវសម្រេចតាមដីកាបដិសេធក្នុងរយៈពេល ១៥ថ្ងៃ។ ដីកាសម្រេចនេះ ត្រូវមានសំអាងហេតុ ហើយត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាក្នុងចិរវេលាយ៉ាងឆាប់បំផុត។

ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ១៥ថ្ងៃទេ ព្រះរាជអាជ្ញា អាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ទៅសភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរបាន មាត្រា ១៣២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ២.៨.២. ការស្នើសុំឲ្យបំពេញកិច្ចដោយជនត្រូវចោទ ឬមេធាវីការពារជនត្រូវចោទ

នៅគ្រប់ពេលនៃការស៊ើបសួរ ជនត្រូវចោទអាចសុំឲ្យចៅក្រមស៊ើបសួរធ្វើការសួរចម្លើយខ្លួន ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឬសាក្សី សួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ពាក្យសុំនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរមិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១ខែ បន្ទាប់ពីពេលទទួលពាក្យសុំ។ ដីកានេះត្រូវតែមានសំអាងហេតុ និងត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ជនត្រូវចោទ ឬមេធាវីការពារក្តីឲ្យជនត្រូវចោទ។

ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ១ខែទេ ជនត្រូវចោទអាចប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ[៨០]។

### ២.៨.៣.ការស្នើសុំឲ្យបំពេញកិច្ច ដោយដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីការពារដើមបណ្តឹងរដ្ឋប្បវេណី

នៅគ្រប់ពេលនៃការស៊ើបសួរ ដើមបណ្តឹងរដ្ឋប្បវេណីអាចសុំដល់ចៅក្រមស៊ើបសួរឲ្យស្តាប់ចម្លើយរបស់ខ្លួន ស្តាប់ចម្លើយសាក្សី សួរចម្លើយជនត្រូវចោទដោយសួរតទល់គ្នា ឬចុះទៅដល់ទីកន្លែងកើតហេតុ។ ពាក្យសុំនេះ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ ប្រសិនបើចៅក្រមស៊ើបសួរ មិនព្រមធ្វើតាមពាក្យសុំនេះទេ ចៅក្រមរូបនេះ ត្រូវចេញដីកាបដិសេធក្នុងរយៈពេល ១ខែ ក្រោយពេលទទួលពាក្យសុំ។ ដីកានេះ ត្រូវតែមានសំអាងហេតុ ហើយត្រូវជូនដំណឹងជាបន្ទាន់ដល់ព្រះរាជអាជ្ញា និងដល់ដើមបណ្តឹងរដ្ឋប្បវេណី ឬមេធាវីការពារក្តីឲ្យដើមបណ្តឹងរដ្ឋប្បវេណី។

[៨០] មាត្រា ១៣៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ប្រសិនបើចៅក្រមស៊ើបសួរ មិនបានសម្រេចក្នុងរយៈពេល ១ខែទេ ដើមបណ្ដឹងរដ្ឋប្បវេណី អាចប្ដឹងដោយផ្ទាល់ តាមរយៈពាក្យសុំដល់សភាស៊ើបសួរ ដែលសម្រេចជំនួសចៅក្រមស៊ើបសួរ មាត្រា ១៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**កថាខណ្ឌទី៣៖ ការបិទការស៊ើបសួរ**

ការបញ្ចប់ការស៊ើបសួរ គឺជាការបញ្ចប់នូវបេសកកម្មរបស់ចៅក្រមស៊ើបសួរ ដែលទទួលបន្ទុកធ្វើការស៊ើបសួរ។ ការបញ្ចប់ពីការទទួលបន្ទុកនៃការស៊ើបសួរនេះ បានស្ដែងឡើងតាមរយៈដីកាដំណោះស្រាយ។ ដីកាដំណោះស្រាយនេះ អាចជា **ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ** ឬ**ជាដីកាលើកលែងការចោទប្រកាន់** (ដោយចេញជាលិខិតជូនព័ត៌មាន ឬជូនដំណឹង) ទៅព្រះរាជ-អាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវី ដើម្បីត្រួតពិនិត្យ និងឆ្លើយតប។

**៣.១.ការសន្និដ្ឋានបញ្ជូនរបស់ចៅក្រមស៊ើបសួរ**

ការសន្និដ្ឋានបញ្ជូនរឿង ឲ្យត្រួតពិនិត្យផ្ទាល់ មិនមែនជាដីកាដំណោះស្រាយទេ។ ចៅក្រមស៊ើបសួរចេញដីកាសន្និដ្ឋាននេះ ដើម្បីបញ្ចប់កិច្ចស៊ើបសួររបស់ខ្លួន និងត្រូវបញ្ជូនមកព្រះរាជអាជ្ញាតាមរយៈដីកាបញ្ជូនរឿងឲ្យពិនិត្យទាំងមូល ក្នុងករណីនេះ ព្រះរាជអាជ្ញាធ្វើសេចក្ដីសន្និដ្ឋានស្ថាពរដើម្បីជាការឆ្លើយតបទៅចៅក្រមស៊ើបសួរវិញ ដោយឡែក ចំពោះការឆ្លើយតបរបស់ព្រះរាជអាជ្ញាអាចជាការយល់ព្រម ឬមិនយល់ព្រមទៅលើដីកាដំណោះស្រាយ (ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះផ្ទាល់ ឬដីកាលើកលែងចោទប្រកាន់) ឬព្រះរាជអាជ្ញា ស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរបន្ថែម។

**៣.២.ការសន្និដ្ឋានដោយព្រះរាជអាជ្ញា**

ក្រោយពីបានទទួលសំណុំរឿង ពីចៅក្រមស៊ើបសួររួចហើយ ព្រះរាជអាជ្ញា ត្រូវធ្វើសេចក្ដីសន្និដ្ឋានរបស់ខ្លួនមួយជាលាយលក្ខណ៍អក្សរ ដែលទាញចេញពីការពិនិត្យសំណុំរឿងទាំងមូលក្នុងរយៈពេល ២ថ្ងៃ គិតចាប់ពីពេលដែលទទួលបានសំណុំរឿង រួចត្រូវបញ្ជូនទៅចៅក្រមស៊ើបសួរទាំងសេចក្ដីសន្និដ្ឋានរបស់ខ្លួន។ សេចក្ដីសន្និដ្ឋានរបស់ព្រះរាជអាជ្ញា ពុំមានកម្លាំងចាប់បង្ខំឲ្យចៅក្រមស៊ើបសួរ យល់ស្របតាមនោះទេ។ តែប្រសិនបើព្រះរាជអាជ្ញា យល់ឃើញថា សំណុំរឿងមិនទាន់ចប់សព្វគ្រប់ នោះព្រះរាជអាជ្ញា នឹងបញ្ជូនសំណុំរឿងនេះ ទៅចៅក្រមស៊ើបសួរវិញ និងស្នើសុំឲ្យបើកការស៊ើបសួរបន្ថែម តាមរយៈដីកាបង្គាប់ឲ្យស៊ើបសួរបន្ថែម ព្រះរាជអាជ្ញា ត្រូវគោរពតាមបញ្ញត្តិមាត្រា ១៣២ (ការស្នើសុំឲ្យបំពេញកិច្ចដោយព្រះរាជអាជ្ញា នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ម៉្យាងវិញទៀត ក្នុងរយៈពេល ១៥ថ្ងៃ ប្រសិនបើជនត្រូវចោទ ត្រូវឃុំខ្លួន និង ១ខែ ក្នុងករណីជនត្រូវចោទនៅក្រៅឃុំ គិតពីថ្ងៃដែលព្រះរាជអាជ្ញាបានទទួលសំណុំរឿង ដីកាសន្និដ្ឋានស្ថាពរត្រូវ

ធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ។ នៅក្នុងដីកាសន្និដ្ឋានស្ថាពរនេះ ព្រះរាជអាជ្ញាអាចប្តឹងសុំឲ្យចៅក្រមស៊ើបសួរ **បញ្ជូនខ្លួនជនត្រូវចោទ ទៅកាន់តុលាការជំនុំជម្រះ ឬក៏លើកលែងចោទប្រកាន់**[៨១]។

### កថាខណ្ឌទី៤៖ ដីកាដំណោះស្រាយ

ចៅក្រមស៊ើបសួរ បិទការស៊ើបសួររបស់ខ្លួនដោយចេញដីកាដំណោះស្រាយ។ ដីកានេះអាចជាដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ឬជាដីកាលើកលែងចោទប្រកាន់។

#### ៤.១.ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ

ក្នុងករណីនេះ ចៅក្រមស៊ើបសួរបញ្ជូនជនត្រូវចោទទៅតុលាការដើម្បីជំនុំជម្រះពីបទឧក្រិដ្ឋ ឬបទមជ្ឈិម ដោយចៅក្រមស៊ើបសួរ ត្រូវរៀបរាប់អំពើដែលត្រូវចោទប្រកាន់ និងឈ្មោះបទល្មើសតាមច្បាប់។ ដីកានេះ ក៏មានអានុភាពបញ្ចប់សមត្ថកិច្ចរបស់ចៅក្រមស៊ើបសួរ ពីសំណុំរឿងបញ្ចប់ការត្រួតពិនិត្យតាមផ្លូវតុលាការ និងបញ្ចប់ការឃុំខ្លួនបណ្តោះអាសន្នផងដែរ។

ម៉្យាងវិញទៀត ចៅក្រមស៊ើបសួរអាចយោងតាមសេចក្តីសម្រេចដោយឡែកនៃដីកាដំណោះស្រាយ និងក្រោមលក្ខខណ្ឌមួយចំនួនដូចកំណត់នៅក្នុងមាត្រា ២០៥ (ករណីនៃការឃុំខ្លួនបណ្តោះអាសន្ន) ក្នុងករណីនេះ ចៅក្រមស៊ើបសួរ អាចរក្សាទុកជនត្រូចចោទ ឲ្យនៅក្រោមវិធានការឃុំខ្លួនបណ្តោះអាសន្ន រហូតដល់ពេលបង្ហាញខ្លួននៅចំពោះមុខតុលាការ[៨២]។

#### ៤.២.ដីកាលើកលែងចោទប្រកាន់

ចៅក្រមស៊ើបសួរ ចេញដីកាលើកលែងចោទប្រកាន់ ឬមិនបញ្ជូនជននោះទៅចំពោះមុខសាលាជម្រះក្តីក្នុងករណីដែល៖

-អំពើប្រព្រឹត្តមិនមែនជាបទឧក្រិដ្ឋ ឬបទមជ្ឈិម ឬបទលហុ

-ជនប្រព្រឹត្តអំពើនោះនៅតែគេមិនស្គាល់

-គ្មានភស្តុតាងដាក់បន្ទុកគ្រប់គ្រាន់លើជនត្រូវចោទ។

មួយវិញទៀត បើក្នុងករណីរលត់បណ្តឹងអាជ្ញា ដោយមូលហេតុដូចមានកំណត់ក្នុងមាត្រា ៧ (ការរលត់នៃបណ្តឹងអាជ្ញា) ក៏ជាមូលហេតុនៃការថ្លឹងថ្លែងក្នុងការលើកលែងការចោទប្រកាន់ផងដែរ។ ចំពោះការលើកលែងចោទប្រកាន់ អាចជាការលើកលែងទាំងស្រុង ឬមួយផ្នែក គឺបានន័យថាទាក់ទងអំពើទាំងអស់ដែលបានដាក់ឲ្យចៅក្រមស៊ើបសួរពិនិត្យ និងស្វែងរកទៅលើបុគ្គល ឬមានតែ

---

[៨១] មាត្រា ២៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨២] មាត្រា ២៤៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

មួយផ្នែកនៃអំពើរបស់ជននោះ។

**បញ្ជាក់:** ដីកានេះ នឹងមានអានុភាពជាធរមាន នៅពេលដែលផុតថិរវេលាប្ដឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា ដែលត្រូវប្ដឹងទៅសភាស៊ើបសួរនៃសភាព្រហ្មទណ្ឌ នៃសាលាឧទ្ធរណ៍ លើកលែងតែព្រះរាជអាជ្ញាយល់ព្រមតាមដីកាលើកលែងចោទប្រកាន់នោះដែរ។

**កថាខណ្ឌទី៥៖ ការប្ដឹងអំពីសេចក្ដីសម្រេចរបស់ចៅក្រមស៊ើបសួរ**

ក្រោយពេលចៅក្រមបញ្ចប់ការស៊ើបសួរ ឬបិទការស៊ើបសួរ របស់ខ្លួនរួចហើយជាកិច្ចបន្ទាប់ចៅក្រមស៊ើបសួររូបនេះ ត្រូវជូនព័ត៌មាន ឬជូនដំណឹងស្ដីពីការបិទការស៊ើបសួរ ដល់គ្រប់ភាគីពាក់ព័ន្ធក្នុងសំណុំរឿងព្រហ្មទណ្ឌ ហើយភាគីណាមួយមិនសុខចិត្តចំពោះសេចក្ដីសម្រេចផ្សេងៗ របស់ចៅក្រមស៊ើបសួរ។ ចំពោះការប្ដឹងនេះ អាចជាការប្ដឹងសុំមោឃភាពកិច្ចនៃនីតិវិធី ការប្ដឹងឧទ្ធរណ៍ ឬការប្ដឹងផ្ទាល់ទៅសភាស៊ើបសួរ ដើម្បីឲ្យសម្រេចជំនួសចៅក្រមស៊ើបសួរ។

**៥.១.ការប្ដឹងសុំមោឃភាពកិច្ចនៃនីតិវិធី**

មានតែសភាស៊ើបសួរប៉ុណ្ណោះ ដែលមានសមត្ថកិច្ច ដើម្បីពិនិត្យមោឃភាពនៃលិខិតនៃកិច្ចនីតិវិធី។ កាលណាចៅក្រមស៊ើបសួរយល់ឃើញថា លិខិតណាមួយនៃកិច្ចនីតិវិធីមានមោឃភាព ចៅក្រមស៊ើបសួររូបនេះ ប្ដឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុភ្ជាប់មកជាមួយ និងជូនដំណឹងដល់ព្រះរាជអាជ្ញា ជនត្រូវចោទ និងដើមបណ្ដឹងរដ្ឋប្បវេណី។ ប្រសិនបើព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី យល់ឃើញថា លិខិតណាមួយនៃកិច្ចនីតិវិធីមានមោឃភាព ប្ដឹងទៅសភាស៊ើបសួរ តាមដីកាដោយមានសំអាងហេតុភ្ជាប់មកជាមួយ និងជូនព័ត៌មានដល់ចៅក្រម ស៊ើបសួរ។ ពាក្យនេះ ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរភ្លាមនោះ ក្រឡាបញ្ជីសុំឲ្យចៅក្រមស៊ើបសួរបញ្ជូនសំណុំរឿងនៃកិច្ចនីតិវិធីមកឲ្យខ្លួនភ្លាម[៨៣]។

មានតែដីកា ដែលមិនអាចប្ដឹងឧទ្ធរណ៍បានទេ ដែលអាចជាកម្មវត្ថុនៃបណ្ដឹងឧទ្ធរណ៍បាន មាត្រា ២៥៣ កថាខណ្ឌចុងក្រោយ។ ចំពោះចំណុចនេះពុំមែនមានន័យថា មានតែដីកាទេដែលអាចជាកម្មវត្ថុនៃការប្ដឹងសុំមោឃភាពបាន ក្រៅពីដីកាក៏មានលិខិតនៃកិច្ចនីតិវិធីផ្សេងទៀតផងដែរ ដូចជាកំណត់ហេតុជាដើម ក៏អាចជាកម្មវត្ថុនៃការប្ដឹងសុំមោឃភាពបានដែរ។

យោងតាមមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌកំណត់ពីករណីដែលនាំឲ្យមានមោឃភាពចំពោះនីតិវិធីស៊ើបសួរ។ វិធាន និងទម្រង់ការដែលចែងដោយមាត្រាខាងក្រោម ស្ដីពីបញ្ញត្តិទូទៅនៃនីតិវិធីស៊ើបសួរមានលក្ខខណ្ឌដាច់ខាតត្រូវតែគោរពតាម បើពុំដូច្នេះទេនាំឲ្យមានមោឃភាពនៃនីតិវិធី៖

[៨៣] មាត្រា ២៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-មាត្រា ១២២ (ការបើកការស៊ើបសួរ)

-មាត្រា ១២៣ (សមត្ថកិច្ចដែនដី)

-កខថាខណ្ឌទី៣ នៃមាត្រា ១២៤ (ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ)

-កខថាខណ្ឌទី ១ និងទី ២ នៃមាត្រា ១២៥ (វិសាលភាពនៃបណ្ដឹង) ក្នុងករណីនេះបើសិនជាចៅក្រមស៊ើបសួរ ធ្វើការស៊ើបសួរលើអង្គហេតុមិនមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ដោយពុំមានដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមទេ។

-មាត្រា ១២៨ (ជំនួយរបស់ក្រឡាបញ្ជី) ឬការឲ្យក្រឡាបញ្ជី បំពេញកិច្ចស៊ើបសួរជំនួសចៅក្រម នៃក្រមនេះ។

នាំឲ្យមានមោឃភាពផងដែរ កាលណាការបំពានវិធាន ឬទម្រង់ការសំខាន់ណាមួយដែលចែងដោយក្រមនេះ ឬបញ្ញត្តិទាំងឡាយស្ដីពីនីតិវិធីព្រហ្មទណ្ឌ ធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍របស់ភាគីដែលទទួលរងការបំពាននេះ។ **ឧទាហរណ៍** ការសួរចម្លើយជនត្រូវចោទ ជាអនីតិជនពុំមានមេធាវីអម (មាត្រា ១៤៣ កថាខណ្ឌទី ៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ក្រៅពីមាត្រា ២៥២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏មានមាត្រា ១០៩ និងមាត្រា ១១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ក៏បញ្ញត្តិពីករណីមោឃភាពនៃលិខិតនៃនីតិវិធី ដែលបានធ្វើនៅក្នុងដំណាក់កាលនៃការស៊ើបអង្កេតករណីជាក់ស្ដែង និងការស៊ើបអង្កេតករណីបឋមដែរ។ យោងតាមមាត្រា ២៥៣ កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ការពិនិត្យមោឃភាពនៃលិខិតនៃនីតិវិធី ជាសមត្ថកិច្ចរបស់សភាស៊ើបសួរ។ បញ្ញត្តិនេះ ពុំបានកម្រិតថា មានតែលិខិតនៃនីតិវិធីស៊ើបសួរប៉ុណ្ណោះទេ ដែលស្ថិតនៅក្នុងសមត្ថកិច្ចរបស់សភាស៊ើបសួរនោះ។ ហេតុនេះ នាំឲ្យអាចសន្និដ្ឋានបានថា ការសុំមោឃភាពលិខិតផ្សេងៗ ទៀតនៃនីតិវិធី។

### ៥.២.អ្នកមានសមត្ថកិច្ចប្ដឹងទៅសភាស៊ើបសួរ

អ្នកដែលអាចប្ដឹងទៅសភាស៊ើបសួរ ឲ្យពិនិត្យពីមោឃភាពនៃលិខិតនៃនីតិវិធីមានដូចជា៖ ចៅក្រមស៊ើបសួរខ្លួនឯង ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្ដឹងរដ្ឋប្បវេណី និងមេធាវីរបស់ជនត្រូវចោទ ឬដើមបណ្ដឹងរដ្ឋប្បវេណីផងដែរ។ ពាក្យសុំឲ្យពិនិត្យមោឃភាព ត្រូវធ្វើជាលាយលក្ខណ៍អក្សរ និងមានសំអាងហេតុ ហើយពាក្យសុំនេះ ត្រូវចុះបញ្ជីនៅការិយាល័យក្រឡាបញ្ជីនៃសភាស៊ើបសួរ និងក្រឡាបញ្ជីសភាស៊ើបសួរ សុំឲ្យចៅក្រមស៊ើបសួរ បញ្ជូនសំណុំរឿងនៃនីតិវិធីមកឲ្យខ្លួនភ្លាម។

### ៥.៣.សេចក្ដីសម្រេចរបស់សភាស៊ើបសួរ

សេចក្ដីសម្រេចរបស់សភាស៊ើបសួរ មានចំនួនពីរយ៉ាងគឺ

#### ៥.៣.១.សភាស៊ើបសួរសម្រេចមិនទទួលពាក្យប្ដឹងសុំមោឃកម្ម

សភាស៊ើបសួរ អាចប្រកាសមិនទទួលពាក្យសុំមោឃកម្ម ក្នុងករណីដូចតទៅ៖

-ពាក្យប្តឹងសុំគ្មានសំអាងហេតុ

-ពាក្យប្តឹងសុំទាក់ទងនឹងដីកា ដែលអាចប្តឹងឧទ្ធរណ៍បាន

-ពាក្យប្តឹងសុំគ្មានមូលកភាពយ៉ាងជាក់ស្តែង។

សេចសម្រេចរបស់សភាស៊ើបសួរ មិនអាចតវ៉ាបានទេ។ មានន័យថា ក្នុងករណីនេះ ការសម្រេចរបស់សភាស៊ើបសួរ បិទផ្លូវតវ៉ា និងជាសេចក្តីសម្រេចចុងក្រោយផងដែរ។ កាលណាពាក្យសុំប្តឹងសុំត្រូវបានប្រកាសមិនអាចទទួលបានទេ សំណុំរឿងត្រូវបង្វិលភ្លាម ទៅចៅក្រមស៊ើបសួរ[៩៤]។

## ៥.៣.២.សភាស៊ើបសួរសម្រេចទទួលពាក្យប្តឹងសុំមោឃកម្ម

ប្រសិនបើសភាស៊ើបសួរ សម្រេចថា មានមោឃកម្មលើលិខិតនៃនីតិវិធីនោះ ។ ក្នុងករណីនេះ កិច្ច ឬលិខិត ដែលត្រូវចាត់ទុកជាមោឃៈ ត្រូវដកចេញពីសំណុំរឿង ហើយត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជី នៃសភាស៊ើបសួរ (មាត្រា ២៨០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ កាលណាបើមានការប្រកាសមោឃកម្ម សភាស៊ើបសួរអាច៖

-បង្វិលសំណុំរឿងទៅចៅក្រមស៊ើបសួរវិញ

-ដកសមត្ថកិច្ចចៅក្រមស៊ើបសួរ ហើយបញ្ជូនសំណុំរឿងទៅចៅក្រមស៊ើបសួរម្នាក់ផ្សេងទៀត ឬ

-បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងនោះ (មាត្រា ២៨១ នៃក្រមនីតវិធីព្រហ្មទណ្ឌ)។

ក្នុងករណីនេះ សភាស៊ើបសួរប្រគល់ភារកិច្ចទៅសមាជិករបស់ខ្លួនម្នាក់ឲ្យប្រើប្រាស់អំណាចជាចៅក្រមស៊ើបសួរ។ ប៉ុន្តែសមាជិកនេះ ពុំមានសិទ្ធិអំណាចទាក់ទិននឹងការបិទការស៊ើបសួរទេ។ ក្រោយពីការបញ្ចប់ការស៊ើបសួរហើយ ប្រធានសភាស៊ើបសួរ កំណត់កាលបរិច្ឆេទនៃសវនាការដើម្បីសម្រេចចេញ **សាលដីកាដំណោះស្រាយ** តាមមាត្រា ២៤៧ ដល់មាត្រា ២៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ក្នុងករណីនេះដែរ ប្រសិនបើសភាស៊ើបសួរសម្រេចដោះលែងជនត្រូវចោទ ដែលជាប់ឃុំ ឲ្យមានសេរីភាពឡើងវិញ សេចក្តីសម្រេចរបស់សភាស៊ើបសួរ មានអានុភាពអនុវត្តភ្លាម[៩៥]។

ការលះបង់ដោយភាគីណាមួយ ក្នុងករណីទាមទារមោឃភាព ដោយបំពាន ឬទម្រង់ការសំខាន់ណាមួយ បានធ្វើឲ្យប៉ះពាល់ដល់ផលប្រយោជន៍ នៃភាគីណាមួយ ភាគីនេះ អាចបោះបង់មិនលើកយកមោឃភាពមកសំអាង។ ការបោះបង់នេះ ត្រូវតែពិនិត្យដោយចៅក្រមស៊ើបសួរនៅក្នុងកំណត់ហេតុ។

---

[៩៤] មាត្រា ២៧៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៩៥] មាត្រា ២៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៥.៤.បណ្តឹងឧទ្ធរណ៍ចំពោះដីការបស់ចៅក្រមស៊ើបសួរ

ដូចមានរៀបរាប់ជូននៅខាងដើមរួចហើយ គឺមានតែដីកាសម្រេចទេ ដែលអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បាន ដោយឡែក ដីកាបង្គាប់ចេញដោយចៅក្រមស៊ើបសួរ ពុំអាចជាកម្មវត្ថុនៃការប្តឹងឧទ្ធរណ៍បានឡើយ។ ប៉ុន្តែ សិទ្ធិក្នុងការប្តឹងឧទ្ធរណ៍ត្រូវបានកម្រិត ចំពោះជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី។

ព្រះរាជអាជ្ញា និងអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ អាចប្តឹងឧទ្ធរណ៍ចំពោះគ្រប់ដីកាសម្រេចទាំងអស់ របស់ចៅក្រមស៊ើបសួរ (មាត្រា ២៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ប៉ុន្តែជនត្រូវចោទ និងដើមបណ្តឹងរដ្ឋប្បវេណី អាចប្តឹងឧទ្ធរណ៍បានតែចំពោះដីកាសម្រេចដែលកំណត់រៀបរាប់នៅក្នុងមាត្រា ២៦៧ និងមាត្រា ២៦៨ តែប៉ុណ្ណោះ។

យោងតាមមាត្រា ២៦៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ នាំឲ្យអាចសន្និដ្ឋានបានថា ដើមបណ្តឹងរដ្ឋប្បវេណីមិនអាចប្តឹងឧទ្ធរណ៍ នឹងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នជនត្រូវចោទបានឡើយ ព្រោះថា ដីកាសម្រេចនេះ មិនត្រូវបានរៀបរាប់ដោយមាត្រា ២៦៨ ឡើយ។

ក្រៅពីនេះ គ្រប់បុគ្គលដែលពាក់ព័ន្ធនឹងនីតិវិធីព្រហ្មទណ្ឌ ជាពិសេសការចាប់យកវត្ថុតាង ក៏មានសិទ្ធិប្តឹងឧទ្ធរណ៍ផងដែរ ក្នុងករណីដែលចៅក្រមស៊ើបសួរ សម្រេចមិនព្រមប្រគល់វត្ថុដែលខ្លួនស្នើសុំប្រគល់ឲ្យខ្លួនវិញ[៨៦]។

រយៈពេលបណ្តឹងឧទ្ធរណ៍គឺ ១ខែ សម្រាប់អគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ យ៉ាងយូរគិតពីពេលប្រកាសដីកា ៥ថ្ងៃ សម្រាប់ព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី និងជនដែលសុំឲ្យប្រគល់វត្ថុចាប់យកឲ្យខ្លួនវិញ (មាត្រា ២៧០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ ត្រូវធ្វើនៅការិយាល័យក្រឡាបញ្ជី នៃតុលាការជាន់ដំបូង (មាត្រា ២៧២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ កាលណា បានទទួលបណ្តឹងឧទ្ធរណ៍ ក្រឡាបញ្ជីជូនដំណឹងភ្លាមដល់ ចៅក្រមស៊ើបសួរ ហើយក្រឡាបញ្ជីនៃចៅក្រមស៊ើបសួរ ត្រូវរៀបចំ និងបញ្ជូនសំណុំរឿងទៅសភាស៊ើបសួរ ដោយមានសេចក្តីចម្លងនៃលិខិតប្តឹងឧទ្ធរណ៍នៅការិយាល័យក្រឡាបញ្ជី នៃសភាស៊ើបសួរ រយៈពេល ៥ថ្ងៃ បន្ទាប់ពីមានបណ្តឹងឧទ្ធរណ៍ លើកលែងតែក្នុងកាលទេសៈ ដែលមិនអាចជំនះបាន[៨៧]។ ដោយឡែក ការដាក់ពាក្យបណ្តឹងឧទ្ធរណ៍ពុំនាំឲ្យនីតិវិធី នៃការស៊ើបសួរត្រូវផ្អាកទេ លើកលែងតែបណ្តឹងឧទ្ធរណ៍ ចំពោះដីកាដំណោះស្រាយរបស់ចៅក្រមស៊ើបសួរ។ ប៉ុន្តែ ប្រធាន

---

[៨៦] មាត្រា ២៦៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨៧] មាត្រា ២៧៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សភាស៊ើបសួរ អាចសម្រេចឲ្យផ្អាកនីតិវិធី នៃការស៊ើបសួរបាន ក្នុងករណីខ្លះ។ សេចក្តីសម្រេចនេះ មិនអាចប្តឹងតវ៉ាបានឡើយ[៨៨]។

បណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា អំពីដីកាសម្រេចដោះលែងឲ្យនៅក្រៅឃុំ ឬលើកលែងចោទប្រកាន់ជនត្រូវចោទ ដែលនៅជាប់ឃុំ ជនត្រូវចោទនេះ ត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតដល់មានសេចក្តីសម្រេចពីសភាស៊ើបសួរ[៨៩]។ ប្រសិនបើមានបណ្តឹងឧទ្ធរណ៍ ពីដីកាលើកលែងចោទប្រកាន់ ហើយសភាស៊ើបសួរទទួលថា បណ្តឹងឧទ្ធរណ៍នេះ មានភាពត្រឹមត្រូវ សភាស៊ើបសួរ បន្តការស៊ើបសួរដោយខ្លួនឯងលើរឿងក្តីនោះ មានន័យថា សភាស៊ើបសួរសម្រេចបិទការស៊ើបសួរតាម **សាលដីកាបញ្ជូនរឿងទៅជំនុំជម្រះ**។ ដោយឡែក សាលដីកានេះ ពុំអាចប្តឹងសាលទុក្ខទៅតុលាការកំពូលបានឡើយ យោងតាមមាត្រា ៤១៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៥.៥.ការប្តឹងផ្ទាល់ទៅសភាស៊ើបសួរ

ការប្តឹងផ្ទាល់ទៅសភាស៊ើបសួរ ត្រូវបានបញ្ញត្តិនៅក្នុងក្រមនីតិវិធីព្រហ្មទណ្ឌ ទៅតាមប្រភេទនៃកិច្ចស៊ើបសួរនីមួយៗ ក្នុងករណី ដែលចៅក្រមស៊ើបសួរ ពុំបានសម្រេចលើពាក្យសុំរបស់អ្នកស្នើសុំក្នុងរយៈពេលដែលច្បាប់តម្រូវឲ្យចៅក្រមស៊ើបសួរ ចេញសេចក្តីសម្រេចរបស់ខ្លួន។ កាលណាសភាស៊ើបសួរ ត្រូវបានប្តឹងដោយផ្ទាល់តាមរយៈពាក្យសុំ ក្រឡាបញ្ជីនៃសភាស៊ើបសួរ សុំឲ្យក្រឡា-បញ្ជីនៃចៅក្រមស៊ើបសួរ ផ្ញើមកឲ្យខ្លួននូវសំណុំរឿងនៃនីតិវិធី ឬសំណុំរឿងបង្ការទុក យោងតាមមាត្រា ២៥៧ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ហេតុនេះ កាលប្តឹងផ្ទាល់នេះ ត្រូវធ្វើនៅការិយាល័យនៃសភាស៊ើបសួរ។

[៨៨] មាត្រា ២៧៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨៩] មាត្រា ២៧៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

## ផ្នែកទី២៖ ដំណាក់កាលចៅក្រមជំនុំជម្រះ

ការសម្រេចក្តីផ្តល់យុត្តិធម៌ ត្រូវធ្វើក្នុងនាមជាប្រជារាស្ត្រខ្មែរ តាមនីតិវិធី និងច្បាប់ជាធរមាន (មាត្រា ១២៩ នៃរដ្ឋធម្មនុញ្ញ)។ ដំណាក់កាលជំនុំជម្រះ គឺជាដំណាក់កាលដ៏សំខាន់មួយ បន្ទាប់ពីដំណាក់កាលស៊ើបសួរបានបញ្ចប់ទៅ។

### កថាខណ្ឌទី១៖ សមត្ថកិច្ចរបស់តុលាការ

ក៏ដូចជាករណី ចៅក្រមស៊ើបសួរដែរ តុលាការមានសមត្ថកិច្ចខាងដែនដី ក្នុងការជំនុំជម្រះក្នុងរឿងក្តីព្រហ្មទណ្ឌគឺ តុលាការនាទីកន្លែងបទល្មើស តុលាការនាលំនៅឋានរបស់ជនត្រូវចោទ ឬតុលាការនាទីកន្លែងចាប់ខ្លួនជនជាប់ចោទ (មាត្រា ២៩០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីដែលមានតុលាការពីរ ឬច្រើន ស្ថិតនៅក្នុងមណ្ឌលនៃសាលាឧទ្ធរណ៍តែមួយ បានទទួលពាក្យបណ្តឹងលើរឿងក្តីតែមួយដូចគ្នា ប្រធានសាលាឧទ្ធរណ៍ចាត់តាំងតុលាការដែលនឹងត្រូវទទួលបន្ទុកលើសំណុំរឿង។ វិវាទសមត្ថកិច្ចដែនដីរវាងតុលាការច្រើន ដែលមានថ្នាក់ស្មើគ្នា ត្រូវសម្រេចដោយប្រធានតុលាការជាន់ខ្ពស់។ ការសម្រេចនេះបិទផ្លូវតវ៉ា។

សមត្ថកិច្ចចំពោះជនជាប់ចោទ ត្រូវពន្លាតរហូតដល់សហចារី អ្នកផ្តើមគំនិត និងអ្នកសមគំនិតទាំងអស់។ នៅក្នុងការជំនុំជម្រះបទល្មើសព្រហ្មទណ្ឌ សាលាដំបូងសម្រេចជាក្រុមសមូហភាពដែលមានចៅក្រមបីរូប ចំពោះបទឧក្រិដ្ឋ ព្រមទាំងបទមជ្ឈិម និងបទលហុដែលជាប់ទាក់ទង។ ប៉ុន្តែបើជាការជំនុំជម្រះបទល្មើសមជ្ឈិម និងបទលហុវិញ សាលាដំបូងសម្រេចជាចៅក្រមទោល (មាត្រា ២៨៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

តុលាការសម្រេចសេចក្តីតែទៅលើអំពើទាំងឡាយណា ដែលមានបង្ហាញនៅក្នុងសាលដីកាបញ្ជូន ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះ ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬកំណត់ហេតុបង្ហាញខ្លួនភ្លាម (មាត្រា ៣៤៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ មានន័យថា តុលាការ ពុំអាចសម្រេចសេចក្តីទៅលើអង្គហេតុផ្សេងពីនេះបានឡើយ។ ក្នុងករណីនេះផងដែរ ប្រសិនបើចៅក្រមទោលយល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងជាបទល្មើសឧក្រិដ្ឋ តុលាការត្រូវបង្វិលសំណុំរឿងជូនព្រះរាជអាជ្ញា ដើម្បីបើកការស៊ើបសួរ។ ប៉ុន្តែបើសិនជាចៅក្រមសមូហភាព យល់ឃើញថា អង្គហេតុដែលត្រូវបានប្តឹងជាបទមជ្ឈិម ឬបទលហុ តុលាការនោះ នៅតែមានសមត្ថកិច្ច ដើម្បីជនុំជម្រះសេចក្តីដដែល។

### កថាខណ្ឌទី២៖ ការប្តឹងទៅចៅក្រមជំនុំជម្រះ

ក្នុងរឿងក្តីព្រហ្មទណ្ឌ សាលាដំបូងត្រូវបានទទួលបណ្តឹងដោយ៖

-ដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរបស់សភាស៊ើបសួរ

-ដីកាបញ្ជូនទៅតុលាការជំនុំជម្រះដោយផ្ទាល់របស់ព្រះរាជអាជ្ញា

-កំណត់ហេតុស្តីពីការចូលបង្ហាញខ្លួនភ្លាម ដែលធ្វើដោយព្រះរាជអាជ្ញា។

គ្រប់បុគ្គល ដែលត្រូវបានបញ្ជូនទៅចំពោះមុខតុលាការតាមនីតិវិធីណាមួយដូចខាងលើនេះ មានឈ្មោះថា **ជាជនជាប់ចោទ**។ ដោយឡែក ចំពោះជនរងគ្រោះនៃបទល្មើស ក៏អាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការ ប្រសិនបើខ្លួនពុំទាន់បានតាំងខ្លួននៅឡើយនៅមុខចៅក្រមស៊ើបសួរ។

ក្នុងករណីនេះ អ្នកដែលមានឈ្មោះថា **ជាអ្នកទទួលខុសត្រូវរដ្ឋប្បវេណី** គឺបុគ្គលគ្រប់រូបដោយអនុវត្តតាមច្បាប់ ដែលត្រូវតែជួសជុលព្យសនកម្មដែលបណ្តាលឲ្យមានដល់ជនរងគ្រោះនៃបទល្មើស[៩០]។

**គួរបញ្ជាក់ថា:** តុលាការព្រហ្មទណ្ឌ អាចជំនុំជម្រះបានតែទៅលើជនដែលគេបញ្ជាឲ្យចូលខ្លួនក្នុងឋានៈជាជនជាប់ចោទប៉ុណ្ណោះ។ ដោយឡែក ចំពោះជនដែលគេកោះហៅមកធ្វើជាសាក្សីត្រូវបានគេរកឃើញថាជា ចារី សហចារី ឬជនសមគំនិត គេត្រូវគោរពតាមនីតិវិធីដូចបានរៀបរាប់ខាងលើ ពោលគឺតុលាការព្រហ្មទណ្ឌពុំអាចជំនុំជម្រះលើជនទាំងនោះតែម្តងទេ។

ជារួមមក សមត្ថកិច្ចជំនុំជម្រះរបស់តុលាការព្រហ្មទណ្ឌ គឺមានដែនកំណត់ត្រឹមអ្វីដែលគេបញ្ជូនមកខ្លួនតែប៉ុណ្ណោះ។ ទោះជាយ៉ាងនេះក្តី ចៅក្រមជំនុំជម្រះក៏នៅមានសេរីភាពក្នុងការកែប្រែបទល្មើសឲ្យត្រឹមត្រូវតាមអង្គហេតុនៃបទល្មើស។

### កថាខណ្ឌទី៣៖ នីតិវិធីជំនុំជម្រះ

#### ៣.១.នីតិវិធីមុនពេលសវនាការជំនុំជម្រះ

ក្នុងករណីនេះ ប្រធានតុលាការជាអ្នកកំណត់កាលបរិច្ឆេទនៃសវនាការ លើកលែងតែករណីនៃនីតិវិធីបង្ហាញខ្លួនភ្លាម។ ក្នុងការកំណត់កាលបរិច្ឆេទនេះ ប្រធានតុលាការ ត្រូវគោរពតាមរយៈពេលដែលមានចែងក្នុងមាត្រា ៤៥៧ និងមាត្រា ៤៦៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

តាមបញ្ញត្តិនៃមាត្រាខាងលើនេះ រយៈពេលរវាងការប្រគល់ដីកាកោះហៅជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលខ្លួននៅមុខតុលាការ ត្រូវកំណត់ដូចតទៅ៖

-១៥ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងដែនដីនៃតុលាការជាន់ដំបូង។

-២០ថ្ងៃ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋនៃទីកន្លែងមួយផ្សេងទៀតនៃដែនដីជាតិ។

-២ខែ ប្រសិនបើជនជាប់ចោទរស់នៅក្នុងរដ្ឋមួយជាប់ព្រំដែននៃព្រះរាជាណាចក្រកម្ពុជា។

---

[៩០]មាត្រា ២៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-៣ខែ ប្រសិនបើជនជាប់ចោទរស់នៅទីកន្លែងមួយផ្សេងទៀត។

ប៉ុន្តែក្នុងករណីជនជាប់ចោទ ត្រូវឃុំខ្លួនគ្មានរយៈពេលណាមួយត្រូវបានទាមទារឡើយ រវាងការប្រគល់ដីកាដល់ជនជាប់ចោទ និងថ្ងៃកំណត់ឲ្យចូលបង្ហាញខ្លួននៅមុខតុលាការ។

ម៉្យាងវិញទៀត ការកោះហៅដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ អ្នកបកប្រែ និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ធ្វើឡើងដោយព្រះរាជអាជ្ញា (មាត្រា ២៩៤ មាត្រា ២៩៥ និង មាត្រា ២៩៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅក្នុងករណី ដែលតុលាការទទួលបណ្តឹងដោយដីកាបញ្ជូនរបស់ចៅក្រមស៊ើបសួរ ឬសាលដីការបស់សភាស៊ើបសួរ និងលិខិតចម្លងដីកាបញ្ជូន ឬសាលដីកាបញ្ជូន ត្រូវភ្ជាប់ជាមួយនឹងដីកាកោះហៅ ដើម្បីប្រគល់ឲ្យជនជាប់ចោទ។ ប្រសិនបើមានមេធាវីជាដាច់ខាត ព្រះរាជអាជ្ញាត្រូវចេញលិខិតអញ្ជើញមេធាវីមកផងដែរ។

មិនត្រឹមតែប៉ុណ្ណោះទេ មេធាវីអាចពិនិត្យមើលសំណុំរឿង នៅការិយាល័យក្រឡាបញ្ជីនៃតុលាការ នៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជី។ មួយវិញទៀត មេធាវី ឬលេខារបស់មេធាវី (ជំនួយការ) អាចត្រូវបានអនុញ្ញាតដោយប្រធានតុលាការឲ្យធ្វើការចម្លងលិខិតនៃសំណុំរឿង ហើយការថតចម្លងនេះទៀតសោត គឺមេធាវីជាអ្នកចេញសោហ៊ុយ ដោយនៅក្រោមការត្រួតពិនិត្យរបស់ក្រឡាបញ្ជីផងដែរ (មាត្រា ៣១៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៣.២.នីតិវិធីនៃការសម្រេចមុនអង្គសេចក្តី

ក្រោយពីបានទទួលសំណុំរឿង ដើម្បីជំនុំជម្រះដល់អង្គសេចក្តី ក្រមនីតិវិធីព្រហ្មទណ្ឌបានអនុញ្ញាតឲ្យជនជាប់ចោទ និងមេធាវីរបស់ជននេះ អាចដាក់ពាក្យសុំឲ្យដោះលែងនៅក្រៅឃុំវិញបាន ដោយយោងតាមមាត្រា ៣០៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ ចំពោះការសុំដោះលែងឲ្យនៅក្រៅឃុំនេះ ជនជាប់ចោទអាចស្នើសុំដោយផ្ទាល់មាត់នាពេលសវនាការ ឬធ្វើតាមលិខិតជាលាយលក្ខណ៍អក្សរ។ ប្រសិនបើពាក្យសុំធ្វើឡើងដោយផ្ទាល់មាត់នាពេលសវនាការ ក្រឡាបញ្ជីត្រូវកត់ត្រាចូលនៅក្នុងកំណត់ហេតុ។ ដោយឡែក នៅពេលមានពាក្យសុំនេះហើយ តុលាការត្រូវសម្រេចពីបញ្ហានេះក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវីរបស់ជននេះ និងព្រះរាជអាជ្ញាផងដែរ។ ចំពោះការសម្រេចនៅក្នុងករណីនេះ ត្រូវធ្វើឡើងជាសាលក្រម ក្នុងរយៈពេល **១០ថ្ងៃ** ក្រោយពីការសុំដោយផ្ទាល់មាត់ ឬក្រោយពីបានទទួលពាក្យសុំ ដែលធ្វើឡើងជាលាយលក្ខណ៍អក្សរ (មាត្រា ៣០៧) ការសម្រេចសេចក្តីនេះ តុលាការធ្វើឡើងដោយផ្អែកលើមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលមានចែងពីមូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន នៅដំណាក់កាលរបស់ចៅក្រមស៊ើបសួរ។ តុលាការអាចចេញសាលក្រម បង្គាប់ឲ្យដោះលែងជនជាប់ចោទឲ្យមានសេរីភាពវិញបាន តែជនជាប់ចោទ ត្រូវរក្សាទុកក្នុងពន្ធនាគារ រហូតដល់ផុតរយៈពេល សម្រាប់ប្តឹងឧទ្ធរណ៍ របស់ព្រះរាជអាជ្ញា លើកលែង

តែព្រះរាជអាជ្ញា យល់ព្រមឲ្យដោះលែងភ្លាមជាលាយលក្ខណ៍អក្សរ។

ប្រសិនបើព្រះរាជអាជ្ញា ធ្វើបណ្តឹងឧទ្ធរណ៍ នោះមានន័យថា ជនជាប់ចោទត្រូវរក្សាទុកនៅក្នុងពន្ធនាគាររហូតទាល់តែសាលាឧទ្ធរណ៍បានសម្រេចអំពីបណ្តឹងឧទ្ធរណ៍នេះ (មាត្រា ៣០៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៣.២.១.រយៈពេលបណ្តឹងឧទ្ធរណ៍របស់ព្រះរាជអាជ្ញា និងពិរុទ្ធជន

ទាក់ទិននឹងរឿងឃុំខ្លួន រយៈពេលបណ្តឹងឧទ្ធរណ៍មានចែងក្នុងមាត្រា ៣៨៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។ នៅក្នុងករណីរឿងឃុំខ្លួន ការប្តឹងឧទ្ធរណ៍ត្រូវតែធ្វើដោយព្រះរាជអាជ្ញា នៅក្នុងរយៈពេល ៤៨ម៉ោង ដោយឡែកសម្រាប់ពិរុទ្ធជនវិញ មានរយៈពេល ៥ថ្ងៃ ហើយរយៈពេលនេះផ្តើមគិតពីថ្ងៃដែលតុលាការសម្រេចឃុំខ្លួន។

ប្រសិនបើពុំមានបណ្តឹងសុំទេ (ពីព្រះរាជអាជ្ញា និងពិរុទ្ធជន) តុលាការក៏អាចបង្គាប់ឲ្យដោះលែងជនជាប់ចោទ ដែលកំពុងនៅជាប់ឃុំឲ្យមានសេរីភាពវិញបានដែរ ដោយយោងទៅលើមាត្រា ២០៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

### ៣.២.២.ការដោះលែងជនជាប់ចោទដោយតុលាការ

យោងតាមមាត្រា ៣០៦ (ការដោះលែងជនជាប់ចោទដែលជាប់ឃុំឲ្យមានសេរីភាពដោយឯកឯង) មានន័យថា នៅគ្រប់ពេលវេលា តុលាការអាចបង្គាប់ឲ្យដោះលែងជនជាប់ចោទដែលជាប់ឃុំ ឲ្យមានសេរីភាពវិញបាន ឬឲ្យបន្តការឃុំខ្លួនជនជាប់ចោទ ដោយយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

នៅក្នុងករណីនេះ គឺតុលាការអាចសម្រេចក្រោយពីបានស្តាប់ជនជាប់ចោទ មេធាវីជនជាប់ចោទ ព្រមទាំងព្រះរាជអាជ្ញាផងដែរ។

នីតិវិធីនាពេលសវនាការ គឺមានលក្ខណៈមិនខុសគ្នាពីនីតិវិធីនៃសវនាការ លើអង្គសេចក្តីទេ។ នីតិវិធីនេះ ក៏បានយកមកអនុវត្តដែរ ក្នុងរកណីដែលជនជាប់ចោទត្រូវបានចាប់តាមដីកាបង្គាប់ឲ្យចាប់ខ្លួនរបស់ចៅក្រមស៊ើបសួរ ក៏ប៉ុន្តែ សំណុំរឿងដែលកំពុងស្ថិតនៅក្រោមចំណាត់ការរបស់ចៅក្រមជំនុំជម្រះ។ ប្រសិនបើនៅក្នុងករណីនេះ ចៅក្រមជំនុំជម្រះត្រូវសម្រេចអំពីការឃុំខ្លួនបណ្តោះអាសន្ន ឬសម្រេចមិនឃុំខ្លួនជនត្រូវចោទតាមសាលក្រម។ ចំពោះក្រមនីតិវិធីពុំបានបញ្ញត្តិពីបញ្ហានេះទេ។ ប៉ុន្តែដោយហេតុថា សំណុំរឿងព្រហ្មទណ្ឌស្ថិតនៅក្នុងដំណាក់កាលជំនុំជម្រះ នោះមានន័យថា ចៅក្រមជំនុំជម្រះពុំអាចបញ្ជូនសំណុំរឿងឲ្យទៅចៅក្រមស៊ើបសួរវិញបានទេ ហើយសេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះ ក៏មិនអាចជាដីកាសម្រេចបានដែរ គឺមានតែសាលក្រមប៉ុណ្ណោះ។

### ៣.៣.នីតិវិធីនៃការបង្ហាញខ្លួនភ្លាម

កាលណាសម្រេចថា ត្រូវប្រើនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ព្រះរាជអាជ្ញាត្រូវ៖

-ពិនិត្យអត្តសញ្ញាណបុគ្គល ដែលគេបញ្ជូនមកឲ្យខ្លួន

-ឲ្យដំណឹងដល់ជននោះ អំពីរឿងហេតុ ដែលចោទប្រកាន់ និងឈ្មោះបទល្មើស

-ទទួលចម្លើយរបស់បុគ្គលនោះ ប្រសិនបើសាមីខ្លួនចង់និយាយ

-ធ្វើកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម។

ព្រះរាជអាជ្ញា ប្រាប់ជនជាប់ចោទថា ខ្លួនមានសិទ្ធិពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន ឬមានការចាត់តាំងឡើងដោយអនុលោមតាមច្បាប់ស្តីពីលក្ខន្តិកៈមេធាវី ហើយមេធាវី ដែលបានជ្រើសរើស ឬចាត់តាំង ត្រូវបានទទួលដំណឹងភ្លាម។ មេធាវីអាចពិនិត្យសំណុំរឿង និងទាក់ទងជាមួយជនជាប់ចោទបាន។

និទ្ទេសនៃទម្រង់ការទាំងនេះ ត្រូវចុះនៅក្នុងកំណត់ហេតុ បើពុំដូច្នោះទេ នីតិវិធីត្រូវទុកជាមោឃភាពបានករណីនេះ។

ក្រោយពីព្រះរាជអាជ្ញា បានបញ្ជូនសំណុំរឿងដល់តុលាការរួចហើយ តុលាការជាន់ដំបូងទទួលដំណឹងតាមកំណត់ហេតុស្តីពីការបង្គាប់ឲ្យចូលបង្ហាញខ្លួនភាម។ ក្នុងករណីនេះ ជនជាប់ចោទត្រូវបានឃុំគ្រងដោយកងការពារ រហូតដល់ពេលសាមីខ្លួនចូលបង្ហាញមុខនៅតុលាការ។ ដោយឡែក ការបង្ហាញខ្លួននេះ គឺត្រូវតែប្រព្រឹត្តិទៅនៅថ្ងៃនោះតែម្តង យោងតាមមាត្រា ៣០៤ និងមាត្រា ៤៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

នៅពេលបង្ហាញខ្លួន នោះតុលាការត្រូវធ្វើចំណាត់ការដូចតទៅ៖

-ផ្ទៀងផ្ទាត់អត្តសញ្ញាណរបស់ជនជាប់ចោទ

-ពិនិត្យមើលរបាយការណ៍សង្ខេបរឿងហេតុ ដែលបានចោទប្រកាន់

-ប្រាប់ដល់ជនជាប់ចោទថា សាមីខ្លួនមានរយៈពេល ដើម្បីរៀបចំការពារខ្លួន។ ប្រសិនបើជនជាប់ចោទសុំរយៈពេល ឬប្រសិនបើតុលាការយល់ឃើញថា រឿងនេះពុំទាន់អាចជំនុំជម្រះបានទេនោះ មានន័យថា ត្រូវលើកទៅសវនាការលើកក្រោយទៀត។ នៅក្នុងករណីនេះ តុលាការអាច **សម្រេចឲ្យឃុំខ្លួនជនជាប់ចោទបណ្តោះអាសន្នតាមសាលក្រម** នៅក្នុងសាលក្រមនោះ តុលាការត្រូវយោងតាមមាត្រា ២០៥ (មូលហេតុនៃការឃុំខ្លួនបណ្តោះអាសន្ន) ដែលមានសំអាងហេតុ និងចេញ **ដីកាបង្គាប់ឲ្យឃុំខ្លួន** លើជនជាប់ចោទនេះបាន។

សាលក្រមលើអង្គសេចក្តី ត្រូវតែប្រកាសក្នុងរយៈពេល ដែលមិនអាចលើសពី **២ សប្តាហ៍** គិតពីថ្ងៃនៃការចូលទៅបង្ហាញខ្លួននៅមុខតុលាការ។ ការឃុំខ្លួនបណ្តោះអាសន្នត្រូវតែបញ្ឈប់ដោយ

ពេញលក្ខណៈច្បាប់ ក្រោយពីការផុតរយៈពេល ២សប្តាហ៍ នេះ។

ប្រសិនបើតុលាការ បានទទួលបណ្តឹងតាមនីតិវិធីបង្គាប់ឲ្យចូលបង្ហាញខ្លួនភ្លាម ហើយយល់ឃើញថា លក្ខខណ្ឌតាមមាត្រា ៤៧ (ការបង្ហាញខ្លួនភ្លាម) នៃក្រមនេះ មិនបានបំពេញទេ ឬក៏ដោយភាពសាំញ៉ាំនៃរឿងទាមទារជាចាំបាច់ឲ្យធ្វើការស្រាវជ្រាវឲ្យបានជ្រាលជ្រៅបន្ថែម នោះតុលាការត្រូវបញ្ជូនសំណុំរឿងទៅព្រះរាជអាជ្ញា ដើម្បីបើកធ្វើការស៊ើបសួរ។ ជនជាប់ចោទ ត្រូវតែនាំទៅបង្ហាញខ្លួននៅថ្ងៃនោះតែម្តង នៅចំពោះមុខចៅក្រមស៊ើបសួរ បើពុំដូច្នេះទេ ជនជាប់ចោទ ត្រូវបានដោះលែងឲ្យមានសេរីភាពវិញដោយឯកឯង។

នីតិវិធីនាពេលសវនាការផ្សេងទៀត និងសវនាការនៃរឿងអង្គសេចក្តី ក្នុងនីតិវិធីបង្ហាញខ្លួនភ្លាមនេះ គឺមានលក្ខណៈមិនខុសគ្នាពីនីតិវិធីនៃសវនាការរឿងអង្គសេចក្តីធម្មតាទេ។

## កថាខណ្ឌទី៤៖ នីតិវិធីនាពេលសវនាការ

មុននឹងចាប់ផ្តើមពេលសវនាការ ក្រឡាបញ្ជី ផ្ទៀងផ្ទាត់វត្តមានរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ដើម្បីរាយការណ៍ជូនតុលាការ។

### ៤.១.សមាសភាពពេលសវនាការ

នៅពេលសវនាការ សមាសភាពជំនុំជម្រះមាន ចៅក្រមម្នាក់ ឬ ៣នាក់ ដែលសម្រេចជាសមូហភាព តំណាងអយ្យការមួយរូប និងក្រឡាបញ្ជីសវនាការមួយរូប។ នៅក្នុងចំណោមចៅក្រមទាំងបីរូបនេះ មានចៅក្រមមួយរូប ជាប្រធាននៃក្រុមប្រឹក្សាជំនុំជម្រះ ចំណែកឯចៅក្រមពីររូបទៀតជាចៅក្រមប្រឹក្សា។ ម៉្យាងវិញទៀត មុខងារជាចៅក្រម និងមុខងារជាព្រះរាជអាជ្ញា មានវិសមិតភាពនឹងគ្នាយ៉ាងដាច់ខាត។ ប្រសិនបើចៅក្រមណាម្នាក់ បានបំពេញមុខងារក្នុងឋានៈជាព្រះរាជអាជ្ញា ជាព្រះរាជអាជ្ញារង ឬជាចៅក្រមស៊ើបសួរ លើសំណុំរឿងណាមួយហើយ ចៅក្រមនេះ ពុំអាចចូលរួមក្នុងការជំនុំជម្រះបានទេ។ បើពុំដូច្នេះទេ សាលក្រមត្រូវទុកជាមោឃៈ មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

<u>**បញ្ជាក់:**</u>

-ក្រឡាបញ្ជី នៃតុលាការ មានភារៈកិច្ច ដែលទទួលបន្ទុកពាក្យបណ្តឹង នៅក្នុងពេលសវនាការ ម៉្យាងវិញទៀត ក្រឡាបញ្ជីអានបទបញ្ជាផ្ទៃក្នុង និងធ្វើការកត់សម្គាល់ហេតុតាមការបង្ហាញរបស់ចៅក្រមជំនុំជំម្រះ។

-តំណាងអយ្យការ គឺចាំបាច់ណាស់ នៅក្នុងនីតិវិធីសវនាការ ព្រះរាជអាជ្ញា ត្រូវតែមានវត្តមាន និងជាអ្នកតំណាងឲ្យសង្គម ជាពិសេស ក្នុងរឿងក្តីព្រហ្មទណ្ឌ ដោយតាងនាមជាគូក្តីដើមជានិច្ច។

-ជនជាប់ចោទ ឬមេធាវីរបស់ជនជាប់ចោទ (ប្រសិនបើមាន) ពុំអាចចូលបង្ហាញខ្លួននៅពេលសវនាការបានទេ នោះតុលាការ ពិនិត្យទៅលើស្ថានភាពនៃរឿងក្តី ហើយអាចជ្រើសរើសសម្រេចតាមវិធីបីយ៉ាង៖

**១**-ប្រសិនបើមិនអាចចូលបង្ហាញខ្លួនបានទេ ដោយមូលហេតុស្ថានភាពសុខភាព ឬដោយមូលហេតុធ្ងន់ធ្ងរ ដែលធ្វើឲ្យជនជាប់ចោទ មិនអាចចូលបង្ហាញខ្លួននៅចំពោះមុខតុលាការបាន ប្រធានតុលាការ អាចបង្គាប់ឲ្យសួរជនជាប់ចោទ នៅទីកន្លែងដែលជននោះនៅបាន ដោយកំណត់កាលបរិច្ឆេទនៃការសួរចម្លើយ។ ការសួរចម្លើយ ត្រូវធ្វើដោយប្រធានសវនាការ នៅចំពោះមុខព្រះរាជអាជ្ញា និងក្រឡាបញ្ជី និងមេធាវីរបស់ជនជាប់ចោទ លើកលែងតែជនជាប់ចោទរូបនេះបានបោះបង់យ៉ាងជាក់លាក់នូវវត្តមានរបស់មេធាវីខ្លួន។ ចំពោះការសួរចម្លើយនេះ ត្រូវធ្វើកំណត់ហេតុ[៩១]។

**២**-ប្រសិនបើជនជាប់ចោទ ជាប់ចោទពីបទឧក្រិដ្ឋ ឬមជ្ឈិម ដែលមិនអាចចូលមកបង្ហាញខ្លួនបានទេ តុលាការអាចបង្គាប់ឲ្យបង្អង់រឿងនេះទុកសិន និងឲ្យចេញដីកាបង្គាប់ឲ្យនាំខ្លួន។ តុលាការត្រូវតែបញ្ជាក់អំពីកាលបរិច្ឆេទនៃការបើកសវនាការថ្មី។ ដីកាបង្គាប់ឲ្យនាំខ្លួន មានចុះនិទ្ទេសដូចតទៅ៖ អត្តសញ្ញាណរបស់ជនជាប់ចោទ បទល្មើសដែលចោទប្រកាន់ និងអត្ថបទច្បាប់ដែលកំណត់និងបង្ក្រាបបទល្មើសនេះ ឈ្មោះ និងឋានៈចៅក្រម ដែលចេញដីកា។ ដីកាបង្គាប់ឲ្យនាំខ្លួនត្រូវមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយប្រធានសវនាការ និងមានបោះត្រាផង (មាត្រា ៣១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ តាមបទប្បញ្ញត្តិមាត្រា ១៩២ (ការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួន) ត្រូវយកមកអនុវត្តដូចគ្នាផងដែរ។

**៣**-ដោយធ្វើការបន្តនីតិវិធីទៅមុខទៀត ក្នុងករណីនេះ តុលាការចេញសាលក្រមកំបាំងមុខ ឬសាលក្រមកំបាំងមុខចាត់ទុកថាចំពោះមុខ។

តាមការធ្វើសវនាការជាសាធារណៈ នោះរាល់សាធារណជន អាចចូលរួមក្នុងសវនាការបានដោយសេរី តែសវនាការខ្លះមិនអនុញ្ញាតឲ្យសាធារណជនចូលរួម ឬបើកជូនសាធារណជនឡើយ តែចាំបាច់ណាស់ ការប្រកាសសាលក្រមត្រូវតែធ្វើឡើងជាសាធារណៈ[៩២]។

### ៤.២.នីតិវិធី និងដំណាក់កាលនៃការជំនុំជម្រះ

ក្នុងដំណាក់កាលនេះ ជាដំណាក់កាលដែលត្រូវសម្រេចអំពីការពិតណាមួយ និងការទទួលខុសត្រូវតាមផ្លូវច្បាប់ ដោយអនុភាពនៃការចាប់បង្ខំគឺ **សាលក្រម**។

---

[៩១] មាត្រា ២៨៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៩២] មាត្រា ៣១៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

មុននឹងសម្រេចបើកសវនាការ ក្រឡាបញ្ជីនៃសវនាការ ត្រូវប្រកាសអំពីបទបញ្ជាផ្ទៃក្នុង និងធ្វើសេចក្តីថ្លែងអំពីសមាសភាពអ្នកដែលចូលរួម ទើបសម្រេចបើកសវនាការដោយចៅក្រម។

តុលាការព្រហ្មទណ្ឌ អាចបើកសវនាការជំនុំជម្រះបានតែលើជនណា ដែលបានបញ្ជូនមកក្នុងឋានៈជាជនជាប់ចោទតែប៉ុណ្ណោះ។ ដោយនៅដំណាក់កាលនេះស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ចៅក្រមជំនុំជម្រះ ដែលយើងហៅថា **ជាដំណាក់កាលជំនុំជម្រះចេញសាលក្រម។** ក្នុងដំណាក់កាលនេះ មានចៅក្រមថ្មីមួយទៀត ដែលមិនធ្លាប់ធ្វើការស៊ើបសួរ ឬធ្វើការចោទប្រកាន់ឡើយ។ រាល់ការជជែកដេញដោល ការតទល់គ្នា ការទាញហេតុផលរៀងៗខ្លួន គឺត្រូវធ្វើឡើងនាពេលសវនាការ។

នៅក្នុងដំណាក់កាលនេះ លែងមានចេញដីកា ដូចមាននៅក្នុងដំណាក់កាលរបស់ចៅក្រមស៊ើបសួរ ឬដំណាក់កាលរបស់អយ្យការទៀតហើយ គឺមានតែ **សាលក្រម** តែម្តង ដែលអានុភាពនៃសាលក្រមនេះ អាចជាការផ្តន្ទាទោសលើជនជាប់ចោទ ឬឲ្យរួចផុតពីការចោទប្រកាន់។

### ៤.៣.ការកំណត់ពេលបើកសវនាការ

បន្ទាប់ពីតុលាការ បានទទួលសំណុំរឿង ដោយយោងតាមនីតិវិធីនៃការប្តឹងទៅតុលាការ ប្រធានតុលាការត្រូវកំណត់ពីកាលបរិច្ឆេទនៃសវនាការ ដោយបើកសវនាការ ដើម្បីកំណត់ពីកាលបរិច្ឆេទនោះ។ ក្នុងករណីតុលាការ បានទទួលបណ្តឹងដោយបញ្ជូនទៅជំនុំជម្រះផ្ទាល់ ដោយដីការបស់ចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនរឿងរបស់សភាស៊ើបសួរ ប្រធានតុលាការត្រូវថ្លឹងថ្លែងអំពីកាលបរិច្ឆេទនេះ ដូចមានចែងនៅក្នុងមាត្រា ៤៥៧ (រយៈពេលដែលត្រូវគោរពរវាងការប្រគល់ដីកាកោះហៅបញ្ជូនទៅជំនុំជម្រះផ្ទាល់ និងការបង្គាប់ឲ្យបង្ហាញខ្លួន) និងមាត្រា ៤៦៦ (រយៈពេលដែលត្រូវគោរពរវាងដីកាកោះហៅ និងការបង្គាប់ឲ្យបង្ហាញខ្លួន) ត្រូវបានយកមកអនុវត្តដូចគ្នាផងដែរ។ ក្នុងករណីនេះ ការជូនដំណឹង ត្រូវជូនដំណឹងដល់ព្រះរាជអាជ្ញាផងដែរ។

### ៤.៤.ការចូលរួមនីតិវិធីសវនាការ

នៅក្នុងនីតិវិធីសវនាការ ចាំបាច់ត្រូវតែមានអ្នកចូលរួម។ តើអ្នកណាខ្លះដែលត្រូវចូលរួមក្នុងនីតិវិធីនេះ?

#### ៤.៤.១.ការចូលរួមរបស់ជនជាប់ចោទ

ក្រោយពីបានទទួលដំណឹងអំពីកាលបរិច្ឆេទនៃការចូលបង្ហាញខ្លួន ជនជាប់ចោទត្រូវបង្ហាញខ្លួននៅពេលសវនាការរបស់តុលាការដោយផ្ទាល់[៩៣]។ ជនជាប់ចោទ ត្រូវអមដោយមេធាវីដែលខ្លួនជ្រើសរើស ឬស្នើសុំឲ្យតុលាការចាត់តាំងមេធាវីជំនួស ឬមិនត្រូវការមេធាវី បើជននោះយល់ថា អាច

[៩៣] មាត្រា ៣០០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ការពារខ្លួនបាននៅចំពោះមុខតុលាការ។ តែការដែលមិនមានមេធាវី មិនត្រូវអនុវត្តដោយចំពោះបទឧក្រិដ្ឋ ឬកាលណាជនជាប់ចោទជាអនីតិជន។ ម៉្យាងវិញទៀត ការចូលខ្លួនរបស់ជនជាប់ចោទ គឺប្រព្រឹត្តិទៅដោយឡែកពីគ្នា ដូចជាក្នុងករណីបញ្ជូនទៅជំនុំជម្រះផ្ទាល់ ជនជាប់ចោទចូលបង្ហាញខ្លួនដោយខ្លួនឯងនៅពេលសវនាការ (មាត្រា ៣០២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៤.៤.២.ការចូលខ្លួនរបស់ដើមបណ្ដឹងរដ្ឋប្បវេណី

ក្នុងពេលសវនាការ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ធ្វើតាមការប្រកាសប្ដឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី។ ការប្រកាសប្ដឹងនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។ ការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ ក្រោយពីសេចក្ដីសន្និដ្ឋានស្នើសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្ដីត្រូវបានបញ្ចប់ (មាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ នៅក្នុងករណីនេះ ដើមបណ្ដឹងរដ្ឋប្បវេណី ក៏អាចត្រូវបានតំណាងដោយមេធាវី សហព័ទ្ធ ឬ ញាតិលោហិតផ្ទាល់ផងដែរ។ តែចំពោះអ្នកតំណាង ដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ (មាត្រា ៣១៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៤.៤.៣.ការចូលខ្លួនរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី

អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចត្រូវបានអមដោយមេធាវី។ អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ក៏អាចត្រូវបានតំណាងដោយមេធាវី ដោយសហព័ទ្ធ ឬដោយញាតិលោហិតផ្ទាល់ដែរ។ អ្នកតំណាងដែលមិនមែនជាមេធាវី ត្រូវតែមានលិខិតប្រគល់សិទ្ធិជាលាយលក្ខណ៍អក្សរ (មាត្រា ៣១៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៤.៤.៤.ការចូលខ្លួនរបស់សាក្សី

មុននឹងឆ្លើយទៅនឹងសំណួរ សាក្សីនីមួយៗ ត្រូវស្បថថា ខ្លួននិយាយតែការពិតស្របតាមសាសនា ឬជំនឿរបស់ខ្លួន (មាត្រា ៣២៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ប្រធានសវនាការ សួរសាក្សីម្នាក់ៗថា តើជាញាតិលោហិត ឬញាតិពន្ធរបស់ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬក៏ជាអ្នកស៊ីឈ្នួលបម្រើជនទាំងនោះឬទេ។

សាក្សី មានករណីកិច្ចផ្ដល់នូវសក្ខីកម្ម។ សាក្សី ត្រូវតែចូលមកបង្ហាញខ្លួន នៅចំពោះមុខតុលាការ តាមការកោះហៅរបស់តុលាការ។ តែបើសាក្សីនោះ រឹងទទឹងមិនព្រមចូលមកបង្ហាញខ្លួនតាមការកោះហៅ របស់តុលាការនោះទេ វិធានការ នៃការប្រើកងកម្លាំងសាធារណៈពីសំណាក់តុលាការ ត្រូវបានយកមកអនុវត្តដើម្បីធានាការបង្ហាញខ្លួនរបស់សាក្សី (មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**កថាខណ្ឌទី៥៖ ការពិភាក្សាដេញដោល**

-ក្រឡាបញ្ជីហៅឈ្មោះជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនរងគ្រោះ សាក្សី អ្នកជំនាញ ព្រមទាំងផ្ទៀងផ្ទាត់អត្តសញ្ញាណ។ ប្រសិនបើដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ត្រូវបានតំណាងដោយសហាព័ន្ធ ឬញាតិលោហិតផ្ទាល់ ក្រឡាបញ្ជី ត្រូវពិនិត្យផ្ទៀងផ្ទាត់ពីសុពលភាពនៃការប្រគល់សិទ្ធិ។ ក្រឡាបញ្ជី សរសេរកំណត់ហេតុសវនាការ ដោយរៀបរាប់អំពីដំណើរការប្រព្រឹត្តទៅ នៃសវនាការ និងសំណួរចម្លើយដល់ជនពាក់ព័ន្ធនៅក្នុង សវនាការ (មាត្រា ៣៩១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ កំណត់ហេតុនេះ ត្រូវចុះហត្ថលេខាដោយ ក្រឡាបញ្ជី និងចុះទិដ្ឋាការក្រោយពីការផ្ទៀងផ្ទាត់ ដោយប្រធានសវនាការ ក្នុងរយៈពេល ១០ថ្ងៃ ក្រោយថ្ងៃប្រកាសសាលក្រម។

-ភាគីនីមួយៗ អង្គុយនៅតាមកន្លែងដែលទុកសម្រាប់ឲ្យខ្លួន នៅក្នុងពេលសវនាការ។

-ប្រធានសវនាការ ប្រាប់ដល់ជនជាប់ចោទ ឲ្យបានដឹងពីអំពើដែលគេចោទប្រកាន់មកលើខ្លួន។

-ប្រធានសវនាការ សួរចម្លើយជនជាប់ចោទ ទាំងដាក់បន្ទុក និងដោះបន្ទុក។

-ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់ជនជាប់ចោទ។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។

-ប្រធានសវនាការ ស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

-ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់ដើមបណ្តឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ ក្រៅពីសំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។

-តុលាការ អាចស្តាប់ចម្លើយរបស់អ្នកប្តឹងបរិហារបានផងដែរ ដើម្បីយកជា **ព័ត៌មាន** (មាត្រា ៣២៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

-ព្រះរាជអាជ្ញា មេធាវី និងភាគី អាចត្រូវបានអនុញ្ញាតឲ្យលើកសំណួរដល់សាក្សី។ ក្រៅពី សំណួររបស់តំណាងអយ្យការ និងមេធាវី សំណួរផ្សេងទៀត ត្រូវសួរតាមរយៈប្រធានសវនាការ។ ភាគីអាចសុំឲ្យតុលាការស្តាប់ចម្លើយក្នុងឋានៈជាសាក្សី នូវបុគ្គលដែលមានវត្តមាននៅក្នុងបន្ទប់សវនាការ ប៉ុន្តែមិនបានកោះហៅឲ្យបានត្រឹមត្រូវនោះទេ។ ការស្តាប់ចម្លើយសាក្សីនេះត្រូវមានការយល់ព្រមពីប្រធានសវនាការទើបបាន[៩៤]។ ក្រឡាបញ្ជីស្រង់អត្តសញ្ញាណ និងអញ្ជើញសាក្សីនេះ ឲ្យថយទៅនៅបន្ទប់រងចាំ។ ប្រសិនបើសាក្សី ពុំអាចចូលមកបង្ហាញខ្លួននៅមុខតុលាការ តាមការកោះហៅ

[៩៤]មាត្រា ៣២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

នោះតុលាការអាចប្រើកម្លាំងសាធារណៈ ដើម្បីបង្ខំសាក្សីឲ្យចូលបង្ហាញខ្លួនបាន[៥៥]។

ប្រសិនបើជនពាក់ព័ន្ធ ជាជនគ ថ្លង់ ក្រឡាបញ្ជីសរសេរសំណួរ ហើយឲ្យសាមីខ្លួនអាន និងឆ្លើយជាលាយលក្ខណ៍អក្សរ។ ប្រសិនបើពុំចេះអានទេ ត្រូវរកអ្នកបកប្រែ ដោយត្រូវឲ្យស្បថតាមសាសនា និងជំនឿរបស់ខ្លួនថា ជួយតុលាការ និងបកប្រែចម្លើយឲ្យបានស្មោះត្រង់ (មាត្រា ៣៣១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អ្នកបកប្រែនេះ អាចជាអ្នកធ្លាប់ប្រាស្រ័យទាក់ទងជាមួយជននេះ។ ប្រសិនបើសាមីខ្លួនពុំអាចនិយាយភាសាខ្មែរបានទេ ត្រូវរកអ្នកបកប្រែ ដែលត្រូវស្បថតាមសាសនា និងជំនឿរបស់ខ្លួន ថាជួយតុលាការ និងបកប្រែចម្លើយឲ្យបានស្មោះត្រង់ (មាត្រា ៣៣០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ អ្នកបកប្រែ ពុំអាចជ្រើសរើសក្នុងចំណោមចៅក្រម ក្រឡាបញ្ជី នគរបាល កងរាជអាវុធហត្ថ គូភាគី ឬសាក្សីទេ។

-ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី អាចធ្វើសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរ និងជូនលិខិតស្នាមទាំងអស់ ដែលខ្លួនយល់ឃើញថា មានប្រយោជន៍ដល់ការសម្ដែងឲ្យឃើញថាពិត។ សេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សរនេះ ត្រូវចុះទិដ្ឋាការដោយប្រធានសវនាការ និងក្រឡាបញ្ជី ហើយភ្ជាប់មកជាមួយក្នុងសំណុំរឿង (មាត្រា ៣៣៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ការដាក់សេចក្ដីសន្និដ្ឋាននេះ ត្រូវធ្វើមុនពេលបិទការពិភាក្សាដេញដោល។

-ប្រសិនបើការពិភាក្សាដេញដោល មិនបានបញ្ចប់នៅក្នុងពេលសវនាការទេ តុលាការអាចបន្តនៅពេលសវនាការក្រោយ តាមកាលបរិច្ឆេទដែលខ្លួនកំណត់[៥៦]។

### ៥.១.សិទ្ធិនិយាយជាបន្តបន្ទាប់

ក្រោយពិភាក្សាដេញដោល ប្រធានសវនាការបើកឲ្យជនដូចខាងក្រោមនេះ និយាយជាបន្តបន្ទាប់គ្នា៖

-ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ជនជាប់ចោទ ដើម្បីធ្វើការកត់សម្គាល់ខ្លីៗ

-មេធាវីរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ

-ព្រះរាជអាជ្ញា ដើម្បីធ្វើសេចក្ដីសន្និដ្ឋានប្ដឹងសុំ

-មេធាវីរបស់អ្នកទទួលខុសត្រូវរដ្ឋប្បវេណី មេធាវីរបស់ជនជាប់ចោទ ដើម្បីធ្វើសេចក្ដីសន្និដ្ឋានការពារ។

[៥៥] មាត្រា ៣១៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៥៦] មាត្រា ៣៤០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

ដើមបណ្ដឹងរដ្ឋប្បវេណី និងព្រះរាជអាជ្ញា អាចធ្វើការឆ្លើយតបទៅវិញបាន។ ប៉ុន្តែ ជនជាប់-ចោទ និងមេធាវីរបស់ខ្លួន ត្រូវនិយាយក្រោយគេបង្អស់ជានិច្ច។

តុលាការថយខ្លួនចូលទៅក្នុងបន្ទប់ពិភាក្សា ដើម្បីសម្រេច។ **ចាប់ពីពេលនេះតទៅ គ្មានបណ្ដឹងសុំណាមួយត្រូវដាក់ជូនតុលាការបានឡើយ** (មាត្រា ៣៣៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីនេះ គ្មានទទ្បីករណ៍ណាមួយអាចត្រូវបានលើកយកមកសំអាងទៀតបានឡើយ។ ព្រះរាជអាជ្ញា និងក្រឡាបញ្ជី មិនឲ្យចូលរួមក្នុងកិច្ចពិភាក្សាសម្រេចនេះទេ។ ការបំពេញទម្រង់ការនេះ ត្រូវតែកត់ត្រាទុកក្នុងកំណត់ហេតុសវនាការ និងក្នុងសាលក្រម (មាត្រា ៣៣៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៥.២.ការចុះដល់ទីកន្លែង

តុលាការ អាចចុះទៅកាន់គ្រប់ទីកន្លែងនៃដែនដីជាតិ ក្នុងផលប្រយោជន៍សម្ដែងឲ្យឃើញការពិត។ ក្នុងករណីនេះ តុលាការត្រូវតែមានព្រះរាជអាជ្ញា និងក្រឡាបញ្ជីអមដំណើរជានិច្ច។ ជនជាប់ចោទ ដើមបណ្ដឹងរដ្ឋប្បវេណី អ្នកទទួលខុសត្រូវរដ្ឋប្បវេណី ព្រមទាំងមេធាវី ក៏អាចជូនដំណើរតុលាការបានដែរ ប្រសិនបើខ្លួនបានស្នើសុំឲ្យចុះដល់ទីកន្លែងនោះ។ ប្រតិបត្តិការទាំងនេះ ត្រូវតែមានធ្វើកំណត់ហេតុ (មាត្រា ៣៣៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៥.២.១.ការស្វែងរកព័ត៌មានបន្ថែមដោយតុលាការ

ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់ តុលាការអាចបង្គាប់តាមសាលក្រមឲ្យស៊ើបសួរបន្ថែម។ ហើយអ្នកដែលមានសមត្ថកិច្ចធ្វើការស៊ើបសួរបន្ថែមរួមមាន៖

-ប្រធានសវនាការ

-ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ កាលណាតុលាការសម្រេចជាក្រុមសមូហភាព

-ចៅក្រមដទៃទៀត នៃតុលាការជាន់ដំបូង។

សាលក្រមដែលបង្គាប់ឲ្យធ្វើការសាកសួរបន្ថែម ត្រូវចាត់តាំងចៅក្រមឲ្យទទួលភារកិច្ចនេះ។ នៅក្នុងលក្ខខណ្ឌដូចគ្នានឹងចៅក្រមស៊ើបសួរ ចៅក្រមនេះអាច៖

-ចុះទៅលើដែនដីវិសាលភាពនៃដែនដីសមត្ថកិច្ចតុលាការ ឬលើគ្រប់វិសាលភាពនៃដែនដីជាតិ។ ក្នុងករណីនេះ តុលាការអាចស្ដាប់ចម្លើយសាក្សី ធ្វើការឆែកឆេរ ចាប់យកវត្ថុតាង បង្គាប់ឲ្យធ្វើកោសលវិច័យ។

ដើម្បីអនុវត្តការស៊ើបសួរបន្ថែមនេះ ចៅក្រម អាចចេញដីកាបង្គាប់ឲ្យសួរជំនួសបានផងដែរ (មាត្រា ៣៣៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

## កថាខណ្ឌទី៦៖ ការប្រកាសសាលក្រម

ការប្រកាសសាលក្រម ត្រូវធ្វើនៅពេលសវនាការ ដែលធ្វើការពិភាក្សាដេញដោល ឬនៅពេល

សវនាការលើកក្រោយ ដែលកាលបរិច្ឆេទត្រូវកំណត់ដោយប្រធានសវនាការ។ គ្រប់សាលក្រមត្រូវតែប្រកាសនៅពេលសវនាការសាធារណៈ ដោយប្រធានសវនាកាអានដោយសម្លេងខ្លាំងៗ ផ្នែកនៃសេចក្ដីសម្រេចរបស់សាលក្រម[៨៧]។ **សាលក្រមដែលត្រូវប្រកាសអាចជា៖**

### ៦.១.សាលក្រមចាត់របៀប

តុលាការ បង្គាប់ឲ្យប្រធានសវនាការ ចៅក្រមមួយរូបនៃក្រុមប្រឹក្សាជំនុំជម្រះ ឬចៅក្រមដទៃទៀតនៃតុលាការជាន់ដំបូង ធ្វើការស៊ើបសួរបន្ថែម ប្រសិនបើយល់ឃើញថា ការស្រាវជ្រាវថ្មីជាការចាំបាច់។ ចៅក្រមដែលទទួលបន្ទុកស៊ើបសួរបន្ថែមនេះ អាចប្រើសិទ្ធិអំណាចដូចជាចៅក្រមស៊ើបសួរដែរ។ សាលក្រមចាត់របៀប មិនអាចប្ដឹងឧទ្ធរណ៍តែឯងបានទេ មានន័យថា សាលក្រមចាត់របៀបអាចដាក់ជូនសាលាឧទ្ធរណ៍ពិនិត្យបាន លុះត្រាតែធ្វើព្រមគ្នាជាមួយនឹងសាលក្រមលើអង្គសេចក្ដី។ ប៉ុន្តែ កាលណាតុលាការ ចេញសាលក្រមចាត់របៀប បណ្ដឹងឧទ្ធរណ៍អាចត្រូវទទួលបានភ្លាម ប្រសិនបើសាលក្រមចាត់របៀបនេះ បានបញ្ចប់នីតិវិធី (មាត្រា ៣៨៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

### ៦.២.សាលក្រមលើអង្គសេចក្ដី

#### ៦.២.១.សាលក្រមចំពោះមុខ

ប្រសិនបើជនជាប់ចោទ ចូលបង្ហាញខ្លួននៅពេលសវនាការ នោះសាលក្រម ជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រមចំពោះមុខជនជាប់ចោទ មិនត្រូវឲ្យដំណឹងដល់ជននេះទេ។ សាលក្រមនេះ នៅតែជាសាលក្រមចំពោះមុខដដែល ទោះបីជាជនជាប់ចោទបានចេញពីបន្ទប់នាពេលសវនាការក៏ដោយ (មាត្រា ៣៦០)។ មួយវិញទៀត សាលក្រមនេះ ក៏ជាសាលក្រមចំពោះមុខដែរ ក្នុងករណីជនជាប់ចោទ មិនអាចចូលបង្ហាញខ្លួននៅចំពោះមុខតុលាការ ដោយមូលហេតុស្ថានភាពសុខភាព ឬមូលហេតុធ្ងន់ធ្ងរ ហើយតុលាការបានធ្វើការសួរចម្លើយជនជាប់ចោទនៅទីកន្លែងដែលជននោះស្នាក់នៅ[៨៨]។ សាលក្រមចំពោះមុខ អាចត្រូវប្ដឹងឧទ្ធរណ៍បាន។

**ក.សាលក្រមចំពោះដើមបណ្ដឹងរដ្ឋប្បវេណី**

ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬមានអ្នកតំណាងដោយត្រឹមត្រូវនោះ សាលក្រម ត្រូវតែជាសាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណីនេះ។ សាលក្រមចំពោះមុខដើមបណ្ដឹងរដ្ឋប្បវេណី មិនត្រូវជូនដំណឹងដល់សាមីខ្លួនទេ។ ដោយឡែកសាលក្រមនេះ អាចប្ដឹងឧទ្ធរណ៍បាន (មាត្រា ៣៦៣កថាខណ្ឌទី១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

---

[៨៧] មាត្រា ៣៥៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[៨៨] មាត្រា ៣០៩ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

**ខ.សាលក្រមចំពោះអ្នកទទួលខុសត្រូវរដ្ឋប្បវេណី**

ប្រសិនបើអ្នកកោះហៅ ក្នុងឋានៈ ជាអ្នកទទួលខុសត្រូវដើមបណ្ដឹងរដ្ឋប្បវេណី ចូលបង្ហាញខ្លួននៅពេលសវនាការ ឬក៏មានអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនោះ ជាសាលក្រមចំពោះមុខអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។ សាលក្រមចំពោះមុខនេះ មិនត្រូវឲ្យដំណឹងដល់អ្នកទទួលខុសត្រូវរដ្ឋប្បវេណីទេ[៩៩] ។ ដោយឡែកសាលក្រមនេះ អាចប្តឹងឧទ្ធរណ៍បាន។

**៦.២.២.សាលក្រមដែលចាត់ទុកថាចំពោះមុខ**

ប្រសិនបើជនជាប់ចោទ មិនចូលមកបង្ហាញខ្លួននៅពេលសវនាការទេ ប៉ុន្តែសាមីខ្លួនបានដឹងអំពីការបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងពីការកោះហៅហើយនោះ សាលក្រមត្រូវចាត់ទុកថាជាសាលក្រមចំពោះមុខជនជាប់ចោទ។ សាលក្រម ដែលចាត់ទុកថាចំពោះមុខនេះ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទនោះ។ សាលក្រមនេះ អាចប្តឹងឧទ្ធរណ៍បាន (មាត្រា ៣៦១)។ ក៏ប៉ុន្តែ ប្រសិនបើជនជាប់ចោទអវត្តមាន បានបង្ហាញមូលហេតុអំពីការអវត្តមានរបស់ខ្លួន ហើយតុលាការក៏ បានទទួលថាត្រឹមត្រូវ នោះតុលាការអាចលើករឿងទៅជំនុំជម្រះនៅពេលសវនាការមួយក្រោយទៀត។

**៦.២.៣.សាលក្រមកំបាំងមុខ**

ប្រសិនបើជនជាប់ចោទ មិនចូលបង្ហាញខ្លួននៅពេលសវនាការទេ ហើយនឹងប្រសិនបើគ្មានភស្តុតាងបង្ហាញឲ្យឃើញថា សាមីខ្លួនដឹងពីដីកាបញ្ជូនទៅជំនុំជម្រះផ្ទាល់ ឬបានដឹងអំពីការកោះហៅនោះទេ នោះសាលក្រម ត្រូវប្រកាសកំបាំងមុខជនជាប់ចោទ។ សាលក្រមកំបាំងមុខ ត្រូវឲ្យដំណឹងដល់ជនជាប់ចោទ[១០០]។ ក្នុងករណី ដែលសាលក្រមប្រកាសដោយពុំមានវត្តមានរបស់ដើមបណ្ដឹងរដ្ឋប្បវេណី ឬអ្នកទទួលខុសត្រូវរដ្ឋប្បវេណី ឬអ្នកតំណាងដោយត្រឹមត្រូវ សាលក្រមនេះ គឺជាសាលក្រមកំបាំងមុខ។ សាលក្រមនេះ អាចប្តឹងទាស់បាន មាត្រា ៣៦៣ និងមាត្រា ៣៦៤ កថាខណ្ឌទី២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

**៦.៣.ខ្លឹមសារនៃសាលក្រម**

សាលក្រម គឺជាសេចក្តីសម្រេចចុងក្រោយបង្អស់នៃដំណើរការនីតិវិធីតាំងពីពេលចាប់ផ្ដើមរហូតត្រូវបានបញ្ចប់ ហើយសាលក្រមនេះទៀតសោត គឺពិតជាមានសារសំខាន់ណាស់ ចំពោះបុគ្គលដែលជាប់ពាក់ព័ន្ធ មានដូចខាងក្រោម៖

---

[៩៩] មាត្រា ៣៦៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១០០] មាត្រា ៣៦២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៦.៣.១. ចំពោះជនជាប់ចោទ

ក-ប្រកាសផ្តន្ទាទោសជនជាប់ចោទ តាមបញ្ញត្តិមាត្រាច្បាប់ ក្រោយពីតុលាការបានពិនិត្យឃើញថា មានពិរុទ្ធភាពលើជនជាប់ចោទនោះ។ ប្រសិនបើតុលាការ ប្រកាសផ្តន្ទាទោសដាក់ពន្ធនាគារកំណត់រយៈពេល ០១ឆ្នាំ យ៉ាងតិច ដោយគ្មានការព្យួរទោសទេ តុលាការធ្វើតាមសេចក្តីសម្រេចពិសេស និងដោយមានសំអាងហេតុ អាចចេញនៅក្នុងពេលសវនាការ **ដីកាបង្គាប់ឲ្យឃុំខ្លួនជនជាប់ចោទដែលមានវត្តមាន និងដីកាបង្គាប់ឲ្យចាប់ខ្លួនជនជាប់ចោទ អវត្តមាន** ។ ដីកាបង្គាប់ឲ្យឃុំខ្លួន និងដីកាបង្គាប់ឲ្យចាប់ខ្លួនមានអានុភាពអនុវត្តភ្លាមៗតែម្តង ។ ដីកាទាំងនោះ មានចុះនិទ្ទេសដូចតទៅៈ

-អត្តសញ្ញាណរបស់ពិរុទ្ធជន

-ប្រភេទនៃទណ្ឌកម្ម និងអត្ថបទច្បាប់ ដែលជាមូលដ្ឋាននៃការផ្តន្ទាទោសនេះ

-ឈ្មោះ និងឋានៈចៅក្រមដែលចេញដីកា

ដីកានេះ ត្រូវតែមានចុះកាលបរិច្ឆេទ និងចុះហត្ថលេខាដោយចៅក្រមនេះ និងបោះត្រាផង (មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

ខ-ប្រសិនបើតុលាការ ធ្វើការវិនិច្ឆ័យ ហើយយល់ឃើញថា អំពើនោះមិនមែនជាបទល្មើសឧក្រិដ្ឋ មជ្ឈិម ឬលហុ ទេ នោះជនជាប់ចោទត្រូវបានរួចខ្លួនពីបទចោទ (មាត្រា ៣៥០ កថាខណ្ឌទី៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ មិនត្រឹមតែប៉ុណ្ណោះទេ ជននេះក៏ត្រូវបានដោះលែងឲ្យមានសេរីភាពវិញផងដែរ និងត្រូវបានលុបពីបញ្ជីថ្កោលទោស ការប្រកាសប្រាប់ជាសាធារណៈ ដើម្បីកសាងកិត្តិយសជននេះឡើងវិញជាដើម។

គ-នៅពេលប្រកាសសាលក្រម ការត្រួតពិនិត្យតាមផ្លូវតុលាការ ក៏ត្រូវបញ្ចប់ផងដែរ។

### ៦.៣.២.ចំពោះផលប្រយោជន៍ផ្នែករដ្ឋប្បវេណី

ការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី អាចធ្វើនៅដំណាក់កាល របស់ចៅក្រមស៊ើបសួរ។ ប្រសិបបើពុំបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅដំណាក់កាលចៅក្រមស៊ើបសួរទេ គេនៅតែអាចតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នាពេលសវនាការតាមការប្រកាសប្តឹងសាមញ្ញនៅចំពោះមុខក្រឡាបញ្ជី។ ការប្រកាសប្តឹងនេះ ត្រូវចុះនិទ្ទេសនៅក្នុងកំណត់ហេតុនៃសវនាការ។ ប៉ុន្តែក្រោយពីសេចក្តីសន្និដ្ឋានប្តឹងសុំរបស់ព្រះរាជអាជ្ញាលើអង្គសេចក្តីរួចហើយ នោះការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី មិនអាចទទួលបានទេ។ មួយវិញទៀត ប្រសិនបើជនរងគ្រោះបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី នៅចំពោះចៅក្រមស៊ើបសួររួចហើយ មិនចាំបាច់បំពេញទម្រង់ការនេះជាថ្មីម្តងទៀតទេ នៅមុខតុលាការ (មាត្រា ៣១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ) ។

តុលាការ វិនិច្ឆ័យអំពីភាពអាចទទួល ឬមិនទទួលយកបាន នៃការតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី ហើយសម្រេចពីពាក្យបណ្ដឹងរបស់ដើមបណ្ដឹងទៅលើជនជាប់ចោទ និងអ្នកទទួលខុសត្រូវផ្នែករដ្ឋប្បវេណី។ កាលណាតុលាការ មិនទាន់អាចសម្រេចបានលើផលប្រយោជន៍ផ្នែករដ្ឋប្បវេណីទេ តុលាការ អាចបង្អង់ទៅសវនាការលើកក្រោយបាន។ បុគ្គលដែលត្រូវផ្ដន្ទាទោសក្នុងបទល្មើសតែមួយជាមួយគ្នានោះ ត្រូវទទួលខុសត្រូវ សងការខូចខាតដោយសាមគ្គីភាព[១០១]។ ប្រសិនបើដើមបណ្ដឹងរដ្ឋប្បវេណី បានជូនពាក្យសុំទាមទារសំណងការខូចខាតនៅមុនពេលសវនាការ តែអវត្តមាននៅពេលសវនាការ ហើយតុលាការប្រកាសថាមាន ពិរុទ្ធភាពលើជនជាប់ចោទ នោះតុលាការត្រូវសម្រេចឲ្យសងសំណងការខូចខាតដល់ជនរងគ្រោះ ដោយផ្អែកលើអត្ថន័យនៃសំណុំរឿង[១០២]។

#### ៦.៣.៣.ចំពោះវត្ថុចាប់យក

តុលាការត្រូវសម្រេចពីការប្រគល់វត្ថុដែលចាប់យក។ ដោយឡែកការសម្រេច អាចជាការប្រគល់ឲ្យទៅម្ចាស់ដើមវិញ ឬរឹបអូសជាសម្បត្តិរដ្ឋ ឬរឹបអូសដើម្បីបំផ្លាញចោល[១០៣]។

### ៦.៤.ទម្រង់នៃសាលក្រម

#### ៦.៤.១.ការសរសេរសាលក្រម

គ្រប់សាលក្រម ត្រូវមានពីរផ្នែក គឺផ្នែកសំអាងហេតុ និងផ្នែកសម្រេច។ ចំពោះផ្នែកសំអាងហេតុ គឺជាទឡ្ហីករណ៍នៃអង្គហេតុ និងអង្គច្បាប់ ដែលនាំឲ្យតុលាការចេញសេចក្ដីសម្រេច។ ដោយឡែក ចំពោះផ្នែកសម្រេច ពោលគឺជាសេចក្ដីសម្រេចរបស់តុលការ។ ម៉្យាងវិញទៀត អង្គហេតុត្រូវតែច្បាស់លាស់ និងគ្មានការសង្ស័យ។ តុលាការ ត្រូវតែពិនិត្យមើលបទចោទនីមួយៗ និងទឡ្ហីករណ៍ដែលបានលើកឡើងនៅពេលសវនាការ។ មិនត្រឹមតែប៉ុណ្ណោះ នៅក្នុងសំអាងហេតុ តុលាការត្រូវឆ្លើយតបទៅនឹងសេចក្ដីសន្និដ្ឋានជាលាយលក្ខណ៍អក្សររបស់គូភាគី។

ផ្នែកនៃសេចក្ដីសម្រេច ត្រូវចុះនិទ្ទេសអំពីបទល្មើស ដែលជបជាប់ចោទបានប្រព្រឹត្តខុសអត្ថបទច្បាប់ដែលអនុវត្តទោស និងទណ្ឌកម្មរដ្ឋប្បវេណី (មាត្រា ៣៥៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

#### ៦.៤.២.និទ្ទេសលើសាលក្រម

សាលក្រម ត្រូវចុះហត្ថលេខាដោយប្រធានសវនាការ និងក្រឡាបញ្ជី។ សាលក្រមត្រូវចុះនិទ្ទេសដូចតទៅ៖

---

[១០១] មាត្រា ៣៥៥ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១០២] មាត្រា ៣៥៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

[១០៣] មាត្រា ៣៥៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

-ការបរិច្ឆេទនៃសវនាការ

-ការបរិច្ឆេទនៃការប្រកាសសាលក្រម

-ឈ្មោះ និងឋានៈរបស់ចៅក្រមជំនុំជម្រះ

-ឈ្មោះ និងឋានៈរបស់តំណាងអយ្យការ

-ឈ្មោះ និងឋានៈរបស់ក្រឡាបញ្ជី

-ឈ្មោះរបស់មេធាវី

-ឈ្មោះ ទីលំនៅ កាលបរិច្ឆេទ និងទីកន្លែងកំណើត មុខរបររបស់ជនជាប់ចោទ របស់ដើមបណ្តឹងរដ្ឋប្បវេណី និងអ្នកទទួលខុសត្រូវរដ្ឋប្បវេណី។

ក្រោយពីបានចុះហត្ថលេខាដោយប្រធាន និងក្រឡាបញ្ជីរួចហើយ សាលក្រមនេះ ត្រូវតម្កល់ទុកនៅការិយាល័យក្រឡាបញ្ជីយ៉ាងយូរបំផុត ៨ថ្ងៃ ក្រោយការប្រកាសសាលក្រម។ ការិយាល័យក្រឡាបញ្ជី ត្រូវរក្សាទុកសាលក្រមច្បាប់ដើមជានិច្ច។ ក្រឡាបញ្ជី អាចផ្តល់ច្បាប់ចម្លងនៃសាលក្រមជាអាទិ៍ ក្នុងករណីមានបណ្តឹងឧទ្ធរណ៍ (មាត្រា ៣៥៨ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**កថាខណ្ឌទី៧៖ ឧប្បត្តិហេតុនាពេលសវនាការ**

នៅក្នុង នាពេលសវនាការ អាចមានបញ្ហាចោទឡើងទាក់ទិននឹងឧប្បត្តិហេតុនានា ដែលពុំទាក់ទងនឹងអង្គសេចក្តីនៃសំណុំរឿងឡើយ។

**៧.១.វិវាទកម្មស្តីពីនិយតភាពនៃការកោះហៅ**

ប្រសិនបើភាគី បានធ្វើការលើកឡើងពីភាពមិនត្រឹមត្រូវ នៃដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់ កំណត់ហេតុស្តីពីការបង្ហាញខ្លួនភ្លាម ឬការកោះឲ្យចូលមកបង្ហាញខ្លួននៅពេលសវនាការ ភាគី ត្រូវតែលើកឡើងអំពីវិវាទកម្មនោះ នៅមុនពេលសួរចម្លើយជនជាប់ចោទលើអង្គសេចក្តី បើពុំដូច្នេះទេ វិវាទកម្មនេះពុំអាចទទួលបានឡើយ (មាត្រា ៣២៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។

**៧.២.ករណីមានបទល្មើសនាពេលសវនាការ**

ប្រសិនបើមានបទល្មើសបានកើតឡើង នៅក្នុងពេលសវនាការ ប្រធានសវនាការ ឲ្យធ្វើកំណត់ហេតុពិនិត្យរឿងហេតុនេះ មិនត្រឹមតែប៉ុណ្ណោះ ប្រធាសវនាការ អាចបង្គាប់ឲ្យចាប់ និងនាំជនល្មើសភ្លាម ជូនទៅព្រះរាជអាជ្ញា ដើម្បីថ្លឹងថ្លែងពីវិធានការដែលត្រូវចាត់ការ។ កាលណាបទល្មើសជាបទលហុ ឬបទមជ្ឈិម តុលាការអាចជំនុំជម្រះជនល្មើសភ្លាមៗ ប្រសិនបើព្រះរាជអាជ្ញាប្តឹងសុំ និងប្រសិនបើជនល្មើសយល់ព្រម[១០៤]។

[១០៤] មាត្រា ៣២០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

### ៧.៣.អញ្ញត្រកម្ម

ក្នុងករណីមានអញ្ញត្រកម្ម ត្រូវតែលើកឡើងមុនដំណាក់កាលការពារដល់អង្គសេចក្ដី បើពុំដូច្នេះទេ នោះគឺពុំអាចទទួលបានឡើយ។ តុលាការ ត្រូវសម្រេចអំពីអញ្ញត្រកម្មតាមសាលក្រមមួយដាច់ដោយឡែកពីសាលក្រមអង្គសេចក្ដី។ ប៉ុន្តែ តុលាការ ក៏អាចបញ្ចូលឧប្បត្តិហេតុទៅនឹងអង្គសេចក្ដី ហើយសម្រេចតាមសាលក្រមតែមួយដូចគ្នាអំពីអញ្ញត្រកម្មជាមួយនឹងអង្គសេចក្ដីដែរ[១០៥]។

នៅក្នុងករណីនេះអាញ្ញត្រកម្មអាចជា៖

#### ៧.៣.១.មោឃភាពនៃនីតិវិធី

លើកលែងតែករណី ដែលតុលាការទទួលជំនុំជម្រះតាមដីកាបញ្ជូនទៅជំនុំជម្រះពីចៅក្រមស៊ើបសួរ ឬសាលដីកាបញ្ជូនឲ្យជំនុំជម្រះផ្ទាល់ពីសភាស៊ើបសួរ។

#### ៧.៣.២.សមត្ថកិច្ចរបស់តុលាការ

ភាគីត្រូវលើកឡើងថា តុលាការ ពុំមានសមត្ថកិច្ចជំនុំជម្រះលើអង្គសេចក្ដីនេះទេ។

#### ៧.៣.៣.បញ្ហាបន្ទាន់បង្ខំ

ជាបញ្ហា ដែលអាចនឹងលុបលាងចរិកនៃបទល្មើសពីអំពើ ដែលចោទប្រកាន់លើជនជាប់ចោទ។ បញ្ហាបន្ទាន់បង្ខំ ច្រើនទាក់ទងនឹងបញ្ហាពីសិទ្ធិខាងកម្មសិទ្ធិ និងសិទ្ធិប្រត្យក្សលើអចលនវត្ថុ និងឋានៈបុគ្គល ដែលជាសមត្ថកិច្ចផ្ដាច់មុខរបស់តុលាការរដ្ឋប្បវេណី (មាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ)។ ក្នុងករណីនេះ សេចក្ដីសម្រេចអាចជា៖

**ក**-សាលក្រមប្រកាសថា មិនអាចទទួលបាននូវបញ្ហាបន្ទាន់បង្ខំ។

**ខ**-សាលក្រមប្រកាសថា ទទួលនូវបញ្ហាបន្ទាន់បង្ខំ ដោយត្រូវបង្អង់មិនទាន់សម្រេចលើអង្គសេចក្ដី ហើយត្រូវកំណត់រយៈពេលឲ្យភាគីពាក់ព័ន្ធប្ដឹងទៅតុលាការមានសមត្ថកិច្ច។ បើភាគីបានបង្ហាញភស្តុតាងថា បានប្ដឹងទៅតុលាការមានសមត្ថកិច្ចរួចហើយ នោះតុលាការកំណត់រយៈពេលថ្មីមួយទៀត ដើម្បីឲ្យបានសេចក្ដីសម្រេចអំពីបញ្ហានេះ។

**ឧទាហរណ៍៖** តុលាការ បានទទួលសំណុំរឿងព្រហ្មទណ្ឌ មកជំនុំជម្រះពីបទ **លួចអចលនវត្ថុរបស់អ្នកដទៃ** ដែលមានចែងឲ្យផ្ដន្ទាទោសតាមមាត្រា ២៥៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ ជនជាប់ចោទ បានលើកឡើងថា អចលនវត្ថុ ដែលខ្លួនបានលក់នោះ គឺជារបស់ខ្លួន។ ចំណុចនេះ គឺជាបញ្ហា **បន្ទាន់បង្ខំ**។ ការសម្រេចថា នរណាជាកម្មសិទ្ធិករលើអចលនវត្ថុ គឺជាសមត្ថកិច្ចរបស់តុលាការរដ្ឋប្បវេណី។ ហេតុដូចនេះ តុលាការព្រហ្មទណ្ឌ ត្រូវតែបង្អង់ការសម្រេចសេចក្ដីរបស់ខ្លួន

[១០៥] មាត្រា ៣៤៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ឆ្នាំ២០០៧

សិន ដើម្បីឲ្យតុលាការរដ្ឋប្បវេណី សម្រេចពីវិវាទកម្មសិទ្ធិជាមុន។ ប្រសិនបើ តុលាការរដ្ឋប្បវេណី បានសម្រេចជាស្ថាពរថា អចលនវត្ថុនោះ ជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទ ជនជាប់ចោទ នឹងត្រូវសម្រេចតាមសាលក្រមឲ្យរួចផុតពីបទចោទ ព្រោះថា ពុំមានបទល្មើសកើតឡើងទេ។ ក្នុងករណីដែលតុលាការរដ្ឋប្បវេណី បានសម្រេចជាស្ថាពរថា អចលនវត្ថុនោះ មិនមែនជាទ្រព្យសម្បត្តិរបស់ជនជាប់ចោទទេ តុលាការព្រហ្មទណ្ឌ នឹងសម្រេចផ្តន្ទាទោសជនជាប់ចោទ ប្រសិនបើរកឃើញថាជនជាប់ចោទ ពិតជាបានលួចលក់អចលនវត្ថុនោះពិតមែន[១០៦]។

[១០៦] សាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និង ចាំង ស៊ីណាត សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ទំព័រ៥៩-៦០ ឆ្នាំ២០១៤

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

# សេចក្តីសន្និដ្ឋាន និងអនុសាសន៍

## ១.សេចក្តីសន្និដ្ឋាន

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងយកចិត្តទុកដាក់បំផុត ក៏ដូចជាការសរសេរយ៉ាងលម្អិតជាប់ទាក់ទងទៅនឹងដំណាក់កាលទាំងបួន នៃរឿងក្តីព្រហ្មទណ្ឌរួមមក គឺពួកយើងខ្ញុំអាចធ្វើសេចក្តីសន្និដ្ឋានបានថា នីតិវិធីនីមួយៗ គឺមានភាពប្រទាក់ក្រឡាគ្នា ចាប់តាំងអំពីដំណាក់កាលនគរបាលយុត្តិធម៌ រហូតដល់ការប្រកាសសាលក្រម ជាពិសេស គឺការអនុវត្តជាក់ស្តែងនៅក្នុងប្រព័ន្ធតុលាការនៃព្រះរាជាណាចក្រកម្ពុជា។

នគរបាលយុត្តិធម៌ គឺជាដំណាក់ដំបូងបង្អស់នៃដំណើររឿងក្តីព្រហ្មទណ្ឌ ដោយហេតុថា នគរបាលយុត្តិធម៌ មានតួនាទីសំខាន់ខ្លាំងណាស់ ក្នុងការស្វែងរកបទល្មើស កំណត់អត្តសញ្ញាណរបស់ជនល្មើស ព្រមទាំងធ្វើការឃាត់ខ្លួនបុគ្គលមួយចំនួនផងដែរ នៅក្នុងករណី ដែលគាត់យល់ឃើញថាបុគ្គលនោះ បានចូលរួមប្រព្រឹត្តិបទល្មើស។ ក្រោយពីការឃាត់ខ្លួនបុគ្គលទាំងនោះរួចហើយ នគរបាលយុត្តិធម៌ នាំខ្លួនជនល្មើសទៅអធិការដ្ឋាននគរបាល បន្ទាប់មកធ្វើការសាកសួរ ក្រោយសាកសួរក៏បង្កសំណុំ រឿងបញ្ជូនមកអយ្យការ ដើម្បីចាត់ការតាមនីតិវិធី។ ទោះជាយ៉ាងនេះក្តី យើងសង្កេតឃើញថា ការអនុវត្តជាក់ស្តែង មន្ត្រីនគរបាលយុត្តិធម៌ បានកំពុងជួបប្រទះនូវបញ្ហាមួយចំនួនដូចជា ខ្វះឧបករណ៍ បច្ចេកទេសប្រើប្រាស់ ការប្រថុយប្រថានក្នុងករណីចុះទៅបង្ក្រាបបទល្មើសជាក់ស្តែង នីតិវិធីនៃការ ដាក់ពិន័យ និងការស្ថិតក្រោមអាណាព្យាបាលចំនួនពីរ គឺការងាររដ្ឋបាលទូទៅ ស្ថិតនៅក្រោមឱវាទក្រសួងមហាផ្ទៃ និងការងារនីតិវិធី គឺស្ថិតក្រោមឱវាទក្រសួងយុត្តិធម៌។

ស្ថាប័នអយ្យការ គឺជាដំណាក់កាល នៃការចោទប្រកាន់ ដែលរដ្ឋធម្មនុញ្ញបានធានាថា មានតែអយ្យការទេ ជាម្ចាស់នៃបណ្តឹងអាជ្ញា។ មុននឹងធ្វើការចោទប្រកាន់ ត្រូវពិនិត្យមើលសំណុំរឿងដែលមន្ត្រីនគរបាលយុត្តិធម៌ បញ្ជូនមក ហើយព្រះរាជអាជ្ញា ត្រូវស្វែងរកភស្តុតាងដាក់បន្ទុក និងធាតុផ្សំនៃបទល្មើស។ កាលណាព្រះរាជអាជ្ញា យល់ឃើញថា មានបន្ទុកគ្រប់គ្រាន់ក្នុងការចោទប្រកាន់ គាត់អាចធ្វើតាមនីតិវិធីដូចជា ចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ ការបញ្ជូនរឿងឲ្យទៅជំនុំជម្រះផ្ទាល់ ឬនីតិវិធីបង្ហាញខ្លួនភ្លាមៗ។ មិនត្រឹមតែប៉ុណ្ណោះ ព្រះរាជអាជ្ញា ក៏អាចតម្កល់រឿងទុកឥតចាត់ផងដែរ ក្នុងករណីមិនមានបទល្មើសព្រហ្មទណ្ឌ។ ព្រះរាជអាជ្ញា ចោទប្រកាន់ ដោយចេញដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងស្នើសុំឲ្យចៅក្រម បើកការស៊ើបសួរផងដែរ។ ទោះជាយ៉ាងនេះក្តី យើងឃើញថា អង្គការអយ្យការ គឺមានឋានានុក្រម មានន័យថា ព្រះរាជអាជ្ញា ស្ថិតនៅក្រោមអគ្គ-ព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍ និងស្ថិតនៅក្រោមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌។ ក្នុងករណី នៅពេលដែលមានអធិបញ្ញាឲ្យធ្វើការចោទប្រកាន់ នោះព្រះរាជអាជ្ញា គឺត្រូវតែធ្វើតាមរបស់បញ្ញាថ្នាក់លើ

បាន សេចក្តីថា ទោះជាព្រះរាជអាជ្ញា មិនចង់ធ្វើការចោទប្រកាន់ក៏ដោយ។

បន្ទាប់ពីព្រះរាជអាជ្ញា បានបញ្ជូនសំណុំរឿងមកដល់ចៅក្រមស៊ើបសួរ ដែលជាដំណាក់កាលទី៣ នៃនីតិវិធីព្រហ្មទណ្ឌ ហើយកិច្ចការរបស់ចៅក្រមនេះទៀតសោត គឺបើកការស៊ើបសួរ តាមដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរពីព្រះរាជអាជ្ញា។ ការស៊ើបសួរ របស់ចៅក្រមស៊ើបសួរ មានទាំងការស៊ើបសួរដាក់បន្ទុក និងដោះបន្ទុក។ ជាគោលការណ៍ ចៅក្រមស៊ើបសួរ អាចបើកការស៊ើបសួរ តាមដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាតែប៉ុណ្ណោះ មានន័យថា ចៅក្រមស៊ើបសួរ មិនអាចស៊ើបសួរក្រៅពីនេះបានទេ។ ប៉ុន្តែ ក្រោយពីការស៊ើបសួររួច ចៅក្រមស៊ើបសួរ យល់ឃើញថា អង្គហេតុថ្មី និងបទល្មើសថ្មី មិនមាននៅក្នុងដីកាសន្និដ្ឋានរបស់ព្រះរាជអាជ្ញាទេ នោះចៅក្រមស៊ើបសួរ ត្រូវស្នើសុំឲ្យព្រះរាជអាជ្ញាចេញដីកាចាត់ឲ្យស៊ើបសួរបន្ថែម។ ទោះជាការរៀបរាប់ខាងលើយ៉ាងនេះក្តី ក៏ករណីមួយចំនួន ចៅក្រមស៊ើបសួរ មានភាព លំបាកមួយចំនួនដូចជា ការប្តឹងនឹងលិខិតនៃកិច្ចនីតិវិធី ឬប្តឹងពីដីកាសម្រេច ដោយព្រះរាជអាជ្ញា ជនត្រូវចោទ ដើមបណ្តឹងរដ្ឋប្បវេណី ឬជនដែលពាក់ព័ន្ធនឹងសំណុំរឿងព្រហ្មទណ្ឌ មួយវិញទៀត នៅពេលដែលមានការតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ចំពោះមុខចៅក្រមស៊ើបសួរ ហើយចៅក្រម ស៊ើបសួរ បានបញ្ជូនពាក្យបណ្តឹងនោះភ្លាមទៅព្រះរាជអាជ្ញាដើម្បីពិនិត្យ និងធ្វើការចោទប្រកាន់ តែករណី ដែលព្រះរាជអាជ្ញា មិនចោទប្រកាន់ តែចៅក្រមស៊ើប-សួរ នៅតែអាចបើកការស៊ើបសួរបាន ដូច្នេះ តើក្នុងករណីនេះ កិច្ចរបស់ចៅក្រមស៊ើបសួរជាកម្មវត្ថុនៃមោឃភាពដែរឬទេ បើយោងតាមកថាខណ្ឌទី៣ មាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ មិនត្រឹមប៉ុណ្ណោះ ករណីខ្លះ ចៅក្រមស៊ើបសួរ ចុះទៅដល់ទីកន្លែងកើតហេតុ ដើម្បីស្វែងរកភស្តុតាង ដែលជាមូលហេតុ នាំឲ្យមានផលពិបាក ចំពោះដល់ចៅក្រមស៊ើបសួរផងដែរ។

ក្រោយពីចៅក្រមស៊ើបសួរ បានបញ្ចប់នៃកិច្ចនីតិវិធីស៊ើបសួរ ចៅក្រមស៊ើបសួរ ត្រូវបញ្ជូនព័ត៌មាន ឬជូនដំណឹងទៅព្រះរាជអាជ្ញា និងគ្រប់ភាគីនៅក្នុងសំណុំរឿង បើព្រះរាជអាជ្ញាយល់ឃើញថា កិច្ចស៊ើបសួរនោះ គ្រប់ជ្រុងជ្រោយរួចហើយ ព្រះរាជអាជ្ញា ត្រូវធ្វើដីកាសន្និដ្ឋានស្ថាពរ ១៥ថ្ងៃ ក្នុងករណី ជនត្រូវចោទនៅក្នុងឃុំ ១ខែ នៅក្នុងករណី ជនត្រូវចោទនៅក្រៅឃុំ។ បន្ទាប់ពីចៅក្រម ស៊ើបសួរ បានទទួលសំណុំរឿងពីព្រះរាជអាជ្ញា ភ្ជាប់ជាមួយដីកាសន្និដ្ឋានស្ថាពរ កិច្ចបន្ទាប់ ចៅក្រម ស៊ើបសួរ ត្រូវបញ្ជូនសំណុំរឿងទាំងមូលទៅចៅក្រមជំនុំជម្រះ។ ក្រោយពីទទួលបានសំណុំរឿង ហើយចៅក្រមជំនុំជម្រះ បើកសវនាការជំនុំជម្រះតែម្តង។ សេចក្តីសម្រេចរបស់ចៅក្រមជំនុំជម្រះ អាចជាការផ្តន្ទាទោសលើជនត្រូវចោទ ឬឲ្យជនត្រូវចោទ រួចផុតពីបទចោទ។

## ២.អនុសាសន៍

ក្រោយពីបានសិក្សាស្រាវជ្រាវយ៉ាងលម្អិត ក៏ដូចជាការធ្វើសេចក្តីសន្និដ្ឋានរួមក យើងខ្ញុំ យល់ឃើញថា ការអនុវត្តតាមច្បាប់ ក៏ដូចជាកិច្ចនៃនីតិវិធីក្នុងដំណើរនៃរឿងក្តីព្រហ្មទណ្ឌ គឺប្រព្រឹត្តិទៅដោយរលូន និងមានភាពប្រទាក់ក្រឡាគ្នារហូតដល់ចប់នីតិវិធី។ ក៏ប៉ុន្តែ នៅក្នុងនោះផងដែរ ចំពោះបញ្ហាមួយចំនួនក្នុងកិច្ចនីតិវិធី ក៏ដូចជាការអនុវត្តជាក់ស្តែង នៅមានចំណុចអសកម្មពាក់ព័ន្ធនឹងបញ្ហាបច្ចេកទេស ស្ថាប័ន និងការរួមសហការ ដែលជាហេតុធ្វើឲ្យមានការចន្លោះប្រហោង និងយឺតយ៉ាងក្នុងការបំពេញការងារ។ ដើម្បីជាការរួមចំណែក ធ្វើឲ្យកាន់តែប្រសើរឡើង ក្នុងវិស័យយុត្តិធម៌នៃព្រះរាជាណាចក្រកម្ពុជា យើងខ្ញុំ ជានិស្សិតសរសេរសារណា សូមចូលរួមជាគំនិតខ្លះៗ ដើម្បីបានផ្តល់ជាអនុសាសន៍បន្ថែមទៅលើចំណុចខ្វះខាតទាំងនោះដូចជា៖

**ក.ត្រូវបំពេញកង្វះខាតឧបករណ៍ បច្ចេកទេស មធ្យោបាយប្រើប្រាស់**

-ការងារមួយចំនួនអសកម្ម ដោយសារកង្វះខាតនៃការចុះផ្ទាល់ដល់មូលដ្ឋាន និងគោលដៅឈរជើង បានធ្វើឲ្យមានភាពចន្លោះប្រហោងក្នុងការអន្តរាគមន៍នៅពេលមានបទល្មើសកើតឡើង។

-ការងារស៊ើបអង្កេត និងការបង្ក្រាបបទល្មើសព្រហ្មទណ្ឌវិញ មិនទាន់បានឆ្លើយតបទៅតាមសំណូមពរ និងទិសដៅផែនការការងារនៅឡើយ ជាពិសេស គឺការគ្រប់គ្រងមុខសញ្ញាក្នុងមូលដ្ឋានដូចជាមុខសញ្ញាក្មេងទំនើង ការប្រើប្រាស់គ្រឿងញៀន មុខសញ្ញាមានដីកាចាប់ខ្លួន មុខសញ្ញាសេសសល់ និងមុខសញ្ញាដោះលែងចេញពីពន្ធនាគារ។

-ខ្វះមធ្យោបាយ សម្ភារ: ថវិកា ដើម្បីបម្រើឲ្យកិច្ចប្រតិបត្តិការស្រាវជ្រាវ ធ្វើឲ្យការងារបង្ក្រាបបទល្មើសព្រហ្មទណ្ឌមិនបានទាន់ពេលវេលា ពេលខ្លះមានមធ្យោបាយខ្វះប្រេង សាំង យានជំនិះ អាគុយ ភ្លើង ជាដើម។

**ខ.យន្តការពង្រឹងការអនុវត្តច្បាប់**

**-ការលុបបំបាត់អំពើពុករលួយ៖** ជាគោលការណ៍ មន្ត្រីមានសមត្ថកិច្ច មិនត្រូវយកតួនាទីខ្លួនទៅការពារបនល្បែងស៊ីសង បនស្រីពេស្យាចារ ឬកន្លែងប្រព្រឹត្តិអំពើអបាយមុខ អំពើពាលា ដែលផ្ទុយនឹងច្បាប់ឡើយ។ មិនត្រូវយកតួនាទីខ្លួនទៅការពារជនល្មើស ឬក្រុមប្រព្រឹត្តិបទល្មើស ឬជនប្រព្រឹត្តិសកម្មភាពចាប់ជំរិត លួច ឆក់ ប្លន់ កេងសម្បត្តិជាតិ ឬកេងប្រវ័ញ្ចកម្មសិទ្ធិអ្នកដទៃ ដែលស្របច្បាប់។ មិនត្រូវប្រើអំណាចគំរាមគំហែងប្រជាពលរដ្ឋ ដើម្បីការពារជនល្មើស និងប្រើប្រាស់សម្ភារៈរបស់រដ្ឋបម្រើផលប្រយោជន៍ខ្លួន ព្រមទាំងប្រព្រឹត្តបទល្មើសផ្សេងៗ ដែលផ្ទុយនឹងច្បាប់។ មិនត្រូវលាក់បំបាំងសំណុំរឿង ឬវត្ថុតាង ឬធ្វើការដោះដូរវត្ថុតាង ដើម្បីប្រយោជន៍បុគ្គលឡើយ។

**-ការលុបបំបាត់វប្បធម៌អន្តរាគមន៍៖** បរិបទនៃសង្គមខ្មែរបច្ចុប្បន្ន គឺតែងតែកើតមាននូវបញ្ហា

អន្តរាគមន៍ជាញឹកញាប់ វាគឺជាទម្លាប់ពលរដ្ឋខ្មែរ។ អ្នកដែលមានអំណាច មានឋានៈ តួនាទីនៅក្នុងសង្គមមួយចំនួន តែងតែលូកលាន់ នៅក្នុងកិច្ចការរបស់មន្ត្រីនគរបាលយុត្តិធម៌ ក៏ដូចជាតុលាការ ដែលធ្វើឲ្យការបំពេញតួនាទីមិនទាន់បានល្អប្រសើរ។ ដើម្បីលុបបំបាត់នូវបញ្ហាទាំងនេះ ចាំបាច់ត្រូវពង្រឹង តួនាទី ភារកិច្ច មន្ត្រីពាក់ព័ន្ធ ក្នុងការអនុវត្តច្បាប់ និងត្រូវយកគោលការណ៍ច្បាប់ជាមូលដ្ឋានគ្រឹះ។ បើមន្ត្រីណាម្នាក់ ដែលមិនបានប្រតិបត្តិតាមច្បាប់ ត្រូវតែទទួលខាងវិន័យ និងដាក់ទណ្ឌកម្មជាដាច់ខាត ដោយមិនត្រូវលើកលែងឡើយ។

**-ការលុបបំបាត់វប្បធម៌និទណ្ឌភាព៖** កាលណាគ្មានយុត្តិធម៌ វានឹងមាននូវនិទណ្ឌភាព បើមាននិទណ្ឌភាព គឺគ្មានទេ ភាពស្មើគ្នាចំពោះមុខច្បាប់។

**គ.ត្រូវបណ្តុះបណ្តាលជំនាញបច្ចេកទេស និងច្បាប់**

**-ការបង្កើតបន្ថែមនៅតុលាការតាមខេត្ត៖** រាជរដ្ឋាភិបាល ក៏ដូចជាស្ថាប័នព័ន្ធពាក់ ត្រូវខិតខំធ្វើយ៉ាងណា បង្កើតឲ្យមានសាលាដំបូងរាជធានី-ខេត្ត ឲ្យបានគ្រប់ចំនួន ដើម្បីកុំឲ្យមានការយឺតយ៉ាវក្នុងការដោះស្រាយរឿងក្តីជូនប្រជាពលរដ្ឋ។

**-ការជ្រើសរើសមន្ត្រីតុលាការ៖** ត្រូវជ្រើសរើសមន្ត្រីរាជការ ក្រឡាបញ្ជី ព្រះរាជអាជ្ញា ចៅក្រម ដើម្បីឲ្យបម្រើការងារនៅតាមស្ថានប័នតុលាការឲ្យបានគ្រប់ចំនួន ព្រោះយើងសង្កេតឃើញថា សព្វថ្ងៃនេះ គឺមានការខ្វះមន្ត្រីផ្នែកតុលាការជាច្រើននាក់។

**-ការបង្កើតតុលាការតាមជំនាញ៖** នាពេលបច្ចុប្បន្ន តុលាការនៃព្រះរាជាណាចក្រកម្ពុជា គឺមិនទាន់គ្រប់តម្រូវការ និងជំនាញឯកទេសរបស់ខ្លួននោះទេ ដូចជា តុលាការពាណិជ្ជកម្ម តុលាការរដ្ឋបាល ជាដើម ដែលជាហេតុធ្វើឲ្យមានការមមាញឹកខ្លាំងក្នុងការដោះស្រាយរឿងក្តីនីមួយៗ។

**-ការផ្សព្វផ្សាយវិស័យយុត្តិធម៌ឲ្យកាន់តែទូលំទូលាយ៖** កត្តាបណ្តុះបណ្តាល និងធ្វើការផ្សព្វផ្សាយពាក់ព័ន្ធទៅនឹងវិស័យយុត្តិធម៌ គឺនៅមានភាពចង្អៀតនៅឡើយ មិនទាន់បានទូលំទូលាយទេ ដូច្នេះ ត្រូវការ ការចូលរួមយ៉ាងសកម្ម អំពីសំណាក់ក្រសួងស្ថាប័ន ក៏ដូចបុគ្គលដែលមានសមត្ថកិច្ចធ្វើយ៉ាងណា បណ្តុះបណ្តាល ផ្សព្វផ្សាយច្បាប់ឲ្យបានដល់ប្រជាពលរដ្ឋទូទៅ ដើម្បីបានយល់ដឹង។

# គន្ថនិទ្ទេស

# គន្ថនិទ្ទេស

## ១.ឯកសារជាភាសាខ្មែរ

### ១.១.លិខិតបទដ្ឋានគតិយុត្ត

**ក.អំពីរដ្ឋធម្មនុញ្ញ**

- រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ១៩៩៣

**ខ.អំពីក្រម**

- ក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧
- ក្រមព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ២០០៩
- ក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៦ ខែកក្កដា ឆ្នាំ២០០៦
- ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧

**គ.អំពីច្បាប់**

- ច្បាប់ស្តីពីការរៀបចំអង្គការតុលាការ ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីលក្ខន្តិកៈចៅក្រម និងព្រះរាជអាជ្ញា ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤
- ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម ចុះថ្ងៃទី០២ ខែកក្កដា ឆ្នាំ២០១៤

**ឃ.អំពីឯកសារជាសៀវភៅ និងអត្ថបទ**

- សៀវភៅ មូលដ្ឋានច្បាប់ និងស្ថាប័នច្បាប់ និពន្ធដោយ ឯកឧត្តម ឥន យឿន បោះពុម្ពលើកទី៣
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ ឯកឧត្តម កើត រិទ្ធ បោះពុម្ពឆ្នាំ២០១៦
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ លោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ និងលោកស្រី ចាំង ស៊ីណាត បោះពុម្ពឆ្នាំ២០១៧-២០១៨
- សៀវភៅជំនួយស្មារតី នីតិព្រហ្មទណ្ឌ និងនីតិគ្រួសារ រៀបរៀងដោយលោកសាស្ត្រាចារ្យ រុន ពណ្ណារិទ្ធ លោកស្រីសាស្ត្រាចារ្យ ចាំង ស៊ីណាត ឆ្នាំ២០១៧
- សៀវភៅ នីតិព្រហ្មទណ្ឌទូទៅ សាស្ត្រាចារ្យ ឆឹង ស៊ីនៀង ឆ្នាំសិក្សា២០១៦-២០១៧
- សៀវភៅ សិក្សាផ្នែកទី៣ ប្រព័ន្ធតុលាការ ដោយវិទ្យាស្ថានខ្មែរដើម្បីលទ្ធិប្រជាធិបតេយ្យ
- សៀវភៅ នីតិរដ្ឋបាលទូទៅ ដោយសាស្ត្រាចារ្យ មីន សំអុល ឆ្នាំសិក្សា២០១៦-២០១៧
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌសម្រាប់នគរបាល អំណោយស្ថានទូតបារាំង ឆ្នាំ២០០៩
- សៀវភៅ ក្បួននីតិវិធីតុលាការព្រហ្មទណ្ឌ ភ្នំពេញ ឆ្នាំ២០០៦
- សៀវភៅ នីតិវិធីព្រហ្មទណ្ឌ រៀបចំដោយលោក ម៉ុង មុនីសោភា ឆ្នាំ២០០៩

- សមត្ថកិច្ចនគរបាលយុត្តិធម៌នៅកម្ពុជា ដោយ សុខ ងី បេក្ខជនបណ្ឌិតជំនាន់ទី១ នីតិសាស្ត្រ
- http:///www.facebook.com/thachantha អត្ថបទស្រាវជ្រាវ ស្តីពីតួនាទី សិទ្ធិអំណាច របស់អង្គការអក្យការ

**ច.អំពីវចនានុក្រម និងសទ្ទានុក្រម**

- វចនានុក្រមខ្មែរ ដោយសម្តេចព្រះសង្ឃរាជ ជួន ណាត ដែលបោះពុម្ពផ្សាយដោយសាសនបណ្ឌិត្យភ្នំពេញ ឆ្នាំ១៩៦៧
- វចនានុក្រមច្បាប់ ស្នាដៃនិពន្ធទី៦ ដោយ ហ៊ីង ធីឫទ្ធិ បោះពុម្ពលើកទី៤ ឆ្នាំ២០១៤
- សទ្ទានុក្រមពាក្យច្បាប់ ពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១២ សម្ព័ន្ធបញ្ញវន្តដើម្បីអភិវឌ្ឍន៍ ឆ្នាំ២០១២

# ឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

## ដីកាបង្គាប់ឲ្យស៊ើបអង្កេតបឋម

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញរបាយការណ៍លេខ: .../១១ តពទ.បជ ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ របស់សាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាលឱ្យប្រើតាមព្រះរាជក្រម លេខ: នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

**សម្រេច**

**១**-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណីឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

**២**-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ ... ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

អយ្យការ
អមសាលាដំបូង
ខេត្តបន្ទាយមានជ័យ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កំណត់ហេតុទទួលវត្ថុតាង

ឆ្នាំពីរពាន់ដប់បី ខែ ... ថ្ងៃទី ពីរ វេលាម៉ោង ដប់ និង សូន្យ នាទី ។
យើង ...ក្រឡាបញ្ជីនៃអយ្យការ អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។
លោក ... ជាមន្ត្រីនគរបាលយុត្តិធម៌នៃស្នងការនគរបាលខេត្តបន្ទាយមានជ័យ
ជាអ្នកប្រគល់រួមជាមួយនិងឈ្មោះ ....ឈ្មោះ ....ឈ្មោះ ...ពីបទៈជួញដូរនិងប្រើប្រាស់ដោយខុសច្បាប់នូវសាធាតុញៀន

បានពិនិត្យគឺនភាគវត្ថុតាង ដែលទាក់ទងក្នុងសំណុំរឿងលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ឃើញដូចខាងក្រោមៈ

១-កញ្ចប់ពណ៌សបិទជិតមានស្នាមមេដៃឈ្មោះ ....ឈ្មោះ ...និងហត្ថលេខាលោក ...លោក ...និងលោក ... ។

២-ទូរស័ព្ទចំនួន ០៦ គ្រឿង មួយគ្រឿងម៉ាក់ SAMSUNG ពណ៌ខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់NOKIA E99I ពណខ្មៅស៊ីមពីរ(ចិន) .មួយគ្រឿងម៉ាក់ NOKIA X1 ពណ៌ខ្មៅ(ចិន) .មួយគ្រឿងទៀតម៉ាក់ NOKIA ចុចពិលពណ៌ផ្កាឈូកលាយពណ៌ស (ចាស់) .មួយគ្រឿងម៉ាក់ NOKIA ចុចពិលពណ៌ខ្មៅបិទស្កុតពណ៌ទឹកប្រាក់ និងមួយគ្រឿងទៀតម៉ាក់ HUAWEI ពណ៌ខ្មៅលាយពណ៌ស។

៣-កាបូបលុយចំនួនមួយពណ៌ខៀវ(គ្មានលុយ).ដែកកេះចំនួនពីរ.កាបូបស្ពាយតូចចំនួនមួយពណ៌ប្រផេះ.សំបកប្រអប់ស្រោមអនាម័យOKចំនួនមួយ.ថង់តូចពណ៌សមួយចំនួន.បំពុងទុយយចំនួនពីរ.កំរបជបទឹកចោះដាក់ទុយយមួយ។

៤-អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរចំនួនពីរ.មួយមានលេខៈ...របស់ឈ្មោះ...និងមួយទៀតមានលេខៈ... របស់ឈ្មោះ ...។

៥-លុយខ្មែរចំនួន ៥០០០០ រៀល និងលុយដុល្លារចំនួន ១០ ដុល្លារ។

៦-ម៉ូតូមួយគ្រឿងម៉ាក់ VIVA ពណ៌ខ្មៅសេរីឆ្នាំ ២០១០ គ្មានកញ្ចក់ .គ្មានកន្ត្រក ពាក់ផ្លាក់លេខៈ ...លេខម៉ាស៊ីន ...។

បញ្ឈប់កំណត់ហេតុនេះនៅវេលាម៉ោង ដប់និងសែសិប នាទី នាថ្ងៃ ខែឆ្នាំដដែល ។

អ្នកប្រគល់ ក្រឡាបញ្ជី ជនជាប់សង្ស័យ

បានឃើញ
បន្ទាយមានជ័យ.ថ្ងៃទី ... ខែ ...ឆ្នាំ ២០១៣
**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្តពោធិ៍សាត់
*សំណុំរឿងព្រហ្មទណ្ឌ*
*លេខ............*
*ចុះថ្ងៃទី ... ខែ... ឆ្នាំ២០១៦*

# កំណត់ហេតុស្តាប់ចម្លើយ

ឆ្នាំ ពីរពាន់ដប់ប្រាំមួយ ខែធ្នូ ថ្ងៃទីពីរ វេលាម៉ោង ដប់ និងសូន្យ នាទី។
យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់ អមដោយលោកជាក្រឡាបញ្ជី ។
យើងបានស្តាប់ចម្លើយឈ្មោះ...ជាជនសង្ស័យដោយមានលោក...ជាមេធាវីការពារ។
បានមកបង្ហាញខ្លួន នៅចំពោះមុខយើង ដែលមានអត្តសញ្ញាណដូចខាងក្រោម:
នាមត្រកូល ៖ ... នាមខ្លួន ៖ ...
ភេទ: ប្រុស
កើតថ្ងៃទី ៖ អាយុ ... ឆ្នាំ
ទីកន្លែងកំណើត ៖ភូមិ...ខេត្តពោធិ៍សាត់
អាសយដ្ឋាន ៖ភូមិ...ខេត្តពោធិ៍សាត់
មុខរបរ ៖ ...
សាសនា: ព្រះពុទ្ធ
☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ៖
សញ្ជាតិ ៖ ខ្មែរ
ឪពុកឈ្មោះ ៖ ... "រ" ម្តាយឈ្មោះ ៖ ... "រ"
អនីតិជន ☐ ឬ នីតិជន ☐
ប្រវត្តិនៃការផ្តន្ទាទោសពីមុនគ្មាន
ជននេះ ៖ ☐ ចេះនិយាយ ☐ ចេះអាន ☐ ចេះសរសេរអក្សរខ្មែរ
ជននេះ ៖ ☐ មិនចេះនិយាយ ☐ មិនចេះអាន ☐ មិនចេះសរសេរអក្សរខ្មែរ
**សួរ-ឆ្លើយ៖** នៅថ្ងៃទី... ខែ... ឆ្នាំ២០១៦ វេលាម៉ោងប្រហែលជា២១ជាង មិត្តភក្តិរបស់ខ្ញុំមានគ្នាបីនាក់ ១.ឈ្មោះ ...២.... ៣.ឈ្មោះ ... ជិះម៉ូតូ០២គ្រឿងមកបបួលខ្ញុំនៅផ្ទះ

នៅភូមិ...ខេត្តពោធិ៍សាត់ ថាទៅដុតត្រីហុប ពេលនោះខ្ញុំនិងមិត្តភក្តិរៀបចេញដំណើរ ស្រាប់តែសមត្ថកិច្ចមកដល់ ហើយបានហៅពួកខ្ញុំទាំងបួននាក់ មកអធិការដ្ឋាននគរបាលក្រុងពោធិ៍សាត់ សមត្ថកិច្ចបានឆែកឆេរក្នុងម៉ូតូ របស់ខ្ញុំ ឃើញមានក្រដាសអាលុយមីញ៉ូមហើយទុយយូមួយដើម និងពិនិត្យទឹកនោមខ្ញុំ ឃើញមានសារធាតុញៀន ។

**សួរ.ឆ្លើយ៖** ខ្ញុំធ្លាប់ប្រើប្រាស់ថ្នាំញៀន ហើយប្រើប្រាស់លើកចុងក្រោយមុនថ្ងៃចាប់ខ្លួនពីរឬបីថ្ងៃ ប្រើម្នាក់ឯងក្នុងផ្ទះរបស់ខ្ញុំ។ថ្នាំញៀនដែលខ្ញុំប្រើប្រាស់នេះ ទិញពីឈ្មោះ ...ណាត់យកមកឲ្យនៅផ្លូវ...ខេត្តពោធិ៍សាត់ ទិញតំលៃ៣ម៉ឺនរៀល។

**សួរ.ឆ្លើយ៖** ពួកម៉ាកបីនាក់ទៀត សមត្ថកិច្ចបានឆែកឆេរអត់ឃើញមានអីពាក់ ពន្ធ័បានឲ្យទៅផ្ទះវិញ ។

**សួរ.ឆ្លើយ៖** ខ្ញុំមិនដែលរកស៊ីជួញដូរ និងចែកចាយថ្នាំញៀនទេ។

**សួរ.ឆ្លើយ៖** នៅក្នុងថ្ងៃខែមិនចាំ ក្នុងឆ្នាំ... ពេលយប់មិនចាំម៉ោង ខ្ញុំបានជិះម៉ូតូម៉ាកស៊ីរូស អត់មានផ្លាកលេខ ចេញពីផ្ទះដើម្បីទៅទិញមីនិងបារីជក់ ពេលជិះមកដល់ស្ពានដែក (ផ្លូវរថភ្លើង) តាមផ្លូវមោត់ស្ទឹង ស្រាប់តែមានរថយន្តតូចមួយគ្រឿង បានជិះមកគៀរម៉ូតូរបស់ខ្ញុំបណ្តាលឲ្យដួល ហើយឃើញគេចុះពីលើឡានរួចស្រែកឲ្យខ្ញុំឈប់ ឃើញដូច្នេះខ្ញុំក៏រត់ចោលម៉ូតូ មកដេកផ្ទះ ។

**សួរ.ឆ្លើយ៖** ពេលបាត់ម៉ូតូខ្ញុំមិនបានប្តឹងសមត្ថកិច្ចទេ ក្រោយមកលឺដំណឹងថាម៉ូតូរបស់ខ្ញុំ នៅប៉េអឹមហើយពាក់ពន្ធ័និងថ្នាំញៀន លឺដូចឆ្នេះខ្ញុំមិនហ៊ានទៅសុំម៉ូតូវិញទេ ព្រោះខ្លាចគេចោទ ថាជួញដូរថ្នាំញៀន ។

**សួរ.ឆ្លើយ៖** ពេលខ្ញុំរត់ចោលម៉ូតូ ខ្ញុំមិនមានថ្នាំញៀនទេហើយថ្នាំញៀនដែលសមត្ថកិច្ចដកហូតបាន ខ្ញុំមិនដឹងថាជារបស់អ្នកណាឡើយ ។

*បញ្ចប់កំណត់ហេតុវេលាម៉ោង ដប់ និង សែសិបប្រាំនាទី នាថ្ងៃ ខែ ឆ្នាំ ដដែល។*

យើងបានប្រាប់ជននេះឱ្យអានឡើងវិញនូវចម្លើយទាំងអស់របស់ខ្លួន ដែលយើងបានកត់ចម្លងចូលក្នុង កំណត់ហេតុនេះ ហើយបើមិនបដិសេធត្រង់ចំណុចណាទេ ផ្តិតម្រាមដៃលើកំណត់ហេតុនេះ ។

បានអានចប់សព្វគ្រប់ ហើយជននេះមិនមានបដិសេធចំណុចណាទេ និង ចុះហត្ថលេខា ឬ ផ្តិតម្រាម ដៃជាមួយយើង ។

| | | |
|---|---|---|
| **អ្នកឆ្លើយ** | **ក្រឡាបញ្ជី** | **ព្រះរាជអាជ្ញារង** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*បន្ទាយមានជ័យ*

កំណត់ហេតុស្រុះស្រួល

ឆ្នាំពីរពាន់ដប់ពីរ ខែ មេសា ថ្ងៃទី ពីរ វេលាម៉ោង ពីរ និង ដប់ នាទី នៅអយ្យការអម សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានធ្វើការស្រុះស្រួលរវាងដើមចោទ និងជនជាប់សង្ស័យ ដូចតទៅ:

-ភាគីដើមចោទឈ្មោះ ... ភេទ ប្រុស អាយុ ... នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានប្តឹងឈ្មោះ ... ភេទ ... ឲ្យប្រគល់ដី ស្រែចំនួន កន្លះហិចតា ឲ្យមកខ្លួនវិញ។

-ជនជាប់សង្ស័យឈ្មោះ ... ភេទ ... អាយុ ... ឆ្នាំ រស់នៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ បានស្រុះស្រួលជាមួយដើមបណ្តឹងដោយយល់ព្រមប្រគល់ដីស្រែចំនួន កន្លះ ហិចតា នេះស្ថិតនៅភូមិ... ឃុំ... ស្រុក... ខេត្តបន្ទាយមានជ័យ ឲ្យដើមបណ្តឹងឈ្មោះ ... ដើម្បីគ្រប់គ្រង និងបានយល់ព្រមសងស្រូវទៅដើមបណ្តឹងវិញចំនួន ០៦ បាវ។

ការស្រុះស្រួលគ្នានេះ ដើមបណ្តឹងឈ្មោះ ... សុខចិត្តដកពាក្យបណ្តឹងឈប់ប្តឹងពីជនជាប់សង្ស័យឈ្មោះ ... វិញហើយ។

បញ្ឈប់កំណត់ហេតុនៅវេលាម៉ោង ពីរ និងហាសិប នាទី នាថ្ងៃ ខែ ឆ្នាំដដែល រួច បានអានឲ្យស្តាប់ ឆ្លើយថាត្រឹមត្រូវ និងយល់ព្រមផ្តិតមេដៃ និងចុះហត្ថលេខាទុកចំណាំ។

ដើមបណ្តឹង ជនជាប់សង្ស័យ

បានឃើញ
ថ្ងៃទី ខែ ... ឆ្នាំ ២០១២
ព្រះរាជអាជ្ញា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូង ខេត្តពោធិ៍សាត់**
សំណុំរឿងព្រហ្មទណ្ឌលេខ ...
ចុះថ្ងៃទី ... ខែ ... ឆ្នាំ...

## ដីកាកោះ

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

បង្គាប់មកឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ ជាសាក្សី ។

ទីលំនៅបច្ចុប្បន្ននៅភូមិ...ខេត្តពោធិ៍សាត់ ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង២.០០ រសៀល ថ្ងៃទី ... ខែ... ឆ្នាំ... ។

ដើម្បី **សួរយកចម្លើយ**

ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី ... ខែ... ឆ្នាំ ... នៅ ចំណុច...ភូមិ...ខេត្តពោធិ៍សាត់។**

សាមីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

យើង..............................................................បានប្រគល់ដីកាកោះនេះដល់

ឈ្មោះ..................................ទីលំនៅបច្ចុប្បន្ននៅភូមិ................... ឃុំ/សង្កាត់ ........................................ ស្រុក/ខណ្ឌ...............ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ.................ឆ្នាំ...................................ហើយយើងបានប្រាប់ថា ឱ្យយកចុង ដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលា ដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៚

អយ្យការអម

សាលាដំបូងខេត្ត

*បន្ទាយមានជ័យ*

*លេខ៖*

## ដីកាផ្ទេរសមត្ថកិច្ច

+++++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញសុំណុំរឿងព្រហ្មទណ្ឌលេខៈ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១១ ។

-បានឃើញមាត្រា ១១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជក្រម លេខៈ នស/រកម ០៨០៧/០២៤ ចុះថ្ងៃទី ០១ ខែ សីហា ឆ្នាំ ២០០៧។

### សម្រេច

១-បង្គាប់ឱ្យសាខាកាំកុងត្រូលខេត្តបន្ទាយមានជ័យ បើកការស៊ើបអង្កេតបឋម លើករណី ឈ្មោះ ... ហើយឱ្យឈ្មោះ ... បង់ប្រាក់ពិន័យអន្តរកាលទៅតាមនីតិវិធី។

២-ពេលស៊ើបអង្កេតចប់បញ្ជូនសំណុំរឿងមកអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យវិញ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**
********

អយ្យការអម
*សាលាដំបូងខេត្ត*
**បន្ទាយមានជ័យ**
**********

លេខ: អក.បជ

# ដីកាបញ្ជាស្វែងរកចាប់ខ្លួន

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត **បន្ទាយមានជ័យ**

បានឃើញ: មាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ: នស/រ កម ០៨ ០៧/០២៨ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ២០០៧ ។

បានឃើញ:របាយការណ៍លេខ: ... ព.គ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២ ស្តីពីទណ្ឌិតឈ្មោះ ... ភេទប្រុស អាយុ ... ឆ្នាំ ពុំមានឃុំខ្លួននៅក្នុងពន្ធនាគារ (រត់គេចខ្លួន)។

## <u>យល់ឃើញថា:</u>

-ទណ្ឌិតឈ្មោះ ...ភេទប្រុស អាយុ... ឆ្នាំ ជាប់ចោទពីបទ: ជួញដូរគ្រឿងញៀនខុស ច្បាប់ ហើយត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យ សម្រេចផ្តន្ទាទោសដាក់ពន្ធនាគារកំណត់ ១០ ឆ្នាំ តាមអំណាចសាលក្រមលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០០៣ ។

-តាមរបាយការណ៍របស់ពន្ធនាគារបានបញ្ជាក់ថា: ទណ្ឌិតរូបនេះមិនបានជាប់ឃុំនៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ (រត់គេចខ្លួន) ។

-តាមកំណត់ហេតុស្តីពីការចុះត្រួតពិនិត្យពន្ធនាគារ ចុះថ្ងៃទី... ខែ...ឆ្នាំ២០១១ បញ្ជាក់ថា ទណ្ឌិតឈ្មោះ ...នៅព្យាបាលជម្ងឺនៅប្រទេសវៀតណាម តែពុំមានកំលាំងពន្ធនាគារការពារ នោះទេ ។

-តាមមាត្រា ៥១១ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជាបានបញ្ជាក់ថា: ក្នុងករណីដែលអ្នកទោសរត់ចេញពីពន្ធនាគារ ឬមណ្ឌលឃុំខ្លួននោះ ព្រះរាជអាជ្ញាចេញបញ្ជាស្វែងរកចាប់ខ្លួន និងចាត់វិធានការជាបន្ទាន់ដើម្បីអនុវត្តបញ្ជាស្វែងរកចាប់ខ្លួន ។

## <u>ហេតុដូច្នេះសម្រេច</u>

-បង្គាប់ឲ្យមន្ត្រីនគរបាលយុត្តិធម៌ និងកងកំលាំងសាធារណៈស្រាវជ្រាវរកចាប់ខ្លួន និងនាំខ្លួនទណ្ឌិតខាងលើនេះទៅក្នុងពន្ធនាគារខេត្តបន្ទាយមានជ័យ ក្នុងរយៈពេលយ៉ាងខ្លីបំផុតដើម្បីធ្វើការឃុំខ្លួន ។

បន្ទាយមានជ័យ ថ្ងៃទី ខែ... ឆ្នាំ២០១២

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

លេខ.......................អយ/១៧

**លិខិតអញ្ជើញ**

**យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត**

អញ្ជើញ លោក ... ភេទប្រុស ជានាយកមន្ទី... ។

ឱ្យចូលទៅកាន់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

នៅវេលាម៉ោង ២.០០ រសៀល ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៧ ។

ដើម្បី បំភ្លឺ ពីដំណើររឿង **បង្ក្រាបបទល្មើសព្រៃឈើ កាលពីថ្ងៃទី... ខែ... ឆ្នាំ ២០១៦ នៅចំណុច... ភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ។**

សាម៉ីខ្លួនត្រូវអញ្ជើញទៅឱ្យទាន់ពេលវេលា និងយកលិខិតផ្សេងៗ ដែលទាក់ទងនិងរឿង ខាងលើ មកជាមួយផងប្រសិនបើមាន។

ធ្វើនៅពោធិ៍សាត់, ថ្ងៃទី ... ខែ ....ឆ្នាំ ២០១៧

**ព្រះរាជអាជ្ញារង**

យើង........................................................................បានប្រគល់ដីកាអញ្ជើញនេះដល់

ឈ្មោះ....................................ទីលំនៅបច្ចុប្បន្ននៅភូមិ.................... ឃុំ/សង្កាត់ ........................................... ស្រុក/ខណ្ឌ................ខេត្ត/ក្រុង..........................នៅថ្ងៃទី .........ខែ..................ឆ្នាំ....................................ហើយយើងបានប្រាប់ថា ឱ្យយកចុងដីកានេះទៅ ប្រគល់ដល់ក្រឡាបញ្ជី នៅពេលដែលខ្លួនចូលទៅចំពោះ មុខសាលាដំបូងខេត្តពោធិ៍សាត់។

**អ្នកទទួល** **អ្នកប្រគល់**

**ហត្ថលេខា ឬ ស្នាមមេដៃ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការ អម
សាលាដំបូងខេត្ត ពោធិ៍សាត់
លេខ.................

# លិខិតជូនដំណឹង

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់

សូមជូនដំណឹងលោក ... អាយុ ... ឆ្នាំ មានទីលំនៅ ភូមិ.... ឃុំ... ស្រុក... ខេត្តបាត់ដំបង អោយបានជ្រាបថា:

ពាក្យបណ្តឹងរបស់លោក ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ ដែលបាន ប្តឹងលោក ... អាយុ...ឆ្នាំមានទីលំនៅភូមិ... ឃុំ... ស្រុក... ខេត្តកំពង់ឆ្នាំង ថា: **បានបង្កគ្រោះថ្នាក់ចរាចរណ៍** ប្រព្រឹត្តនៅភូមិ... ឃុំ... ស្រុក... ខេត្តពោធិ៍សាត់ ដែលមានសំណុំរឿងព្រហ្មទណ្ឌ លេខ:... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៣ នោះត្រូវបានតំណាងអយ្យការតម្កល់រឿងទុកឥតចាត់ការ តាមដីការតម្កល់រឿងទុកឥតចាត់ការ លេខ:... អយ/១៦ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ហើយ សូមលោកជ្រាប។

លោកមានសិទ្ធិប្តឹងតវ៉ារយៈពេលពីរខែគិតចាប់ពីថ្ងៃលោកបានទទួលដំណឹងនេះ។

ពោធិ៍សាត់, ថ្ងៃទី... ខែ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

អង្គហេតុនេះជាបទល្មើស: ***រំលោភលំនៅដ្ឋាន*** តាមមាត្រា ២៩៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៨។

-យើងបានទទួលចម្លើយសារភាពអំពីជនជាប់ចោទឈ្មោះ ... ថា: ពីថ្ងៃទី... ខែ... ឆ្នាំ ២០១៨ ឪពុកម្ដាយរបស់ខ្លួនឈ្លោះប្រកែកគ្នា ខ្លួនធុញពេកក៏បានចូលទៅផ្ទះរបស់គេនៅម៉ុ
បេន

ឡានដោយយកដែកគាស់ជញ្ជាំងហើយលូនចូលទៅក្នុង បន្ទាប់មកខ្លួនបានរុញទូររបស់គេទៅកៀនដើម្បីយកកន្លែងដេកបណ្ដាលឲ្យទូរបែកកញ្ចក់ ពេលនោះម្ចាស់គេមកដល់ក៏ចាប់ខ្លួនឲ្យសមត្ថកិច្ចតែម្ដង។

យើងបានប្រាប់ដល់ជននេះថា: ខ្លួនមានសិទ្ធិពឹងពាក់មេធាវីតាមការជ្រើសរើសរបស់ខ្លួន រឺ ស្នើសុំឲ្យ មានការចាត់តាំងមេធាវី ដោយអនុឡោមតាមបញ្ញត្តិច្បាប់ ។

ជននេះបានឆ្លើយថា:

☐ខ្ញុំជ្រើសរើសលោក-លោកស្រីមេធាវី........................................................។

☐ ខ្ញុំសូមស្នើសុំឲ្យមានការចាត់តាំងមេធាវីស្របតាមបញ្ញត្តិច្បាប់ ។

☐ ខ្ញុំមិនត្រូវការមេធាវីទេនៅពេលនេះ ។

យើងបានបញ្ជាក់ថា:

☐ លោក-លោកស្រីមេធាវី ..............................................អាចពិនិត្យសំណុំរឿង នឹងទាក់ជា មួយជនត្រូវចោទ

☐ យោងលើសំណើសុំ ឲ្យមានការចាត់តាំងមេធាវី ស្របតាមបញ្ញត្តិច្បាប់ស្ដីពីលក្ខន្តិកៈមេធាវី តំណាងគណៈមេធាវីត្រូវបានជូនដំណឹងភ្លាម ។

☐លោក-លោកស្រីមេធាវី..........................................................អវត្តមាន ។

បានឃើញមាត្រា ៤៧ , ៤៨ និងមាត្រា ៣០៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

**យល់ឃើញថា:** បទល្មើសជាបទល្មើសមជ្ឈិមជាក់ស្ដែង

**យល់ឃើញថា:** ជនជាប់ចោទជានីតិជន ។

**យល់ឃើញថា:** រឿងក្ដីមានលក្ខណៈគ្រប់គ្រាន់ល្មមជំនុំជម្រះបាន ។

សម្រេច

-បញ្ជូនជនជាប់ចោទឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ ទៅតុលាការដើម្បីជំនុំជម្រះពីបទ: ***រំលោភលំនៅដ្ឋាន*** តាមមាត្រា ២៥៩ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៥

តាមនីតិវិធីនៃការបង្ហាញខ្លួនភ្លាម ចំពោះអង្គហេតុ និង បទល្មើសខាងលើ ។

ក្រោយពីបានអាន ជនជាប់ចោទបានផ្តិតមេដៃ ជាមួយយើង ។

ជនជាប់ចោទ                    តំណាងអយ្យការ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការអម
សាលាដំបូងរាជធានីភ្នំពេញ
លេខ........................

# ដីកាតម្កល់រឿងទុកឥតចាត់ការ

យើង ............តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:..................ចុះថ្ងៃទី........ខែ.........ឆ្នាំ២០១....
.របស់អយ្យការអមសាលាដំបូងរាជធានីភ្នំពេញ
និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

**១- អវត្តមានបទល្មើស**

☐ ១.១. អវត្តមានបទល្មើស

**២- ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់**

☐ ២.១. ធាតុផ្សំបទល្មើសមិនគ្រប់គ្រាន់

**៣- មូលហេតុគតិយុត្ត**

☐ ៣.១. ការដកពាក្យបណ្តឹង

☐ ៣.២. ការលើកលែងទោសជាទូទៅ

☐ ៣.៣. មរណភាពជនល្មើស

☐ ៣.៤. ផុតអាជ្ញាយុកាល

☐ ៣.៥. និរាករណ៍នៃច្បាប់ព្រហ្មទណ្ឌ

☐ ៣.៦. អាជ្ញាអស់ជំនុំ

☐ ៣.៧. ការសម្របសម្រួលជាមួយរដ្ឋ

☐ ៣.៨. ការបង់ប្រាក់ពិន័យសរុប ឬពិន័យសម្របសម្រួល

☐ ៣.៩. អភ័យឯកសិទ្ធ

☐ ៣.១០. អនិយ័តភាពនៃនីតិវិធី

☐ ៣.១១. ការរួចផុតពីការទទួលខុសត្រូវរបស់ជនល្មើស[1]

**៤- ការចោទប្រកាន់មិនផ្តល់ប្រយោជន៍**

☐ ៤.១. ការស្វែងរកមិនបានផល

☐ ៤.២. ការបោះបង់ពាក្យបណ្តឹងរបស់ដើមបណ្តឹង[2]

☐ ៤.៣ ស្ថានភាពវិបល្លាសស្មារតីដែលបន្ថយនូវការដឹងខុសត្រូវ

☐ ៤-៤ ការខកខានរបស់ដើមបណ្តឹង

☐ ៤.៥. អាកប្បកិរិយារបស់ជនរងគ្រោះ

☐ ៤.៦. ជនរងគ្រោះមិនចាប់អារម្មណ៍ នឹងបទល្មើស

☐ ៤.៧. និយ័តកម្មដោយឯកឯង[3]

☐ ៤.៨. ព្យសនកម្ម ឬការរំខានតិចតួចបង្កដោយបទល្មើស

**៥- នីតិវិធីជាជម្រើសអនុវត្តដោយព្រះរាជអាជ្ញា**

☐ ៥.១. ការជួសជុលការខូចខាតដោយ/ដល់អនីតិជន

☐ ៥.២. សន្ធានកម្ម[4]

☐ ៥.៣. អចិបញ្ញាផ្តល់ការព្យាបាល

☐ ៥.៤. ជនរងគ្រោះ/ដើមបណ្តឹងបោះបង់បណ្តឹង តាមការស្នើសុំរបស់ព្រះរាជអាជ្ញា

☐ ៥.៥. និយ័តកម្មតាមសំណើររបស់ព្រះរាជអាជ្ញា

☐ ៥.៦. ការរំលឹកពីអត្ថបទច្បាប់/ការព្រមាន[5]

☐ ៥.៧. ការកំណត់ទិសដៅចំពោះរចនាសម្ព័ន្ធនៃសុខភាព នៃសង្គម ឬវិជ្ជាជីវៈ

☐ ៥.៨. ការសម្រុះសម្រួលព្រហ្មទណ្ឌ[6]

**៦- នីតិវិធីជាជម្រើសអនុវត្តដោយអាជ្ញាធរផ្សេងៗ**

---

[1]) ដូចជាមូលហេតុ វិកលចរិត ការការពារស្របច្បាប់ ការបង្ខំ ស្ថានភាពចាំបាច់

[2]) ដើមបណ្តឹងឈប់ប្តឹង

[3]) សកម្មភាពដែលជនល្មើសបានបញ្ឈប់បទល្មើស និង ស្តារស្ថានភាពឡើងវិញ

[4]) ករណីចែងដោយច្បាប់

[5]) ព្រះរាជអាជ្ញាប្រាប់អំពីអំពើដែលជាបទល្មើស តាមកំណត់ច្បាប់ និងធ្វើការព្រមានឲ្យឈប់ប្រព្រឹត្ត

[6]) ករណីចែងដោយច្បាប់

☐ ៦.១. ការចោទប្រកាន់ ឬទណ្ឌកម្មផ្សេងទៀតមិនមែនព្រហ្មទណ្ឌ

**៧-ជនល្មើសមិនត្រូវបានស្គាល់**

☐ ៧.១. ជនល្មើសមិនត្រូវបានស្គាល់

**៨-ជំនួយការអប់រំ**

☐ ៨.១. ការផ្តល់ជំនួយការអប់រំជំនួសការចោទប្រកាន់

**ការអង្កេតផ្សេងៗ ៖**កាលពីថ្ងៃទី.......................................................................

.................................................................................................................................................

.......................................................................................................................................

**បានឃើញ:**

-កំណត់ហេតុស្តាប់ចម្លើយដើមបណ្តឹងឈ្មោះ

-កំណត់ហេតុស្តាប់ចម្លើយជនសង្ស័យឈ្មោះ ។

-ពាក្យស្នើសុំដកបណ្តឹងរបស់ឈ្មោះ ចុះថ្ងៃទី ...........ខែ ........... ឆ្នាំ ...........។

**យល់ឃើញថា:**

-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ

**ហេតុដូច្នេះ សម្រេច**

-តម្កល់រឿងព្រហ្មទណ្ឌលេខ ........... ថ្ងៃទី ..... ខែ ........... ឆ្នាំ ........... ទុកឥតចាត់ការតទៅ។

ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី... ខែ....... ឆ្នាំ........

**ព្រះរាជអាជ្ញារង**

អយ្យការអម

សាលាដំបូងខេត្ត

*ពោធិ៍សាត់*

*លេខ៖*

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

# ដីកាបញ្ជូនរឿងទៅជំនុំជម្រះផ្ទាល់

យើង ............ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ចុះថ្ងៃទី ខែ ឆ្នាំ ២០ ។

បានឃើញមាត្រា ៨៣ និង ៨៦ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ដែលប្រកាសឱ្យប្រើតាមព្រះរាជ ក្រមលេខ: នស/រ កម ០៨ ០៧/០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា ៖**

១-នាមត្រកូលនាមខ្លួន ៖ ភេទ សញ្ជាតិ ៖ ខ្មែរ

កើតថ្ងៃទីខែឆ្នាំ ៖

ទីកន្លែងកំណើត ៖ភូមិ ឃុំ ស្រុក ខេត្ត

អាស័យដ្ឋានសព្វថ្ងៃ:ភូមិ ឃុំ ស្រុក ខេត្ត

មុខរបរ ៖ ប្តីឬប្រពន្ធឈ្មោះ ៖ កសិករ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖ "រ"

អនីតិជន ☐ ឬ ☐ នីតិជន

**ឃើញថា:**

កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៨

ពីបទ: ដែលល្មើសមាត្រា នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

-ឯកសារនានាទាក់ទងសំណុំរឿង លេខ: ចុះថ្ងៃទី ខែ ឆ្នាំ ២០១៨ ។

-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ

-តាមចម្លើយរបស់ជនរងគ្រោះឈ្មោះ

-តាមរបាយការលេខ:

**យល់ឃើញថា:**

-

-អង្គហេតុខាងលើ មានលក្ខណៈមូលសព្វគ្រប់ និងភស្តុតាងដែលប្រមូលបានអាចកំណត់អំពីធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ហេតុ ដូច្នេះគប្បីសម្រេចបញ្ជូនសំណុំរឿងនេះដោយផ្ទាល់ទៅសាលាដំបូង ខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះតាមច្បាប់ជាធរមាន។

**ហេតុដូច្នេះសម្រេច ៖**

**បញ្ជូនជនជាប់ចោទ** ឈ្មោះ ភេទ អាយុ ឆ្នាំ ពីបទៈ ដែលល្មើសមាត្រា ប្រព្រឹត្តនៅភូមិឫស្សីក្រោក ឃុំឫស្សីក្រោក ស្រុកមង្គលបូរី ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី ខែ ឆ្នាំ ២០១៨។**ទៅសាលាដំបូងខេត្ត បន្ទាយមានជ័យ ដើម្បីជំនុំជម្រះ តាមនីតិវិធីកោះហៅបញ្ជូនទៅជំនុំជំម្រះផ្ទាល់ ចំពោះអង្គហេតុខាងលើ ។**

បន្ទាយមានជ័យ ថ្ងៃទី ខែ ឆ្នាំ ២០១

**តំណាងអយ្យការ**

អយ្យការអម

សាលាដំបូងខេត្ត

*ពោធិ៍សាត់*

*លេខ៖...........*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

# ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ

យើង ............ តំណាងអយ្យការអម សាលាដំបូងខេត្ត ពោធិ៍សាត់

បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ .... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១...

បានឃើញរបាយការណ៍របស់អធិការដ្ឋាននគរបាលស្រុកក្រគរ លេខ: ...

ចុះថ្ងៃទី... ខែ... ឆ្នាំ២០១... ។

ក្រោយពីបានពិនិត្យឯកសារខាងលើ

**ឃើញថា មានតម្រុយសន្មតបានថា:**

១-នាមត្រកូល ៖ ... នាមខ្លួន ............ហៅតា ភេទ...

អាយុ ៖ ....ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន ៖ .............................................................................

មុខរបរ ៖ ...

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ..............

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

២-នាមត្រកូល ៖........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ............ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................................

អាសយដ្ឋាន៖ ......................................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ........... នាមខ្លួន ........... ភេទ...........

អាយុ ៖ ...........ឆ្នាំ

ទីកន្លែងកំណើត៖ ...........................................................

អាសយដ្ឋាន ៖ ...........................................................

មុខរបរ ៖ ...........

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្រពន្ធ ៖ ...........

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ ........... "ស" ម្តាយឈ្មោះ ៖ ........... "ស"

អនីតិជន ☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

កាលពីថ្ងៃទី........... ខែ...........ឆ្នាំ........... វេលាម៉ោង...........និង...........នាទី មានបទល្មើស........... ........... ...........នៅតំបន់........... ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ បង្កឡើងដោយជនសង្ស័យចំនួន០៧នាក់ ១.ឈ្មោះ...........ភេទ........... អាយុ ...........ឆ្នាំ ជា...........២.ឈ្មោះ ........... ភេទ........... ហៅ ........... ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ........... ភេទ ........... អាយុ ...........ឆ្នាំ។ ពេលទទួលបានបណ្តឹងពីប្រជាពលរដ្ឋ លោកអធិការបានបញ្ជាឲ្យលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ ដោយសហការជាមួយប៉ុស្តិ៍ ........... ចុះទៅកន្លែងកើតហេតុដើម្បីធ្វើការស្រាវជ្រាវ បន្ទាប់ពីទៅដល់កន្លែងកើតហេតុលោកអធិការរងទទួលផែនការយុត្តិធម៌ ដឹកនាំផ្នែកជំនាញ និងប៉ុស្តិ៍........... ធ្វើការស្រាវជ្រាវកំណត់មុខសញ្ញា ។លុះដល់ថ្ងៃទី........... ខែ........... ឆ្នាំ........... កំលាំងអធិការដ្ឋាននគរបាលស្រុក........... ធ្វើការឃាត់ខ្លួន ១.ឈ្មោះ........... ភេទ........... អាយុ ...........

ឆ្នាំ ជាប្រធានអង្គការ........... ២.ឈ្មោះ ...........ភេទ........... ហៅ...........ភេទ........... អាយុ ...........ឆ្នាំ ៣.ឈ្មោះ ........... ភេទ........... អាយុ...........ឆ្នាំ ៤.ឈ្មោះ ........... ភេទ ........... អាយុ ...........ឆ្នាំ ៥.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ៦.ឈ្មោះ ........... ភេទ........... អាយុ ...........ឆ្នាំ ៧.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ ០៦នាក់ជាសមាជិក...........។

អំពើខាងលើជាបទល្មើសៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ........... ស្ថិតនៅភូមិ...........ឃុំ...........ស្រុក........... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី...........ខែ........... ឆ្នាំ...........។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សម្រេច ៖

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

1.ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ ៖

ក. ឈ្មោះ ...........ហៅ........... អាយុ ...........ឆ្នាំ

ខ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

គ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ឃ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ង.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ច.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ឆ.ឈ្មោះ ...........ភេទ........... អាយុ ...........ឆ្នាំ

ពីបទៈ កំហែងយក តាមមាត្រា ៣៦៣,៣៦៤ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅ ..................... ស្ថិតនៅភូមិ........... ........... ........... ........... ........... ...........កាលពីថ្ងៃទី ........... ខែ........... ឆ្នាំ...........។

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

ធ្វើនៅពោធិ៍សាត់,ថ្ងៃទី....... ខែ ....... ឆ្នាំ ...........

**ចៅក្រមស៊ើបសួរ**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម
សាលាដំបូងខេត្ត
*ពោធិ៍សាត់*
*លេខ៖*

## ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបទល្មើសថ្មីបន្ថែម

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តពោធិ៍សាត់

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញនីតិវិធីស៊ើបសួរលើឈ្មោះ ... ឈ្មោះ... និង ឈ្មោះ...ជាជនត្រូវចោទពីបទ: ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ និង នៅខណ្ឌ... ក្រុង ... កាលពីថ្ងៃទី... ខែ ... ឆ្នាំ ២០១៦។

**ឃើញថាអង្គហេតុ:** តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ ... ហៅ ... ចំនួនពាក់កណ្តាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកធនៅភូមិរលាប សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកធនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់.... ក្រុង... ខេត្តពោធិ៍សាត់។

☐ ដែលត្រូវបានចៅក្រមស៊ើបសួររកឃើញ ហើយបានជូនដំណឹងតាមលិខិតលេខ... ចុះថ្ងៃទី ... ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ និងសំណុំលិខិតភ្ជាប់មកជាមួយព្រមទាំងភស្តុតាងនានា។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់អយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ ។

-បានឃើញលិខិតជូនដំណឹងលេខ... ចុះថ្ងៃទី ...ខែ... ឆ្នាំ ២០១៦ របស់ចៅក្រមស៊ើបសួរ ស្តីពីលេចចេញនូវអង្គហេតុថ្មី។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

**ឃើញថា មានតម្រុយសន្មតបានថា:**

១-នាមត្រកូល ៖... នាមខ្លួន ៖ ហៅ ... ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

២-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្តី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្តាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

៣-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ សង្កាត់... ក្រុង.... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្ដី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្ដាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

៤-នាមត្រកូល ៖ ... នាមខ្លួន ៖ ភេទ ប្រុស

កើតថ្ងៃទី ៖

ទីកន្លែងកំណើត ៖

អាសយដ្ឋាន ៖ ភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

មុខរបរ ៖

☐ នៅលីវ ឬរៀបការ ☐ ឈ្មោះប្ដី ឬប្រពន្ធ ៖

សញ្ជាតិ ៖ ខ្មែរ

ឪពុកឈ្មោះ ៖ "រ" ម្ដាយឈ្មោះ ៖

អនីតិជន☐ ឬ នីតិជន ☐

## បានប្រព្រឹត្តអំពើដូចតទៅ ៖

តាមចម្លើយរបស់ជនត្រូវចោទឈ្មោះ.... បានឆ្លើយសារភាពថា ៖ កាលពីអំឡុង ខែ... ឆ្នាំ២០១៥ខ្លួនធ្លាប់បានទៅទិញថ្នាំញៀនពីឈ្មោះ... ហៅ ... ចំនួនពាក់កណ្ដាលកន្លះជ្រុង តម្លៃ១២០០០០០រៀល(មួយលានពីរសែនរៀល) ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុង ខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនកន្លះហ៊ុន នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។ នៅអំឡុងខែ... ឆ្នាំ២០១៥ខ្លួនបានទៅទិញថ្នាំញៀនពីឈ្មោះ... ចំនួនមួយហ៊ុន ហើយឈ្មោះ...យកថ្នាំមកចនៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។ នៅចុងខែ... ឆ្នាំ២០១៥ ខ្លួនបានទិញថ្នាំញៀនពីឈ្មោះ ... ចំនួនមួយជ្រុង តម្លៃ៧០០ដុល្លា (ប្រាំពីររយ) ទិញនៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់។

- អំពើខាងលើជាបទល្មើស៖ **ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន** តាមមាត្រា ៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅ ក្រុង... ខេត្តពោធិ៍សាត់ កាលពីអំឡុង ខែ... ខែ... ខែ... ខែ.... ឆ្នាំ ២០១៥។

**យល់ឃើញថា**

-តាមចម្លើយសារភាពរបស់ជនត្រូវចោទឈ្មោះ.... ឃើញថា លេចចេញនូវអង្គហេតុថ្មី ហើយអង្គហេតុថ្មីនេះតំណាងអយ្យការមិនទាន់បានបើកការស៊ើបសួរនៅឡើយ។

បានឃើញមាត្រា ៤៤ និងមាត្រា ១២៤ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**សម្រេច៖**

បើកការស៊ើបសួរលើអង្គហេតុខាងលើ និង:

☐ ដាក់ឱ្យស្ថិតនៅក្រោមការពិនិត្យលើ៖

១-ឈ្មោះ ... ហៅ...ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្ត កាលពីអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ ។

២-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តនៅអំឡុង ខែ... ឆ្នាំ២០១៥ នៅភូមិ... សង្កាត់... ក្រុង ... ខេត្តពោធិ៍សាត់ ។

៣-ឈ្មោះ ... ភេទ ប្រុស

ពីបទ ៖ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៤០ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ប្រព្រឹត្តកាលពីអំឡុងខែ... ឆ្នាំ២០១៥ នៅភូមិ ... សង្កាត់... ក្រុង... ខេត្តពោធិ៍សាត់

☐ ដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការ

☐ ដាក់ឱ្យស្ថិតនៅក្រោមការឃុំខ្លួនបណ្តោះអាសន្ន ៖ ដើម្បីធានារក្សាជនត្រូវចោទ ទុកជូនតុលាការ ចាត់ការតាមនីតិវិធី។

ធ្វើនៅ,ពោធិ៍សាត់ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

អយ្យការអម

សាលាដំបូងខេត្តពោធិ៍សាត់

*លេខ៖*

## ដីកាស្នើសុំឱ្យបំពេញកិច្ចស៊ើបសួរបន្ថែម

យើង ... តំណាងអយ្យការអមសាលាដំបូងខេត្ត ពោធិ៍សាត់។

-បានឃើញមាត្រា ២៤៦ និង ១៣២នៃក្រមនីតិវិធីព្រហ្មទណ្ឌដែលប្រកាសអោយប្រើ

-តាមព្រះរាជក្រមលេខ នស. រកម . ០៨០៧.០២៤ ចុះថ្ងៃទី ១០ ខែ សីហា ឆ្នាំ ២០០៧។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៥។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងអោយស៊ើបសួរលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥។

**ដែលបានបើកការស៊ើបសួរលើ:**

១-ឈ្មោះ ... ភេទ ប្រុស អាយុ...ឆ្នាំ

២-អញ្ញាតជន

ពីបទ៖ អំពើលួច ,ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន និង ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន តាមមាត្រា៣៥៣ ,៣៥៦នៃក្រមព្រហ្មទណ្ឌ និងតាមមាត្រា៤៥ ,៤០នៃច្បាប់ស្តីពីការត្រួតពិនិត្យ គ្រឿងញៀន ។

ប្រព្រឹត្តិនៅសង្កាត់... ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ,ទី...ខែ.... ឆ្នាំ២០១៥។

**បានឃើញ** ៖ដីកាបញ្ជូនអោយឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ... ចុះថ្ងៃទី... ខែ... ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរ។

**យល់ឃើញថា:**

-ដីកាសន្និដ្ឋានបញ្ជូនរឿងឲស៊ើបសួរលេខ ... ចុះថ្ងៃទី...ខែ..។ ឆ្នាំ២០១៥ បានបើកការស៊ើបសួរលើ អញ្ញាតជន ពីបទ ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិ... សង្កាត់...ក្រុង... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ខែ... ឆ្នាំ០១៥។

- ចៅក្រមស៊ើបសួរពុំទាន់បានបំពេញកិច្ចស៊ើបសួរ រកសាវតាជាតិរបស់អញ្ញាតជន នៅឡើយ

**ហេតុដូច្នេះសម្រេច**

១-ស្នើសុំឱ្យចៅក្រមស៊ើបសួរបំពេញកិច្ចស៊ើបសួរបន្ថែម ៖

-បំពេញកិច្ចស៊ើបសួររកសាវតាជាតិរបស់ជនត្រូវចោទ (អញ្ញាតជន) ទៅតាមនីតិវិធ

២-បញ្ជូនសំណុំរឿងលេខ ... ចុះថ្ងៃទី... ខែ... ឆ្នាំ ២០១៥ ទៅចៅក្រមស៊ើបសួរដើម្បីបំពេញកិច្ចស៊ើបសួរបន្ថែម។

ធ្វើនៅពោធិ៍សាត់ ថ្ងៃទី ខែ ... ឆ្នាំ ២០១៦

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

អយ្យការ អម

សាលាដំបូងខេត្តបន្ទាយមានជ័យ

សំណុំរឿងព្រហ្មទណ្ឌ

លេខ:

# ដីកាសន្និដ្ឋានសុំដល់ចៅក្រមស៊ើបសួរកុំឲ្យស៊ើបសួរ

យើង ...តំណាងអយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ:...ចុះថ្ងៃទី...ខែ ...ឆ្នាំ ២០១២របស់ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ។

-បានឃើញ មាត្រា១៣៧ មាត្រា១៣៨ និង មាត្រា១៣៩នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណា ចក្រកម្ពុជា។

-បានឃើញ ដីកាសម្រេចលេខ៖...ព.ស/ព្រ.ទ ចុះថ្ងៃទី... ខែ... ឆ្នាំ២០១២របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងខេត្តបន្ទាយមានជ័យ លើពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី។

## ក្រោយពីបានពិនិត្យឯកសារខាងលើ:

០១-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស អាយុ ...ឆ្នាំ សញ្ជាតិ...
ទីកន្លែងកំណើត: ខេត្ត...
ទីលំនៅបច្ចុប្បន្ន: ភូមិ...ខេត្តបន្ទាយមានជ័យ
មុខរបរ: នៅផ្ទះ (ចាស់ជរា) សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ... (ស្លាប់)
ឪពុកឈ្មោះ ... (ស) ម្ដាយឈ្មោះ ... (ស)
នីតិជន ☑ ឬអនីតិជន □

០២-នាមត្រកូល និងនាមខ្លួន: ...
ភេទប្រុស កើតថ្ងៃទី ... ខែ... ឆ្នាំ ... សញ្ជាតិខ្មែរ
ទីកន្លែងកំណើត: ភូមិ...ខេត្តស្វាយរៀង
ទីលំនៅបច្ចុប្បន្ន: ភូមិ... ខេត្តបន្ទាយមានជ័យ
មុខរបរ: ...សាសនា ព្រះពុទ្ធ
ប្រពន្ធឈ្មោះ ...

ឪពុកឈ្មោះ ... (ស) ម្ដាយឈ្មោះ ... (រ)
និតិជន ☑ ឬអនីតិជន □

**ការសង្កេតផ្សេងៗ៖**

កាលពីថ្ងៃទី ...ឈ្មោះ ...ហៅ ...ភេទប្រុស បានមកដាក់ពាក្យប្ដឹងនៅ អយ្យការអមសាលាដំបូងខេត្តបន្ទាយមានជ័យ ដោយប្ដឹងឈ្មោះ ...ថា៖ បានធ្វើ និង ប្រើប្រាស់នូវឯកសារក្លែងក្លាយលើពាក្យស្នើ សុំដីស្រែ ចុះថ្ងៃទី...ខែ... ឆ្នាំ១...ដើម្បីយកមកធ្វើជាឯកសារយោងសំរាប់ចេញប័ណ្ណសំគាល់សិទ្ធកាន់កាប់ អចលនវត្ថុហើយ នៅក្នុងនោះមានឈ្មោះ ...ជាមេឃុំ...បានចូលរួមបញ្ជាក់ និងប្រព្រឹត្តអំពើក្លែងឯកសារនេះ ផងដែរ។ លុះថ្ងៃទី... ខែ... ឆ្នាំ... ឈ្មោះ ...ហៅ ...បានមកដាក់ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹង
រដ្ឋប្បវេណីតាមផ្លូវអន្តរាគន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌលេខ៖... ចុះថ្ងៃទី... ខែ ... ឆ្នាំ... មក ចៅក្រមស៊ើបសួរ ។

**យល់ឃើញថា:**

-ពាក្យបណ្ដឹងសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណី
តាមផ្លូវអន្តរាគមន៍ក្នុងសំណុំរឿងព្រហ្មទណ្ឌ លេខ៖
... ចុះថ្ងៃទី...ខែ...ឆ្នាំ២... របស់ឈ្មោះ ...ហៅ ...បានប្ដឹងមកចៅក្រមស៊ើបសួរហើយតាមរយៈដីកាសម្រេចលើ
ពាក្យសុំតាំងខ្លួនជាដើមបណ្ដឹងរដ្ឋប្បវេណីលេខ៖... ចុះថ្ងៃទី... ខែ...ឆ្នាំ...
របស់ចៅក្រមស៊ើបសួរបានបញ្ជូនមក
អយ្យការដើម្បីអោយតំណាងអយ្យការធ្វើការពិនិត្យនិងសម្រេច។
បន្ទាប់ពីតំណាងអយ្យការទទួលបានពាក្យ បណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ ...ហៅ......តាមដីកាបញ្ជូនលេខ៖ ...រប/សលដ.បជ ចុះថ្ងៃទី ... ខែ... ឆ្នាំ ... របស់សាលាដំបូងខេត្តបន្ទាយមានជ័យ និងក្រោយពីបានអង្កេតបឋមរួចរាល់តំណាងអយ្យការបានសម្រេចតម្កល់រឿងទុកឥតចាត់ការលើសំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ... ចុះថ្ងៃទី ... ខែ ...ឆ្នាំ ... របស់ អយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ដោយមូលហេតុផុតអាជ្ញាយុកាលនៃបទល្មើសតាមដីកា លេខ៖... ចុះថ្ងៃទី... ខែ ...ឆ្នាំ...របស់ អយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ។

-តាមមាត្រា ១៣៩ (ការបញ្ជូនបណ្ដឹងទៅព្រះរាជអាជ្ញា) វាក្យខ័ណ្ឌ៣ នៃ ក្រមនីតិវិធីព្រហ្មទណ្ឌ ព្រះរាជ អាជ្ញា អាចសុំ ដល់ ចៅក្រមស៊ើបសួរ កុំអោយស៊ើបសួរ លើពាក្យបណ្ដឹងសុំតាំងខ្លួន ជាដើមបណ្ដឹងរដ្ឋប្បវេណី របស់ឈ្មោះ...ហៅ ...ដោយហេតុថា៖ នៅក្នុងពាក្យបណ្ដឹងរបស់ឈ្មោះ...បានប្ដឹង ពីឈ្មោះ...និង ឈ្មោះ.. ថាបានក្លែងដោយសិកសៀតអក្សរលើពាក្យ ស្នើ សុំ ដីស្រែ របស់ ឈ្មោះ...ចុះថ្ងៃ ទី... ខែ ... ឆ្នាំ ...

ដែលពាក្យស្នើសុំនេះកើតមានឡើងតាំងពី ឆ្នាំ..... មកម្ល៉េះ ដោយយោងតាមមាត្រា ៦១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌបានចែងថា៖ "អាជ្ញាយុកាលនៃ បណ្តឹង អាជ្ញា និង អាជ្ញាយុកាលនៃទោស ចំពោះបទល្មើស ដែលត្រូវបានប្រព្រឹត្ត នៅមុនក្រម នេះចូលជា ធរមាន ត្រូវអនុវត្តតាមបទប្បញ្ញត្តិនៃច្បាប់ចាស់" ហេតុនេះ អាជ្ញាយុកាលនៃបទល្មើសត្រូវអនុវត្តតាមច្បាប់ព្រហ្មទណ្ឌអន្តរកាល។ តាមមាត្រា៣០នៃច្បាប់ព្រហ្មទណ្ឌ អន្តរកាលបានចែងថា" អាជ្ញាយុកាលសំរាប់បទមជ្ឈឹមមានរយះពេល០៣ឆ្នាំ រីឯអាជ្ញាយុកាលសំរាប់បទ ឧក្រិដ្ឋមានរយះពេល១០ឆ្នាំ" ដូចនេះនាំអោយផុតអាជ្ញាយុកាលនៃបទល្មើស ព្រោះថា បើគិតរយះពេល ពីឆ្នាំ១៩៩៥មកដល់ថ្ងៃដែល ឈ្មោះ ...ហៅ ... បានដាក់ពាក្យប្តឹងគឺមានរយះពេល១៦ឆ្នាំហើយ (ប្រសិនបើមើលទៅមាត្រា ១០ នៃក្រមនីតិវិធី ព្រហ្មទណ្ឌវិញ ថិរវេលានៃអាជ្ញាយុកាលនៃបណ្តឹងអាជ្ញា១៥ ឆ្នាំចំពោះបទឧក្រិដ្ឋ ចំណែកឯ បទមជ្ឈិម រយះ ពេល ៥ឆ្នាំ ដូចនេះបើតាមក្រមនីតិវិធីព្រហ្មទណ្ឌឆ្នាំ២០០៧ អាជ្ញាយុកាលនៃបទល្មើសក៏បានផុតហើយដែរ)កន្លងមក ឈ្មោះ ... ហៅ ... ពុំបានប្តឹងតវ៉ាអំពីការក្លែងលិខិតនេះដែរ ហេតុនេះ ថេរវេលា នៃ អាជ្ញាយុកាលនៃបណ្តឹងអាជ្ញាបានផុតហើយ គប្បីរំលត់បណ្តឹងអាជ្ញា (តាមមាត្រា ៧នៃ ក្រ.ន.ព្រ)។

## ហេតុដូច្នេះសម្រេច

-ស្នើសុំដល់ចៅក្រមស៊ើបសួរ

កុំអោយស៊ើបសួរលើពាក្យបណ្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី តាមផ្លូវអន្តរាគមន៍ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ របស់ឈ្មោះ...ហៅ...ដែលបាន ចុះនៅក្នុង សំណុំរឿងព្រហ្មទណ្ឌ លេខ ៖ ...ចុះថ្ងៃទី ... ខែ ...ឆ្នាំ ២... របស់អយ្យការអមសាលាដំបូងខេត្ត - បន្ទាយមាន ជ័យ ដោយ មូលហេតុនៃការផុតរំលត់អាជ្ញាយុកាលនៃបទល្មើស។

ធ្វើនៅ បន្ទាយមានជ័យ, ថ្ងៃទី ខែ ...ឆ្នាំ ...

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តពោធិ៍សាត់**
**សំណុំរឿងព្រហ្មទណ្ឌលេខ: ...**
**ចុះថ្ងៃទី...ខែ... ឆ្នាំ..**
**លេខ:......................អ.យ/០១៦**

## <u>ដីកាសន្និដ្ឋានស្ថាពរ</u>

**យើង........... តំណាងអយ្យការអមសាលាដំបូងខេត្តពោធិ៍សាត់ ។**

បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលេខ: ... ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់តំណាងអយ្យការអមសាលាដំបូងពោធិ៍សាត់ ។

បានឃើញ សំណុំរឿងស៊ើបសួរលេខ:... ចុះថ្ងៃទី ... ខែ... ឆ្នាំ... របស់សាលាដំបូងខេត្តពោធិ៍សាត់ ។

បានឃើញ ដីកាបញ្ជូនឲ្យឆ្លើយដើម្បីបិទបញ្ចប់ការស៊ើបសួរលេខ: ... ពស ចុះថ្ងៃទី... ខែ... ឆ្នាំ... របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តពោធិ៍សាត់ ។

**ក្រោយពីបានពិនិត្យឯកសារខាងលើ**

ឃើញថា:

១-នាមត្រកូល៖...នាមខ្លួន ... ហៅ... ភេទ... កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនា ៖ មុខរបរ៖... ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ... ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅលីវ ជានីតិជន។
២-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖... សាសនាព្រះពុទ្ធ ៖ មុខរបរ៖ធ្វើស្រែ ទោសពីមុនគ្មាន
-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់
-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់
-ឪពុកឈ្មោះ ... (រ) ម្តាយឈ្មោះ ... (រ) នៅលីវ ជានីតិជន។
៣-នាមត្រកូល៖... នាមខ្លួន ... ភេទប្រុស កើតនៅឆ្នាំ ...
-សញ្ជាតិ៖ សាសនា៖

-ទីកន្លែងកំណើត៖ ភូមិ...ខេត្តពោធិ៍សាត់

-ទីលំនៅបច្ចុប្បន្ន៖ ភូមិ...ខេត្តពោធិ៍សាត់

-ឪពុកឈ្មោះ៖ ... (រ) ម្តាយឈ្មោះ៖... (ស) ប្រពន្ធឈ្មោះ ... (រ)

កាលពីថ្ងៃទី...ខែ...ឆ្នាំ...វេលាម៉ោង...នាទីរសៀល មានអំពើ...របស់ជនរងគ្រោះឈ្មោះ...ដែលបានចងទុកនៅក្រោមផ្ទះនៅភូមិ...ខេត្តពោធិ៍សាត់។ ដល់ថ្ងៃខែឆ្នាំដដែលវេលាម៉ោងប្រហែល...និង...នាទី ឈ្មោះ...ហៅ... និងឈ្មោះ...បានហៅឈ្មោះ ...ឲ្យយកឡានមកដឹកក្របី ពេលកំពុងរៀបចំយកក្របីនោះដាក់ឡាន ពេលនោះឈ្មោះ...បានឃើញក៏រាយការណ៍ប្រាប់សមត្ថកិច្ច រួចសមត្ថកិច្ចក៏ចុះដេញតាមឡានដឹកក្របីដល់ភូមិ ...ខេត្តពោធិ៍សាត់ បានតាមទាន់ហើយ ក៏ឃាត់ខ្លួនឈ្មោះ ...ហៅ... និងឈ្មោះ... ជាអ្នកបើកឡានដឹកក្របី។

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខៈ ...ចុះថ្ងៃទី...ខែ... ឆ្នាំ...របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខ: ...)

បានឃើញ ឈ្មោះ ...ត្រូវបានឃុំខ្លួនបណ្តោះអាសន្នតាមដីកាលេខៈ ... ចុះថ្ងៃទី...ខែ...ឆ្នាំ... របស់ចៅក្រមស៊ើបសួរ។ (ឯកសារលេខ:...)

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ឈ្មោះ... ថាខ្លួនមិនបានកត់កំណត់ហេតុថា ក្របីខ្លួនបានពេលណា រកឃើញពេលណាទេ គ្រាន់តែនគរបាល ហៅឲ្យយកក្របី។ ក្របីនោះខ្លួនទាក់បង្គន់ក្របី(ក្រោល) ព្រឹកឡើងលែងចោលដោយដើរមើល។ ក្របីខ្លួនមានចំនួន ០៤ក្បាល ពេលព្រឹកឡើងឃើញបាត់មួយនៅសល់០៣ក្បាល។ ការបាត់នោះដោយដឹកខ្សែដើរចេញតែមួយ។ក្របីនោះរកឃើញវិញហើយខ្លួនមិនទាមទារសំណងទេ សុំធ្វើតាមច្បាប់។ ខ្លួនមិនថាអ្នកណាចូលលួចទេ ហើយក៏គ្មានសង្ស័យអ្នកណាទេ ពេលដែលសមត្ថកិច្ចចាប់បានក្របី និងមនុស្ស គឺមនុស្សនោះដែលមិនមែនជាអ្នកភូមិខ្លួនទេ ដែលអ្នកនោះមិនស្គាល់ខ្លួន ហើយខ្លួនមិនស្គាល់គាត់ ដែលមើលទៅមិនមែនជាអ្នកលួចដឹកពីផ្ទះខ្លួនទេ ព្រោះគេមិនដែលឃើញ និងស្គាល់ផ្ទះខ្លួនទេ។ តាមខ្លួនគិតគឺមានអ្នកជិតភូមិខ្លួនជាអ្នកដឹកដើរចេញពីក្រោយរបស់ខ្លួន ចំណែកអ្នកដែលសមត្ថកិច្ចចាប់ខ្លួននេះមិនដឹងថាទំនាក់ទំនងជាមួយអ្នកនៅជិតៗខ្លួនយ៉ាងណាទេ។ សំណូមពរសុំផ្តន្ទាទោសតាមច្បាប់។

បានឃើញ កំណត់ហេតុស្តីពីការស្តាប់ចម្លើយរបស់សាក្សី ឈ្មោះ...ខ្លួនធ្លាប់ស្គាល់ឈ្មោះ... រយៈពេល...ឆ្នាំហើយ។ តាំងពីស្គាល់គាត់ ឃើញគាត់ប្រកបមុខរបរជាអ្នកទិញ

គោក្របី។ កន្លងមកឈ្មោះ......ធ្លាប់ទិញក្របីយកមកផ្ញើនៅផ្ទះខ្លួនម្តង ហើយក្របីនោះបានរួចពីចំណង ហើយដេញចាប់ភ្លាមៗ មិនមានបាត់ទេ ក៏ឡើងឡានបាត់ទៅ។ក្រោយមកប្រហែល២អាទិត្យវេលាម៉ោង ប្រហែល ១០ ទៅ ១១ ថ្ងៃត្រង់ ឈ្មោះ...បានចូលលេងផ្ទះខ្លួន ហើយក៏បាននិយាយថាឈ្មោះ... នៅ...បានហៅឲ្យទៅទិញក្របី ដោយឈ្មោះ... នៅ...គាត់ទិញបានក្របីមួយ ហើយហៅឈ្មោះ...ទៅមើល និងទិញបន្ត។ ពេលនោះឈ្មោះ...ទៅបាត់មួយ ប្រហែលម៉ោង ... រសៀលក៏ឈ្មោះ...ទូរស័ព្ទប្រាប់ថានគរបាលបានចាប់។ខ្លួនធ្លាប់ស្គាល់ឈ្មោះ...នៅ...នោះដែរ ធ្លាប់ទៅលេងកន្លែងខ្ទមស្រែរបស់ឈ្មោះ... នៅកន្លែងស្រែតែមិនស្គាល់នោះទេ។ ឈ្មោះ... នោះខ្លួនធ្លាប់ជួបមុខចំនួន២ ដងហើយ ស្គាល់មុខច្បាស់។ កន្លងមកឈ្មោះ...ជាអ្នកទិញពីណាពីណីមកហើយទើបលក់ឲ្យឈ្មោះ...។កាលពីថ្ងៃដែលគេចាប់ខ្លួននោះ គឺឈ្មោះ...បានប្រាប់ខ្លួនថា មានលុយចំនួន ៨.០០០.០០០ (ប្រាំលានរៀល) ហើយដើររកក្របី នៅភូមិខ្លួនផង និងកន្លែងផ្សេងៗ។ពេលនគរបាលចាប់នោះខ្លួនទៅមើលឈ្មោះ...បានប្រាប់ថាលុយបានឲ្យទៅឈ្មោះ ... នៅ...អស់ហើយ។ កន្លងមកការរាប់អានគ្នា ខ្លួនធ្លាប់បានដើរលេង ជាមួយឈ្មោះ...ពេលគេទិញក្របីដែរ ដោយឃើញមានលិខិតស្នាមត្រឹមត្រូវ តែចំពោះថ្ងៃដែលគេចាប់ខ្លួននេះមិនដឹងថាមានសំបុត្រអត់នោះទេ។ ក្របីនោះខ្លួនជឿជាក់ថាឈ្មោះ... ទិញពីឈ្មោះ...នៅ...ចំពោះការចាប់ខ្លួនឈ្មោះ...ខ្លួននិងសហការ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ហៅ... ខ្លួនជាអ្នកប្រកបមុខរបរលក់ទិញគោក្របីអស់ រយៈពេល ៣-៤ ឆ្នាំហើយ។កាលពីថ្ងៃទី មិនចាំខែ ធ្នូ ឆ្នាំ២០១៥វេលាម៉ោង ១០ព្រឹក ឈ្មោះ... អ្នករកស៊ីទិញគោ ក្របី បានដឹកខ្ញុំដោយម៉ូតូគាត់ដើម្បីទៅមើលក្របីនៅកំរែង។ ពេលនោះខ្លួនមិនបានសួរអំពីដំណើរទំនងអំពីក្របីនោះឡើយដោយខ្លួននិងឈ្មោះ...ធ្លាប់រកស៊ីជាមួយ ហើយកន្លងមកឈ្មោះ...ជាអ្នកផ្ញើ។ ខ្លួនបានព្រមព្រៀងជាមួយឈ្មោះ... ក្នុងតម្លៃ៣.០០០.០០០(បីលានរៀល)។ ខ្លួនមិនបានផ្តិតមេដៃពីឈ្មោះ... ឡើយ។ ឈ្មោះ... មានផ្ទះនៅផ្ទុំភូមិ...ខេត្តពោធិ៍សាត់ ដែលខ្លួនកូនប្រុសគាត់ម្នាក់ឈ្មោះ...(កំលោះ)នៅម៉ុំផ្លូវកោង ទូរស័ព្ទលេខ ០៩៧...។ពេលនោះនគរបានលបានចាប់ខ្លួនបានប្រាប់នគរបាលតាមដំណើររឿង ហើយនគរបាលបានយក ទូរស័ព្ទខ្លួនទៅទាក់ទងឈ្មោះ... ហើយឈ្មោះ... បាននិយាយជាមួយនគរបាលថាគាត់ធានា ឲ្យខ្លួនទៅទៅតែដោយគ្មានសំបុត្រនគរបាលមិនឲ្យទៅទេ។ការទិញនេះឈ្មោះ... បានឲ្យសំបុត្រដែលទិញ

ក្របីពីគេនោះមកខ្លួនកាន់ដែរ តែពេលជិះតាមផ្លូវជ្រុះបាត់ ដោយខ្លួនដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ។ ក្រោយពីបិទទូរស័ព្ទ ដែលទាក់ទងគ្នាម្តងរួចហើយ ទាក់ទងគ្នាលែងចូលរហូត។ ចំណែកអ្នកស៊ីឈ្នួលដឹកគាត់បានទារថ្លៃ១០.០០០០(ដប់ម៉ឺនរៀល) ហើយគាត់សួរខ្លួនថាមានសំបុត្រទេ ខ្លួនប្រាប់ថាមាន ព្រោះសំបុត្រនោះខ្លួនមានមែនខ្លួនទទួលពីឈ្មោះ... មកខ្លួនមិនបានមើលទេខ្លួនបានដាក់ជាមួយទូរស័ព្ទក្នុងហោប៉ៅ ហើយបាត់ទៅ។

បានឃើញ កំណត់ហេតុស្តីពីការសួរចម្លើយជនត្រូវចោទ ឈ្មោះ...ពេលនោះខ្លួនបានសួរអំពីដំណើរទំនងអំពីក្របីនោះ គាត់ថាមានច្បាប់ត្រឹមត្រូវអស់ហើយ។ក្រោយពីតថ្លៃដប់ម៉ឺនរៀល ខ្លួនក៏ចេញទៅ ពេលទៅដល់ឃើញគាត់ មានគ្នា២នាក់ ហើយបន្ទាប់ពីឡើងក្របីរួចខ្លួនក៏សួររកក្រដាសស្នាម គាត់ថាមាន ហើយគាត់ទាញឲ្យខ្លួនមើលដោយមិនចេះអក្សរ ឃើញគាត់ដកឯកសារមកជាច្រើនខ្លួនក៏ជឿទៅ ដោយមិនបានដឹងថាក្រដាសនោះ ពីថ្ងៃណានោះទេ។ ពេលដឹកប្រហែលបាន ៣ គីឡូម៉ែត ខ្លួនឃើញនគរបាលបានជិះម៉ូតូតាមក្រោយ ហើយស៊ីផ្លេខ្លួនឃើញតាមកញ្ចក់ខ្លួនក៏ឈប់ ហើយគាត់ទារមើលឯកសារ (គឺឈ្មោះ...កំពុងជិះម៉ូតូជាមួយខ្លួនក៏បានបង្ហាញឯកសារ) មិនដឹងថាឯកសារនោះយ៉ាងណាទេ ក៏គេឲ្យមកប៉ុស្តិ៍នគរបាលទាំងអស់គ្នា។ ពេលនគរបាលសួរខ្លួនឆ្លើយតាមដំណើររឿងដូចឆ្លើយនៅពេលនេះដែល ចំណែកចម្លើយឈ្មោះ... នោះយ៉ាងណាខ្លួនមិនដឹងទេ។ ខ្លួនមិនបានដឹងថាក្របីនោះ ខុសច្បាប់នោះទេ បើខ្លួនដឹងថាខុសច្បាប់ខ្លួនក៏មិនដឹកឡើយ ឈ្មោះ... អះអាងថាមានសំបុត្រ(ច្បាប់)។

យល់ឃើញថា

- មានភស្តុតាងគ្រប់គ្រាន់លើឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ និង ឈ្មោះ...ភេទប្រុស អាយុ ...ឆ្នាំ ពីបទ: អំពើលួច ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី... ...ខែ... ឆ្នាំ២...បទល្មើសដែលមានចែងឲ្យផ្តន្ទាទោស តាម បញ្ញត្តិមាត្រា ៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ។

-មិនមានភស្តុតាងគ្រប់គ្រាន់លើជនត្រូវចោទឈ្មោះ ...ភេទប្រុស អាយុ ...ឆ្នាំ

ពីបទ៖សមគំនិតក្នុងអំពើលួច តាមមាត្រា ២៩,៣៥៣,៣៥៦ នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...

<u>ដូច្នេះសម្រេច</u>

I. ប្តឹងសុំឲ្យចៅក្រមស៊ើបសួរសម្រេច:

១.បញ្ជូនជនត្រូវចោទលើ ៖

ក-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ខ-ឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទ: អំពើលួច តាមមាត្រា៣៥៣,៣៥៦ ប្រព្រឹត្តនៅភូមិ... ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី...ខែ... ឆ្នាំ២... ទៅ ជំនុំ ជម្រះ។

២.លើកលែងជនត្រូវចោទ៖

- ឈ្មោះ...ភេទប្រុស អាយុ ... ឆ្នាំ

ពីបទ៖ សមគំនិតក្នុងអំពើលួច តាមមាត្រា២៩,៣៥៣,៣៥៦នៃក្រមព្រហ្មទណ្ឌ ប្រព្រឹត្តនៅភូមិ...ខេត្តពោធិ៍សាត់ កាលពីថ្ងៃទី ... ខែ... ឆ្នាំ២...។

ធ្វើនៅអយ្យការ, ថ្ងៃទី........ខែ........... ឆ្នាំ២...

**តំណាងអយ្យការ**

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**
**សាលាដំបូងខេត្តបន្ទាយមានជ័យ**
លេខ:.............................................
**********

## ដីកាសម្រេចឱ្យយកជនជាប់ចោទមកជំនុំជំរះ

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ...ខែ ... ឆ្នាំ ២០១២ ដែលមានជនជាប់ចោទ:

១-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
២-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្នុងឃុំ)
៣-ឈ្មោះ ... ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ**ជួញដូរដោយខុសច្បាប់នូវសារធាតុញៀន និងប្រើប្រាស់ខុសច្បាប់នូវសារធាតុញៀន** ប្រព្រឹត្តនៅភូមិគីឡូម៉ែត្រលេខ...សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី... ខែ... ឆ្នាំ២០១២ បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្ដន្ទាទោសតាមបញ្ញត្តិមាត្រា **៩៥** និងមាត្រា **៩០** នៃច្បាប់ស្ដីពីការត្រួតពិនិត្យគ្រឿងញៀន ឆ្នាំ២០១២។

### ហេតុដូច្នេះសម្រេច

**ឱ្យជនជាប់ចោទ**

១-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ
២-ឈ្មោះ .... ភេទប្រុស អាយុ ... ឆ្នាំ

ទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ ទីកន្លែងជំនុំជម្រះសាលាដំបូងខេត្ត **នៅថ្ងៃទី... ខែ... ឆ្នាំ២០១២ វេលាម៉ោង ៨. ០០ នាទី ព្រឹក** ដើម្បីជំនុំជម្រះពីបទដែលបានចែងដូចខាងលើ ។

**ចៅក្រមជំនុំជំរះ**
- លោក ... ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**
- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**
- លោក .... ក្រឡាបញ្ជី

ឱ្យជំណឹងដល់ជនជាប់ចោទស្ដីពីសិទ្ធិរបស់ខ្លួន
នៅចំពោះមុខតុលាការដូចតទៅ:
- សិទ្ធិពីការដឹងឮពីដីកាសន្និដ្ឋានស្ថាពរ និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជំទាស់ចិត្តចៅក្រមជំនុំជម្រះ

- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ២០១២

**ព្រះរាជអាជ្ញារង**

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៙

**អយ្យការអម**

**សាលាដំបូងខេត្ត បន្ទាយមានជ័យ**

**លេខ:**

## តំណាងអយ្យការអមសាលាដំបូងខេត្ត បន្ទាយមានជ័យ

**<u>សូមគោរពជូន</u>**

## ឯកឧត្តមអគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍

**<u>កម្មវត្ថុ:</u>** របាយការណ៍បណ្តឹង ឧទ្ធរណ៍ នឹងដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ: ... ចុះថ្ងៃទី ...

ខែ ... ឆ្នាំ ២០១៤។

**<u>យោង:</u>** -សំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១៤ ។

-ដីកាសម្រេចមិនឃុំខ្លួនបណ្តោះអាសន្នលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ ។

តបតាមកម្មវត្ថុ និងយោងខាងលើខ្ញុំសូមជំរាបជូន ឯកឧត្តម មេត្តាជ្រាបថា: លោកចៅក្រម ស៊ើបសួរនៃសាលាដំបូងខេត្តបន្ទាយមានជ័យ បានសម្រេចមិនឃុំខ្លួនជនត្រូវចោទឈ្មោះ ... ដែលដាក់ ឲ្យស្ថិតនៅក្រោមការពិនិត្យពីបទ:អំពើហិង្សាដោយចេតនា(ស្ថានទម្ងន់ទោស) តាមដីកាសំរេចលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ តំណាងអយ្យការមិនយល់ស្របដោយសំអាងថា:

-តាមចម្លើយរបស់ដើមបណ្តឹងឈ្មោះ ... និងចម្លើយសាក្សីឈ្មោះ ... .ឈ្មោះ... ឈ្មោះ ... .ឈ្មោះ ... .ឈ្មោះ ... មានភាពស៊ីសង្វាក់គ្នាបញ្ជាក់ថា:កាលពីថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤ នៅចំណុចភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ មានការទាស់គ្នា រវាងក្រុមជនរងគ្រោះ និងក្រុមជនត្រូវចោទ ឈ្មោះ ... មានការវាយ និងកាប់ចាក់គ្នា ដោយពេលទាស់គ្នានោះជនត្រូវចោទឈ្មោះ ... បានយកកាំបិត ចាក់ទៅលើជនរងគ្រោះឈ្មោះ ... ហើយជនរងគ្រោះឈ្មោះ ... បានយកដៃរងបណ្តាលឲ្យមុតដៃតែម្តង មិនមែនជនរងគ្រោះដួលទៅប៉ះ កាំបិទដែលជនត្រូវចោទកាន់ បណ្តាលឲ្យរបួស ដូចចម្លើយរបស់ជនត្រូវ ចោទឆ្លើយដោះសារនោះទេ ។

-ការប្រព្រឹត្តរបស់ជនត្រូវចោទមានបក្សពួកជាក្រុម និងមានអាវុធ បណ្តាលឲ្យប៉ះពាល់ដល់ សន្តិសុខសណ្តាប់ធ្នាប់សង្គម និងព្យសនៈកម្មធ្ងន់ធ្ងរ។

-ជនត្រូវចោទជាកម្មករ មានទីលំនៅមិនច្បាស់លាស់ ការសម្រេចមិនឃុំខ្លួន ជនត្រូវចោទនិង មិនចូលមកបង្ហាញខ្លួនទៅតាមនីតិវិធីឡើយ ។

-ជនត្រូវចោទជាកម្មករ មានបក្សពួកច្រើន ជាក្រុមទំនើងការមិនឃុំខ្លួន ជនត្រូវចោទអាចនិងទៅបង្កបទល្មើសជាថ្មីទៀត។

-ជនត្រូវចោទប្រព្រឹត្តបទល្មើសមានគ្នាច្រើន ការអោយជនត្រូវចោទនៅក្រៅឃុំអាចត្រូវរ៉ូវគ្នារវាងជនត្រូវចោទ និងជនត្រូវចោទ ធ្វើឲ្យបាត់ភស្តុតាង និងអាចជនត្រូវចោទទៅគាបសង្កត់លើសាក្សី ឬជនរងគ្រោះធ្វើឲ្យមានការលំបាកដល់ការស៊ើប អង្កេតប្រមូលភស្តុតាង។

-ដោយផ្អែកលើមូលហេតុទាំងអស់នេះ ទើបតំណាងអយ្យការអមសាលាដំបូង ខេត្តបន្ទាយមានជ័យ ប្តឹងឧទ្ធរណ៍និងដីកាសម្រេចមិនឃុំខ្លួនលេខ ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤។

សេចក្តីដូចបានជំរាបជូនខាងលើសូមឯកឧត្តម **អគ្គព្រះរាជអាជ្ញានៃមហាអយ្យការអមសាលាឧទ្ធរណ៍** មេត្តាជ្រាបជារបាយការណ៍ ។

សូម ឯកឧត្តម ទទួលនូវការគោរពដ៏ខ្ពង់ខ្ពស់អំពីខ្ញុំបាទ ។

ធ្វើនៅ បន្ទាយមានជ័យ , ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:.............................................

**********

## ដីកាកោះឱ្យចូលរួមសវនាការ

យោង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឲ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

## ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង** ២^h០០ រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

**ចៅក្រមជំនុំជម្រះ**

- លោក ...ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ
- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ

- សិទ្ធិប្ដឹងជិតចិត្តទៅក្រមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការអម**

**សាលាដំបូងខេត្តបន្ទាយមានជ័យ**

លេខ:............................................

**********

## ដីកាកោះឱ្យចូលរួមសវនាការ

យើង ...ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

ក្រោយពីបានពិនិត្យសំណុំរឿងព្រហ្មទណ្ឌលេខ: ... ចុះថ្ងៃទី ... ខែ ... ឆ្នាំ ... ដែលមានជនជាប់ចោទ:

១-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

២-ឈ្មោះ ...ភេទ ប្រុស អាយុ ... ឆ្នាំ (ក្រៅឃុំ)

ជាប់ចោទពីបទ **បើកបរបង្កឲ្យគ្រោះថ្នាក់ស្លាប់ដល់អ្នកដទៃ** ប្រព្រឹត្តនៅភូមិ... ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី...ខែ... ឆ្នាំ... បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា **៨១.៨២** នៃច្បាប់ស្តីពីចរាចរណ៍ផ្លូវគោក ។

### ហេតុដូច្នេះសម្រេច

បង្គាប់ឱ្យឈ្មោះ ...ភេទប្រុស អាយុ ... ឆ្នាំជាតិខ្មែរ ទីលំនៅបច្ចុប្បន្នរស់នៅភូមិ...ខេត្តបន្ទាយមានជ័យ ឱ្យចូលទៅកាន់សាលាដំបូងខេត្តបន្ទាយមានជ័យ **នៅថ្ងៃទី... ខែ... ឆ្នាំ...វេលាម៉ោង** ២"០០ រសៀល ជាកំហិត ដើម្បីឆ្លើយដោះសាពីការចោទប្រកាន់មកលើខ្លួនដូចខាងលើ ។

**ចៅក្រមជំនុំជម្រះ**

- លោក ...ចៅក្រមសាលាដំបូងខេត្ត

**តំណាងអយ្យការ**

- លោក ... ព្រះរាជអាជ្ញារង

**ក្រឡាបញ្ជីសវនាការ**

- លោក ...ក្រឡាបញ្ជី

**សិទ្ធិរបស់ជនជាប់ចោទមានដូចតទៅ:**

- សិទ្ធិពីការដឹងឮពីលិខិតចោទប្រកាន់ទោស និងដីកាកោះឱ្យចូលរួមសវនាការ

- សិទ្ធិបង្ហាញភស្តុតាង សំអាងសាក្សី ឬសំណូមពរផ្សេងៗ
- សិទ្ធិប្តឹងជិតចិត្តទៅក្រុមជំនុំជម្រះ
- សិទ្ធិការពារខ្លួនដោយខ្លួនឯង ឬពឹងពាក់មេធាវីជួយការពារ

បន្ទាយមានជ័យ, ថ្ងៃទី ... ខែ ... ឆ្នាំ ...

**ព្រះរាជអាជ្ញារង**

យើង[១].......................................................................ជា.....................................................

..........................

បានប្រគល់ដីកានេះឱ្យឈ្មោះ........................................................ទីលំនៅសព្វថ្ងៃភូមិ.....
................................ឃុំ-សង្កាត់......................................ស្រុក-
ខណ្ឌ.....................................ខេត្តក្រុង..................................
........... នៅថ្ងៃទី.............ខែ........................ឆ្នាំ ២០........ ហើយយើងបានប្រាប់ថា សាមីខ្លួនត្រូវប្រគល់ចុងដីកានេះដល់ក្រឡាបញ្ជីនៅពេលដែលខ្លួនចូលទៅចំពោះមុខសាលាដំបូងខេត្តបន្ទាយមានជ័យ ។

**អ្នកទទួល**

**អ្នកប្រគល់**

ហត្ថលេខា ឬផ្តិតមេដៃ

ហត្ថលេខា

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**អយ្យការ**

អមសាលាដំបូង

ខេត្តបន្ទាយមានជ័យ

លេខ: ________ អក

# ដីកាឲ្យដំណឹងពីសេចក្ដីសម្រេចរបស់តុលាការ

យើង ... ព្រះរាជអាជ្ញារង អមសាលាដំបូងខេត្តបន្ទាយមានជ័យ ។

-បានឃើញសំណុំរឿងព្រហ្មទណ្ឌលេខ ... ចុះថ្ងៃទី... ខែ ... ឆ្នាំ ២០១០ ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ៖ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ។

បានឃើញមាត្រា ៤៨២ និងមាត្រា ៤៨៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ

**<u>ជូនដំណឹងមក</u>**

ឈ្មោះ ... ភេទប្រុស ឆ្នាំកំណើត ... (អាយុ ... ឆ្នាំ) សញ្ជាតិ ខ្មែរ មានទីលំនៅ ភូមិ... សង្កាត់... ក្រុង... ខេត្តបន្ទាយមានជ័យ ជាជនជាប់ចោទឲ្យបានជ្រាប ថា៖ រឿងក្ដីរបស់លោក ត្រូវបានសាលាដំបូងខេត្តបន្ទាយមានជ័យធ្វើការជំនុំជម្រះ និងសម្រេចសេចក្ដីរួចហើយ តាមរយៈសាលក្រម ដូចបានយោងខាងលើ និងភ្ជាប់ជាមួយស្រាប់ ។

អាស្រ័យហេតុនេះសូមលោកជ្រាបបើលោកមិនសុខចិត្តនឹងការសម្រេចសេចក្ដីតាមសាលក្រមខាងលើនេះទេលោកមានសិទ្ធិប្ដឹងទាស់និង សាលក្រមខាងលើនេះបានក្នុងរយៈពេល **១៥ថ្ងៃ** ដោយគិតចាប់ពីថ្ងៃ បានទទួលដីកាឲ្យដំណឹង នេះតទៅនិងមានសិទ្ធិប្ដឹងឧទ្ធរណ៍រយៈពេល **០១ខែ** គិតចាប់ពីថ្ងៃផុតកំណត់ នៃការប្ដឹងទាស់។

ផ្ញើនភ្ជាប់មកជាមួយនូវសាលក្រមព្រហ្មទណ្ឌលេខ៖ ... (គ) ចុះថ្ងៃទី... ខែ... ឆ្នាំ២០១១ របស់ សាលាដំបូងខេត្តបន្ទាយមានជ័យ ។

បន្ទាយមានជ័យ ថ្ងៃទី ... ខែ ... ឆ្នាំ ២០១៤

**ព្រះរាជអាជ្ញារង**

យើង..............................................ជា............................................................
បានប្រគល់ដីកាឲ្យដំណឹងនេះដល់ឈ្មោះ.........................ទីលំនៅសព្វថ្ងៃភូមិ............................
ឃុំ/សង្កាត់..............................ស្រុក/ខណ្ឌ............................ខេត្ត/ក្រុង...........................
នៅថ្ងៃទី.............ខែ..................ឆ្នាំ២០........... រួចហើយ ។

| | |
|---|---|
| **អ្នកទទួល** | **អ្នកប្រគល់** |
| **ហត្ថលេខា ឬ ផ្តិតមេដៃ** | **ហត្ថលេខា** |

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
៚

អយ្យការអម
សាលាដំបូងខេត្ត
*បន្ទាយមានជ័យ*
*លេខ៖*

# ដីកាដោះលែងទណ្ឌិត

+++

យើង ... ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្ត បន្ទាយមានជ័យ ។

-បានឃើញមាត្រា ៤៩៦.៤៩៧ នៃក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

-បានឃើញ សាលក្រមព្រហ្មទណ្ឌលេខៈ ... (ព) ចុះថ្ងៃទី ... ខែ ... ឆ្នាំ ២០១២ នៃសាលាដំបូងខេត្ត បន្ទាយមានជ័យ។

**<u>យើងចេញដីកាដោះលែងឈ្មោះដូចខាងក្រោម</u>**

-នាមត្រកូល-នាមខ្លួនៈ ...ជាតិ ខ្មែរ សាសនា

-កើតថ្ងៃទី ខែ ឆ្នាំ (អាយុ ៣៦ ឆ្នាំ ) ភេទ ប្រុស

-ស្រុកកំណើតភូមិ...ខេត្តបាត់ដំបង

-ទីលំនៅមុនពេលជាប់ទោសភូមិ...ខេត្តបន្ទាយមានជ័យ

-ជាប់ពីបទ **អំពើហិង្សាប្រព្រឹត្តដោយសហព័ទ្ធ**

-ត្រូវបានវិនិច្ឆ័យទោសចំនួន ០២ឆ្នាំ ដោយអនុវត្តទោសក្នុងពន្ធនាគារកំណត់ ០១ ឆ្នាំ គិត ចាប់ពីថ្ងៃទី ... ខែ ... ឆ្នាំ ...។

បច្ចុប្បន្នទណ្ឌិតរូបនេះ បានអនុវត្តទោសគ្រប់ចំនួនអស់ហើយ ។

ឈ្មោះ ...នេះត្រូវវិលត្រឡប់ទៅរស់នៅមូលដ្ឋាន ដើម្បីប្រកបការងារចិញ្ចឹមជីវិតជាមួយគ្រួសារវិញ។

លោកប្រធានពន្ធនាគារខេត្តបន្ទាយមានជ័យ មានភារកិច្ចអនុវត្តតាមដីកានេះប្រសិនបើទណ្ឌិតរូបនេះមិនត្រូវបានឃុំខ្លួនពីបទល្មើសអ្វីផ្សេងទៀតទេ។

ធ្វើនៅបន្ទាយមានជ័យ ថ្ងៃទី ខែ មករា ឆ្នាំ ២០១៣

ព្រះរាជអាជ្ញារង

យើង......................................ប្រធានមន្ទីរឃុំឃាំងខេត្តបន្ទាយមានជ័យបាន
ដោះលែងឈ្មោះ.............................ភេទ...............អាយុ.............ឆ្នាំលេខខ្លួន
........................ចុះថ្ងៃទី                ខែ.............. ឆ្នាំ ..............ប្រព្រឹត្តបទល្មើស
..................................................នៅចំណុចភូមិ .......................ឃុំ..............
ស្រុក...............................ខេត្ត បន្ទាយមានជ័យ កាលពីថ្ងៃទី ........ខែ ................
ឆ្នាំ..........តាមអំណាចដីកានេះថ្ងៃទី.....ខែ..........ឆ្នាំ..........រួចហើយ។

បន្ទាយមានជ័យ ថ្ងៃទី ........ខែ.........ឆ្នាំ.........

ប្រធានមន្ទីរឃុំឃាំង